# រឿង

# ចរណៃឈ្លងទ័យា

ប្រលោមលោកមនោសញ្ចេតនា

និពន្ធនិងគំនូររចនាក្របដោយ
អ្នកស្រី កែវ ចន្ទ័បូរណ៍

P.O.Box 600279
Saint Paul, MN 55119
USA
khmervissal@yahoo.com
www.angkorwat.com

CHANBOKEO . COM

ខែឧសភា២០០០

រក្សាសិទ្ធិគ្រប់យ៉ាង

# ស្នាដៃខ្លះៗរបស់អ្នកស្រីកែវចន្ទ័បូរណ៍

១- រឿង សំនៀងស្នេហ៍កវី
២- រឿង និស្ស័យស្នេហ៍
៣- រឿង ផ្កាយវង្វេងមេឃ
៤- រឿង ស្នាមញញឹម
៥- រឿង កុលាបស្ទឹងខៀវ
៦- រឿង ក្លិនផ្កាមាលតី
៧- រឿង លិខិតមរតកសម្ងាត់
៨- រឿង បំណុលជីវិត
៩- រឿង ចរណៃដួងទ័យា
១០- រឿង អំបែងអណ្តែត
១១- រឿង ស្នេហ៍ចាកផុតទៅ
១២- រឿង តន្ត្រីបេះដូង
១៣- រឿង សារាណីយមាតា
១៤- រឿង ទារុណដួងចិត្ត
១៥- រឿង បើសិននៅមានថ្ងៃស្នេហ៍
១៦- រឿង លំអងផ្កាស្នេហ៍
១៧- រឿង ត្រៃមិត្ររតននារី
១៨- រឿង ខ្មើយវាសនា
១៩- រឿង បើសិនអាចបង្វិលផែនដី
២០- រឿង លីវបុរេកាល
២១- រឿង មេឃដ៏សក្តិសិទ្ធិ
២២- រឿង មួយពាន់ទំព័រ
២៣- រឿង អាមេរិកដែនដីមាស
២៤- រឿង អាធ្រាតថ្ងៃរះ
២៥- រឿង បក្សីស្អួនសុបិន
២៦- រឿង ម្លប់អសោក
២៧- រឿង ពិជេដ្ឋភានុមា
២៨- រឿង ផ្ការីកក្រៅស្អួន
២៩- រឿង មន្តស្នេហ៍ស្រីខ្មៅ
៣០- រឿង អនង្គលាភា
៣១- រឿង ពណ្ណរាយពេជ្រ
៣២- រឿង សារិកា
៣៣- រឿង ផ្ការាជបឹងរាំង
៣៤- រឿង នភាមណី
៣៥- រឿង ស្រីនាថភ្លួងមាលា
៣៦- រឿង វាយោដួងចិត្ត

កំណាព្យ :

១- ឧទ្យានកំណាព្យ ភាគ១ : គុណ និង សីលធម៌

២- ឧទ្យានកំណាព្យ ភាគ២ : គុណ និង សីលធម៌

៣- ឧទ្យានកំណាព្យ ភាគ៣ : គុណ និង សីលធម៌

៤- ឧទ្យានកំណាព្យ ភាគ២៤: គុណ និង សីលធម៌

CHANBOKEO.COM

## សូមឧទ្ទិសចំពោះ

- លោក មេង សួង សុវណ្ណធី ជាស្វាមី
- កុមារី សុវណ្ណធី ធម្មិកា បារមីបុណ្យ ជាបុត្រីទោល
- លោកឪពុក ប៊ុនថង និងអ្នកម្តាយ កែវយឿង
- លោកឪពុកក្មេក មេងសួង និងអ្នកម្តាយក្មេក កូវសាវ៉ាន់
- លោកគ្រូប៊ុនឈុនទាម លោកគ្រូប៊ុនណាំ អ្នកគ្រូអ៊ុកវ៉ាន់ថា លោកគ្រូរស់សាន់
- ព្រះគ្រូ  សាស្ត្រាចារ្យ និងលោកគ្រូអ្នកគ្រូរបស់នាងខ្ញុំទាំងអស់។
- អ្នកគ្រូទូចសារឿង អ្នកគ្រូកែវសុផុន លោកគ្រូលីតាយហុង លោកគ្រូរីនរស់ អ្នកគ្រូ មៀច សុខារី លោកលេកស៊ីវហុង អ្នកនាងប៉ក់ដារិនី អ្នកស្រីមាងបេងយង់ ជាមិត្ត
- ចំពោះប្រិយមិត្តដែលជា អ្នកនិពន្ធ គន្ថការី និងកវីទាំងឡាយ។
- លោកខូតាវាឫទ្ធិ នាយកកម្មវិធីសមូហ៍កម្មអក្សរសិល្ប៍ទូហាច

CHANBOKEO . COM




អ្នកស្រី កែវ ចន្ទ័បូរណ៍

រដ្ឋមិនីសូតា សហរដ្ឋអាមេរិក

# វាចាអ្នកនិពន្ធ

ប្រលោមលោករឿង ចរណៃដួងច័យា បានត្រូវកែសម្រួលលើកទីពីរ ពីសាច់រឿងដើម ដែលអ្នកនិពន្ធបានចងក្រងឡើងក្នុងឆ្នាំ១៩៨០ នៅជំរំទល់ដែនខ្មែរថៃ ក្នុងនាមថា ភូមិបញ្ចា សម្ពន្ធ័។ បន្ទាប់មក រឿងនេះបានត្រូវនិពន្ធជាល្ខោននិយាយ ចាក់ផ្សាយសាជាថ្មី នៅក្នុងវិទ្យុ សម្លេងខ្មែររដ្ឋមិនិសូតានៅឆ្នាំ១៩៩២ ហើយត្រូវបានកែសម្រួលទៅជា ប្រលោមលោកមនោ សញ្ចេតនានៅឆ្នាំ២០០០ ដើម្បីឧទ្ទិសដល់បុព្វការីជនទាំងឡាយរបស់អ្នកនិពន្ធដែលមានស្រុកកំណើតនៅភូមិព្រះនេត្រព្រះ ក្នុងភូមិភាគខាងជើងនៃខេត្របាត់ដំបង ដែលបច្ចុប្បន្ននេះបាន ផ្លាស់ឈ្មោះទៅជាខេត្របន្ទាយមានជ័យ។

ចំពោះកំហុសអក្ខរាវិរុទ្ធដោយអចេតនាទាំងឡាយក្នុងសាច់រឿង សូមប្រិយមិត្តមេត្តា ជួយកែសំរួលអោយបានត្រឹមត្រូវតាមវេយ្យាករណ៍ខ្មែរប្រពៃផង។ សូមប្រសិទ្ធិពរជ័យដល់ ប្រិយមិត្តអ្នកអានទាំងអស់ឱ្យបានជួបតែវឌ្ឍនសុខ សុវត្ថិភាពនិងសុភមង្គលរាល់ទិវារាត្រី។

នាងខ្ញុំអ្នកនិពន្ធសូមទទួលនូវមតិយោបល់ពីប្រិយមិត្តអ្នកអាន តាមរយៈអស័យដ្ឋានដូច ខាងក្រោមនេះ :


Pannalai Khmer Visal
P.O.Box 600279
Saint Paul, MN 55119
USA
Khmervissal@yahoo.com


សូមប្រិយមិត្តបានជួបប្រទះតែវឌ្ឍនសុខ និងសុវត្ថិភាពរាល់ទិវារាត្រី ។

អ្នកនិពន្ធ

អ្នកស្រី កែវ ចន្ទ័បូរណ៍

ខែឧសភា ២០០០

CHANBOKEO . COM

# កំណាព្យ

## **មេមាន់**

មេមាន់ក្រាបពងមិនប្រកាន់　　ពងទាពងមាន់គ្រាន់ទាំងអស់
ក្រាបលុះដល់ថ្ងៃកូនត្រូវញាស់　　ចិញ្ចឹមទាំងអស់មិនត្អូញត្អែ ។
ត្រុកៗត្រដាងស្លាបការពារ　　កូនគ្រប់អង្គាសុខហូរហែ
មេមាន់កកាយឥតគ្នាន់គ្នេរ　　ចែកកូនឆីហែរស់គ្រប់ប្រាណ ។
មិនដែលនឹកទាមទារសគុណ　　គុណម៉ែសែនធ្ងន់លើកល្បាណ
ចិញ្ចឹមគ្រប់កូនគ្មានលំអាន　　ដូចខេមរាក្សាន្តថៃច្រើនសាសន៍ ។
កូនគេកូនឯងកេងប្រយោជន៍　　អោយជាតិខ្មែរខ្លោចខ្មៅមុខណាស់
មិនខុសមេមាន់កូនមិនខ្វះ　　តែកូនបែរប្រាសភ្លេចធ្វើល្អ ។
ជាតិជាមេមាន់ទ្រាំតស៊ូ　　កូនវិញបែរប្តូរបាត់គុណធម៌
ធ្វើបាបម៉ែឯងអោយត្រដរ　　ត្រដឹតដកកស្មើរក្ស័យអើយ...!

CHANBOKEO.COM

## ផ្ទុល់ រថយន្ត និងអ្នកបើកបរ

ជាអ្នកបើកបរខាងរថយន្ត          ដឹកនាំជញ្ជូនមនុស្សច្រើនគ្នា
ត្រូវមានជំនាញខាងការងារ          មានបណ្ណ័បោះត្រាបញ្ជាក់ច្បាស់ ។
ដៃកាន់ចង្កូតភ្នែកមើលផ្លូវ          បើកបរត្រឹមត្រូវមិនផ្តេសផ្តាស
បើគ្មានជំនាញឡាននឹងបះ          ក្រឡាប់កៀរប៉ះគ្រោះមិនខាន ។
ថ្វីបើជំនាញខាងបើកបរ          ក៏ពឹងយានល្អផុតរំខាន
ទើបគេអាចដឹកនាំផលបាន          ទៅមកក្សេមក្សាន្តគ្មានកង្វល់ ។
បើសិនឡានល្អចរជោគជ័យ          តែថៃដន្យអ្វីចង្រៃផ្ទុល់
មិនអំណោយទានច្បាស់អំពល់          គន្លុករចល់បរយ៉ាកក្រៃ ។
ដូចអ្នកដឹកនាំក្នុងសង្គម          ត្រូវមានជំនាញសមស្នាដៃ
ដឹកនាំស្រុកទេសថ្កើងល្បាញល្បី          ឯកទេសប្រពៃព្រមវិជ្ជា ។
ឡានចាស់ដូចជាតិកំពុងខ្សោយ          ត្រូវកែកុនហើយប៉ះពាវផ្សា
ឡានឈើមិនអាចប្រែជានា          បើអ្នកបើកបរមិនជួសជុល ។
ចំណែកមាគ៌ាទៅថ្ងុំថ្កើង          យើងត្រូវថៃឡើងចរនាំផល
ប៉ះពាវគន្លុកទុក្ខអំពល់     ផ្លូវល្អនាំដល់ភាពរុងរឿងរហ័សទាន់ចិត្ត ។

CHANBOKEO.COM

## កោងកង់ត្រង់កាំ

បើសិនឈើកោងឈូសធ្វើកង់ កុំឡើយតម្រង់ក្រែងវាស្រាំ
បើសិនត្រង់ល្អឈូសធ្វើកាំ កើនប្រយោជន៍ស្ដាំត្បិតសាមគ្គី ។
បណ្ដុះបុគ្គលក្នុងសង្គម តាមកោសល្យសមសួនសោភី
ឯកទេសជំនាញក្រើត្យបញ្ជី កាន់មុខនាទីសមចំណេះ ។
ជាងដែកខុសប្លែកពីជាងគូរ មិនអាចផ្លាស់ប្ដូរប្រាជ្ញតម្រេះ
វិរិស្វករបច្ចេកទេស មិនអាចពារប៉ះដោយកវី ។
ជំនាញខាងណាធ្វើខាងហ្នឹង ជាតិយើងរំពឹងគ្រប់វិស័យ
មុខការសំខាន់កាន់កែឆ្នៃ មានមួយខ្វះមួយព្រួយមិនខាន ។
កិច្ចការដឹកនាំសាងប្រទេស ពឹងលើតម្រេះល្អចំណាន
សព្វមុខជំនាញគ្រប់លំអាន សាងជាតិថ្កើងថ្កានក្សាន្តសុខា ។
បើឡើងដំណែងដោយលួចគេ ច្រៀកហែកចែកផ្ទេរមុខកិច្ចការ
ខុសពីជំនាញហ្វឹកសាស្ត្រា ឡើងសក្ដិកាលណាស្វាសូមខ្មាស ។
កិត្តិយសបុគ្គលឱ! គម្ដែង គួរចៀសប្រលែងល្បែងផ្ដេសផ្ដាស
មានយសខ្លួរយ៉ាប់ចុកចាប់ណាស់ បុណ្យសក្ដិត្រចះខ្វះជំនាញ ។
ប្រសិនបើខ្សត់អត់កោសល្យ យូរឆាប់លទ្ធផលគង់បង្ហាញ
កិច្ចការតូចធំខុសជំនាញ ដូចហូលតម្បាញខុសអន្ទង ។
ច្នេះឱមិត្តអើយកុំភ្លេចខ្លួន បុរាណចារក្បួនអប់រំយើង
ធ្វើការតាមចេះទើបថ្កុំថ្កើង បើសិនរើសអើង...ស្វាវាសូមខ្មាស់យើងទៀតហើយ!

CHANBOKEO.COM

## អ្នកក្រុងនិងអ្នកស្រែ

អ្នកក្រុងរស់នៅក្នុងវិទ្យា　　　　រវល់ដេកបន្លាស្រោះស៊ុំជិត
អ្នកស្រែមានញាតិរាប់ស្ពាលស្និទ្ធ　　　　ការពារជុំជិតឥតភ័យអ្វី ។
អ្នកក្រុងមានអាងទឹកហែលលេង　　　　ត្រឹមតែប្រវែងដប់ម៉ែត្រដី
អ្នកស្រែមានស្ទឹងវែងដល់ព្រៃ　　　　ហាក់ហែលរាល់ថ្ងៃយ៉ាងសប្បាយ ។
អ្នកក្រុងខ្សត់ដីជុំវិញផ្ទះ　　　　ថ្ងៃរះចាំងដល់ខ្លួនក្រហាយ
អ្នកស្រែដីវាលវែងអន្លាយ　　　　ជំនោរផាត់ផាយរហើយប្រាណ ។
អ្នកក្រុងចិញ្ចឹមត្រឹមសត្វឆ្កែ　　　　ចាញ់ដៃអ្នកស្រែយ៉ាងចំណាន
ចិញ្ចឹមជ្រូកគោមាន់ទាក្ងាន　　　　លក់អោយអ្នកមានឆីទាំងក្រុង ។
អ្នកក្រុងទិញសព្វ ពីអ្នកស្រែ　　　　អង្ករបន្លែត្រីសាច់ផង
អ្នកក្រុងដេកពូកស្រោសរបង　　　　អ្នកស្រែក្រ ហោងដេកសេរី ។
អ្នកក្រុងអោយគេមកបំរើ　　　　អ្នកស្រែខំធ្វើមិនមានស្តី
ចេះសព្វការងារច្រើនវិស័យ　　　　អ្នកក្រុងដេកភ័យបើសិនអ្នកស្រែបះបោរ...

**បើសិនយើងក្រ**

បើក្រត្បិតព្រោះអវិជ្ជា ចូរខំសិក្សាអោយជ្រៅជ្រះ
បើក្រព្រោះយើងគ្មានឱកាស ត្រូវឆ្លៀតរហ័សត្រិះរកផ្លូវ ។
បើក្រព្រោះយើងលង់កំជិល ក្រោកឡើងដើរភិលសំដៅទៅ
រពីសដៃជើងដាំស្រែស្រូវ ចំការទូទៅនូវដំណាំ ។
បើក្រព្រោះតែលង់កម្លៅ ចាកភាពត្រឹមត្រូវធ្លាក់ផ្លូវកម្ម
ស្រីស្រាគ្រឿងញៀនអាភៀនផ្តាំ កែខ្លួនចាកកម្មរស់រុងរឿង ។
បើក្រព្រោះយើងលង់ងងិត ចាកភាពសុចរិតក្នុងបេះដូង
ចូរប្រឹងសាងល្អនឹងញាតិផង ដើរដោយគន្លងច្បាប់គុណធម៌ ។
សាងល្អវិបុលផលស្នងវិញ ដណ្តប់អ្នកមិញយ៉ាងបវរ
ទាំងក្រុមគ្រួសារក្បួងផលល្អ ទទួលជ័យពរក្នុងជាតិនេះមិនយូរមិនឆាប់!

CHANBOKEO.COM

## ឆ្អិនក្រៅឆៅក្នុង

បកចេកយកអាំងបង្ខំភ្លើង ក្រហមឆាប់ឡើងបេះយកឆី
ចៃដន្យចេកឆ្អិនក្រហមខ្ចី ឆៅក្នុងតិចអីចត់ពេញមាត់ ។
ចិញ្ចឹមកូនចៅអោយសូត្ររៀន ទូន្មានឱ្យបុត្រសូត្រចាំស្ទាត់
ចៃដន្យកូនចាំបានតែមាត់ គំនិតបែរភ្លាត់ភ្លេចរៀនន័យ ។
ច្នេះពេលយើងប្រៀនរៀនពន្យល់ អោយកូនស្គាល់ផលផងសេចក្តី
គំនិតជ្រៅរាក់លាក់អត្ថន័យ កុំចាំពាក្យម្តាយត្រឹមមាត់ក្រៅ ។
បើកូនមិនចាំសូត្រមិនបាន តែបុត្រគ្រប់ប្រាណយល់ជំរៅ
ប្រសើរជាងឆ្អិនតែខាងក្រៅ ក្នុងវិញបែរឆៅខានប្រយោជន៏ ។

CHANBOKEO . COM

## ស្រលាញ់កាយកប់ ស្អប់កាយឡើង

ស្រលាញ់ផ្លែផ្កាចូរដាក់គ្រាប់ ស្រវាកាយកប់ដាំដាក់ទ្រើង
ស្អប់ស្មៅទន្ទ្រានត្រូវកាយឡើង ជីកឫសរំលើងកុំសល់ឡើយ ។
ស្រលាញ់សាស្ត្រាចាប់សៀវភៅ អានកប់ខ្លួនទៅកុំខ្វល់ខ្វាយ
បើស្អប់ចិត្តពាលប្រទុស្តរាយ កាយកាត់បោះឆ្ងាយកុំសន្សំ ។
ស្រលាញ់ម៉ែឪត្រូវត្រងត្រាប់ កប់ពាក្យម៉ែប្រាប់ក្នុងអារម្មណ៍
ពិចារណ៍អត្ថរសល្អភិរម្យ កប់ក្រឹត្យឧត្ដមក្នុងបេះដូង ។
ស្អប់ភាពក្រក្រី...កាយកុំស្ញៀម ឧស្សាហ៍ព្យាយាមទាំងជើងត្បូង
ធ្វើការសស្រាំផលអឹងកង ភោគទ្រព្យសហោងថ្កើងកល្យាណ ។
ច្នេះបើស្រលាញ់សូមកាយកប់ បើសិនជាស្អប់កាយកុំខាន
កវីជំរាបលោកអ្នកអាន បើសិនភ្លេចប្រាណ... ខានប្រយោជន៍ ។

CHANBOKEO.COM

# លាង...

លាងសំអាតផ្ទះពេលប្រលាក់ ជំរះកខ្វក់ភក់ជ្រាំរាយ
លាងអស់ធូលីពីរូបកាយ ឱ្យខ្លួនសប្បាយមានសុខា ។
លាងឡានម៉ូតូសម្ភារៈ លាងប្លែកប្រត្យក្ស័លាងដុល្លារ
លាងកត្តិយសពង្សសក្តា លាងឈ្មោះអស្នាវ្សរតនានិល ។
ថៃដន្យគេលាងត្រឹមខាងក្រៅ ភ្លេចបែរខ្លួនទៅលាងមន្ទិល
សំអាតគំនិតចាស់គឹរិល ចិត្តថ្លើមខ្មៅងិលខ្វះគុណធមិ ។
លាងសំអាតអ្វីមិនស្អាតស្មើ ខាត់ចិត្តប្រសើរប្រព្រឹត្តល្អ
នឹងអ្នករងគ្រោះអ្នកក្រីក្រ ឱ្យគ្នាក្រោកឈរពឹងខ្លួនឯង ។
ចិត្តស្អាតប្រកបដោយសីលធមិ លាងភាពកករងចំបែង
ស្រង់រាស្ត្រផុតខ្លោសោកសង្រេង ជាតិថ្កើងអង្វែងត្រកាលអើយ ។

CHANBOKEO.COM

## តឹងពេកវាដាច់ ធូរពេកវាភ្លាវ

ចាប៉ីខ្សែតឹងប្រឹងខ្លាំងដាច់ លែងពិរោះស្រេចផ្ដាច់សម្លេង
ពេលខ្សែធូរពេកភ្លាវអស់ភ្លេង ទ្រិង១ទ្រេង១លែងពិរោះ ។
ដូចការណែនាំអប់រំបុត្រ តឹងពេកដាច់ប៉ាត់បាត់កូនអស់
បើធូររលុងកូនស្រីប្រុស មិនស្ដាប់ម៉ែសោះរស់យ៉ាងណា?
ដូចច្បាប់សង្គមអប់រំពល តឹងពេកបុគ្គលរើកាយា
ធូរពេកពលរដ្ឋក្លាយខ្ជីខ្ជា ស្រុកក្លាយអនាធិបតេយ្យច្បាស់ ។
បើតឹងវាដាច់ធូរវាភ្លាវ ដូច្នេះត្រូវរាវខ្វង់ល្អល្អះ
រកផ្លូវកណ្ដាលដូចធមិព្រះ លោកតែងប្រៀនដាស់ឱ្យយើងចាំ ។
តើផ្លូវកណ្ដាលនៅត្រង់ណា អស់ជាតិខេមរាចូរចំណាំ
កណ្ដាលមានន័យផ្លូវចៀសកម្ម សុចរិតឥតស្រាំត្រាំសុក្រិត!!!

CHANBOKEO.COM

## ដេរម្ជុលតម្រូវក្បាល

ដេរម្ជុលតម្រូវក្បាល ផលិតផាលមើលនង្គ័ល
ធ្វើទានមើលអ្នកទ័ល បុណ្យកុសលផលធំធេង ។
ធ្វើម្ហូបមើលអ្នកឆី កាត់អាវថ្មីមើលម្ចាស់តែង
ចាក់តែតម្រូវពែង សង់ផ្ទះល្វែងមើលដីធ្លី ។
សាងច្បាប់មើលពលរដ្ឋ អោយហ្មត់ចត់កត់សំភី
បើធ្វើទាំងខ្វាខ្វី ពលប្រជារស់យ៉ាកក្រៃ ។
ប្រដៅកូនស្រីប្រុស មើលចន្លោះសព្វអ្វីៗ
ទូន្មានអោយប្រពៃ សមនឹងវ័យព្រមឱកាស ។
ធ្វើស្រែអោយមើលទឹក ដីព្រៃព្រឹក្សប្រយោជន៍ច្បាស់
គិតការមធ្យត័ណាស់ ផលគាប់ច្បាស់ជូនមិនខាន ។

CHANBOKEO.COM

**ចៃ**

ចៃរស់លើក្បាលណាមិនស្អាត ម្ចាស់ភ្លេចសង្វាតថែទាំសក់
ចៃពិតរំភើបក្បាលកខ្វក់ អង្គែរុំសក់រស់សប្បាយ ។
ចៃខាំសាច់ក្បាលបឺតយកឈាម ជំទើតអង្កៀមឥតជិនណាយ
បើម្ចាស់រិតខ្ជិលចៃរីករាយ ម្ចាស់រិតរាយមាយចៃឡើងបុណ្យ ។
ក្នុងការិយាល័យក្នុងសង្គម ហ្វូងចៃលួចឃ្លាំពេលម្ចាស់ស៊ុន
ឃើញម្ចាស់ខ្ជីខ្ជាចៃរួសរាន់ ចេញមុខខាំលាន់អង្កៀមលាភ ។
ច្នេះឱខ្មែរអើយកុំភ្លេចខ្លួន ហ្វូងចៃជ្រកពួនក្បាលតម្រៀប
ចូរសំអាតក្អែលមានរបៀប ប្រយ័ត្នចៃកៀបអង្កៀមឈាមខ្មែរ..!

CHANBOKEO . COM

## ប៉ោត

ធុងប៉ោតទទេមិនមានទឹក    គោះឮគគ្រឹកខ្ទ័រខ្ទារខ្លាំង
ប៉ោតប្រហោងក្នុងលាន់ក្នុងក្នាំង    បញ្ចេញឫកខ្លាំងបង្អើលញាតិ ។
រីប៉ោតទឹកពេញហៀរដល់មាត់    មិនភ្លាត់ក្នុងក្នាំងបំភ្លៃស្ងៀត
ស្ងាត់ៗមានទឹកពេញមាត់ប្រៀប    បំរើរផៅញាតិមិនអួតអាង ។
ដូចមនុស្សអុងអាត់អាងសំដី    ប្រាជ្ញមុខធំក្រៃប្រឹងបំប៉ោង
លាន់ឮខ្ទ័រមេឃក្នុងប្រហោង    ដូចប៉ោតក្នុងក្នាំងថាំងអត់ទឹក ។
រីឯអ្នកចេះតម្រេះជា    ស្ងៀមមិនអួតក្លាបញ្ចេញឫក
បង្កើនប្រយោជន៍ទាំងល្ងាចព្រឹក    ធ្វើការគគ្រឹកមិនឡូឡា ។
ច្ចេះឱមិត្តអើយគប្បីគិត    ប្រាជ្ញដោយគំនិតរសសាស្ត្រា
និងប្រាជ្ញសំបកឥតខ្លឹមសារ    គួរគិតពិចារណ៍ខ្លឹមអត្ថរស ។

CHANBOKEO.COM

# សង្គ្រាមជំនឿ

អ្នកខ្លះជឿគ្រីស្តខ្លះជឿពុទ្ធ ខ្លះជឿមេមត់គ្រូចូលរូប
ខ្លះជឿអាឡាហ៏ខ្លះអាបធ្មប់ ខ្លះទៀតជំពប់គ្រប់អ្វី១។
ថៃ្ងដន្យអ្នកជឿគ្មានព្រំដែន មិនសូវបត់បែនគិតវែងខ្លី
កាលបើអ្នកផ្សេងជឿទីទៃ តាំងគិតអប្រិយរកបំផ្លាញ។
ខ្លះសម្លាប់គេព្រោះជឿខ្លាំង មោហ៏ងើបមកបាំងមិនសូញសាញ
ខ្លះបូជាខ្លួនយ៉ាងផ្ទាលផ្ទាញ់ ដើម្បីបង្ហាញជំនឿមាំ។
ជឿនេះពិតខុសសច្ចធម៌ ភ្លេចគិតផ្លូវល្អផ្ទូរឧត្តម
បំផ្លាញជីវិតពិតក្រៀមក្រំ លង់នរកកម្មស្រង់ពុំរួច។
ច្នេះសូមប្តូរចិត្តគិតជាថ្មី កុំគិតអប្រិយចងគំនួច
ថ្វីអ្នកដទៃជឿមិនដូច សូមអោយប្រាសរួចពីភាពប្រទុស្តនឹងគ្នា..!

CHANBOKEO.COM

## ខ្លាំងខ្លាខ្លឹមខ្លាញ់

អ្នកខ្លាំងជើងកាងកម្លាំងបាយ　　អួតអាងប៉ប្រាយខ្លាយទឹកមាត់
អ្នកខ្លឹមធ្វើការជាមិនភ្លាត់　　វិន័យទៀងស្ទាត់ម៉ាត់បានការ ។
អ្នកខ្លាំងអាងដាវលីកាប់ចាក់　　អុងអាត់ឥតអាក់ឆ្លាក់ចេស្តា
អ្នកខ្លឹមញញឹមនឹមកិច្ចការ　　ដៃជើងឧស្សាហ៍ជាងបប្បូរមាត់ ។
អ្នកខ្លាំងអួតអាងពើងដើមទ្រូង　　ដូចស្គរក្ហួង១ទូងច្រវាត់
អ្នកខ្លឹមតត្រុកការងារស្ទាត់　　បំរើញាតិគាប់មិនមានស្តី ។
អ្នកខ្លាំងក្តាំងក្ហុងធុងអត់ទឹក　　ខ្ទរខ្ទារគគ្រឹកផ្អើលប៉ុរី
អ្នកខ្លឹមធុងពេញឥតឡើយភ័យ　　ប្រមូលវិស័យល្អវិសេស ។
អ្នកខ្លាំងអាងលុយទិញមុខមាត់　　អ្នកខ្លឹមពួនបាត់ចាប់តម្រេះ
អ្នកខ្លាំងអាងទ្រព្យហៀរប៉ប៉េះ　　ទិញសក្តិខ្ទិះ១បិតសំបក ។
អ្នកខ្លឹមពឹងគោលសាស្ត្របញ្ញា　　អ្នកខ្លាំងជើងក្លាមិនមានខក
ផ្អែកសញ្ញាបត្រ័ត្រឹមសំបក　　អ្នកខ្លឹមសកញ៉ូកត្រកសុទ្ធត្រី ។
ខ្លាំងខ្លាខ្លឹមខ្លាញ់ចម្រាញ់យស　　នាមាពិរោះថ្កើងល្បាញល្បី
ស្ថិតលើខ្លឹមការប្រយោជន៍ក្រៃ　　ខេមរាមេត្រីទទួលផល ។

# វគ្គទីមួយ

## ត្រៀម

ឃុំព្រះនេត្រព្រះ ខែសីហា ឆ្នាំ១៩៥៨...

នាយភុំជិះកង់ឌុបតាញ៉ោមេឃុំលើខ្សាច់សលើផ្លូវលំក្រវិកក្រវក់ កាត់ ពាសពេញភូមិ ប្រកូកហៅគ្នីគ្នាឱ្យមកជួយរៀបចំប្រក់ដំបូល ប្រក់ជញ្ជាំង សាលារៀនបឋមសិក្សាដែលមានតែប្រាំបន្ទប់ប៉ុណ្ណោះ។ ពេលនេះ តាញ៉ោបានទទួលពត៌មានពីក្រុងបាត់ដំបងមកថា ក្រសួងសិក្សាធិការកំពុងបញ្ជូន គ្រូថ្មីមកថែមម្នាក់ទៀត ត្បិតឥលូវនេះគេកំពុងចង់តម្លើងចំនួនថ្នាក់រៀន ថែមមួយថ្នាក់ ដើម្បីតម្រូវតាមសេចក្ដីត្រូវការក្នុងឃុំ។ នៅជំនាន់នោះ ផ្លូវក្នុងភូមិតូចចង្អៀតជណ្ដប់ដោយខ្សាច់ផង់ពណ៌ស ពិបាកធ្វើដំណើរទៅ ណាមកណាណាស់។ នៅរដូវក្ដៅបើសិនគេដើរជើងទទេនោះច្បាស់ជា រលាកមិនខាន បើជិះកង់ឬបររទេះវិញ ក៏ផុងពិបាកធ្វើដំណើរដូចគ្នា។ ប៉ុន្ដែបើនៅខែភ្លៀង ដីរាងធឹងបន្ដិច អ្នកស្រុកធ្វើដំណើរមិនសូវពិបាកប៉ុន្មាន ទេ។ ម្យ៉ាងទៀត អ្នកស្រុកក៏រស់នៅរប៉េះរប៉ោះរប៉ាត់របាយពាសពេញឃុំ មិនទៅជិតៗគ្នាប៉ុន្មានដែរ ដោយគេម្នាក់ៗប្រកបរបរធ្វើស្រែ ឬក៏រកស៊ីដាំដុះអ្វីៗទៀតទៅតាមដីដែលមានអំណោយផល ទើបបានជាមិននៅម្ដុំៗគ្នា ទេ ហើយស្រុកភូមិម្ដុំនោះក៏មិនសូវសំបូរទឹកទៀតផង។ នៅរាល់ខែប្រាំង អ្នកស្រុកតែងតែដើរទៅរែកទឹកពីបឹង ដែលស្ថិតនៅឆ្ងាយពីភូមិរាប់គីឡូឯណោះ។

ទំរាំនាយភុំជិះកង់ឌុបតាញ៉ោ ដើម្បីប្រាប់ដំណឹងអ្នកស្រុកពីដើមភូមិ ជប់ទៅប៉ោយក្បឿង ប៉ុសចាស់ ភូមិកណ្ដាល រហូតដល់ប៉ោយព្រីងជាដើម អស់នោះ គេដង្ហក់ខ្យល់ដូចក្របីឃ្លៀកត្រូវថ្ងៃអត់ទឹកភក់ត្រាំដូច្នោះឯង។ មកដល់ផ្ទះវិញ នាយភុំរអ៊ូរដាក់តាញ៉ោថា :

- មើលទៅ ខ្ញុំអាចជួយតា បានតែថ្ងៃហ្នឹងទេ។ នៅពេលព្រឹកស្អែកនេះ ខ្ញុំសុំដេកហើយ!
- យីអើ អីក៏ឆាប់បាក់លោងម្ល៉េះ! យើងជិះពីក្រោយមិនឃើញហត់អីបន្ដិច
- អញ្ជឹង ស្អែកនេះ ពេលចេញទៅប្រក់សាលា តាឌុបខ្ញុំវិញម្ដងណា៎!
- អើ! ចាំយើងឌុបតែឯងចុះ! តែកុំភ្លេចចុះជួយរុញយើងផង ពេលកង់ ជាប់ផុងក្នុងខ្សាច់ ឮហើយនៅនាយភុំ?

នាយភុំសើចរ៉េសៗខ្ចាយទឹកមាត់តែម្ដង។ ការពិត នាយភុំ គឺជាក្មេង កម្លោះមានកំណើតនៅភ្នំស្រុក ដែលតាញ៉ោចិញ្ចឹមជាកូនជាចៅ ត្បិតគេជា មនុស្សគ្មានម្ដាយឪពុកឬសាច់ញាតិអ្វីសោះ។ ចំណែកតាញ៉ោនិងយាយព្រីង

CHANBOKEO.COM

ជាប្រពន្ធក៏គ្មានកូនគ្មានចៅអ្វីមួយគ្រាប់ដែរ ម្ល៉ោះហើយនាយភុំក៏ក្លាយជា ប្រមាត់បេះដូងរបស់តាមេឃុំនិងប្រពន្ធគាត់តែម្តងទៅ ត្បិតគេជាមនុស្ស ល្អ មានសន្តានចិត្តហើយចេះកំប្លែងរួសរាយណាស់ ។

ព្រឹកស្អែកឡើង...

អ្នកភូមិជាច្រើននាក់ឆ្លៀតឱកាសពីស្រែចំការរបស់ខ្លួន នាំគ្នារត់មក ជួយកាប់ឫស្សី ក្រងស្លឹកត្នោត ដើម្បីសង់ថ្នាក់រៀនមួយថ្មីបន្តពីរោងចាស់ ដែលមានសភាពទ្រុឌទ្រោមបន្តិចទៅហើយ ។ រំពេចនោះ បុរសសង្ហាមួយ រូបរាងស្តើងស្រឡះ បានជិះសេះមកដល់ ។ កាលបើក្រលេកឃើញអ្នកភូមិ កំពុងធ្វើការយ៉ាងញាប់ដៃញាប់ជើង មាណពនោះក៏បន្លឺវាចាឡើងថា :

- ជំរាបសួរតាមេឃុំ! អ្នកភូមិធ្វើការប្រញ៉ាប់ប្រញ៉ាល់យ៉ាងនេះ ប្រហែលជា មានពិធីអ្វី ពិសេសក្នុងភូមិហើយមែនទេ?

- អូហ៎! លោកចក្រា! គឺយើងកំពុងប្រក់សាលាទទួលគ្រូថ្មីម្នាក់មកពី បាត់ដំបង ។ ថ្ងៃស្អែកនេះ គ្រូបង្រៀនថ្មីនោះនឹងមកដល់ឃុំយើងហើយ ។ ហើយចុះលោកវិញ អញ្ជើញមកដល់ព្រះនេត្រព្រះតាំងពីអង្កាល់ហ្នឹង?

- គឺខ្ញុំមកដល់តាំងពីយប់មិញម្នាក់ឯង មកជួបជាមួយអ្នកស្រុកឯភូមិ ប៉ោយក្បឿង និងប៉ុស្តិ៍ចាស់ ។

- អញ្ចឹង លោកនៅពិសារជុំគ្នាជាមួយយើងទីនេះសិនទៅ ។ ពេលនេះ ថ្ងៃត្រង់ហើយ ដល់ពេលយើងត្រូវឈប់សំរាកទទួលទានបាយល្ងាច ។

- បាទ! មិនអីទេ អរគុណតាមេឃុំ! ចាំថ្ងៃក្រោយចុះ!

- បើអញ្ចឹង តាសូមអញ្ជើញលោកចក្រាអោយហើយណា៎ ថាកុំភ្លេចមក ចូលរួមពិធីទទួលគ្រូបង្រៀនថ្មីនិងពិធីសម្ពោធសាលារៀនយើងនេះផង ។

- បាទ! ខ្ញុំនឹងមកចូលរួមមិនខានឡើយ ។

ថាហើយមាណពក៏បំផាយសេះចេញទៅ ។ ភ្លាមនោះ នាយភុំក៏ស្ទុះ មកខ្សិបសួរតាញ៉ៅយើងថា :

- តា! តា! ខ្ញុំមិនដែលឃើញបុរសសង្ហាម្នាក់ហ្នឹងពីមុនមកទេ ។ តើគេជា នរណាដែរ?

- អូហ៎! គឺជាកូនប្រុសទោលរបស់ដង្ហោស្រែដ៏មានអំណាចម្នាក់ នៅស្រុក ព្រះនេត្រព្រះនេះ ។

- មើលទៅឫកពាបុរសនេះ ហាក់ដូចជារើសអើងឆ្មើងឆ្មៃដល់សូរហើយ!

- ឯងមានភ្នែកមុតគ្រាន់បើ នាយភុំ!

- ចុះអ្នកភូមិយើងបណ្តាក់ទុនជាមួយបុរសម្នាក់នេះគ្រប់គ្នាដែរទេតា?

- គ្រួសាររបស់គេជាមនុស្សមានអំណាចខ្លាំងក្លា ហើយមានដីស្រែច្រើន ណាស់នៅម្តុំៗយើងនេះ ដែលគេប្រវាសជាមួយអ្នកភូមិម្តុំនេះជាច្រើន គ្រួសារ ។ លុះដល់រដូវចម្រូត ពេលស្រូវឡើងលាន គេក៏មកដើរប្រមូលយកថ្លៃស្រែរបស់គេជាស្រូវថាំងត្រលប់ទៅវិញ... ។ ភាគច្រើន គេមិនសូវ មកប្រមូលស្រូវដោយខ្លួនឯងទេ មានតែកូនចៅដៃជើងរបស់គេប៉ុណ្ណោះ ដែលមកទារស្រូវបំណុល ។ ពេលនេះ មិនដឹងជាមាន ខ្យល់ចម្លែកអ្វីទេ

CHANBOKEO.COM

សុខៗស្រាប់តែគេមកដល់ទីនេះដោយខ្លួនឯងតែម្តង។ តាមមើល ឆ្នាំនេះ ប្រហែលជាមានកូនបំណុលកើនជាងមុនហើយ ទើបគេចេញមុខមកដើរ ជួបអ្នកស្រុកក្នុងឃុំព្រះនេត្រព្រះនេះដោយខ្លួនឯង។

ភ្លាមនោះ ស្រាប់តែជាងប្រក់ដំបូលម្នាក់ស្រែកកូកឡើង កាត់ផ្តាច់ការ សន្ទនារបស់អ្នកទាំងពីរ :

- តាមេឃុំ! ភុំអើយ! ដល់ម៉ោងពិសារបាយហើយបាទ!

តាព្នៅបែររកម្ចាស់សម្លេង ក៏ប្រទះនឹងនរៈមួយរូបក្នុងវ័យប្រមាណ ២៧ឆ្នាំមានស្នាមសម្លាកនៅលើចង្កាខាងស្តាំ រួចនៅលើដៃទាំងពីររបស់គេ ទំនងដូចជាធ្លាប់ត្រូវរបួសដោយការរលាកភ្លើងដូច្នោះឯង។ ចៃដន្យគេបាន ពាក់អាវដៃវែងលប់ជិតខ្លួនអស់ ទើបគ្មាននរណាឃើញឬទាយដឹងថាតើ គេមានស្នាមសម្លាកលើខ្លួនប៉ុណ្ណាទេ តាមមើលប្រហែលជាមិនតិចដែរទេ ត្បិតស្នាមនៅលើដៃនិងចង្ការបស់គេ បានបង្ហាញនូវសភាពដែលគេបាន ទទួលរងគ្រោះនាអតិតកាលមិនតិចតួចឡើយ។ គេបានហក់ចុះពីលើដំបូល សាលាមក ហើយស្ទុះទៅដោះស្រាក់បាយយ៉ាងរហ័សរហួន រួចរៀបរប ជូនអ្នកធ្វើការបរិភោគជុំគ្នា។ អ្នកភូមិបួនដប់នាក់ទៀតក៏នាំគ្នាលាងដៃ ដើងចូលបរិភោគស្ងៀមស្ងាត់។ ភ្លាមនោះ តាព្នៅក៏សួរឡើងថា :

- យីអើ! ពីណាគេហ្នំ ចិត្តល្អទូលាយម្ល៉េះ មានសន្តានចិត្តយកបាយសម្លមក ផ្ញើពួកយើងដែលខំធ្វើការហត់នឿយថ្ងៃនេះ? យើងទៅរកអរគុណគេសិន!

ភ្លាមនោះ អ្នកស្រុកម្នាក់ឆ្លើយថា :

- អ្នកស្រុកគេនាំគ្នាទៅស្រែអស់ហើយ តាមេឃុំអើយ! គ្មាននរណាគេ មានពេលយកបាយមកផ្ញើយើងទេ។ ការពិតគឺនាយជាងសម្លាកនេះ គេ ក្រោកតាំងពីព្រហាម ស្លដាំយកមកផ្ញើយើង មុននឹងគេមកជួយប្រក់ដំបូល សាលានេះអី តាមិនដឹងទេហ៎?

តាព្នៅឮដូច្នោះក៏លាន់មាត់ឡើង :

- អូហ៎អើ! យើងភ្លេចគិតអោយឃើងថា ថ្ងៃនេះជាងសម្លាកគេមកចូល រួមជាមួយយើងដែរ! យី! ចំមែនតាព្នៅនេះ!

មានប្រសាសន៍លាន់មាត់ចប់ តាមេឃុំក៏បែរទៅបុរសសម្លាកហើយ ពោលបន្តថា:

- អរគុណណាស់ជាងអើយ! ឯងឧស្សាហ៍មែនណ៎ា ដែលឯងបានដាំបាយ មកផ្ញើពួកយើងហើយថែមទាំងមកជួយប្រក់សាលាទៀត។ ឯងជាមនុស្ស កម្លោះ មិនមានប្រពន្ធកូនមែន តែឯងមានសន្តានចិត្តឈឺឆ្អាលចេះគិតគូរ ដល់ក្មេងភូមិយើងហាក់បី ដូចជាសាច់ញាតិ ឬជាឪពុករបស់គេម្នាក់។ តា សូមអរគុណឯងជំនួសអ្នកភូមិយើងផងណ៎ា!

បុរសសម្លាកឈរធ្វើញញឹមៗហើយឈ្ងោកមុខនៅស្ងៀម មិនឮស្រដី តបអ្វីទៅរកតាមេឃុំវិញទេ។ បន្តិចមក តាព្នៅក៏ដើរទៅទះស្មានរៈយើង ហើយសួរថា :

- យ៉ាងម៉េចទៅហើយរឿងសង់កុដិនៅវត្តក្រោម? សង់ហើយឬនៅ?

CHANBOKEO.COM

- បាទ! មិនទាន់ហើយទេ តែខ្ញុំបានសុំច្បាប់ព្រះគ្រូអធិការមកជួយខាង សាលារៀនសិន ព្រោះលោកគ្រូថ្មីនឹងមកដល់អាទិត្យនេះហើយ ក្រែងតែ កុនសង់សាលាមិនទាន់។

- អឺៗ! ពិតជាមានទឹកចិត្តមែនណាំជាងសម្លាក! តែប៉ុណ្ណេះ ក្មេងៗក្នុង ភូមិពិតជាត្រេកអររំភើបណាស់ ដែលមេជាងនាំអ្នកភូមិមកជួសជុលសង់ សាលា អោយគេបានរៀនបានសូត្រចេះអក្សរអ្វីហ្នឹងគេ។

ជាងងើបមុខឡើងហើយឆ្លើយវិញទាំងមុខស្លូតថា :

- បាទ! នោះមកពីខ្ញុំចង់ឃើញប្អូនៗមានឱកាសបានរៀនសូត្រខ្ពង់ខ្ពស់.. ព្រោះខ្លួនខ្ញុំល្ងិតល្ងង់ រៀនបានត្រឹមតែនមោកខក្នុងវត្តបន្តិចបន្តួច... យក ជាការមិនបាន...

តាមេឃុំក៏យកដៃអង្អែលខ្នងលួងចិត្តជាងសម្លាក ដែលមានកិរិយា ហាក់ដូចជាទឹកស្តាយ ដោយគេមិនបានចូលរៀនសូត្រអ្វីនឹងគេកាលនៅពី ក្មេងៗឱ្យបានខ្ពង់ខ្ពស់។ បន្តិចមក តាញ៉ៅក៏មានប្រសាសន៍លួងលោមនាយ វិញដោយវាចាស្រទន់ថា :

- កុំតូចចិត្តអី... ជាងឯងក៏មានជំនាញខាងខាងសង់ផ្ទះអីៗទាំង នោះដែរ ថ្វីបើជាងមិនបានរៀនអក្សរសាស្ត្រអ្វីបានជ្រុំជ្រើងអ្វីហ្នឹងគេក៏ដោយ ក៏ជាង នៅមានទេពកោសល្យយ៉ាងជំនាញ សំរាប់ជួយដោះស្រាយទុក្ខធុរៈអ្នក ស្រុកយើងជាច្រើនរាប់មិនអស់..! នោះក៏មិនមែនធម្មតាដែរណាំជាង!

ជាងសម្លាកញញឹមឡើងវិញ កាលបើឮតាមេឃុំមានវាចាលើកទឹក ចិត្តរូបគេដូច្នោះ។ បន្ទាប់មក ទាំងអស់គ្នាក៏បរិភោគអាហារយ៉ាងស្ងាត់ ស្ងៀម។ រសៀលបន្តិច រោងថ្មីក៏បានប្រក់ហើយ តែស្លឹកត្នោតដែលក្រងទុក មកនោះអាចបាំងបានត្រឹមតែ ដំបូលមួយមូលនិងជញ្ជាំងបីផ្ទាំងប៉ុណ្ណោះ។ ចំណែកឯថ្នាក់រៀនវិញ ត្រូវនៅចំហល្ហល្ហេវ បើមើលពីទីធ្លាមុខសាលាមក ឃើញសិស្សឃើញគ្រូទាំងអស់គ្នា មិនកំបាំងឡើយ។ ពេលនោះ ស្រាប់ តែក្មេងភូមិម្នាក់អាយុប្រមាណ១៣ឆ្នាំ ឈ្មោះនាយប្រវឹក លាន់មាត់ថា :

- អីយ៉ា ដល់សង់រួចហើយ សាលានេះស្អាតអីស្អាត! មានជញ្ជាំងបី ចំហ ជញ្ជាំងមុខ បើសិនយើងខ្ចីរោងរៀននេះ សម្តែងយីកេចូលឆ្នាំថ្មី ប្រហែល ជាឡូយយ៉ាងហើយ!

តាមេឃុំយារដៃខោកក្បាលមាណពមួយក្រញ៉ាំដៃលាន់ផ្លក់ :

- យ៉ាប់មែន នាយប្រវឹក! នេះយកមួយទៅអោយវាភ្លឺស្វាងបន្តិច។ ពួក យើងនាំគ្នាសង់សាលា ដើម្បីឱ្យក្មេងរៀនសូត្រកុំអោយវាល្ងង់ តែឯងវិញ បែរជាលង់នឹងយីកេយ៉ាងសឿង នេះឯងមិនចង់ឱ្យក្មេងរៀនសូត្រអីទេហ្អី?

- អីយ៉ូយ តា! ដៃធ្ងន់ម្ល៉េះ? គ្រាន់តែនិយាយលេងផងមិនបានដែរ។

- អើ! អញក៏ខោកឯងលេងដែរតើ រអ៊ូស្អី? អាទិត្យក្រោយនេះ ចូរឯង កុំភ្លេចជួយដើរប្រមូលកូនក្មេង អោយគេមកចូលរួមទទួលគ្រូថ្មីគ្រប់ៗគ្នា ឮហើយនៅ?

នាយប្រវឹកយកដៃអង្អែលក្បាលហើយក៏ឆ្លើយថា :

CHANBOKEO.COM

- មិនហៅទេ... ចាំប្រវឹកបាត់ពកក្បាលសិន បានហៅអោយ ។

រួចហើយនាយយើងក៏រត់បាត់ទៅ ។ អ្នកភូមិក៏នាំគ្នាសើចកក្អឹកឡើង យ៉ាងរីករាយ ។ មែនហើយ! តាញ៉ៅជាមនុស្សមាត់អាក្រក់តាំងពីដើម តែគាត់ជាមនុស្សជាមានសន្ដានចិត្តល្អ តែងតែរកផ្លូវជួយអ្នកស្រុកអោយមានជីវិតថ្កុំថ្កើងជាងមុនជានិច្ច ។

ព្រឹកស្អែកឡើង ជាងសម្លាកក៏ក្រោកពីព្រហាមតាមទម្លាប់របស់គេ ចេញពីភូមិសំដៅទៅកំពូលភ្នំព្រះនេត្រព្រះ ដោយមានកាន់ផ្កាស្មៅរឿង មួយកម្រងទៅជាមួយផង ។ ឱ! តើគេយកផ្កាទៅណាហ្ន៎?

មកដល់ចង្កេះភ្នំ ស្រាប់តែជាងសម្លាកយើងប្រទះនឹងក្មេងប្រុសមួយរូបអាយុប្រមាណ១២ឆ្នាំកំពុងរែកអង្ករឡើងទៅលើភ្នំដែរ ។ ឃើញយ៉ាប់ ភ្នែកពេក ជាងសម្លាកមុខក៏មានវាចាឡើងថា :

- នាយខ្លែងអើយ! ម៉ោះ! អោយពូជួយរែកឯងវិញ!

កុមារជំទង់នោះងាកមកឃើញជាងសម្លាកភ្លាម ក៏ញញឹមភ្លែតតែម្ដង រួចហើយដាក់អម្រែកចុះភ្លាមឱ្យជាងសម្លាកសាងយកវិញ ។ បុរសយើង ក៏រែកអង្ករឡើងរហូតដល់លើភ្នំ រួចយកទៅប្រគេនព្រះសង្ឃមួយអង្គនិង តាអាចារ្យម្នាក់ដែលស្នាក់នៅវត្តខាងលើភ្នំជាប្រចាំ ។ ឃើញបុរសយើង ភ្លាមតាអាចារ្យក៏លាន់មាត់ថា :

- អីយ៉ា ជាងសម្លាក! បាត់មុខប៉ុន្មានអាទិត្យហើយមិនឃើញឡើងភ្នំសោះ អាល័យ បាត់ទៅណាយូរម្ល៉េះ? ដឹងទេថាតានឹកឯងដល់សួរហើយ ។

- គឺខ្ញុំអាល័យជាប់សង់កុដិនៅវត្តក្រោមផង  អាល័យជួយសង់សាលារៀន យើងផង ទើបមិនអាចឆ្លៀតមកបាននោះអីណាំបាទ ។

- អឺ! យ៉ាងណាក៏កុំភ្លេចតាវ៉ើយ! មកអើត១ខ្លះផង ហ្ន៎ក! សូម្បីតែ ព្រះគ្រូក៏ចាំមើលផ្លូវឯងផ្សាភ្នែកដែរ ។

បន្ទាប់ពីយកអង្ករទៅរៀបទុកដាក់ហើយ បុរសយើងក៏ចូលទៅថ្វាយ បង្គំព្រះគ្រូនៅក្នុងកុដិ ។ បន្តិចក្រោយមកគេក៏ចុះដើរត្រលប់ទៅក្បែរ ល្បាក់ភ្នំខាងត្បូងវត្ត ហើយសសៀរចុះសំដៅទីធ្លាមួយ ដែលមានផ្នូរបី តម្រៀបទន្ទឹមគ្នា ព្រមទាំងមានកន្លែងតាំងទីសក្ការៈសំរាប់អុជធូបបូជា ដល់វិញ្ញាណក្ខន្ធ័របស់ម្ចាស់ផ្នូរផង ។ គ្រាន់តែចុះមកដល់ទីធ្លាម្ដុំនោះភ្លាម បុរសយើងបានក្រលេកពីចម្ងាយមក ឃើញស្រមោលមាណវីមួយរូបមាន កេសាវែងសាយរវែងអន្លាយដល់ចង្កេះ កំពុងតែអោនក្រាបបង្គំនៅចំពោះមុខ ផ្នូរ រួចហើយក៏ងើបដើរចេញទៅម្ខាងទៀត រកតែមើលមុខសំគាល់ថាជានរណាក៏មិនបានផង ។ នរៈយើងរំពៃមើលតាមរហូតដល់បាត់រូបនាងទៅ ក្នុងព្រៃលើភ្នំបាត់ទៅ ។ ពេលនោះ គេនឹកឆ្ងល់ណាស់ថាតើនារីនោះជា នរណា ។ ការពិត គេមកទីនេះរៀងរាល់អាទិត្យ អស់រយៈជាយូរឆ្នាំហើយ តែមិនដែលប្រទះឃើញនរណាម្នាក់មកសំពះសពម្ចាស់ផ្នូរទាំងបីនេះទេ ។ នេះជាលើកទីមួយហើយដែលគេជួបមនុស្សចំលែកមកដល់ទីនេះ ។ ជាងសម្លាកយកដៃញីភ្នែកដដែល១ ជាច្រើនដង ថែមទាំងនឹកគិតក្នុងចិត្តថា :

- តើខ្ញុំកំពុងស្រម័យ ឬក៏កំពុងប្រទះការពិត?... តើនារីនោះជាមនុស្ស ពិតឬក៏ជាព្រលឹងវិញ្ញាណ ដែលចេញមកបញ្ឆោតលលេងសតិអារម្មណ៏ របស់ខ្ញុំទេ?...គួរអោយឆ្ងល់ណាស់...!

CHANBOKEO.COM

លុះនាយដាក់ភ្នែកទៅខាងទីសក្ការៈ ដែលមានជើងដាក់ជើងធូបធំ មួយនៅលើសិលាយ៉ាងធំមួយផ្ទាំង ស្រាប់តែប្រទះឃើញមានធូបកំពុង ឆេះហុយៗ នៅឡើយ ។ នាយយើងក៏ញញឹមឡើង :

- មែនហើយ.. នាងមិនមែនជាព្រលឹងវិញ្ញាណទេ... ច្បាស់ជាមនុស្សពិត ប្រាកដណាស់!

ជាងសម្លាកក៏បែរមើលទៅទិស ដែលធិតាមួយរូបនោះដើរចេញទៅ ទំនងដូចជាមិនទាន់អស់ចិត្តដែលងឿងឆ្ងល់ថានាងជានរណា ។ បន្តិចមក នាយយើងក៏យកកម្រងផ្កាស្បែរឿងទៅដាក់នៅលើទីសក្ការៈ ហើយក៏អុជ ធូបបួងសួងភ្លាមដែរ ។ គេនៅអង្គុយទីនោះយ៉ាងយូរ រហូតដល់ផ្សែងធូប រលត់អស់ ទើបអោនបង្គំលាម្ចាស់ផ្នូរ ត្រលប់ចុះពីភ្នំសំដៅទៅសាលារៀន ដែលនាយបានមកជួយសង់ពីម្សិលមិញ ។

ថ្ងៃដន្យ ថ្ងៃនេះ អ្នកស្រុកបានត្រលប់នាំគ្នាទៅចុះស្រែអស់ហើយ នៅសល់តែនាយភុំម្នាក់ប៉ុណ្ណោះ ដែលតាញៀដេញមកឱ្យជួយបោសជួយជំរះ ស្មៅសំអាតទីធ្លាសាលាបង្ហើយការ ត្បិតអីសាលាបើកចូលរៀនអាទិត្យ ថ្មីនេះហើយ ។ កាលបើប្រទះឃើញជាងសម្លាកមកដល់ នាយភុំញញឹម ឡើងបំព្រងតែម្តង :

- បងសម្លាក! មិនទៅសង់កុដិថ្មីទេថ្ងៃនេះ?

ជាងក៏ឆ្លើយវិញថា :

- ចឹមិនទៅ តែបងចង់មកជួយប្អូនម៉ាភ្លែតសិន ។

ថាហើយនាយក៏ទាញចបកាប់មកចាំងស្មៅភ្លាម ។ ទាំងពីរនាក់ធ្វើការ យ៉ាងស្វាហាប់រហូតដល់ហើយរួចរាល់មុនពេលបាយថ្ងៃត្រង់ ។ កំពុងតែ សំរាកបរិភោគអាហារ ស្រាប់តែនាយភុំស្រដីសួរជាងយើងថា :

- បងសម្លាក! មានដឹងទេ ថាតើគ្រូថ្មីដែលមកបង្រៀនក្នុងឃុំយើងនេះ ក្មេងឬចាស់ ប្រុសឬក៏ស្រី?

- បងអត់ដឹងទេ ភុំអើយ! ប៉ុន្តែ បងគិតថា ច្បាស់ជាប្រុស ហើយ ចាស់ទៀតផង ។

- ហ្អា៎ក! ម៉េចអញ្ចឹងទៅវិញ?

- តើមានគ្រូក្មេងឯណាទៅ ដែលសុខចិត្តបណ្តាច់ខ្លួនពីសង្គមធំៗ ចេញមក បង្រៀន នៅស្រុកស្រែជនបទអត្តខាត់ដូចជាឃុំយើងនោះ? ជាពិសេស បើជានារីវិញ... គឺច្បាស់ជាអត់ហើយ... មានន័យថា បើគ្រូស្រីនោះនៅលីវ ច្បាស់ជាមិនហ៊ានផ្លាស់មកសោះ ហើយបើសិនជាមកវិញ គឺឪពុកម្តាយ របស់នាងត្រូវតែដូរផ្ទះ រត់មកតាមការពារកូនមិនខាន ។ តែបើគ្រូស្រី នោះជាមនុស្សមានក្រុមគ្រួសាររួចហើយ ប្តីរបស់គាត់ត្រូវតែប្តូរការងារ រត់មកតាមប្រពន្ធមិនខាន.. គាត់ពិតជាមិនហ៊ានបណ្តោយអោយប្រពន្ធ មករស់ នៅចុងកាត់មាត់ញកតែម្នាក់ឯងដូច្នេះទេ ។

- ប៉ុន្តែនៅសាលាយើងនេះ មានសុទ្ធតែគ្រូប្រុសៗ ហើយចាស់ៗទៀត ។ លើកនេះ បើសិនយើងបានគ្រូស្រីម្តង ប្រហែលជាស្រុកយើងអាចផ្លាស់ប្តូរ បរិយាកាសខ្លះៗណា៎!

CHANBOKEO.COM

- ម៉េចក៏ឯងនិយាយដូច្នេះ នាយភុំ?

- ព្រោះអីស្រុកយើងនេះមិនដែលមានអ្នកចេះដឹងជាភេទស្រីទេណាបង ។ មើលចុះ! នៅម្តុំយើង តើមាននារី១ឬស្រ្តីប៉ុន្មាននាក់ទៅដែលបានចូលរៀន មានការចេះដឹងនោះ? ហើយបើសិនជាមានគឺយ៉ាង ច្រើនចេះត្រឹមធ្វើឆ្អប បុរាណប៉ុនហ្នឹង ។

- ឯងគិតយ៉ាងនេះក៏សមរម្យដែរណាភុំ! ប៉ុន្តែ... តើយុំយើងមានវាសនា ទេហ្ន៎...
ដែលនឹងបានទទួលគ្រូស្រីមកបង្រៀនក្មេង១នៅទីនេះ?

ភុំក៏ញញឹមឡើង :

- ខ្ញុំសុំបន់ស្រន់អោយគ្រូបង្រៀនថ្មី ដែលនឹងមកដល់អាទិត្យក្រោយនេះ ជាស្រី ហើយនៅលីវទៀតផង... !! សាធុ!!

នាយភុំលើកដៃឡើងសំពះបន់ ។ ជាងសម្លាកឃើញ ក៏សើចខឹក១ :

- ម៉េចទៅហើយ? ដល់ថ្នាក់បន់រកគូព្រេងហើយឬ ប្អូនភុំ?

- ហ៎ៃស១! អត់ទេ.. ខ្ញុំនៅក្មេងណាស់ ទើបតែចូល២០ឆ្នាំទេ បើសិនជា បន់រកគូព្រេងវិញនោះ
ខ្ញុំសូមបន់រកគូព្រេងអោយបងសម្លាកឯងមុន ហើយ ។ មើលហ្ន៎ក! នៅកម្លោះចាស់ព្រេងចាស់ព្រឹទ្ធយូរណាស់ហើយ មិនឃើញទៅណាមកណានឹងគេសោះ ។

ឮដូច្នោះ ជាងយើងដាក់មុខចុះ ធ្វើមុខស្ងួត ហើយក៏ស្រដីខ្សិប១ថា :

- បុរសដែលមានមុខមាត់អាក្រក់អាក្រីដូចជាបងនេះ តើនារីណាមួយទៅ គេនឹងយកភ្នែកមើល? ជាពិសេស បងក៏ជាមនុស្សក្រីក្រ គ្មានវិជ្ជា គ្មាន ទ្រព្យសម្បត្តិ គ្មានក្រុមគ្រួសារសាច់ញាតិចាស់ទុំអ្វីផងនោះ?

- កុំទាន់អស់សង្ឃឹមអីបងសម្លាកអើយ! ខ្ញុំថានារីដែលសម្លឹងបងដោយ ភ្នែក ច្បាស់ជាមិនអាចមើលឃើញតម្លៃពិតរបស់បងឡើយ តែបើគេ យកបេះដូងមកសម្លឹងបងវិញ ខ្ញុំថាបងប្រាកដជាបេក្ខជនដែលត្រូវទទួល ជ័យលាភីលេខមួយជាមិនខាន ។

ជាងសម្លាកនៅស្ងៀមមិនឆ្លើយ គ្រាន់តែញញឹមស្ងួតតែប៉ុណ្ណោះ ។ នាយភុំមិនអស់ចិត្តទេ
កាលបើឃើញជាងសម្លាកគេសម្តែងឫកពា ហាក់ ដូចជាមានការអស់សង្ឃឹមក្នុងជីវិតណាស់ចំពោះរឿងគូស្រករ ។ មុននឹងបែកគ្នាទៅ គេបែរទៅមាណពយើងហើយនិយាយលួងចិត្តថា:

- បងសម្លាក! បងជាមនុស្សល្អប្រពៃមួយរូប បងប្រាកដជានឹងបានជួប គូព្រេងដែលជាមនុស្សល្អប្រសើរមិនខានឡើយ
មិនយូរមិនឆាប់ខាងមុខ នេះ ។ ភុំហ៊ានភ្នាល់បងទុកជាមុនណា៎!

ថាហើយ នាយយើងក៏ឡើងធាក់កង់ចេញទៅ ។ ជាងសម្លាកក៏បែរ សម្លឹងទៅរោងថ្មីដែលទើបសង់ហើយ
សំរាប់គ្រូថ្មីដែលនឹងមកដល់អាទិត្យ ក្រោយនេះ ទាំងចិត្តច្របូកច្របល់.... មិនដឹងថា អ្វីដែលនាយភុំស្រដី អំបាញ់មិញនេះ
ជាប្រផ្នូល ឬក៏ជាទំនាយវាសនារបស់នាយ... ។ បន្តិចមក
នាយក៏ដើរចេញសំដៅទៅវត្ត ដើម្បីសង់កុដិលោកបង្ហើយ ។

នៅថ្ងៃបន្ទាប់មក...

CHANBOKEO.COM

ជាងសម្លាកបានងើបពីដំណេកចេញពីផ្ទះតាំងពីព្រហាម ដើម្បីទៅតុប

តែងទីធ្លាខាងមុខសាលាសំរាប់បើកពិធីទទួលស្វាគមន៍គ្រូបង្រៀនថ្មី ។ លុះ ចូលមកដល់បរិវេណរបស់សាលាភ្លាម

ស្រាប់តែនរៈយើង ប្រទះឃើញ មាណវីមួយរូបដ៏ស្រស់ស្អាតសោភា មានកេសាវែងអន្លាយ ដំណើរទំនងដូច

ជានារីដែលនាយបានឃើញស្រមោលពីក្រោយ កាលពីថ្ងៃម្សិលនោះដល់ ហើយ ។ ធិតាកំពុងឈរស្ងៀមស្ងាត់

ពិនិត្យបរិយាកាសជុំវិញសាលា ។ កាលបើឮសូរបជើងរបស់ជាងសម្លាកចូលមកដល់ ឆវីងាកវឹងបែរមុខមក រកមើលយ៉ាងរហ័ស

ហើយស្រាប់តែអ្នកទាំងពីរប្រទាក់នឹងខ្សែភ្នែកគ្នាទៅ វិញទៅមកជាលើកដំបូង ។ ពុទ្ធោអើយ! មាណវីមួយរូបនោះ មានសម្ផស្ស

ទាក់ភ្នែកជាងយើងណាស់! គ្រាន់តែជាងសម្លាកយើងក្រឡេកឃើញភក្ត្រា របស់ស្រស់ស្រីភ្លាមកាលណា

បេះដូងរបស់គេរំភើបរំជើបរំជួលលាន់ឮ ឱបខ្ទាក់ៗខ្ទរខ្ទារពាសពេញដើមទ្រូងខុសចង្វាក់តែម្ដង ។ គេឈរសម្លឹងទៅ

នាងយ៉ាងភាំងស្មារតី ក្នុងចិត្តស្រម័យថាខ្លួនគេកំពុងតែហោះអណ្ដែតនៅ លើផ្ទៃអាកាសវេហាស៍ដ៏ធំធេង

ក្បែរទេពធិតាដែលមានរូបឆោមលោម ពណ៌ស្រស់ស្អាតគួរឱ្យប្រតិពទ្ធ័ឥតឧបមា ។ រីឯឆវីមួយរូបនោះវិញ សោត

ក៏សម្លឹងមុខបុរសយើងដោយ ទឹកមុខភ្ញាក់ផ្អើលមិនខុសគ្នាឡើយ មិនដឹង ថានាងមានអារម្មណ៍យ៉ាងណា

ចំពោះវត្តមានរបស់បុរសយើងទេ ។ កាល បើប្រទះនឹងកែវភ្នែកធិតាដ៏ភ្លឺថ្លារលោងសម្លឹងមករកខ្លួន ជាងសម្លាកយើង

ក៏ឈ្ងោកទំលាក់មុខចុះ សំដែងឫកពាដ៏មានសុជីវធម៌ ចំពោះនារីមួយរូប នោះ ហើយក៏ដកខ្លួនទៅម្ខាង

មិនហ៊ានទៅរំខានអារម្មណ៍ដ៏ស្ងៀមស្ងាត់ របស់នារីយើងដែរ ។ គេក៏ប្រញាប់បែរទៅចាប់ធ្វើកិច្ចការ ដែលគេបាន

ត្រៀមកាលពីម្សិលទុកមក ។ យូរៗម្ដង មាណពលួចចោលកន្ទុយភ្នែកទៅ រកធិតាសោភានោះភ្លេកៗ

ហាក់បីដូចជាមិនអស់ចិត្តសោះឡើយ ។ ពេល នោះ មាណពមានអារម្មណ៍ថា បេះដូងរបស់នាយកំពុងត្រូវវេទមន្តខ្សែ

ភ្នែករបស់ធិតារូបស្រស់ ខាបស្រូបឆក់យកចេញពីទ្រូងនាយបាត់ទៅតាំងពី វិនាទីដំបូង ដែលនាយបានប្រទះរូបធិតានោះមកម៉្លេះ ។

ព្រមជាមួយគ្នា នោះដែរ មាណពក៏ចាប់ភ្លឹកថា ឆវីសោភាហាក់ដូចជាលួចសម្លឹងមករក នាយភ្លេកៗ មិនដាច់ខ្សែភ្នែកដូចគ្នាដែរ

ព្រោះគេបានប្រទាក់ខ្សែភ្នែក ជាមួយធិតាជាច្រើនដងច្រើនសា ពេលគេលួចចោលកន្ទុយភ្នែកលួចមើល ទៅនាង ។

នរៈយើងមានអារម្មណ៍ញាប់ញ័រក្នុងចិត្តយ៉ាងណាមិនដឹងទេ គឺ ចេះតែញាប់ញ័ររហូតក្ដៅមុខមាត់ភាយៗតែម្នាក់ឯង ។ ចៃដន្យ

អ្នកទាំង ពីរមានកិរិយាស្ងៀមស្ងាត់តែរៀងៗខ្លួន ។ ម្នាក់ៗ រកនឹកពាក្យពេចន៍អ្វីនឹង

ស្រដីសួរអ្វីគ្នាទៅវិញទៅមកមិនឃើញទាល់តែសោះ ប្រហែលជាម្នាក់រង់ ចាំឱ្យម្នាក់ទៀតស្រដីរកខ្លួនមុនផងក៏មិនដឹង ។

ជាងសម្លាកយើង ធ្លាប់តែ មានជំនាញយ៉ាងប៉ិនប្រសព្វបំផុតខាងកិច្ចការ សាងសង់តូចធំទាំងឡាយ ។ ប៉ុន្តែ...ប្លែកអីព្រឹកនេះ

នាយបែរជាក្លាយជាមនុស្សដែលចាប់អ្វីមិនជាប់ ទៅវិញ ធ្វើនេះខុសនេះ ចាប់នេះជ្រុះនោះ ឱ្យតែរហូត ពេញមួយព្រឹក ហើយ ។

ដោយនឹករអៀសខ្លួនចំពោះក្រសែភ្នែករបស់មាណវីដែលលួច សម្លឹងរូបនាយមិនឈប់ឈរ

ជាងសម្លាកក៏ឈ្ងោកមុខគេចខ្លួនចេញទៅវិញ ទាំងដួងចិត្តរន្ធត់ភ័យអរៗ យ៉ាងចម្លែកក្រៃលែង ដែលខ្លួនមិនធ្លាប់មាន

អារម្មណ៍បែបនេះពីមុនមកសោះឡើយ ។ ឯធិតានោះវិញក៏ចោលកន្ទុយ ភ្នែកសម្លឹងមើលតាមនាយយើងរហូត

ដល់បាត់ស្រមោលពីក្រសែភ្នែកទៅ ទំនងហាក់ដូចជាពិនិត្យពិច័យ វិភាគពិចារណាអំពីអ្វីមួយដែរក៏មិនដឹង

CHANBOKEO.COM

ត្បិតទឹកមុខរបស់នាងក៏មានលាក់អាថិ កំបាំងក្នុងចិត្តយ៉ាងចម្លែកដូចគ្នា ដែរ ហើយកិរិយាក៏ហាក់ដូចជារន្ធត់ញាប់ញ័រ ក្នុងចិត្តមិនខុសពីនរៈយើង ប៉ុន្មានឡើយ ។

ជាងសម្លាកដើររហូតមកដល់ផ្ទះតូចរបស់នាយ ដែលសង់នៅក្បែរដង អូរ មានដំណាំដាំដុះជុំវិញពណ៌ខៀវស្រងាត់ ។ គេមកអង្គុយសំកុកនៅកាំ ជណ្តើរ នឹកពិភាល់ក្នុងចិត្តមិនអស់មិនហើយអំពីវត្តមានរបស់ធិតាសោភា មួយរូបនោះ មិនដឹងថាហេតុអ្វីបានជានាយគ្មានសេចក្តីក្លាហានគ្រប់គ្រាន់ នឹងប្រឈមមុខចំពោះក្រសែភ្នែកធិតា ដែលសម្លឹងមកនាយយ៉ាងស្រទន់ នោះឡើយ ។ តាំងពីធំពេញវ័យកាលណាមក ជាងយើងមិនដែលមាន អារម្មណ៍នឹកខ្មាសមនុស្សស្រីអ្វីដល់ថ្នាក់ហ្នឹងទេ ។ ថ្ងៃនេះមាណពយើងបែក ញើសជោគខ្លួនតែម្តង ដែលត្រូវចុះចាញ់ឥទ្ធិពលក្រសែភ្នែកដ៏ថ្លាស្រទន់ របស់នារីចម្លែកមួយរូប ។ តើធិតានោះជានរណា? ហេតុអ្វីបានជានាងមក ដល់ភូមិព្រះនេត្រព្រះនេះ? មួយសន្ទុះធំក្រោយមក នាយប្រវឹកនិងនាយ ខ្លែងរត់មកដល់ :

- ពូសម្លាកអើយ! តាមេឃុំអោយមកតាម ទៅជួយធ្វើការនៅសាលា
បន្តិច ត្បិតអីជិតដល់ម៉ោងបើកការប្រជុំអ្នកភូមិហើយ ។

ឮដូច្នោះ ជាងសម្លាកក៏ទាញអាវមកពាក់ ហើយធ្វើដំណើរត្រលប់ ទៅសាលារៀនវិញយ៉ាងលឿន ។ ពេលនោះ នាយយើងក៏ប្រទះឃើញអ្នក ស្រុកអ្នកស្រែមកដល់យ៉ាងកុះករ ។ តាមេឃុំក៏ហៅអោយនាយយើងជួយ រៀបចំតុកៅអីនិងទីកន្លែងទទួលភ្ញៀវ ។ មិនទាន់ទាំងរៀបរបរួចផង ស្រាប់ តែមានរថយន្តហ្ស៊ីបមួយផ្ទុកអ្នកដំណើរចំនួនបីនាក់ចូលមកដល់ ជាបុរស ចំណាស់ពីររូបនិងនារីវ័យក្មេងប្រមាណ២០ឆ្នាំមួយរូបទៀត ។ កាលបើអស់ កិច្ចការរបស់ខ្លួនហើយ ជាងសម្លាកក៏គេចខ្លួនទៅឈរនៅម្ខាង ទុកអោយ តាញ៉ោចាត់កិច្ចការតទៅទៀត ។ ភ្លាមនោះ តាមឃុំក៏ធ្វើការបង្ហាញណែនាំ របស់គណៈប្រតិភូដែលមកពីក្រុងបាត់ដំបង :

- ជំរាបបងប្អូនទាំងឡាយនៅឃុំព្រះនេត្រព្រះនេះ! កាលដើមឡើយ សាលារៀនយើងមានតែប្រាំថ្នាក់ទេ ។ តែពេលនេះ រាជការបានអនុញ្ញាត្តិ អោយយើងបន្ថែមមួយថ្នាក់ទៀតដើម្បីបំពេញសេចក្តីត្រូវការរបស់កុមារា កុមារីក្នុងភូមិរបស់យើង ។ ហេតុដូច្នេះហើយ បានជាសាលារៀនភូមិយើង ត្រូវទទួលស្វាគមន៍គ្រូថ្មីថែមម្នាក់ទៀត សំរាប់ឆ្នាំសិក្សាដែលនឹងចូលមក ដល់ខាងមុខនេះ ។

អ្នកស្រុកក៏ទះដៃហ៊ោរកញ្ជ្រៀវឡើងយ៉ាងអឹងកង ។ រំពេចនោះបុរស ចំណាស់ចំណួលថ្មីមួយរូបក្នុងសម្លៀកឯកសណ្ឋានពណ៌កាគី ក៏ចេញខ្លួនមក ប្រកាសខ្លាំងៗថា :

- ជំរាបសួរបងប្អូនទាំងអស់! ខ្ញុំបាទជាភូឈ្មួយខេត្តបាត់ដំបង មានឈ្មោះ ថាលោកចំណាប់ សូមណែនាំគ្រូបង្រៀនមួយរូបជូនបងប្អូននៅទីនេះ ។

ទាំងអស់គ្នាក៏នាំគ្នាបែរមើលទៅមនុស្សពីរនាក់ទៀត ដែលទើបចុះពី រថយន្តហ្ស៊ីបមកព្រមគ្នា ។ លោកចំណាប់ក៏មានប្រសាសន៍បន្តថា :

- នៅខាងណេះ គឺជាលោកភូរិន នាយកមជ្ឈមណ្ឌលគ្រប់គ្រងគ្រូបង្រៀន នៅខេត្តបាត់ដំបងយើងនេះ ។

CHANBOKEO.COM

លោកភូរិនក៏ងើបឈរគោរពហ្វូងប្រជាកសិករក្នុងភូមិទាំងឡាយ រួច ហើយក៏មានប្រសាសន៍បន្ថែមថា :

- គឺខ្ញុំមានកិត្តិយសណែនាំគ្រូបង្រៀនថ្មីសំរាប់សាលាយើងនេះដែរ...

ភ្លាមនោះអ្នកទាំងអស់នាំគ្នាបែរមើលទៅនារីមួយរូប ដែលឈរក្បែរ លោកភូរិន នឹកថា ប្រហែលជាមាណវីរូបនោះហើយដែលជាគ្រូបង្រៀន ថ្មី ។ រីឯជាងសម្លាកដែលកំពុងឈរនៅក្បែរនាយកុំ នាយប្រវឹកនិងនាយខ្លែងនោះ ក៏បានលួចសម្លឹងមើលនារីរូបនោះជាយូរមកហើយដែរ ប៉ុន្តែ មាណពបានសំគាល់ឃើញថា ធិតានោះមិនមែនជាមាណវីដែលនាយប្រទះ កាលពីព្រឹកមិញនោះទេ ថ្វីបើនរីមានរូបឆោមសោភណ៍គួរចាប់អារម្មណ៍ បំផុតយ៉ាងណាក៏ដោយ ។ លោកភូរិនក៏វាចាបន្តថា :

- រីឯគ្រូបង្រៀនដែលក្រសួងបានត្រៀមអោយមកបង្រៀននៅទីនេះគឺ អ្នកគ្រូ ចរណៃ ដែលនៅឈរខាងនុ៎ះបាទ !

ទាំងអស់គ្នាបែរក្រោយ មើលទៅតាមទិស ដែលលោកភូរិនចង្អុល ស្រាប់តែគេប្រទះនឹងធិតាមួយរូបកំពុងឈរទន្ទឹមក្បែរជាងសម្លាក តាំងពី អង្កាល់មិនដឹង ។ លុះជាងយើងងាករឹងមកឃើញវត្តមានរបស់នាងក្បែរ ខ្លួនបង្កើយ ក៏នឹកភើតក្នុងពោះគ្រលួចតែម្នាក់ឯង នឹកខ្មាស់ធិតាតែក្នុងចិត្ត ព្រោះអីឆរីនោះគឺជានារីរូបស្រស់សោភា ដែលនាយបានប្រទះកាលពីព្រឹក មិញនោះឯង ។

អ្នកគ្រូចរណៃ..! ឈ្មោះនេះលាន់រណ្តំយ៉ាងពិរោះក្នុងបេះដូងរបស់ ជាងសម្លាកយើង ។ ជាងយើងទន្ទេញយូរឡើងកាន់តែឱ្យចាប់ចិត្តបេតី ប្រតិពទ្ធ័នាងឡើងយ៉ាងមានជំរៅកប់ក្នុងដួងចិត្ត រកស្ពានជំរៅមិនត្រូវ សោះ ។ ជាងលួចចោលភ្នែកសម្លឹង មើលធិតាយ៉ាងភ្លន់ភ្លឹកអារម្មណ៍ ។ លុះឃើញកិរិយាភ្លឹក១ភាំង១របស់នរៈយើង កុំក៏លួចកេះគ្នាខ្សិបជាមួយ នាយប្រវឹកនិងនាយខ្លែងថា :

- នែ៎អាអូនពីរនាក់.. ឯងមានឃើញបងជាងទេ? គាត់លួចឈរគយ គន់សោភណ័របស់អ្នកគ្រូថ្មីឡើងភ្លឹកស្មារតីតែម្តង... សង្ស័យតែគាត់លួច ពេញចិត្តអ្នកគ្រូសោភានោះហើយមើលទៅ ។

នាយខ្លែងនិងនាយប្រវឹកនាំគ្នាលួចសើចរអឹក១ ធ្វើអោយជាងសម្លាក ចាប់ភ្លឹកភ្លាមថាអ្នកទាំងបីកំពុងនិយាយដើមខ្លួន :

- នែ៎ ពួកឯងនាំគ្នាសើចស្អីហ្នឹង? (ជាងសម្លាកសួរ)

- អត់មានទេ ពូសម្លាក! អត់មានទាល់តែសោះ ។ (នាយខ្លែងរាដៃ ឆ្លើយតបវិញ)

រំពេចនោះ ស្រាប់តែអ្នកគ្រូចរណៃឡើងប្រកាសថា :

- នាងខ្ញុំចរណៃ មានចិត្តសោមនស្សរីករាយណាស់ដែលនាងខ្ញុំមានឱកាស បានមកធ្វើការជាគ្រូបង្រៀននៅព្រះនេត្រព្រះយើងនេះ ហើយសង្ឃឹមថា យើងនឹងរួមសហការគ្នាយ៉ាងជិតស្និទ្ធ រវាងឪពុកម្តាយ និងគ្រូបង្រៀន ដើម្បីរកមធ្យោបាយណែនាំកូនចៅរបស់យើង ឱ្យបានទទួលការសិក្សា អប់រំយ៉ាងល្អប្រពៃបំផុត ។

ឮដូច្នោះ អ្នកស្រុកទះដៃលាន់ប្រាវ១ យ៉ាងរំពងទទួលស្វាគមន៍អ្នកគ្រូ របស់យើងភ្លាម ។ ពេលនោះ ស្រាប់តែមានបុរសសង្ហាមួយរូប ជិះសេះ ត្រិប១ចូលមកដល់យ៉ាងស្ងៀមស្ងាត់ ពីក្រោយខ្នងអ្នកស្រុកដែលកំពុងឈរ ស្តាប់ការប្រកាសរបស់លោកភូឈ្មួយខេត្ត ដែលកំពុងតែមានប្រសាសន៍បន្ត ពីក្រោយអ្នកគ្រូយើងថា :

CHANBOKEO.COM

- ពេលនេះ ដោយសារអ្នកគ្រូយើងមិនទាន់មានកន្លែងស្នាក់នៅស្រួលបួល នៅឡើយ
ទើបយើងខ្ញុំសូមសូមប្រកាសអំពាវនាវសុំវិភាគទានពីបងប្អូន ជាប្ញស្សី ជាស្លឹកត្នោត និងកម្លាំងសំរាប់សង់ផ្ទះជូនអ្នកគ្រូយើង
នៅក្បែរៗ សាលារៀននេះ ដើម្បីឱ្យងាយស្រួលដល់អ្នកគ្រូ ក្នុងការមកបង្រៀនរាល់ ថ្ងៃ
ព្រោះភូមិយើងពុំទាន់មានផ្លូវថ្នល់លូតលាស់ អោយអ្នកគ្រូធ្វើដំណើរ ទៅមកបានស្រួលនៅឡើយទេ។

ពេលនោះ អ្នកស្រុកក៏បែរពិគ្រោះគ្នាអ៊ូអរឡើង។ អ្នកគ្រូចរណៃដាក់ ក្រសែភ្នែកដោយចៃដន្យទៅចំភក្ត្រ័បុរសសង្ហា ដែលកំពុងសម្លឹងត្រលប់ មករូបនារីយើងវិញដូចគ្នាដែរ ស្រាប់តែបុរសនោះញញឹមដាក់នាងយ៉ាង ត្រកាល។ មែនហើយ! គេមានរូបរាងសង្ហាណាស់ សង្ហាខុសប្លែកបុរស ទាំងឡាយដែលមកប្រជុំគ្នានៅទីនោះតែម្តង។ ធិតាក៏សម្តែងភាពញញឹម លើផ្ទៃមុខបន្តិចតបទៅវិញជាការគួរសម ហើយក៏បែរសម្លឹងទៅអ្នកស្រុក
ម្នាក់ដែលឧទានតបមកលោកចំណាប់និងលោកភូរិនថា :
- យើងទាំងអស់គ្នាអាចធ្វើអំណោយជាប្ញស្សីនិងស្លឹកត្នោត ព្រមទាំង កម្លាំង សំរាប់សាងសង់លំនៅជូនអ្នកគ្រូចរណៃបាន ប៉ុន្តែយើងគិតថា ត្រឹម កូនខ្ទមប្ញស្សីប្រក់ស្លឹកត្នោតតូចមួយយ៉ាងដូច្នោះ មើលទៅហាក់ដូចជាមិន សូវមានសុវត្ថិភាព ហើយមិនសក្តិសមនឹងឋានៈរបស់អ្នកគ្រូយើងផង។ ហេតុដូច្នេះ យើងខ្ញុំសូមពេលវេលាប្អូនដប់ថ្ងៃ ដើម្បីអង្គាសឈើនិងសង្កសី សង់ផ្ទះ អោយបានសមរម្យជាងខ្ទមស្លឹកត្នោតនោះវិញ។
- ប៉ុន្តែអ្នកគ្រូត្រូវការលំនៅឆាប់ៗនេះ មិនអាចរង់ចាំយូរបានទេ។

លោកភូរិនមានប្រសាសន៍តបវិញ។ ស្រាប់តែអ្នកភូមិម្នាក់ឆ្លើយថា :
- អ្នកគ្រូបានមកស្នាក់នៅជាមួយនឹងក្រុមគ្រួសាររបស់សែបផៃ នាយ ប៉ូលីសប្រចាំភូមិជប់តាំងពីម្សិលមកម្ល៉េះ។ យើងគិតថានៅទីនោះអ្នកគ្រូ ច្បាស់ជាមានសុវត្ថិភាពគ្រប់គ្រាន់ហើយ ទំរាំយើងអង្គាសគ្នារកថវិកាសង់ ផ្ទះជូនអ្នកគ្រូរួច។
- ហើយចុះ បងប្អូនទាំងអស់អាចកាក់ស្មានបានទេ ថាតើពេលវេលានៃការ
អង្គាសអំណោយនិងការសាងសង់ផ្ទះជូនអ្នកគ្រូរបស់យើងនេះ ត្រូវការ ពេលវេលាយូរប៉ុនណាដែរ? ព្រោះអី ពីផ្ទះសែបផៃទៅសាលារៀន មាន ចម្ងាយដល់ទៅបីគីឡូម៉ែត្រឯណោះ តើធ្វើម៉េចអ្នកគ្រូអាចដើរទៅមក បានងាយស្រួលទៅ?

លោកភូរិនសួរ។ ភ្លាមនោះបុរសសង្ហាក៏ហក់ចុះពីខ្នងសេះ ដើរចូលមក
កណ្តាលហ្វូងបណ្តាជនភ្លាម ព្រមទាំងប្រកាសឡើងថា :
- ណ្ហើយចុះ! ដើម្បីជាកិត្តិយសដល់ភូមិយើងដែលកំពុងទទួលស្វាគមន៍
គ្រូបង្រៀនថ្មីហើយជានារីភេទទៀតផង ខ្ញុំបាទនាមចក្រា សូមបរិច្ចាគ អំណោយជាសង្កសីនិងឈើមួយចំនួន
សំរាប់ចាប់ផ្តើមសង់ផ្ទះជូនអ្នកគ្រូ របស់យើងនៅថ្ងៃនេះតែម្តង។

ការប្រកាសនេះ បានធ្វើអោយអ្នកស្រុកទាំងឡាយភ្ញាក់ផ្អើលហើយ រីករាយក្រៃលែង។ តាញ៉ោមេឃុំក៏មានប្រសាសន៍ឡើង :
- ប្រសើរណាស់! ពេលនេះ យើងទាំងអស់គ្នាសូមអរគុណចំពោះទឹកចិត្តដ៏ ថ្លៃថ្លារបស់លោកចក្រាយ៉ាងអនេកប្បការ។
តាមេឃុំខ្ញុំសូមប្រកាស ហៅរកកម្លាំងដើម្បីមកជួយសាងសង់ផ្ទះជូនអ្នកគ្រូរបស់យើង តើមានអ្នក ណាអាចមកជួយ បានទេ?

CHANBOKEO.COM

ភ្លាមនោះ អ្នកស្រុកជាច្រើននាំគ្នាលើកដៃច្រូងច្រាងឡើង មានរួម ទាំងនាយកុំ នាយខ្លែង និងនាយប្រើកផង ។ ចៃដន្យ អ្នកទាំងបីមិនឃើញ ជាងសម្លាកលើកដៃអ្វីនឹងគេសោះ ។ នាយកុំទ្រាំមិនបាន ក៏ចាប់ដៃជាង សម្លាកលើកឡើងដែរ ល្មមពេលដែលអ្នកគ្រូរបស់យើងបែរសម្លឹងចំមក តែម្តង ធ្វើឱ្យជាងយើងរន្ធត់ញាប់ញ័រក្នុងចិត្តសាជាថ្មីទៀតហើយ ។ ពេល នោះ មាណពហាក់ដូចជាភ្លេចភ្លាំងស្មារតីអស់ហើយ ជាពិសេសពេលដែល គេបានប្រទះក្រសែភ្នែកដ៏ស្រទន់ភ្លឺថ្លាពណ្ណរាយ របស់អ្នកគ្រូយើងម្តងៗ ។ បន្តិចមក អ្នកគ្រូរបស់យើងក៏បែរមកបង្ហាញខ្លួននារីសោភាមួយរូបទៀត ដែលធ្វើដំណើរមកជាមួយលោកភូរិននិងលោកភូឈួយខេត្តចំណាប់ :

- ជំរាបប្រសាសន៍ បងប្អូនក្នុងភូមិព្រះនេត្រព្រះទាំងអស់! នាងខ្ញុំសូម ណែនាំអ្នកគ្រូពេទ្យវ័យក្មេងមួយរូប ដែលស្ម័គ្រចិត្តមកធ្វើការជូនភូមិយើង ចំនួនមួយឆ្នាំដោយឥតគិតកម្រៃ... នោះគឺអ្នកគ្រូចំណាននដែលនៅឈរខាង នេះចាស!!

តរុណីសោភាក៏ងើបឡើងប្រណម្យគោរពអ្នកស្រុក នៅទីនោះភ្លាម ។ ទាំងអស់គ្នាក៏ទះដៃស្វាគមន៍យ៉ាងទ្រហឹងអឹងកង ដោយក្តីសប្បាយរីករាយ ដែលគេបានទទួលគ្រូបង្រៀនថ្មីម្នាក់ ថែមទាំងទទួលទាំងគ្រូពេទ្យមួយរូប ទៀតផង ។ ម្យ៉ាងទៀត អ្វីដែលធ្វើឱ្យគេសប្បាយរីករាយបំផុតនោះគឺ ទាំងអ្នកគ្រូបង្រៀន ទាំងអ្នកគ្រូពេទ្យ បានស្ម័គ្រចិត្តមកបំរើសេចក្តីត្រូវការ ក្នុងឃុំដោយមិនទទួលយកប្រាក់កម្រៃបៀវត្សរ៍ រហូតដល់ទៅមួយឆ្នាំ ឯណោះ ។ ក្នុងចន្លោះពេលដ៏អ៊ូអរនោះ ជាងសម្លាករបស់យើងបានសង្កេត ឃើញថា បុរសសង្ហាឈ្មោះចក្រាហាក់ដូចជាចេះតែលួចចោលកន្ទុយភ្នែក ដាក់អ្នកគ្រូចរណៃញឹកញាប់ដល់សួរហើយ ធ្វើអោយមាណពមានអារម្មណ៍ មិនល្អទាល់តែសោះ រហូតដល់អស់ទឹកចិត្តនឹងចង់នៅឈរស្តាប់កិច្ចការក្នុង កិច្ចប្រជុំនោះទៀតហើយ ។ បន្តិចមក គេក៏បែរខ្លួនថយក្រោយ ដកខ្លួន ចេញទៅយ៉ាងស្ងាត់ស្ងៀម ដោយមិនស្រដីអ្វីមួយម៉ាត់ប្រាប់នរណាសោះ ឡើយ ។ ចៃដន្យ គេមិនបានដឹងថាអ្នកគ្រូចរណៃរបស់យើងក៏កំពុងតែលួច ចោលកន្ទុយភ្នែក តាមលបមើលកិរិយារបស់នាយភ្លៀកៗនោះដែរទេ ។ កាលបើឃើញនាយយើងឈ្ងោកមុខដើរចេញទៅស្ងៀមស្ងាត់ ធិតាយើងក៏ ប្រែទឹកមុខ ហាក់ដូចជាលែងរីករាយដូចពេលមុនទៀត ។ បន្តិចមក នារីក៏ សុំខ្លួនទៅរកកន្លែងសមគួរ គេចពីហ្វូងមនុស្សខ្សៀវខ្សាទាំងឡាយនោះទៅ ទុកអោយតាញ៉ោនៅជួបប្រជុំជាមួយលោកចំណាប់ និងលោកភូរិន ដើម្បី អំពីកិច្ចការប្រចាំឃុំដែលនឹងត្រូវអនុវត្តន៏តទៅទៀត ។

ជាងសម្លាកដើរមកដល់ផ្ទះវិញ ដាក់ខ្លួនប្រាសលើគ្រែភីង យកដៃគង ថ្ងាស ដកដង្ហើមយូៗ សំដែងកិរិយាអស់កម្លាំងចិត្តល្វិតល្វែក្រៃលែង ។ មិនដឹងជាយ៉ាងម៉េចទេ តាំងពីរូបគេបានប្រទះវត្តមានរបស់អ្នកគ្រូចរណៃ វេលាណាមក នរៈយើងក៏ប្រែក្លាយខ្លួនទៅជាមនុស្សដែលមានអារម្មណ៍ ប្រែប្រួលផ្លាស់ប្តូរសប្បាយរំភើប រួចហើយកើតទុក្ខក្នុងចិត្តចំលែកណាស់ ។ កាលពីដើមឡើយ គេជាមនុស្សមានសំដីតិច មានអារម្មណ៍ស្ងប់ស្ងៀម មិនរំភើប មិនភ្ញាក់ផ្អើលនឹងអ្វីៗជុំវិញខ្លួនទេ គឺគេមានចិត្តត្រជាក់ជានិច្ច មិនថាវេលាណាឡើយ ប៉ុន្តែពេលនេះគេបានផ្លាស់ប្តូរអត្តចរិតរបស់ខ្លួនអស់ រលីង ។ ពិតមែនហើយដែលជាងយើងទើបតែប្រទះអ្នកគ្រូចរណៃជាលើក ដំបូង ហើយក៏មិនទាន់មានការប្រទាក់វាចាសន្ទនាអ្វីជាមួយនិងធិតាអ្វីមួយ ម៉ាត់ផង ប៉ុន្តែ...ហេតុអ្វីក៏វត្តមានរបស់អ្នកគ្រូចរណៃ

CHANBOKEO.COM

មានឥទ្ធិពលសណ្ដំ ដួងចិត្តនិងអារម្មណ៍របស់នាយយ៉ាងខ្លាំងក្លាបែបនេះ? នរៈយើងពិតជាមិន យល់ទេ...! មិនយល់ទាល់តែសោះ! គេគេងយកដៃគងថ្ងាសសម្លឹងដំបូល ផ្ទះ ដកដង្ហើមធំយូៗបន្ទរនូវការតានតឹងក្នុងអារម្មណ៍ ។ បន្តិចមក គេងើប ទៅអង្គុយនៅមុខកញ្ចក់ លូកដៃស្រវាដោះ ខ្សែកវេញដោយអំបោះពណ៌ ក្រហមពី ក របស់នាយ យកបន្តោងចែកាច់រូបផ្កាចំប៉ាមួយមកសម្លឹងមើល យ៉ាងយូរ ទើបស្រដីខ្សិបៗតែម្នាក់ឯងយ៉ាងសោកសៅថា :

- ឱ! បន្តោងអើយ...សូមប្រាប់ខ្ញុំផង ថាគូរបស់អ្នកកំពុងវិលវិញហើយ!

វំពេចនោះ ស្រាប់តែ បុរសយើងក៏អួលដើមកស្រក់ទឹកភ្នែកចុះមក ដោយឯកឯង ។ គេក៏ស្រវាក្តាប់បន្តោងនោះ ដាក់នៅលើដើមទ្រូងរបស់គេ ព្រមទាំងវាចាខ្សិបៗបន្តទៀតថា:

- ពំងាម្ចាស់ចិត្តបងអើយ! មិនថាពេលវេលាកន្លងទៅយូរប៉ុនណាទេ បង នៅតែទន្ទឹងរង់ចាំការវិលត្រឡប់របស់អូនជានិច្ច..!

បន្ទាប់មក គេក៏ទាញខ្សែកមកថើបហើយលើកពាក់នៅកវិញ រួចទាញ អាវមកពាក់ពីលើ ទំលាក់ខ្សែកទៅក្នុងអាវ ទំនងហាក់ដូចជាចង់លាក់ទុក របស់នោះជាកំណប់ទ្រព្យក្បែរបេះដូងរបស់នាយ មិនឱ្យនរណាបានឃើញ បានយល់ឡើយ ។ ពេញមួយរាត្រីនោះ បុរសយើងគេងស្រម័យដល់ធិតា យើង មិនអស់មិនហើយក្នុងចិត្តតែម្នាក់ឯងយ៉ាងរសាប់រសល់បំផុត ។ នរៈ គេងគងថ្ងាសនឹកដល់អតិតកាលមួយ ដែលបានធ្វើអោយគេក្លាយទៅជា មនុស្សកណ្ដោចកណ្ដែងរហូតមកដល់សព្វថ្ងៃនេះ ។ យូរៗម្ដង គេរអ៊ូតិចៗ ក្នុងមាត់ថា :

- ទោះបីជាគូគាប់ ទោះបីជាគូកម្ម...ក៏បងនៅតែស៊ូរង់ចាំ...ចាំអូនវិលវិញ.. ជានិច្ច... ចាំ... ចាំ... ចាំកងណៃតែមួយរបស់បង...!

0000000000000000

0000000

0

CHANBOKEO.COM

# វគ្គទី២

# ស្រមោលអតីតកាល

ភូមិប៉ោយក្បឿង ឃុំព្រះនេត្រព្រះ ឆ្នាំ ១៩៤៧..

មីងនួនកូកហៅកូនស្រីពីលើរានហាលផ្ទះឈើមួយខ្នងសង់ខ្ពស់ពីដី :

- កងណាវអើយ... ទៅណាហ្នឹងកូន?

យុវតីមួយរូបក្នុងវ័យប្រហែល១៦ឆ្នាំ រែកកូនកញ្ជើពីរដើរនាំមុខប្អូន ស្រីមួយរូបទៀតអាយុប្រហែល១៣ឆ្នាំ ដែលកំពុងលីចប់ជីកដើរតាម ក្រោយ ។ កាលបើឮម្តាយកូកហៅ នាងតូចក៏ស្រដីឡើងថា :

- ចាំសម៉ែ! ខ្ញុំនាំមីអូនណៃទៅរកជីកដំឡូងជ្រៅ ។

- អឺ! កុំទៅឆ្ងាយពេកណាកូន ប្រយត្ន័វង្វេងរកផ្លូវមកផ្ទះមិនឃើញ។

- ចាំស!

យុវតីដើរបណ្តើរ ច្រៀងជាមួយប្អូនស្រីបណ្តើរ យ៉ាងសប្បាយ ។ តាម ពិត ក្មេងស្រីទាំងពីរជាកូនស្រីរបស់មីងនួននិងតាមាំង ដែលជាជាងដែកដ៏ ល្បីប្រចាំភូមិ ។ ថ្ងៃនេះ តាមាំងមិននៅផ្ទះទេ អាល័យចេញទៅផ្សារសេរី សោភ័ណ ជាមួយគូកនដើម្បីរកទិញប្រដាប់ប្រដាផ្សេងៗសំរាប់រោងជាង ។ ចំណែកមីងនួនជាមេផ្ទះ ថៃទាំកូន ដាំដំណាំ និងចិញ្ចឹមមាន់ទាបន្តិចបន្តួច ។

មកដល់វាលមួយក្បែរជើងភ្នំ តរុណីទាំងពីរក៏ប្រទះនឹងយុវជន ជំទង់មួយរូបវ័យប្រហែលនឹងនាងកងណាវដែរ កំពុងឈរច្រត់ចង្កេះស្រែក
បញ្ជាអោយយុវជនភូមិពីររូបទៀត វាយដំទាត់ធាក់យុវជនម្នាក់ទៀតរាង ស្គមស្គើងយ៉ាងមូរនប ។
កាលបើប្រទះនឹងហេតុការណ៏ដូច្នោះ យុវតីទាំង ពីររូបភ្ញាក់ស្រឡាំងកាំង នឹករន្ធត់ក្នុងចិត្តពេកក្រៃ ។ កងណៃជាប្អូនក៏ លាន់មាត់ស្រែកអឺងកងឡើងថា :

- នែ៎! បងក្រា ម៉េចបានជាពួកបងព្រួតគ្នាវាយបងខ្នាអញ្ចឹង?

នាងថាផង ស្ទុះរត់យកខ្លួនទៅពាំងមិនអោយគេវាយយុវជនរងគ្រោះ នោះតទៅទៀត ថែមទាំងស្រែកឃាត់បន្តថា :

- បងទាំងអស់ឈប់វាយបងខ្នាទៅ.. មើលហ្ន៎! គាត់មានរបួសចេញឈាម ពាសពេញខ្លួនហើយ...

តែយុវជនបីរូបទៀតមិនស្តាប់នាងឡើយ ។ គេយកជើសកៀសនាង ប្រច្រានចេញទៅម្ខាងធ្វើឱ្យកងណៃដួលច្រងាប់ច្រងិល ។ ឃើញដូច្នោះ កងណាវក៏យកដងរែកគាស់ជើងយុវជនដៃឆៅទាំងពីរនោះភ្លាម :

CHANBOKEO.COM

- យើ! ហ៊ានធ្វើបាបប្អូនស្រីយើងផងហ្អែសឬនាយក្រា? តើនាងធ្វើអីឯង បានជាឯងធ្វើខ្លួនដូចជាសត្រូវដាក់នាងដូច្នេះទៅវិញ?

យុវជនម្នាក់ទប់ខ្លួនមិនទាន់ក៏ដួលផ្ងារពោះចង្រ្កាង ។ ស្រាប់តែយុវជន រូបសង្ហាសំដីក្អេងក្អាងនោះស្រែកវ៉ាងកាត់ឡើងថា :

- នែ៎ នាងណាវ! ជៀសចេញ! ខ្លួនជាស្រីសោះ ចេះមកហៅហៃអីនឹងគេ ដែរ? តិចលោយើងអត់មិនបានទៅ!

- អឺ! បើអត់មិនបានវាយ៉ាងម៉េច? ហើយចុះនាយក្រាឯងវិញនោះ ជា ប្រុសនោះមានកត្តិយសប៉ុណ្ណាដែរ ដែលព្រួតគ្នាច្រើនវាយគេម្នាក់?

កងណាវខមដាក់វិញហាក់ដូចជាឥតញញើតសោះ ។ ភ្លាមនោះយុវជន ក្អេងក្អាងនោះស្ទុះទៅច្បាមនាងចេញមិនឱ្យប្រលូកជួយ តែត្រូវនាងយក ដងរែកវាយតបវិញ ធ្វើអោយនាយក្រាដួលថ្ងោលអុកគូថទឹសទៅដី ។ គេ ខឹងណាស់ក៏ស្រែកឡើងថា :

- នាងណាវ! យើងមិនបានធ្វើអីនាងទេ ហេតុអ្វីមកវាយយើងផង? ដឹងទេ ថាឈឺណាស់រ៉ើយ?

- អូហ៍ ចេះឈឺដែរតើ...ហើយចុះឯងធ្វើបាបនាយខ្នាឡើងឈាមពេញខ្លួន ទៅហើយតើគេមិនឈឺទេឬអី?

- ចុះបើអាខ្នាវាបណ្តោយឱ្យគោវាដើរចូលដីរបស់យើង ជាន់ឥវ៉ាន់របស់ របរយើងខ្ទេចខ្ទីអស់ តើមិនអោយយើងខឹងម្តេចកើត?

- ហើយចុះ គោនោះវាដើរជាន់ស្អី បានជាឯងខឹងនឹងនាយខ្នារហូតដល់ វាយគេបែកមុខបែកមាត់យ៉ាងនេះ?

- គឺដើរជាន់កែវចិញ្ចឹមត្រីក្រឹមរបស់យើងបែកអស់បីបួនកែវឯណោះ ងាប់ អស់អាមេខ្លឹមៗដែលយើងខំចិញ្ចឹមមកយូរហើយ ។

- ងាប់ហើយ! ឯងស្រលាញ់ត្រីក្រឹមរបស់ឯងដល់ម្លឹង រហូតដល់ហ៊ានធ្វើ បាបមនុស្សដូចគ្នាដើម្បីត្រីងាប់? នេះ ជីវិតនាយខ្នា មិនមានតម្លៃស្មើនឹង ត្រីក្រឹមរបស់ឯងទេ មែនទេ?

ថាហើយ កងណាវបែរក្រោយ ឃើញប្អូនស្រីកំពុងយកក្រមាជូត ឈាមអោយនាយខ្នា រួចហើយនាងក៏បែរមកវិញ ស្រដីថា :

- ឯងមើលហ្ន៎? គេឈាមពេញខ្លួនទៅហើយ នៅមិនទាន់ស្កប់ចិត្តឯងទៀត ឬអី? មើលទៅយើងត្រូវទៅជំរាបតាមេឃុំហើយ ។

- អឺ! យើងឈប់វាយវាក៏បានដែរ មិនបាច់ទៅប្រាប់តាមេឃុំធ្វើអ្វីទេ ។ យើងរួចគ្នាត្រឹមហ្នឹងចុះ!

ថាហើយនាយក្រាក៏ក្រោកឡើងហៅគូកនបំរុងដើរចេញទៅ ស្រាប់ តែកងណៃដើបឡើងស្រែកថា :

- មិនទាន់រួចគ្នាទេ... បងក្រាឯងនៅជំពាក់បងខ្នានៅឡើយទេ ។

នាយក្រាបែរក្រោយយ៉ាងរហ័សហើយស្រដីថា :

- យើងជាកូនដង្ហៃស្រែដ៏មានបំផុតនៅព្រះនេត្រព្រះនេះ ។ រឿងអីដែល ថាយើងត្រូវជំពាក់នាយខ្នាដែលរកតែកន្ទបវណ្ណ័ខ្លួនមិនបានផងនោះ?

- មែន! បងក្រាឯងជាកូនអ្នកមានពិតមែន តែអ្វីដែលបងឯងជំពាក់ បងខ្នានោះ គឺពាក្យសុំទោស...

- ស្អី? យើងមិនបានធ្វើអ្វីខុសផង រឿងអីទៅសុំទោសវា?

- មិនក៏ថាមិនខុស កាលបើប្រព្រឹត្តខ្លួនដូចប្រេតនរកមិនស្គាល់បាបកម្ម ធ្វើ បាបមនុស្សអោយរបួសពេញខ្លួនហើយនៅថាខ្លួនត្រូវទៀត?

CHANBOKEO.COM

- យើងមិនសូមទោស នោះវាយ៉ាងម៉េច?

- មានយ៉ាងម៉េច! បើមិនសូមទោស គឺបងឯងនឹងក្លាយជាកូនបំណុល របស់បងខ្មា ហើយក៏ជំពាក់គេរហូតតទៅក្នុងជីវិតរបស់ខ្លួន... ថ្ងៃណាមួយ ល្បងនឹងត្រូវសងគេវិញមិនខាន... បើនិយាយតាមធម៌ព្រះ ។

- ចង់ដាក់ទំនាយយើងផងឬនាងល្អិត? តិចអត់មិនបាន យើងដាក់ឈោម មាត់ម្នាក់ទៀតឥលូវ!

នាយក្រាស្រដីផង យារដៃរកទះកំភ្លៀងនាងតូចផង តែត្រូវកងណាវ ជាបងយកដងរែកពាំងជាប់ :

- នែ៎! កុំប៉ះពាល់ប្អូនរបស់យើងអោយសោះ!

- សុទ្ធតែស្រី១ ធ្វើឫកគ្រាន់ស្អី? ស្មានថាយើងខ្លាចនាងណាស់ទៅឬ?

ថាហើយ នាយក្រាហក់ទាត់កងណាវយ៉ាងរហ័សតែត្រូវនាងយកដង រែកគ្រវីរងវិញត្រូវចំស្មងជើងបាំងធ្វើអោយនាយដួលថ្ងោល ។ ឈឺណាស់ នាយយើងក៏ងើបឡើងវិញស្រែកហៅគូកនអោយជួយ :

- អាលុត អាក្រាប នៅធ្វើអីទៀត ម៉េចមិនចាត់ការទៅ?

នាយលុតនិងនាយក្រាបឮដូច្នោះ ក៏ហក់រឹងមករកជួយស្រាប់តែ :

- ឆាប់ថយក្រោយភ្លាមនាយក្រា នាយលុត និងនាយក្រាប!

អ្នកទាំងអស់គ្នាភ្ញាក់ព្រើតចំពោះសម្លេងបុរសដែលស្រែកឃាត់នោះ ។ លុះគេបែរមើលទៅ ឃើញព្រះអង្គមួយអង្គនាំកូនសិស្សម្នាក់ដើរចូលមក ។ គេក៏ដកដៃថយក្រោយរវៀងខ្លួនហើយខំរៀបឥរិយាបថមកវិញ តែក៏មិន ព្រមឈប់ប្រើខ្សែភ្នែកសម្លក់គ្នាទៅវិញទៅមកនោះដែរ ។ ព្រះសង្ឃក៏មាន ដីការឡើងថា :

- ហើយចុះយ៉ាងម៉េចទៅហើយនាយចក្រា? ធ្លាក់ឋានៈ ធ្លាក់រាសី ខ្លាំង ណាស់មែនទេ បានជាឯងប្រមូលជើងបីនាក់ មកវាយស្រីម្នាក់យ៉ាងនេះ? បើសិនដឹងដល់ណា ឯងនិងក្រុមគ្រួសារនឹងខ្មាស់គេដល់ហ្នឹង ថាកូនប្រុស ទោលរបស់ថៅកែចក្រី អន់នេះអន់ នាំគ្នាម៉ាហ្វូងមកវាយមនុស្សស្រី...

ចក្រាមិនហ៊ានងើបមុខទេ កាលបើឮព្រះគ្រូមានដីការចំចំណុចខ្សោយ របស់ខ្លួន ។ បន្តិចមក ព្រះគ្រូក៏មានដីការបន្តថា :

- ចក្រា! ឱ្យយើងសូមបិណ្ឌបាត្រកំហឹងពុះពោរក្នុងខ្លួនរបស់ចៅឯងនោះ ទៅណ៎ា! ចូរទៅផ្ទះ មុជទឹកឱ្យត្រជាក់ខ្លួនហើយទៅជួបយើងនៅវត្តបន្តិច ប៉ុន្តែបើចៅមិនមករកយើងទេ នោះយើងនឹងទៅរកឯងដល់ផ្ទះ ។ យ៉ាង ម៉េចដែរ? ធ្វើបានទេ?

នាយចក្រាមិនហ៊ានមាត់តបថាម៉េចទេ ក៏ញាក់មុខឱ្យសញ្ញាទៅដៃ ជើងរបស់ខ្លួនហើយក៏ក្រាបបង្គំចេញទៅ ។ តែមុននឹងបោះជំហានទៅ នាយ លួចឆ្លៀតមកសម្លក់កងណាវនិងប្អូនស្រី ដោយក្រសែភ្នែកប្រកបដោយ ភាពប្រទុស្តឧត្បាតក្នុងចិត្ត ។ បន្ទាប់មក គេក៏ចេញទៅបាត់អស់រលីង ។

CHANBOKEO.COM

ការពិតព្រះសង្ឃមួយអង្គនោះមានព្រះនាមឧត្តរៈ ជាព្រះចៅអធិការ វត្តព្រះនេត្រព្រះក្រោម ។ សព្វថ្ងៃព្រះអង្គមានព្រះជន្មហាសិបប្លាយហើយ តែនៅមានសុខភាពមាំមួនរវៀសរវៃហើយស្វាហាប់ណាស់ ។ លោកបានគង់នៅប្រចាំវត្តភូមិនោះតាំងពីព្រះអង្គចូលផ្នួសនៅក្មេងមកម្ល៉េះ ម្ល៉ោះ ហើយនរណាក៏ស្គាល់ ទុកចិត្តហើយគោរពព្រះអង្គណាស់ ។ លុះក្រលេក មកឃើញកងណៃកំពុងជួយជូតឈាមអោយនាយខ្នា ដែលមានរបួសពេញ ខ្លួន ព្រះគ្រូឧត្តរៈក៏បន្ទឹដីការថា :

- នាយខ្នាអើយ! មើលទៅចៅឯងស្គមដល់ហើយ! តើឯងឈឺអីហ្នែស? ឬក៏ ជីវភាពនៅផ្ទះរបស់ឯងវាយ៉ាប់យ៉ឺន...?

នាយខ្នាក្រោកឡើងលុតជង្គង់ថ្វាយបង្គំ :

- ករុណាព្រះគ្រូ គឺទាំងពីរយ៉ាងហ្នឹង ។ ខ្ញុំកូណាមានជំងឺគ្រុនចាញ់ តែឪពុករកប្រាក់ដើម្បីព្យាបាលមិនបាន ទើបបណ្តោយខ្លួនយ៉ាងនេះទៅទំរាំដល់ថ្ងៃអស់បុណ្យ ។

- ពុទ្ធោពុទ្ធំ! ហេតុអ្វីឪពុកឯងបិទមាត់អោយឈឹងមិនព្រមពឹងពាក់គេឯង ក្នុងភូមិអោយជួយ?

- គឺ អ្នកភូមិយើងសុទ្ធតែជាអ្នកក្រ មិនដឹងទៅពឹងនរណាទេព្រះគ្រូ!

- ល្អើយចុះ! យើងសន្យាថានឹងជួយអង្គាសវិភាគទានយកសោហ៊ុយមក ព្យាបាលឯងចុះ ប៉ុន្តែ យើងសុំឯងវិញនូវរបស់ម្យ៉ាង ។

- ខ្ញុំកូណានឹងប្រគេនព្រះអង្គវិញបើសិនជាអាចធ្វើបាន ។

- មិនមានអ្វីធំដុំទេ នាយខ្នា! ពេលឯងជាសះស្បើយ យើងសុំបំបួសឯងបី វស្សា តើឯងព្រមទេ?

នាយខ្នាញញឹមឡើង :

- កុំថាឡើយបីវស្សា ច្រើនជាងហ្នឹងទៀត ក៏ខ្ញុំកូណាធ្វើបានដែរព្រះអង្គ ។

ថាហើយនាយថ្វាយបង្គំបីដង ថ្លែងអំណរគុណភ្លាម ។ បន្ទាប់មក ព្រះ គ្រូអធិការក៏បែរមកកងណារីនិងកងណៃ :

- កងណារី! កងណៃ! ចៅជាស្រី តែមានសមានចិត្តហើយក្លាហាន ហ៊ាន ចេញមុខតតាំងដើម្បីជួយអ្នកភូមិដូចគ្នាជាពិសេសក្នុងឱកាសដែលគេ កំពុងទទួលរងគ្រោះ នោះគឺជាទឹកចិត្តដ៏ថ្លៃថ្លាក្រៃលែង ។ សង្ឃឹមថាថ្ងៃមុខអ្នកទាំងពីរនឹងបានក្លាយជាបុគ្គលគំរូនិងជាទីទុកចិត្តរបស់អ្នកភូមិយើង ។

យុវតីទាំងពីរក៏លុតជង្គង់ក្រាបបង្គំព្រះអង្គព្រមគ្នា ។ ភ្លាមនោះ កង ណារីស្រដីថា :

- អរគុណព្រះគ្រូណាស់ដែលបាននិមន្តមកជួយកូនចៅទាន់ពេលវេលា ។

- អឺ! មិនអីទេចៅអើយ ។ នៅស្រុកយើង នរណាមួយមិនស្គាល់នាយចក្រាដែលដើរអុងអាត់ពាសពេញភូមិនោះ? ឪពុកម្តាយគេទំរើសកូនជ្រុលរហួត ដល់ខូចមាយាទអស់ ។ អឺនែ! ចៅខ្នា! កាលណាឯងជាពីជំងឺ កុំភ្លេចហាត់ រៀនតម្លើងសាច់ដុំខ្លះ ឮហើយឬនៅ? មានសាច់ដុំធំៗទៅ ធ្វើអោយក្រុមនាយចក្រាវាញញើតខ្លះដែរ មិនមែនអោយដូចពេលនេះទេ... មើលចុះ វាវាយឯងបែកមុខបែកមាត់អស់ ព្រោះតែឯងស្គមពេក ។

នាយខ្នាឈ្ងោកមុខស្តាប់សំដីព្រះគ្រូ មិនមានតបអ្វីទេ ។ បន្តិចមក ព្រះគ្រូក៏ហៅកូនសិស្សជំទង់ម្នាក់នោះអោយមកជួយគ្រាហ៍នាយខ្នាទៅផ្ទះ វិញ ។

CHANBOKEO.COM

ចំណែកកងណាវនិងកងណៃក៏ខកខានលែងបានទៅជីកដំឡូងទៅ ។

គេទាំងពីរក៏ជួយដេញគោដើរតាមពីក្រោយព្រះគ្រូឧត្តរៈរហូតដល់ផ្ទះនាយ ខ្មាទើបមិត្តម្នាត្រលប់ទៅផ្ទះរបស់ខ្លួនដែរ ។

គ្រាន់តែអ្នកទាំងពីរមកដល់មាត់ទ្វាររបងដីភូមិរបស់ខ្លួន ស្រាប់តែគេ ប្រទះនឹងអ្នកស្រុកមួយហ្វូងធំឈរកុះករពាសពេញផ្ទះ ។ ធិតាទាំងពីរបែរ សម្លឹងមុខគ្នាសម្ដែងការងឿងឆ្ងល់ រួចហើយក៏នាំគ្នារត់រឹង វែកហ្វូងមនុស្ស ឡើងទៅលើផ្ទះយ៉ាងលឿន ។ ពេលនោះ គេប្រទះបុរសចំណាស់ប្រហែល សែបួយកំពុងដេកស្ដូកស្ដឹងដណ្ដប់ភួយលើគ្រែ ។ យុវតីទាំងពីរស្រែកលាន់មាត់ព្រមគ្នាថា :

- ពុក! ពុកយ៉ាងម៉េចហ្នឹងចាស?

មែនហើយ! នោះគឺតាមាំងជាឪពុករបស់យុវតីដែលកំពុងរងរបួសជាទម្ងន់ ។ នៅក្បែរនោះ មីងនួនអង្គុយស្រក់ទឹកភ្នែកស្ងៀមស្ងាត់ ។ កងណៃសួរទៅម្ដាយថា :

- ម៉ែ! ហេតុអីពុកក្លាយទៅជាបែបនេះ?

មីងនួនមិនទាន់ឆ្លើយអីផង ស្រាប់តែបុរសចំណាស់ម្នាក់ដែលនៅឈរ ក្បែរនោះ ឆ្លើយជំនួសថា :

- គឺតាមាំងនិងគូកនគាត់ពីរនាក់ទៀតត្រូវចោរប្លន់នៅម្ដុំភ្នំជញ្ជាំង ។ ម្នាក់ ត្រូវស្លាប់ ពីរនាក់របួសធ្ងន់ ទើបត្រូវអ្នកស្រុកសង្គ្រោះយកមកដល់មុននេះ បន្តិច ។ ពេលនេះ តាបានពឹងគេ អោយទៅតាមគ្រូហ្មហើយ ។

ឮដូច្នោះ តរុណីយើងទាំងពីររូបរន្ធត់ចិត្តណាស់ ។ គេក៏ដាក់ខ្លួនលុត ជង្គង់ក្បែរឪពុកភ្លាម ។ ចៃដន្យតាមាំងមិនទាន់ដឹងស្មារតីនៅឡើយទេ ។ មើលទៅគាត់ដូចជារបួសធ្ងន់ធ្ងរណាស់ ។ ថ្ងៃនោះ អ្នកស្រុករត់ស្រូ៊ស្រចេញ ចូលវាស់ព្រឹក ដើម្បីជួយជាដៃជើងដល់ក្រុមគ្រួសារមីងនួន ។ ការពិត មីង នួនតាមាំងជាមនុស្សមានសន្ដានចិត្តចំពោះញាតិជិតខាងណាស់ ។ កាលបើ ក្រុមគ្រួសាររបស់គាត់ធ្លាក់ក្នុងសភាពបែបនេះ គ្មាននរណាមួយគេមើល បំណាំទេ ។ គេនាំគ្នាមកជួយមើលថែតាមាំងហាក់ដូចជាសាច់ឈាមរបស់ គេដូច្នោះដែរ ។

ពីរថ្ងៃកន្លងទៅ...

តាមាំងបានដឹងស្មារតីវិញហើយ តែអាការៈនៅទ្រុឌទ្រោមណាស់ មិន អាចងើបពីកន្ទេលបានឡើយ ហើយមិនដឹងជាត្រូវសំរាន្តលើកន្ទេលយូរ ប៉ុណ្ណាទេ ។ ចំណែកកិច្ចការក្នុងរោងជាងដែកក៏ត្រូវទុកចោលមួយរយៈ ។ ព្រឹកនេះ កងណាវក្រោកពីព្រឹកដាំបាយធ្វើម្ហូប មួយចំណែក រៀបដាក់ស្លក មួយចំណែកទៀត រៀបដាក់ចាន់ស្រាក់យ៉ាងផ្ចិតផ្ចង់ ។ បន្ទាប់ពីឱ្យបាយ ជ្រូកហើយ កងណៃក៏ចូលផ្ទះបាយជួយជាដៃជាជើងរបស់បងស្រី ។ កាល បើឃើញនាងរៀបចាន់ស្រាក់ដាក់ម្ហូប ធិតាក៏សួរទៅបងស្រីថា :

- បងណាវ! យកអាហារទៅវត្តហ្អែសថ្ងៃនេះ?

កងណាវញញឹមឡើងឆ្លើយខ្សឹបៗវិញថា :

CHANBOKEO.COM

- អូហ៎អត់ទេ គឺបងចង់អោយប្អូនយកម្ហូបនេះទៅផ្ញើបងខ្នាទេតើហ៎ ឃើញ គាត់ឈឺមិនស្រួលខ្លួន
គិតថាចង់ផ្ញើអ្វីអោយគាត់ពិសារខ្លះ ។

កងណៃព្ញដូច្នោះក៏និយាយសួរបងស្រីវិញថា :

- ម៉េចក៏មិនយកទៅខ្លួនឯង? បើយកទៅខ្លួនឯង ប្រហែលបងខ្នាពេញចិត្ត ជាជាងឃើញកូនក្មេងមុខដូចឆ្មាអោង
របៀបខ្ញុំនេះណាស់ ។

- ឆ្កួត! នរណាគេហ៊ានដើរយួរបាយយកទៅផ្ញើប្រុសកម្លោះនោះ?

- យី! ម៉េចក៏បងនឹកខ្លាចអីថ្ងៃនេះអញ្ចឹង? ចុះថ្ងៃមុន ម៉េចហ៊ានយកខ្លួនលី ដងរែក ចូលប្រយុទ្ធការពារប្រុសកម្លោះនោះកើត?

កងណាវញញឹមទ្រង់អៀនតិច១ :

- កាលៈទេសៈវាខុសគ្នាណាអូន! កាលនោះ គេកំពុងតែមានរបួស រឿង ជួយមនុស្សជារឿងធម្មតារបស់អ្នកស្រុកភូមិទេ ។

- តែថ្ងៃនេះ គាត់ឈឺនៅផ្ទះ ។ បើយកបាយសម្លទៅផ្ញើ ក៏ជាទឹកចិត្តរបស់
អ្នកជិតខាងក្នុងភូមិផងរបងជាមួយដដែលហ្នឹង ។

- អឺ! ឥចឹងហើយ បានជាបងអោយអូនណៃឯងយកទៅផ្ញើគាត់ហ្នឹងអី!!
ម៉េច? មិនចង់ទៅសម្តែងទឹកចិត្តអីទេឬប្អូនស្រី? បងដាំឆ្អិនហើយ ប្អូនអ្នក យួរទៅអោយគាត់ ស្មើភាគគ្នាហើយតើហ៎!

និយាយមិនឈ្នះបងស្រី ធិតាយើងក៏សើចខឹក១ឡើង :

- ណ្ហើយចុះ! ចាំខ្ញុំយួរទៅឱ្យ ហើយបងចង់ឱ្យខ្ញុំប្រាប់គាត់ថាម៉េចខ្លះដែរ?

- មិនបាច់ប្រាប់អីទេ គ្រាន់តែរៀបបាយរៀបទឹកអោយគាត់ពិសារ បំរើឱ្យ ល្អមួយពេល
ក៏ចាត់ទុកថាជាការសម្តែងទឹកចិត្តយ៉ាងថ្លៃថ្លាហើយណាអូន! - ជាការសម្តែងទឹកចិត្តថ្លៃថ្លា? ពីនរណាចំពោះនរណា?
ពីណៃចំពោះបង ណាវ ពីណៃចំពោះបងខ្នា ឬក៏ពីបងណាវចំពោះបងខ្នា?

- យីអើ! ហេតុអ្វីក៏សួរច្រើនម្ល៉េះ ប្អូនស្រីបង? ណេះ ឆាប់យកទៅទាន់ម្ហូប នៅក្តៅ១ ។

កងណៃសើចកខឹកដាក់បងស្រី រួចហើយក៏ស្រវាចានស្រាក់ដើរចេញ ទៅ ។
លុះមកដល់មាត់ផ្ទះឈើមួយសង់ខ្ពស់ពីដីក្បែរមាត់អូរ នាងក៏ស្ទុះ ឡើងប្រុយហាក់ដូចជាស្គាល់គ្នានឹងម្ចាស់ផ្ទះស្និទ្ធស្នាលមិនខ្លាចចិត្ត
ថែម ទាំងកួកហៅឡើងថា :

- បងខ្នា! បងខ្នា! នៅផ្ទះទេ?

ភ្លាមនោះ នាយខ្នាអើតមុខចេញមកតាមបង្អួចឆ្លើយថា :

- ណៃ! មានការអី មករកបងទាំងព្រឹកដូច្នេះ?

- បងណាវអោយយកសម្លមកផ្ញើ!

នរៈកម្លោះក៏ស្ទុះចេញមកទទួលយ៉ាងរហ័ស :

- អរគុណណាស់អូនណៃ ដែលមានទឹកចិត្តយកអាហារមកផ្ញើ ។ ហើយប្អូន

CHANBOKEO.COM

ក្រោកដាំពីម៉ោងប៉ុន្មានទើបបានម្ហូបឆ្អិនតាំងពីព្រឹកយ៉ាងនេះ?

- ហែស១! គឺណៃមិនបានក្រោកពីព្រហាមទេ ។ បងណាវតើហ៏ដែលខំ ក្រោកពីព្រឹកដាំស្លផ្ញើបងនោះ ។

- ហើយថ្ងៃនេះអូនណៃមិនទៅរៀនទេ?

- ទៅរៀនអី... ណៃរៀនអស់ថ្នាក់នៅសាលាហើយ ។ បើចង់បន្ត ទាល់តែ ទៅរៀននៅឯសេរីសោភ័ណឯណោះ ។ ពុកថាកូនស្រីឱ្យទៅនៅឆ្ងាយផ្ទះ ឆ្ងាយភ្នែកម៉ែឪមិនល្អទេ ទើបគាត់អោយខ្ញុំឈប់រៀនទៅ ។

- គួរអោយស្តាយណាស់ ។ អូនណៃជាក្មេងឆ្លាតវៃ ប៉ុន្តែបែរជាមិនបានទៅ រៀន ព្រោះអូនណៃជាស្រី ។ ចំណែកបងវិញ ចង់រៀនណាស់ តែខ្លួនក្រទី ទ័លហើយមានជំងឺទៀត មិនអាចទៅរៀនឯណាបានជ្រៅជ្រះនឹងគេ ។

នាយខ្នាដាក់មុខជ្រប់កាលបើនិយាយដល់ត្រង់នេះ ។ ឃើញដូច្នោះ ធិតាយើងក៏និយាយកម្លាចិត្តនាយឡើងថា :

- បងខ្នា! ទោះបីយ៉ាងណា បងអាចទៅបួសហើយរៀននៅវត្តយើងនេះក៏ បានដែរ ។ ដល់ពេលបងជាពីជំងឺចូលបំបួស ចាំអូនណៃទៅជួយហែកូននាគ ណា៎ ។ រៀនជ្រៅជ្រះនៅក្នុងវត្ត ក៏មានតម្លៃមិនខុសពីរៀននៅសាលារៀន ធម្មតាដែរណា៎បង ។

ឮប្រយោគនោះកាលណា នរះដ៏ក្មេងរបស់យើងក៏ញញឹមឡើង :

- អូនណៃជាមនុស្សឆ្លាត និយាយអ្វី១ តែងតែមានន័យជ្រៅជ្រះ ធ្វើឱ្យ ចិត្តបងភ្លឺថ្លាជានិច្ច ។ អរគុណណាស់អូនណៃ ។

- ចា៎ស!

បន្តិចមក ឆវីតូចក៏ស្ទុះចូលចង្ក្រានបាយ ដោះស្រាក់រៀបអាហារដាក់ ស្តុកលើកអោយនាយខ្នាតាមដែលបងស្រីនាងផ្តាំមក ។ ខ្នាលួចសម្លឹងតាម មើលនាងឥតព្រិចសោះ ធ្វើអោយកងណៃចាប់ភ្លឹកដល់ក្រសែភ្នែកនោះ ភ្លាមតែម្តង :

- បងខ្នា! ហេតុអី មើលមុខណៃម្ល៉េះ?

- គឺបងកំពុងនឹកស្ញើចក្នុងចិត្តនោះអី!

- ស្ញើចរឿងអីទៅ?

- គឺ... ពីដើមមុនមក បងស្មានថា អូនណៃជាកូនក្មេង មិនដែលចេះកិច្ចការ អីក្នុងចង្ក្រានបាយដូចបងណាវទេ មើលទៅចេះត្រឹមតែទៅសាលានិងរត់ លេងប៉ុណ្ណោះ ការពិតបងគិតខុសសោះ ។

- ការពិតគឺអញ្ចឹងមែនតើហ៎! ម៉េចក៏បងថាគិតខុស?

- មែនណា៎! បងគិតខុសមែន ។ ការពិត អូនណៃជាមនុស្សមានចិត្តគំនិត ចាស់ទុំជាងវ័យរបស់អូនច្រើនណាស់ ។

- ពុទ្ធោអើយ! គ្រាន់តែណៃយកបាយសម្លមកផ្ញើបងមួយពេល ស្រាប់តែ មកបញ្ជោរណៃយ៉ាងផ្អែមតែម្តងហ្ន៎!

កងណៃសើចខឹក១ដាក់នាយខ្នា តែនាយនៅតែញញឹមធ្វើមុខមាំទំនង ជឿជាក់នូវអ្វីដែលគេគិតឃើញពេលនោះណាស់ ។ គេក៏ស្រដីបន្តទៅកាន់ កងណៃបន្តទៀតថា :

- បងមិននិយាយលេងទេណា៎អូន!

- មែនហ្អែស? ហេតុអ្វីបងគិតដូច្នោះ?

- គឺ មកពីកិរិយានិងសំដីរបស់អូនពីម្សិលម៉្ងៃចំពោះនាយចក្រា ហើយនឹង សំដីរបស់អូនដែលលើកទឹកចិត្តបងថ្ងៃនេះ ធ្វើអោយបងគិតថា អូនណៃជា មនុស្សឆ្លាតវៃណាស់ គួរអោយកោតសរសើរ ។

- មកពីខ្ញុំមានឪពុកម្ដាយចាស់ៗហើយជាអ្នកធម៌អាចិទេដឹងទើបនិយាយ ដូចមនុស្សចាស់យ៉ាងនោះ ។ ណ្ហើយចុះ! កុំពិចារណាច្រើនអីបងខ្នា! ណៃ មិនទាន់ចង់ធ្វើមនុស្សចាស់ទេ ។ នេះ បាយនិងសម្លនៅក្ដៅឧណ្ហៗនៅឡើយ ឆាប់ទទួលទានទៅ ប្រយត្ន័ត្រជាក់លែងឆ្ងាញ់អស់ទៅ ។

នរៈកម្លោះមិនប្រកែកទៀតទេ ។ គេក៏ចាប់ស្លាបព្រាចូកបាយចុកមាត់ ភ្លាម ។ យុវជនបរិភោគបាយបណ្ដើរ លួចមើលមុខនាងតូចយើងបណ្ដើរ ឃើញនាងញញឹមមានថ្ពាល់ខួចគួរឱ្យស្រលាញ់ ហើយមានកិរិយាល្អ មាន សំដីរួសរាយ និយាយស្ដីជាមួយនាំអោយចិត្តសប្បាយរីករាយណាស់ ។ គេ លួចញញឹមហើយគិតតែម្នាក់ឯងថា :

- ណៃ! ដល់ពេលអូនពេញវ័យ មិនដឹងជាស្រីនាងស្រស់ស្អាតយ៉ាងណាទេ! បងពិតជាចង់ឃើញរូបអូននៅពេលពេញវ័យនោះណាស់ ។ បើជានិស្ស័យ យើងមាន សុំឱ្យបងក្លាយជាកម្លោះទីមួយនៅស្រុកព្រះនេត្រព្រះនេះ ដែល បានឃើញភក្ត្រ័ទងវង មុនគេបង្អស់ពេលអូនពេញក្រមុំ ។

ស្រាប់តែសម្បជ្ជញ្ញៈមួយលេចធ្លោចេញមកស្ដីអោយនាយថា :

- នែ៎ នាយខ្នា! គិតអ្វីផ្ដេសផ្ដាសយ៉ាងនេះ? កងណៃគ្រាន់តែជាក្មេងស្រី តូចមួយរូប កុំរវើរវាយខុសបែបយ៉ាងនេះ ប្រយត្ន័ធ្លាក់នរកទៅ!

យុវជនក៏ឈ្ងោកបរិភោគបាយស្ងៀមស្ងាត់ទៅវិញ ។ ភ្លាមនោះ នាង តូចកងណៃ ស្រដីសួរនាយថា :

- បងខ្នា! ម៉េចទៅជំងឺបង មានស្រាកស្រាលខ្លះទេ?

គេញញឹមហើយក៏តបថា :

- ព្រះគ្រូឧត្តរៈបាននាំគ្រូហ្មមកមើលបងពីម្សិលម៉្ងៃ ហើយបងបានទទួល ថ្នាំទៀងទាត់ ឃើញថា បងមានកម្លាំងបន្ដិចជាងមុនហើយ ។

- ហើយបើបងមានជំងឺយ៉ាងនេះ ហេតុម៉េចចេញក្រៅផ្ទះញឹកញាប់ម្ល៉េះ?

- មកពីយើងក្រនោះអី អូនណៃ! ឪពុកបងជរាហើយ អាយុជាង៦០ ទៅ ធ្វើការចិញ្ចឹមជីវិតអីកើតទៅ? បងត្រូវតែងើបទាំងឈឺទាំងជា ដើម្បីដោះ ស្រាយជីវិត ។ ការពិតឆ្នាំនេះ បងមិនបានធ្វើស្រែទេ ព្រោះអាល័យតែឈឺ ព្រោះតែហេតុហ្នឹង ទើបពុកបងទៅស្នាក់នៅជាមួយកូនដើមរបស់គាត់នៅ ឯក្រឡាញ់ ត្បិតបងអាល័យឈឺមិនបានបំរើគាត់ជិតដល់ ។ ម្យ៉ាងទៀត តាំងពីម្ដាយបងស្លាប់ទៅ គាត់ដូចជាបាក់ទឹកចិត្តណាស់ ម្ល៉ោះហើយបងគិត ថា ប្រហែលបងស្រីធំនោះ អាចជួយលើកទឹកចិត្តគាត់បានគ្រាន់បើជាងបង ទើបសំរេចចិត្តអោយគាត់ទៅរស់ទីនោះទៅ ។

- ហើយចុះបងវិញ មិនកណ្ដោចកណ្ដែងស្លាប់ហើយទេ?

CHANBOKEO.COM

- ចឹក៏មិនកណ្ដោចកណ្ដែង តែបងមិនទាន់ស្លាប់ទេណា៎ អូនណៃ ។

កងណៃសើចខឹកៗយកដៃក្ដិចកំភួនដៃនាយខ្នាខ្លាច់ដោយឃ្នាន់ខ្នាញ់ ។

- អីយ៉ូយ! ស្រាំងពីណា ទិចឈឺម្ល៉េះ? (នាយខ្នាលាន់មាត់)

ឃើញនាយខ្នាលាន់មាត់ដូច្នោះ នាងរិតតែសើចខឹកៗថែមទៀត :

- ស្រាំងទិចដើម្បីកុំអោយបងកណ្ដោចកណ្ដែងក្នុងអារម្មណ៍ទៀតនោះអី!

អ្នកទាំងពីរក៏សើចកក្អឹកឡើងយ៉ាងរីករាយ រួចហើយគេក៏សំណេះសំណាលគ្នាតាមបែបក្មេងយុវវ័យក្នុងភូមិដែលស្គាល់គ្នាជិតស្និទ្ធ ។ មុននឹង ត្រលប់មកផ្ទះវិញ នាយខ្នាបានស្រដីផ្ដាំទៅកាន់កងណៃថា :

- អូនណៃ! ពេលទំនេរ មកលេងនឹងបងផងណា៎!

- អោយណៃមកញឹកញាប់ មិនខ្លាចណៃនាំសំបុកស្រាំងមកតាមទេហ៏?

- បានស្រាំងទិច ប្រសើរជាងគេងគងថ្ងាស មើលដំបូលស្បូវរាប់សម្លេងតុក កែឃំនោះដែរ ។ អូនណៃ... មកទៀតកុំខានណា៎! បងចាំ!

- ណៃមិនសន្យាទេ! ឃើញមុខថ្ងៃណាគឺថ្ងៃហ្នឹងហើយ ។

ថាហើយធិតាយើងក៏បោះជំហានចេញទៅ ទុកអោយយុវជនយើង មើលតាមពីក្រោយរហូតដល់បាត់ស្រមោល ទាំងដួងចិត្តរំភើបរីករាយតែ ម្នាក់ឯង ។

នៅក្នុងបន្ទប់គេង រាត្រីថ្ងៃដដែល...

- អូនណៃ!

- ចា៎ស!.. មានការអ្វីបងណារ?

- តើបងខ្នាមានផ្ដាំផ្ញើអ្វីមកបងខ្លះទេ?

- អឺ... គាត់និយាយលលេងអូនណៃច្រើនពេក ឥលូវភ្លេចអស់រលីង មិនចាំ ថាគាត់និយាយអ្វីខ្លះទេ ។

- អត់មានពាក្យអរគុណអីម៉ាម៉ាត់មែនហ្អេស?

- គឺ...ដូចជាអត់.... ហ៊ឺ... បងអើយ! កុំសួរណៃអី បើចង់ដឹង ទាល់តែបង ទៅសួរបងខ្នាខ្លួនឯងហើយ ។ ណៃងុយគេងហើយ ចាំសួរពេលព្រឹកស្អែក

ទៅក្រែងណៃចាំមកវិញ ។

ថាហើយនាងតូចក៏ប្រែខ្លួនបិទភ្នែកគេងលក់ទៅ ទុកអោយកងណារ នៅធ្វើភ្លឹះៗ

នឹកមិនអស់ចិត្តមិនអស់មិនហើយដែលនាយខ្នាមិនផ្ដាំផ្ញើអ្វីមក នាងមួយម៉ាត់ ។

បួនដប់ថ្ងៃកន្លងទៅ...

CHANBOKEO.COM

កងណាវធាក់កង់ទៅភូមិជប់ដើម្បីទទួលយកថ្នាំធាតុ ដែលមិត្តភឿន របស់តាមាំងបានផ្ញើពីបាត់ដំបងតាមអ្នករត់ឡានឈ្នួលដឹកឥវ៉ាន់ ។ មីងនួន នៅមើលថៃតាមាំងមិនដែលចេញដើរទៅណាទេ ។ ថ្ងៃនេះ កងណៃនៅផ្ទះ ម្នាក់ឯងហាក់ដូចជាធុញថប់យ៉ាងណាមិនដឹងទេ ។ បន្ទាប់ពីឱ្យបាយជ្រូករួច ហើយ នាងក៏រត់រឹង លីសន្ទូចទៅមាត់អូរ រកស្ទូចត្រីលេង ស្រាប់តែប្រទះ នឹងនាយខ្នាកំពុងអុំទូកនៅក្នុងអូរ :

- បងខ្នា ( នាងតូចកូកហៅ) អុំទូកទៅណាហ្នឹង?

យុវជនកម្លោះយើងក្រលេកបែរមកឃើញធិតាតូចក៏ញញឹមឡើង :

- ទៅបេះផ្កាស្មោ... អូនណៃចង់ទៅជាមួយទេ?

- ចាស...!

នាយខ្នាក៏អុំទូកអែបខាង អោយនាងតូចកងណៃហក់ចូល ហើយក៏អុំ បណ្តែតតាមទឹកចេញទៅ ។ ភ្លាមនោះ ស្រីតូចស្រដីសួរថា :

- បងខ្នាជាពីជំងឺហើយឬ បានជាមកអុំទូកលេង?

- នរណាថា? បងនៅគ្រុនមិនទាន់ជាទេ តែបើបងមិនខំងើបប្រឹងមកទេ តើបងបានអីបរិភោគទៅ បើបងគ្មានបងប្អូនឬសាច់ញាតិណាគេផ្គត់ផ្គង់ផង នោះ? នេះបងមកបេះផ្កាស្មោធ្វើទ្រនាប់ទឹកគ្រឿងបរិភោគបាយនោះអី ។

ពេលនោះ ស្រាប់តែនាងតូចដកដង្ហើមធំ :

- ខ្ញុំអាណិតបងខ្នាណាស់ ។ ថាក្រុមគ្រួសារខ្ញុំទៅវាយ៉ាប់ កាលបើពុកត្រូវ របួសមានជំងឺសម្រាន្តកន្ទេល គ្មាននរណារែកពុនទំនុកបំរុង តែបងយ៉ាប់ ជាងពួកយើងទៅទៀត ត្បិតបងមានតែម្នាក់ឯង...

- បងមិនអីទេ អូនណៃ! បងជឿថា ព្រះមិនធ្វើទារុណកម្មបងរហូតមួយ ជីវិតបងឡើយ ។ បងនឹងស៊ូប្រឹងប្រែងជានិច្ចដើម្បីជួយខ្លួនឯងអោយផុត ទុក្ខលំបាកនេះ ។ ជីវិតអ្នកក្រីក្រវាយ៉ាប់ណាស់... បងចង់រកផ្លូវគេចចេញពី ជីវិតបែបនេះ តែមិនទាន់ដឹងថាបងត្រូវធ្វើអ្វីទេ ដើម្បីដើរចៀសអោយផុត ជីវិតអ្នកក្រដុនដាប ។

ឃើញនរៈយើងមានសំដីស្រពាប់ស្រពោន នាងតូចក៏និយាយបន្លប់ បរិយាកាសឡើងថា :

- បងខ្នា! មើលហ្ន៎! ផ្កាស្មោម្តុំនោះច្រើនណាស់! បងអុំទៅ ទុកអោយខ្ញុំជា អ្នកបេះ ហើយយកទៅធ្វើម្ហូបទទួលទានទាំងអស់គ្នា ដើម្បីកុំអោយបង ត្រមង់ត្រមោចពេក យ៉ាងម៉េចដែរ? បងសុខចិត្តទេ?

ភ្លាមនោះ នាយខ្នាញញឹមពព្រាយឡើង :

- បងរីករាយណាស់ បើបានអូនតូចនៅបរិភោគបាយជាមួយនឹងបង ។

កងណៃញញឹមឡើងតបវិញយ៉ាងស្រស់ សម្តែងនូវទឹកចិត្តថ្លារីករាយ

CHANBOKEO.COM

របៀបក្មេងស្រីដែលមានសេចក្ដីកក់ក្ដៅនៅក្នុងចិត្ត ។ នាយខ្នាអុំទូកបណ្ដើរ លួចស្រម័យផ្ដេសផ្ដាសបណ្ដើរ ។ យូរៗម្ដង នាយលួចទះកំភ្លៀងខ្លួនឯងឱ្យ ភ្ញាក់រលីកពីក្ដីស្រម័យក្លែងក្លាយនោះ ស្រាប់តែត្រូវកងណៃចាប់ភ្លឹកតែម្ដង ម្ល៉ោះហើយ នាងក៏សួរយុវជនយើងថា :

- បងខ្នា! បងកើតអីហ្នឹងបានជាទះកំភ្លៀងខ្លួនឯងពីរបីដងមកហើយ?

ឃើញនាងស្រដីសួរដូច្នោះ នាយនឹកខ្មាសក្នុងចិត្តពេក ក៏អុំទូកសំដៅ វាលស្រែ ដែលមានព្រលិតរំចង់ដុះប្រជ្រៀតគ្នាចេញផ្ការហង់យ៉ាងស្រស់ ត្រកាល ។ នរះក៏សួរទៅនារីតូចបន្ទប់ថា :

- អូនណៃចង់បានខ្សែកពាក់មួយទេ?

កងណៃភ្ញាក់ព្រើត លាន់មាត់ថា :

- ស្លាប់ហើយ! បងខ្នាកើតអ្នកមានពីអង្កាល់បានជាមានប្រាក់ទិញខ្សែកឱ្យ អូនណៃពាក់?

- គឺបងជាអ្នកមានមួយជីវិតបងទៅហើយ... ត្រឹមខ្សែកបំពាក់អូនណៃ បងមិនខ្វះនឹងរកអោយអូនទេ ។

- មែនហ្អែស? ចុះឯណាខ្សែកនោះ? អោយណៃសុំមួយមកបានទេ?

នាយខ្នាញញឹមលាក់គំនួច ហើយក៏ឈ្ងោកលូកដៃដកផ្ការំចង់ដ៏ស្រស់ ស្អាតមួយទង យកមកបកទងកាច់ចុះកាច់ឡើង រួចហើយក៏លើកឡើង ចេញជារាងខ្សែកមួយដែលមានផ្កាជាបន្ដោង :

- ឃើញទេ? នេះជាខ្សែកម៉ូដផ្ការំចង់ដ៏វិចិត្រសំរាប់អូនណៃនោះអី!

- អីយ៉ា ពិតជាស្រស់ស្អាតមែន! បងខ្នាពូកែណាស់ ។

- អូនណៃអោនមកនេះ បងបំពាក់អោយណ៎ា!

នាងតូចញញឹមហើយអោនកេសាចុះ ទទួលយកខ្សែកផ្ការំចង់ពីនាយ ទាំងចិត្តរីករាយ ។ ចំណែកយុវជនយើងវិញក៏រំភើបចិត្តមិនតិចដែរថែមទាំង លួចបន់ស្រន់ក្នុងចិត្តតែម្នាក់ឯងផងថា :

- សូមព្រះជាម្ចាស់ជួយតម្រង់ផ្លូវ អោយអូនណៃបានក្លាយជាគូជីវិតរបស់ នាយខ្នានៅនាអនាគត ពេលនាងធំពេញវ័យនោះផង!!

អ្នកទាំងពីរហាក់ដូចជាស៊ីខ្សែគ្នាណាស់ ចេះតែមានរឿងនិយាយគ្នា សើចក្អាកក្អាយតែរហូត ។ ថ្វីបើនាយខ្នាមិនទាន់ជាសះស្បើយពីជំងឺ ប៉ុន្តែ វត្តមានរបស់នាងតូចកងណៃបាននាំភាពរីករាយមានសុភមង្គលដល់ដួងចិត្ត និងអារម្មណ៍របស់យុវជនយើង ព្រមទាំងផ្ដល់កម្លាំងចិត្តអោយគេប្រឹងអុំ ទូកបានយ៉ាងយូរ ទំរាំគេនាំគ្នាត្រលប់មកត្រើយវិញ...

- អូនណៃទើបមកពីណាហ្នឹង?

កងណៃបែរមើល ឃើញកងណាវចាក់កង់មកដល់មុខផ្ទះ ។ នាងតូច ក៏ឆ្លើយយ៉ាងរហ័សថា :

- ខ្ញុំទើបតែមកពីផ្ទះបងខ្នា!

- អូហ៍! ហើយចុះគាត់សុខសប្បាយទេហ៍?

- សុខ តែមិនទាន់ជាទេ នៅឈឺនៅឡើយ គ្រាន់តែគាត់ជាមនុស្សមិនចេះ នៅស្ងៀមប៉ុណ្ណឹង ឃើញតែធ្វើនេះធ្វើនោះ មិនឈប់សោះ ។

CHANBOKEO.COM

- អឺ! ជំរាបគាត់ទៅ ថាបងផ្តាំអោយគាត់ថែខ្លួនផង ។ អូហ៍ន៎ែ បើសិនថ្ងៃ ណាគាត់ស្រួលខ្លួន បបួលគាត់មកលេងផ្ទះយើងផង ចាំបងធ្វើម្ហូបអោយ

គាត់ពិសារ ។

- ចាំស! ហើយចុះបងមិនចង់ទៅអើតសួរសុខទុក្ខមនុស្សឈឺខ្លះទេ?

កងណាវមើលមុខប្អូនហើយញញឹម តបវិញថា :

- ចាំដល់ប្អូនពេញក្រមុំទៅ នោះអូននឹងយល់ពីអារម្មណ៍នោះហើយថា ហេតុអ្វី បានជាបងមិនហ៊ានទៅលេងផ្ទះគាត់ឥចឹង ។

ថាហើយ នាងក៏បោះជំហានឡើងជណ្តើរទៅខាងលើផ្ទះបាត់ទុកឱ្យកង ណៃឈរអេះក្បាលសួរខ្លួនឯងថា :

- ម៉េចបានជាខ្ញុំត្រូវចាំដល់ពេញក្រមុំផង? គ្រាន់តែឆ្លើយប្រាប់ពេលនេះក៏ មិនបានដែរ ។ ខ្ញុំមិនយល់សោះ ថាបងណាវចិត្តកំណាញ់តាំងពីអង្កាល់...?

000000000000000

00000

0

CHANBOKEO . COM

# វគ្គទីបី

# គំនួចចិត្ត

នៅរសៀលមួយ ក្រោយពេលត្រលប់មកពីសង់កុដិថ្មីនៅវត្តក្រោម វិញ ជាងសម្លាកក៏ស្ទុះរឹង ដោះអាវមុជទឹកលាងខ្លួន ដែលកំពុងតែស្ទុះស្អាប់ ក្រៃលែង ។ ទើបតែដួសទឹកជះលើខ្លួនអស់ពីរបីផ្តិល ស្រាប់តែនាយប្រទះ ឃើញស្រមោលមនុស្សម្នាក់បានដើរមកដល់មុខផ្ទះរបស់ខ្លួន ។ គេស្ទុះទាញ អាវពាក់យ៉ាងរហ័ស ហើយរត់ចេញទៅទទួលភ្លាម ។ គ្រាន់តែដាក់ភ្នែក ទៅប្រទះឃើញមុខភ្ញៀវរូបនោះកាលណា បុរសយើងបើកភ្នែកធំៗ ភ្ញាក់ស្រលាំងកាំងដូចគេចាប់គ្រវែងយ៉ាងដូច្នោះឯង ត្បិតគេនោះមិនមែនជា នរណាក្រៅពីអ្នកគ្រួចរណៃដ៏ស្រស់ស្អាតមួយរូបនោះឡើយ ។ ចៃដន្យ អ្នក គ្រួមិនបានចាប់ភ្លឹកនឹងវត្តមានរបស់ជាងសម្លាក ដែលកំពុងលួចលយរសម្លឹង គយគន់រូបនាងពីលើផ្ទះមកនោះឡើយ តែបែរជាកំពុងចាប់អារម្មណ៍ ផ្កាស្បៃរឿង ដែលដាំជាជួរនៅមុខផ្ទះ ដ៏រីកស្រស់ត្រកាលទាំងឡាយនោះ ទៅវិញ ។ មាណវីញញឹមបំព្រង ហើយលូកដៃអង្អែលផ្កាទាំងនោះថ្នមៗ សម្តែងឫកពាហាក់បីដូចជា ត្រេកត្រអាលនឹងសោភណ័ផ្កាទាំងឡាយនោះ យ៉ាងពេញចិត្តពេញថ្លើមបំផុត ។ បន្តិចមក ធិតាក៏បែរខ្លួនងាកក្រោយ រក មើលម្ចាស់ផ្ទះ នឹកថាបំរុងថានឹងសុំបេះទៅហើយ ស្រាប់តែទាក់ខ្សែភ្នែក ជាងសម្លាកដែលកំពុងឈរច្រងុកនៅមុខផ្ទះ សម្លឹងមករកនាងដោយឥត ព្រិចភ្នែក ។ អ្នកគ្រូយើងភ្ញាក់ព្រើត សម្តែងកិរិយាហាក់ដូចជានឹកខ្មាស់ ក្នុងចិត្តយ៉ាងណាមិនដឹង ដែលមានបុរសមកលួចឈរគយគន់រូបនាង ពី ក្រោយដោយមិនដឹងខ្លួនយ៉ាងដូច្នោះ ។ បន្ទាប់ពីប្រមូលអារម្មណ៍បានមក វិញ ឆវីក៏វាចាយ៉ាងស្រទន់ទៅកាន់បុរសយើងទាំងទឹកមុខញញឹមថា :

- ព្រះអើយ! បងជាងដាំសួនផ្កាស្បៃរឿង លំអបរិវេណផ្ទះដូច្នេះ មើលទៅ ស្រស់ស្អាតមនោរម្យគួរអោយចង់រស់នៅដល់ហើយ!

ឮវាចាសរសើរដ៏ពិរោះរបស់មាណវីយើង មាណពរំភើបចិត្តក្រៃលែង ចៃដន្យ គេបែរជាគាំងសំដី រកទឹកពាក្យអ្វីហារតបចំពោះអ្នកគ្រូយើងមិន បានមួយម៉ាត់សោះ គឺបានត្រឹមតែញញឹម ធ្វើភាំងៗ ដោយឱរាញ្ញាប់ញ័រតែ ម្យ៉ាងប៉ុណ្ណោះ ។ គេឈរទ្រឹងនៅស្ងៀមមួយកន្លែង ធ្វើកិរិយាអេះអុញៗ មិនដឹងថា នាយត្រូវធ្វើយ៉ាងណាអោយសម ត្បិតអ្នកគ្រូចរណៃយើងគឺជា នារីទីមួយហើយ ដែលបានដើរមកដល់ផ្ទះរបស់នាយ នៅជាយភូមិជិតដង អូរ ។ តាំងពីយូរណាស់មកហើយ កម្រមាននរណាដើរមកដល់ម្តុំនេះណាស់ ក្រៅពីហ្វូងក្មេងៗ ដែលដើរកាត់ ពេលគេមករាយមងនៅអូរតែប៉ុណ្ណោះ ។ លុះឃើញកិរិយាអឹមអៀនរបស់បុរសយើង អ្នកគ្រូយើងក៏ស្រដីទៅនាយ បន្តទៅទៀតថា :

CHANBOKEO.COM

- ចរណៃសូមចូលលេងផងបានទេ បងជាង?

- បាទ!... គឺ... សូមអញ្ជើញ...អ្នកគ្រូ!

មាណពឆ្លើយទាំងតតាក់តតុប ។ បន្ទាប់មក នរៈក៏ស្ទុះឆ្លេឆ្លារត់ទៅ ទាញកន្ទេលមកក្រាលនៅលើគ្រែរនាបឫស្សីមួយ ឯរានហាលមុខផ្ទះយ៉ាង រហ័សដើម្បីទទួលអ្នកគ្រូយើង ។ មិនទាន់នឹងដាក់ខ្លួនអង្គុយផង ស្រាប់តែ អ្នកគ្រូចរណៃដាក់ភ្នែកទៅមាត់របង ឃើញនាយភុំជិះកង់មកដល់ ថែម ទាំងកូកហៅឡើងថា :

- បងជាងអើយ! តាមេឃុំមានប្រសាសន៍អោយទៅជួបគាត់ម៉ាភ្លែត ។

ជាងសម្លាកញញូច្នោះ ក៏បែរមើលទៅអ្នកគ្រូចរណៃ សម្ដែងកិរិយា ហាក់ដូចជាខកចិត្តត្បិតមិនអាចនៅទទួលអ្នកគ្រូយើងបាន ។ មាណវីយល់ ចិត្តរបស់មាណព ក៏ញញឹមឡើងហើយស្រដីទៅកាន់នាយភុំថា :

- អរគុណណាស់ភុំ! ខ្ញុំកំពុងតែមកបបួលបងជាងទៅជួបគាត់ដែរ ។ ប្អូន ត្រលប់ទៅមុនទៅ ចាំបងដើរទៅជាមួយបងជាងតាមក្រោយ ។

- បាទ អ្នកគ្រូ!

នាយភុំឆ្លើយហើយ ក៏បត់កង់ បែរក្រោយ ធាក់ត្រលប់ទៅវិញយ៉ាង លឿន ។ អ្នកគ្រូចរណៃបែរមើលទៅជាងសម្លាក ហើយក៏មានវាចាថា :

- តោះ បងជាង!

អ្នកគ្រូញញឹមហើយបោះជំហានចុះពីលើផ្ទះ ដើរចេញតម្រង់ទៅផ្ទះតា ញ៉ៅភ្លាម ដោយមានជាងសម្លាកដើរទៅតាមពីក្រោយនាងផង ។ តាមផ្លូវ អ្នកទាំងពីរមិនមានស្រដីអ្វីរកគ្នាមួយម៉ាត់សោះ ប៉ុន្តែគេបែរជាលួចចោល កន្ទុយភ្នែកដាក់គ្នាជាញឹកញាប់ទៅវិញ ហាក់បីដូចជាកំពុងផ្ញើសារពីក្នុងដួង ចិត្តប្រាប់គ្នាតាមរយក្រសែភ្នែកអញ្ចឹង ។ ជាងសម្លាកយើងដើរនៅជាយ ផ្លូវម្ខាងហើយអ្នកគ្រូដើរនៅជាយម្ខាងទៀត ។ គេមិនហ៊ានដើរក្បែរអ្នកគ្រូ ទេត្បិតហាក់ដូចជារន្ធត់ចិត្តភ័យអរយ៉ាងណាមិនដឹង ។ នរៈដើរបណ្ដើរ យក ដៃស្ទាបបន្ទោងខ្សែក ដែលកំពុងយោលយោគក្នុងអាវរបស់នាយបណ្ដើរ ។ រីឯបេះដូងរបស់នាយវិញ ក៏រណ្ដំគគ្រឹកគគ្រេងស្ទើរតែធ្លាយទ្រូងមកក្រៅ ។ ថៃដន្យគេជាមនុស្សដែលខ្វះមាត់កតាំងពីដើមមក ម្ល៉ោះហើយគេមិនដឹង ថានឹងត្រូវរកពាក្យអ្វីមកចចារជាមួយអ្នកគ្រូយើង ឱ្យបានសមរម្យសោះ ។ ម្យ៉ាងទៀត មួយជីវិតរបស់នាយកន្លងមក មាណពមិនដែលមានឱកាស បាននារីណាមកដើរក្បែររូបនាយម្ដងណាឡើយ ។ នេះជាលើកដំបូងហើយ ហើយក៏ជាលើកពិសេសដែរ ដែលជាងសម្លាកបានដៃគូដើរក្បែរ១ ជានារីដ៏ ស្រស់ស្អាតសោភាបំផុត ថែមទាំងជាអ្នកគ្រូបង្រៀនមានតម្រេះចេះដឹង ទៀតផង ។ ជាងសម្លាកលួចនឹកសរសើរសំណាងរបស់ខ្លួនតែម្នាក់ឯង ដែល ជីវិតរបស់នាយបានទទួលវាសនាដ៏ថ្លៃថ្លារបៀបនេះ ថ្វីបើគេបានដើរក្បែរ មាណវីសោភាត្រឹមតែមួយស្របក់ក៏ដោយ ។

មួយសន្ទុះក្រោយមក អ្នកទាំងពីរក៏បានមកដល់បរិវេណផ្ទះតាញ៉ៅ ។ កាលបើយល់វត្តមានអ្នកពីរភ្លាម តាមេឃុំក៏ស្ទុះចេញមក ព្រមទាំងមាន លាន់មាត់ថា:

CHANBOKEO.COM

- អ៊ើ! ហៅមួយបានពីរ ពិតជាឡូយអស្ចារ្យមែន! នែ៎ មេជាងកម្លោះ! ថ្ងៃនេះលោកចក្រាបានបញ្ជូនឈើមួយត្រាក់ទ័រមកដល់ហើយ តើមេជាង មានពេលមកជួយសង់ផ្ទះជូនអ្នកគ្រូរបស់យើងបានខ្លះទេហ៎?

ឮតាមេឃុំមានប្រសាសន៍ដូច្នោះ ជាងសម្លាកក៏បែរមើលទៅអ្នកគ្រូដែលកំពុងសម្លឹងមកនាយដូចគ្នាដែរ ។ កាលបើប្រទះក្រសែភ្នែករបស់ ធិតាសោភា ជាងក៏ទំលាក់មុខចុះសម្តែងការគោរពហើយក៏ស្រដីថា :

- ខ្ញុំបានសុំច្បាប់ព្រះគ្រូអធិការវត្តក្រោមហើយថា នឹងទៅជួយសង់កុដិ មួយថ្ងៃ ហើយមកជួយសង់ផ្ទះអ្នកគ្រូមួយថ្ងៃ ផ្លាស់វេនគ្នារហូតដល់ សង់ហើយ ។

- ល្អហើយអញ្ចឹង! តាក៏បានរាប់ចំនួនអ្នកស្រុកមានប្រហែលជិតដប់នាក់ ទៀតដែលត្រូវដាក់វេនគ្នាមួយជួយធ្វើការមេជាងឯងដែរ ។

រួចហើយតាញ៉ៅក៏បែរមកខាងអ្នកគ្រូយើង ហើយពោលបន្តថា :

- ចំណែកអ្នកគ្រូវិញ មានគិតហើយឬនៅថា អ្នកគ្រូចង់បានផ្ទះម៉ូដបែប ណាដែរ?

ឮតាញ៉ៅសួរដូច្នោះ អ្នកគ្រូក៏បែរមើលទៅជាងសម្លាកមួយស្របក់រួច ក៏ញញឹមឡើង វាចាថា :

- ស្រេចតែលើស្នាដៃមេជាងគិតគូរទេ លោកតាមេឃុំ! ខ្ញុំទទួលបានទាំង អស់ ឱ្យតែមេជាងសង់អោយ ។

ជាងសម្លាកញញឹមអោនមុខនៅស្ងៀម ធ្វើអេះអុញមិនហ៊ានស្រដីថា អ្វីទេ ប៉ុន្តែក្នុងចិត្តវិញហាក់ដូចជារំភើបចំឡែកណាស់ដែលអ្នកគ្រូយើង សម្តែងការទុកចិត្ត យ៉ាងមុតមាំចំពោះទឹកដៃរបស់គេនៅចំពោះមុខតាមេ ឃុំ ។ បន្តិចមក តាញ៉ៅក៏នាំអ្នកទាំងពីរទៅមើលដីសំរាប់សង់ផ្ទះ ។ នៅទី នោះ គេបានឃើញមានឈើជាសសរនិងក្តារបន្ទះព្រមទាំងសង្ក័សីមួយចំនួនដាក់គរចោលយ៉ាងច្រើន ទំនងហាក់ដូចជាសំរាប់សង់ផ្ទះមួយយ៉ាងធំជង្រ្គឹងតែម្តង ។ តាញ៉ៅក៏លាន់មាត់ឡើងថា :

- យី! អ្នកគ្រូទាំងពីរមានសំណាងម្ល៉េះហ្ន៎! មានគេអោយឈើសង់ផ្ទះយ៉ាង ធំ ហើយមានមេជាងមកជួយសង់យ៉ាងចំណានទៀតផង ។ នៅឃុំយើងនេះ មិនទាន់មាននរណាសំណាងដល់ម្លឹងទេណ៎ាអ្នកគ្រូ!

អ្នកគ្រូចរណៃញញឹមហើយនៅស្ងៀម លួចចោលកន្ទុយភ្នែកទៅមើល ជាងសម្លាកដែលកំពុងដើរមើលចំនួនឈើសំរាប់សង់ ។ បន្តិចមក ទាំងបី នាក់ក៏បំបែកដូរគ្នាទៅផ្ទះវិញរៀង១ខ្លួន ។

ព្រហាមស្អែកឡើង...

ជាងសម្លាកកាន់ស្បៃរឿងមួយកម្រងដើរឡើងទៅលើភ្នំព្រះនេត្រព្រះ សំដៅទៅផ្នូរបីដែលតាំងនៅល្បាក់ខាងលិចកំពូលភ្នំតាមទំលាប់ដែលនាយ តែងធ្វើរៀងរាល់ពេលដែលស្បៃរឿងចេញផ្កាស្គុះស្គាយ ។ មកដល់ទីនោះ ពេលណាមាណពយើងបានប្រទះនារីពីររូបនៅអង្គុយទីនោះស្រេច ។ ភ្លាម នោះ មាណពលាន់មាត់ខ្សិប១តែម្នាក់ឯងថា :

- អ្នកគ្រូចរណៃ! អ្នកគ្រូចំណាន!

កាលបើឃើញវត្តមានរបស់ជាងសម្លាកភ្លាម មាណវីសោភាទាំងពីរ រូបក៏បែរញញឹមដាក់នាយយ៉ាងបំព្រង។ អ្នកគ្រូចំណានក៏លាន់មាត់សួរថា :

- បងប្រុសជាសាច់ញាតិនឹងម្ចាស់ផ្ទះនេះដែហ៎?

- បាទ...គឺ... គឺ...

ជាងសម្លាកឆ្លើយតតាក់តតុប ព្រមទាំងចោលភ្នែក លួចមើលទៅអ្នកគ្រូចរណៃដែលកំពុងអោនបាំងដៃអុជធូបក្បែរនោះ ត្បិតមិនដឹងថាត្រូវ ឆ្លើយយ៉ាងម៉េច។ មិនដឹងជាហេតុអ្វីទេ ពីរបីថ្ងៃកន្លងមកនេះ ពាក្យសំដី អ្វីៗ រត់ចោលមេជាងយើងអស់រលីងតែម្តង។ បន្ទាប់មក ចរណៃក៏ហុចធូបបីសរសៃទៅអោយនាយយើង ហើយបីសរសៃទៀតទៅអោយចំណាន រួច ស្រដីឡើងថា :

- សូមអ្នកទាំងពីរបួងសួងទៅ តាមបំណងដែលជំរុញអោយអ្នកទាំងពីរ បានមកដល់ទីនេះ។

បន្ទាប់មក ធិតាយើងក៏ក្រាបបង្គំប្រណម្យបួងសួងយ៉ាងស្ងៀមស្ងាត់។ ឃើញដូច្នោះ ជាងសម្លាកក៏យកស្បៃរឿងទៅដាក់នៅលើផ្ទះមួយ ហើយក៏ លុតជង្គង់ក្បែរមាណវីយើង សំពះផ្នូរភ្លាមដែរ។ រីឯចំណានអ្នកគ្រូពេទ្យ សោភាវិញក៏មិម្មាធ្វើតាមអ្នកទាំងពីរដូចគ្នា។ មួយស្របក់ក្រោយមក ជាងសម្លាកក៏ក្រោកដើរពីក្រោយមាណវីទាំងពីររូបនោះ ចុះពីភ្នំត្រលប់ទៅភូមិ វិញ។ ដោយឃើញបរិយាកាសស្ងៀមស្ងាត់ពេក ចំណានក៏បែរក្រោយ ស្រដីសួរទៅជាងយើងថា :

- បងប្រុសមានឈ្មោះអ្វីទៅ? ហើយត្រូវជាសាច់ញាតិយ៉ាងម៉េចនឹងបង ចរណៃដែរ បានជាមកអុជធូបសែនផ្នូរទីនេះជូនគ្នាឥចឹង?

មាណពព្ធហើយ ក៏ឈ្ងោកមុខលួចចោលកន្ទុយភ្នែកទៅចរណៃដែលលួចចោលក្រសែភ្នែកតបនាយវិញយ៉ាងស្ងៀមស្ងាត់មិនស្រដី។ គេនៅអេះ អុញមួយស្របក់ទើបឆ្លើយទាំងតតាក់តតុបថា:

- គឺ... អ្នកស្រុកគេហៅខ្ញុំថា ជាងសម្លាក....

វំពេចនោះ ស្រាប់តែមានបុរសសង្ហាមួយរូបបើកត្រាក់ទ័រកាត់ផ្លូវអ្នក ទាំងបី។ ចៃដន្យគេមិនបានសណ្តោងអូសទូពីក្រោយទេ។ កាលបើប្រទះ ឃើញអ្នកគ្រូសោភាកំពុងដើរកាត់ផ្លូវត្រាក់ទ័ររបស់គេ បុរសសង្ហាក៏ញញឹមឡើងហើយស្រែកកូកកាត់ការសន្ទនារបស់គេទាំងបី ថា :

- សួស្តីអ្នកគ្រូចរណៃ អ្នកគ្រូពេទ្យចំណាន! អញ្ជើញទៅណាដែរ?

លុះក្រលេកឃើញបុរសយើងភ្លាម ចរណៃក៏ញញឹមឡើងឆ្លើយភ្លាម :

- ជំរាបសួរលោកចក្រា! ពួកយើងកំពុងត្រលប់ទៅជួយអ្នកស្រុកសង់ផ្ទះ គ្រូ ហើយចុះចំណែកលោកវិញ ទៅណាមកណាដែរ?

- បាទ៎! ថ្ងៃនេះខ្ញុំទៅជួយដឹកពូជស្រូវពីជង្រុក ចែកអ្នកស្រុកធ្វើស្រែ ប្រវាស!

លោកចក្រាសម្លឹងគយគន់ភក្ត្រអ្នកគ្រូចរណៃយ៉ាងភ្លន់ភ្លឹក រួចហើយ ក៏ស្រដីថែមថា :

- អ្នកគ្រូចរណៃចង់ជិះត្រាក់ទ័រលេងទេ? អញ្ជើញឡើងមក ខ្ញុំជូនអ្នកនាង ដើរមើលទេសភាពឃុំព្រះនេត្រព្រះមួយជុំ..

- ពុទ្ធោ! លោកហៅតែបងចរណៃ មិនហៅចំណានជិះត្រាក់ទ័រដើរលេង ផងទេ?

CHANBOKEO.COM

អ្នកគ្រូពេទ្យរូបស្អាតនិយាយលលេងលោកចក្រា។ រីឯចរណៃវិញ កាលបើឮលោកចក្រាបបួល ក៏លួចចោលកន្ទុយភ្នែកសម្លឹងទៅជាងសម្លាក ឃើញនាយឈរឈ្ងោកមុខស្ងៀមស្ងាត់នៅម្ខាង សម្ដែងឫកពាហាក់ដូចជាគោរពការសន្ទនា រវាងមាណវីនិងលោកចក្រាមិនហ៊ានរំខាន។ ពេលនោះ ធិតាយើងមានអារម្មណ៍ប្លែកក្នុងចិត្តយ៉ាងណាមិនដឹងទេ ក៏បែរទៅលោក ចក្រាហើយស្រដីថា :

- សូមទោសលោកចក្រា! ខ្ញុំដូចជាវិលមុខមិនស្រួលខ្លួន មិនហ៊ានជិះ ត្រាក់ទ័រទេ ត្បិតខ្លាចរលាក់នាំតែវិលមុខជាងមុន។ បើសិនជាលោកមាន អាធ្យាស្រ័យពិតមែន សូមមេត្តាជួយដឹកចំណានប្អូនស្រីរបស់ខ្ញុំទៅទម្លាក់ នៅផ្ទះផង។

លោកចក្រាកំពុងតែលួចញញឹម នឹកសង្ឃឹមក្នុងចិត្តថានឹងបានអ្នកគ្រូ រូបស្អាតឡើងជិះត្រាក់ទ័រក្បែរខ្លួន ដើម្បីដើរបង្អួតអ្នកស្រុកទៅហើយ ស្រាប់តែបែរជាឮមាណវីយើងប្រកែកការអញ្ជើញរបស់គេទៅវិញ ធ្វើឱ្យបុរសយើងខកចិត្តរលីងធេងតែម្ដង។ គេធ្វើមុខស្ងួត មិនឮឆ្លើយតបអ្វីទៅ ប្រយោគអ្នកគ្រូចំណានមួយម៉ាត់សោះ។ រំពេចនោះនាយភុំជិះកង់កាត់ តាមផ្លូវនោះដែរ។ កាលបើប្រទះឃើញអ្នកទាំងបួនឈប់ឈរសន្ទនាគ្នា គេក៏បញ្ឈប់កង់ហើយស្រដីថា :

- ជំរាបសួរបងសម្លាក ជំរាបសួរអ្នកទាំងអស់ បាទ! មានត្រូវការអោយ ខ្ញុំឌុបកង់ ទៅណាមកណាទេ?

ឮដូច្នោះ អ្នកគ្រូពេទ្យរូបស្រស់ ដែលកំពុងតែចុកជើងស្រាប់ផង ក៏ ពោលឡើងថា :

- មែនហើយ! ខ្ញុំកំពុងតែចង់ទៅម៉ុំដែលគេសង់ផ្ទះគ្រូផង។ ភុំជួយឌុបខ្ញុំ ទៅទីនោះបន្តិចបានទេ?

- បាទ អញ្ជើញអ្នកគ្រូពេទ្យ! ជំរាបលាទាំងអស់គ្នាសិនហើយបាទ!

ថាហើយភុំក៏ឡើងធាក់កង់ឌុបចំណានចេញទៅ ទុកឱ្យលោកចក្រា នៅធ្វើអេះអុញហាក់មិនអស់ចិត្តដែលអ្នកគ្រូចរណៃមិនព្រមទទួលសំណូម ពររបស់គេ។ ភ្លាមនោះ គេក៏ងាកមកបញ្ជាក់ជាចុងក្រោយជាមួយមាណវី របស់យើងថា :

- ពិតជាមិនចង់អោយខ្ញុំជូនអ្នកគ្រូមែនឬបាទ?

- ចាស មិនទេ! អរគុណណាស់លោកចក្រា!

- អញ្ចឹង! ខ្ញុំលាសិនហើយណា អ្នកគ្រូ!

លោកចក្រាស្រដីផង លួចចោលភ្នែកសម្លឹងទៅជាងសម្លាកដែលឈរ ស្ងៀម មិនស្រដីក្បែរនោះផង មិនដឹងថាក្នុងចិត្តគេគិតបែបណាទេ។ បន្តិច មក គេក៏បរត្រាក់ទ័រចេញទៅ។ អ្នកគ្រូចរណៃក៏បែរបបួលជាងសម្លាក :

- តោះបងជាង! ជូនខ្ញុំទៅកន្លែងសង់ផ្ទះគ្រូណា!

ភ្លាមនោះ អ្នកគ្រូចរណៃបានប្រទះឃើញស្នាមញញឹមដ៏ស្រស់បំព្រង មួយនៅលើផ្ទៃមុខរបស់ជាងសម្លាកយើង។ នោះគឺជាភាពញញឹម យ៉ាង ស្រស់របស់គេលើកដំបូងចំពោះធិតាដោយមិនមានខាំក្របួចមាត់លួចលាក់ នៅក្នុងចិត្តដោយការអៀនប្រៀនតទៅទៀត។ នារីយើងក៏ញញឹមតបវិញ យ៉ាងស្រស់ស្រាយ រួចហើយក៏បោះជំហានធ្វើដំណើរចេញទៅទាំងអារម្មណ៍ រីករាយឥតឧបមា ទុកឱ្យជាងសម្លាកដើរពីក្រោយលួចញញឹមតែម្នាក់ឯង ស្ងៀមស្ងាត់បន្តទៅទៀត។ តាមផ្លូវ បុរសយើងមិនមានមាត់កអ្វីទៅកាន់ នារីយើងទេ

CHANBOKEO.COM

ថ្វីបើនាងងាកមកញញឹមដាក់នាយជាច្រើនដង ទំនងហាក់ដូច ជាកំពុងរង់ចាំការឆ្លើយឆ្លងសន្ទនាពីរូបនាយក៏ដោយ ។ តាមពិតទៅ
នរៈ ចង់ហារមាត់ស្រដីចចារជាមួយអ្នកគ្រូរូបស្រស់យើងណាស់ ប៉ុន្តែបេះដូង របស់គេញាប់ញ័រដើរខុសចង្វាក់ពន់ពេក
ធ្វើអោយគេលែងនឹករកពាក្យអ្វី មកនិយាយអស់រលីងតែម្តង ។

នៅថ្ងៃនោះ អ្នកស្រុកជាច្រើនបានមកជួយសង់ផ្ទះគ្រូដែលមានជាង សម្លាកជាមេជាងដឹកនាំកិច្ចការ
រហូតដល់គម្រោងតួផ្ទះលេចជារូបរាង ឡើងមុនថ្ងៃលិច ។ អ្នកគ្រូចរណៃឈរមើលពីម្លប់ឈើទៅទាំងទឹកចិត្ត
សោមនស្សពន់ពេកណាស់ ត្បិតមិនប៉ុន្មានថ្ងៃទៀតទេ មាណវីនឹងមានជំរក ជ្រកនៅសមសួនហើយ ។ ពេញមួយថ្ងៃនេះ
អ្នកគ្រូយើងក៏ធ្វើការជាមួយ អ្នកស្រុកមិនដាក់ដៃដែរ ហើយពេញមួយថ្ងៃដូចគ្នាដែរ ដែលអ្នកគ្រូលួច
សង្កេតឃើញជាងសម្លាកចោលកន្ទុយភ្នែក លួចមើលមកនាងជាច្រើនដង
ប៉ុន្តែគេតែងតែឈ្ងោកមុខគេចក្រសែភ្នែករបស់នាងជានិច្ច ពេលដែលនាង ក្រលេកចំទៅវិញ
មិនដឹងថាគេកំពុងគិតយ៉ាងណានៅក្នុងចិត្តចំពោះនាង ឡើយ ។ យូរៗម្តង ធិតាជួសទឹកដើរហុចជូនអ្នកធ្វើការទាំងអស់ រួមទាំង
ជាងសម្លាកផង ប៉ុន្តែ ចរណៃហាក់ដូចជាទទួលអារម្មណ៍រំភើបចម្លែកបំផុត ពេលនាងមកដល់ចំពោះមុខមេជាងរបស់យើង ។
កែវភ្នែករបស់គេទាំងពីរ ហាក់ដូចជាកំពុងមានចរន្តឥទ្ធិពលអ្វីម្យ៉ាង ទាក់ចិត្តទាក់អារម្មណ៍របស់គេ
អោយគួចត្របាញ់រកគ្នាយ៉ាងមានន័យជ្រាលជ្រៅធំធេង ដោយគ្មាននរណា អាចយល់បានឡើយ ។
សូម្បីតែនៅពេលគេឈរឆ្ងាយពីគ្នារាប់សិបម៉ែត្រ ធ្វើការញាប់ដៃរៀងៗខ្លួនក៏ខ្សែភ្នែករបស់គេហោះទៅហោះមកគួចត្របាញ់ រកគ្នា
ស្ទើរតែគ្មានចន្លោះពេលសោះឡើយ ។ ថ្វីបើពេលនោះ ហាក់បីដូចជា គ្មាននរណាមានកិរិយាចាប់ភ្លឹកនឹងខ្សែភ្នែក
ដែលវេញពន្ធ័ប្រទាក់គ្នាទៅ មករវាងអ្នកទាំងពីរក៏ដោយ ក៏អ្នកភូមិមួយចំនួនបានសង្កេតឃើញថា ជាង
សម្លាកប្រឹងធ្វើការយ៉ាងមមាញឹកជាងសព្វកាល រួចហើយក៏មិនសូវហ៊ាន
និយាយស្តីលេងជាមួយអ្នកស្រុកដូចទម្លាប់របស់គេរាល់ដងទេ ។

ថ្ងៃរះគងព្រៃហើយ....

អ្នកស្រុកក៏រៀបចំទុកដាក់ឥវ៉ាន់ ហើយក៏ធ្វើដំណើរត្រលប់ទៅផ្ទះរៀង ខ្លួន ។
ចរណៃឃើញជាងសម្លាកនៅរៀបឥវ៉ាន់មិនទាន់ឈប់ដៃ ក៏វាចា ឡើងទៅមាណពថា :

- បងជាង! ដល់ពេលសំរាកហើយ! ចាំថ្ងៃក្រោយយើងធ្វើបន្តទៀតណ៎!

ឮដូច្នោះ ជាងក៏ទម្លាក់ឥវ៉ាន់ចុះភ្លាម រួចក៏បែរសួរធិតាវិញថា :

- អ្នកគ្រូត្រូវការអោយខ្ញុំជូនទៅផ្ទះទេ? ព្រលប់បន្តិចហើយ ដើរម្នាក់ឯង ក្រែងពុំមានសុវត្ថិភាព ។

ស្រាប់តែចរណៃញញឹមឡើង :

- បើមិនទើសទាល់ទេ ចរណៃក៏ចង់អោយបងជាងជូនទៅផ្ទះដែរ ។ យើង ជួបគ្នាច្រើនដងហើយ តែមិនដែលបាននិយាយគ្នាសោះ
ថ្ងៃនេះ យើងដើរ ផង និយាយគ្នាផង យ៉ាងម៉េចដែរ បងជាង?

CHANBOKEO.COM

មាណពញញឹមធ្វើអេះអុញ មិនហ៊ានឆ្លើយថាយ៉ាងណាទេ។ បន្តិចមក គេក៏ដើរពីក្រោយចរណៃជូននាងទៅផ្ទះសែបផៃ។ តាមផ្លូវ ចរណៃសួរទៅ ជាងសម្លាកថា :

- បងជាងសុខសប្បាយទេហ៍ សព្វថ្ងៃនេះ?

- បាទ! គឺ... ធម្មតាទេ... អ្នកគ្រូ។

- ហើយចុះបងរស់នៅជាមួយនរណាដែរ? ហើយប្រកបរបរទទួលទាន អ្វីដែរទៅ?

- គឺ... នៅតែម្នាក់ឯង... ជួនធ្វើជាងឆ្លាក់ផង ជួនធ្វើជាងផ្ទះផង តាមតែ ដំណើរ...

- ហើយ... បងឡើងទៅលើភ្នំព្រះនេត្រព្រះញឹកញាប់ប៉ុនណាដែរ?

- គឺ... រាល់អាទិត្យ... ជួនកាលញឹកជាងហ្នឹង ជាពិសេសគឺទៅបំរើព្រះគ្រូ ដែលគង់នៅលើភ្នំ។

អឺយ៉ា! ដល់នារីយើងបើកការសន្ទនា មាណពយើងក៏ចេះមានពាក្យ មកឆ្លើយឆ្លងចចារខ្លះដែរតើហ៍។ ចរណៃលួចញញឹមក្របួចមាត់ កាលបើ ឃើញបុរសយើងចេះនិយាយស្ដីតបមករកនាងវិញ។ បន្តិចមក គេក៏បាន មកដល់មុខផ្ទះសែបផៃ :

- ចូលលេងសិនទេ បងជាង? (ឆរីបបួល)

- មិនអីទេ អ្នកគ្រូ... គឺ.. យប់បន្តិចហើយ... ចាំថ្ងៃក្រោយចុះ

ថាហើយមាណពក៏បែរខ្លួនដើរបកក្រោយទៅវិញ បានពីរបីជំហានក៏ ទុចង៉ក់ រួចក៏បែរមកវិញបំរុងលួចមើលអ្នកគ្រូយើង។ ចៃដន្យ ចរណៃ មិនទាន់ដើរចូលទៅក្នុងរបងផ្ទះនៅឡើយទេ។ ពេលនោះ នាងនៅឈរ សម្លឹងមើលបុរសយើងពីក្រោយនៅឡើយ។ មាណពភ្ញាក់ព្រើត កាលបើ ប្រទះនឹងក្រសែភ្នែករបស់មាណវីភ្លាម។ គេក៏ឈ្ងោកមុខដើរបន្តទៅទៀត បន្តិចមក ក៏ងាកជាថ្មី ស្រាប់តែប្រទះនឹងឆរីឈរញញឹមពីចម្ងាយដាក់នាយ វិញដដែល។ ម្ដងនោះ ជាងសម្លាកមានអារម្មណ៍ហាក់ដូចជាក្ដៅមុខក្ដៅ មាត់ភាយៗតែម្ដង ដែលត្រូវធិតាចាប់ទាន់កិរិយាច្រាស់ច្រាលរបស់នាយ ដល់ទៅពីរដង។ បន្តិចមក គេក៏ឈប់ទុចង៉ក់នៅឈរស្ងៀមមួយកន្លែង មិន ដើរទៅមុខតែក៏មិនហ៊ានងាកក្រោយដែរ។ ចរណៃហាក់ដូចជាចាប់ភ្លឹក ចំពោះកិរិយារបស់នាយ ហើយឃើញនាយហាក់ដូចជាកំពុងក្ដាប់អ្វីម្យ៉ាង នៅក្នុងដៃស្ដាំ។ ធិតាក៏ដើរលបៗ មកជិតហើយសួរពញ្ញាក់ស្មារតីនរៈពី ក្រោយខ្នងមកថា :

- បងជាង!... ចង់សួរអ្វីខ្ញុំ មែនទេ?

ភ្លាមនោះ ជាងសម្លាកភ្ញាក់ក្រញាងដូចគេចាប់គ្រវែង ត្បិតមិននឹកថា ធិតាដើរត្រលប់មកវិញ សួរពញ្ញាក់ស្មារតីនាយដូច្នោះទេ។ គេបែរសម្លឹង មកអ្នកគ្រូទាំងរន្ធត់ក្នុងចិត្ត ហាក់ដូចជាចង់ឧទានអ្វីម្យ៉ាងតែនិយាយមិន ចេញ។ គេក៏ឈ្ងោកមុខនៅស្ងៀមដដែល។ កាលបើឃើញកិរិយាអេះអុញ របស់នាយ ចរណៃក៏សួរបន្ថែម :

- មានបញ្ញើអីផ្ញើចរណៃមែនទេ បងជាង? ឥលូវចរណៃមកដល់ហើយ ចាំទទួល... ឆាប់អោយមកណ៎!

ថាហើយ ធិតាលើកលាតបាតដៃហុចទៅមុខនាយ ហាក់ដូចជាកំពុង

CHANBOKEO.COM

ចាំទទួលអ្វីមួយពីមាណព ។ ជាងសម្លាកងើបមុខឡើងសម្លឹងធិតាទាំងទឹក មុខខ្មាស១ ដែលនាងទាយចិត្តនាយត្រូវ រួចហើយក៏ឆ្លើយតបទាំងតគាក់ តតុបទៅវិញថា :

- គឺ... គឺ...ចាំព្រឹកស្អែកបានទេ... ព្រោះបញ្ញើមួយនេះ... គឺ... មិនសមនឹង ជូនអ្នកគ្រូទេ បាទ!

- អត់ទេ! មិនចាំស្អែកទេ.. ខ្ញុំសុំទទួលពេលហ្នឹងទាន់ចិត្តក្តៅ... ម៉ោះ! មាន អ្វីផ្ញើហ្នឹង... ឆាប់ហុចមក! លឿនឡើង!

ឮមាណវីសម្លុតដូច្នោះ ជាងសម្លាកក៏យករបស់ដែលនាយក្តាប់ក្នុងដៃ ទៅដាក់នៅលើបាតដៃរបស់នាងភ្លាម ។ ធិតាស្រវាទាញយកមកកាន់មើល រួចហើយក៏លាន់សំណើចខឹក១ឡើង :

- ស្លាប់ហើយ! ជួបគ្នាតាំងពីព្រហាមស្រាង១ ហេតុម្តេចទាល់តែថ្ងៃលិច ទើបនឹកឃើញយកមកអោយឥចឹង? មើលហ្ន៎! ស្វិតផ្កាអស់រលីងតែម្តង ។

ឮធិតាបន្ទោសដូច្នោះ មាណពមិនហ៊ានឆ្លើយទេ គ្រាន់តែឈ្ងោកមុខខាំ មាត់ធ្វើកិរិយាទំនងខ្មាស់១ ។ ការពិត របស់នោះគឺជាខ្សែកក្រងពីគ្រាប់ ស្លួយ ហើយមានចងផ្កាស្បៃរឿងជាបន្តោងផង ។ ចរណៃសម្លឹងមុខបុរស យើងទាំងទឹកមុខញញឹម រួចក៏លើកខ្សែកយកមកពាក់ថែមទាំងស្រដីថា :

- បងជាង មើលនែ៎! ចរណៃពាក់ស្អាតទេ? បើសិនបានពីព្រឹក ម្លេះសម បានពាក់ បង្ហួតអ្នកភូមិបាត់ទៅហើយ... គិតទៅគួរអោយស្តាយមែន!

ជាងសម្លាកមិនហ៊ានគន់មើលចំវិញទេ ត្បិតគេហាក់ដូចជាខ្លាចចិត្តអ្នក គ្រូ យ៉ាងម៉េចមិនដឹង តែគេរំភើបក្នុងចិត្តណាស់ ដែលឃើញមាណវីសម្តែង កិរិយាមិនរើសអើងប្រកាន់នឹងខ្សែកគ្រាប់ស្លួយបន្តោងស្បៃរឿងនោះទោះ បីជាខ្សែកនោះគ្រាន់តែជាកម្រងខ្សែក ដែលគេក្រងសម្រាប់កូនក្មេងពាក់ លេងក៏ដោយ ។ រំពេចនោះចរណៃក៏ស្រដីថា :

- អរគុណណាស់បងជាង ដែលមានទឹកចិត្តនឹកឃើញដល់ចរណៃ ថ្វីបើខ្សែ កនេះ មើលទៅមិនស្រស់ស្អាតមិនវិសេសអ្វីប៉ុន្មានក៏ដោយ ។ ការពិត បង ជាង គឺជាមនុស្សដំបូងហើយ ដែលយកខ្សែកមកបំពាក់ទទួលស្វាគមន៍ វត្តមានរបស់ខ្ញុំ នៅភូមិព្រះនេត្រព្រះនេះ ។ អរគុណ បងជាងណាស់! គឺ អរគុណ ពិតមែនណា៎!

ថាហើយ នារីក៏ញញឹមដាក់មេជាងរបស់យើងយ៉ាងពព្រាយ ។ បុរស យើងក៏ញញឹមតបវិញ ហើយដកដង្ហើមយ៉ាងវែងមួយបន្ធូរទ្រូង ទំលាយនូវ ការតប់ប្រមល់ខ្លាចចិត្តអ្នកគ្រូយើងកន្លងមក ។ បន្តិចមក អ្នកគ្រូចរណៃក៏ ចូលទៅក្នុងរបងផ្ទះបាត់ទៅ ។ រីឯមាណពក៏ប្រញាប់ប្រញាល់ត្រលប់មកផ្ទះ ខ្លួនវិញទាំងដួងចិត្តរំភើបហួសព្រំដែន ។ មែនហើយ...ថ្ងៃនេះ ជាថ្ងៃដំបូង បង្អស់ក្នុងជីវិតដ៏ក្រៀមក្រោះរបស់នាយ ដែលនាយមានអារម្មណ៍ថាខ្លួន កំពុងទទួលពរពីទេវតាយ៉ាងត្រចះត្រចង់មួយ ។ គេដើរញញឹមតែម្នាក់ឯង រហូតមកដល់លំនៅវិញ ។

រាត្រីនេះ ជាងយើងគេងយកដៃគងថ្ងាស ត្រេកអររំភើបផង ព្រួយ ផង ច្របូកច្របល់... យូរ១ម្តង គេលើកយកបន្តោងខ្សែកចែកាច់មកថើប ហើយស្រដីខ្សិប១តែម្នាក់ឯងថា :

CHANBOKEO.COM

- ណៃ... តើអូននៅចាំទេ ថាយើងធ្លាប់មានអនុស្សាវរីយ៍អ្វីខ្លះជាមួយគ្នា

កាលពីអតិតកាល? ចំពោះបង... អ្វីៗទាំងឡាយនៅតែមានជីវិតរស់រវើក ក្នុងអារម្មណ៍របស់បងជានិច្ច

មិនដែលភ្លេចមួយគ្រាណាឡើយ ហើយបង ក៏មានបេះដូងតែមួយដែរសំរាប់ទុកផ្ញើអូន... នោះគឺជាសេចក្តីស្រឡាញ់ដ៏

ស្ថិតស្ថេរនៅក្នុងជីវិតរបស់បង ដែលគ្មានថ្ងៃនឹងថមថយអនុភាពឡើយ ហើយបងក៏នៅតែរង់ចាំអូន.. រង់ចាំ...

រហូតដល់ពេលដែលអូនត្រឡប់មក ស្រាយចំណងដួងចិត្តរបស់យើង ពីអតិតកាលមកវិញ... ណៃ! យើងបាន

បែកគ្នា១០ឆ្នាំហើយ... តើពេលនេះ ចិត្តអូនផ្លាស់ប្តូរយ៉ាងណាខ្លះ? តើបង ត្រូវត្រៀមចិត្តបែបណាដើម្បីទទួលស្វាគមន៍រូបអូន?

មាណពប្រឹងបិទភ្នែកនិទ្រាទៅទាំងដួងចិត្តវិលវល់ រំជើបរំជួល រំភើប សប្បាយលាយឡំនឹងភាពកន្ទះរា... មិនដឹងថាថ្ងៃស្អែក ដំណើរជីវិតរបស់ នាយនឹងបោះជំហានទៅទិសណាឡើយ ។

0000000000000000

000000

0

CHANBOKEO . COM

# វគ្គទី៤

# ចិត្តប្រេះឆា

ច្រើនថ្ងៃក្រោយមក...

ផ្ទះគ្រូក៏សង់ហើយ កុដិលោកនៅវត្តក្រោមក៏សង់ហើយ ដំណាលគ្នា ដោយការប្រឹងប្រែងព្យាយាមរបស់ជាងសម្លាក និងអ្នកស្រុកបួនដប់នាក់ ទៀត រួមទាំងតាមេឃុំនិងនាយភុំផង ។ ព្រឹកនេះ អ្នកស្រុកបានធ្វើបុណ្យ មួយយ៉ាងធំប្រារព្ធឆ្លងកុដិថ្មីនៅវត្តព្រះនេត្រព្រះក្រោម ហើយមានគំរោង ការនឹងធ្វើពិធីឡើងផ្ទះ ជូនអ្នកគ្រូចរណៃនិងអ្នកគ្រូចំណាន នៅថ្ងៃបន្ទាប់ នោះដែរ ។ លុះថ្ងៃត្រង់ចប់ពិធីប្រស់ព្រំឆ្លងកុដិថ្មី តាមេឃុំដូចជាចាប់ភ្លឹក ថាដូចបាត់ មិនឃើញវត្តមានរបស់ជាងសម្លាក ក្នុងពេលបាយនោះឡើយ ។ គាត់ក៏សួរនាយភុំថា :

- មានឃើញជាងសម្លាកទេភុំ? ទៅហៅគេមកបរិភោគបាយភ្លាមទៅ ។

ស្រាប់តែនាយខ្លែងស្រែកឆ្លើយផ្ទួងថា :

- មិនបាច់រកទេ តាមេឃុំ ។ អំបាញ់មិញ ខ្ញុំឮពូសម្លាកពិត្រតេជគុណថា ទៅជួយរែកទឹកដាក់ពាងនៅផ្ទះគ្រូឯណោះ សំរាប់ពិធីបុណ្យថ្ងៃស្អែកនេះ ។ គាត់ថាចាំគាត់វិលមកបរិភោគបាយតាមក្រោយ ពេលគាត់រែកទឹកពេញ ពាងរួចហើយ ។

អ្នកគ្រូចរណៃដែលកំពុងរៀបរបបរិភោគក្បែរអ្នកគ្រូចំណាន បានលួច ដៀងភ្នែកតាមរកជាងសម្លាកយូរហើយ ត្បិតបាត់នាយពីហ្វូងពិធីបុណ្យ ទៅមិនឃើញមកទទួលទានបាយនឹងគេ ។ កាលបើឮវាចាសន្ទនារបស់តា មេឃុំនិងនាយខ្លែង ធិតាក៏ស្រវារកស្លឹកឈូក ខ្ចប់បាយនិងអាហារគ្រៀមៗ ទុកភ្លាម ។ ចំណានក្រឡេកឃើញកិរិយារបស់ចរណៃដូច្នោះ ក៏វាចាឡើង :

- បងខ្ចប់បាយផ្ញើបងជាងមែនទេ?

- មែនហើយ... មើលហ្ន៎! គេមានទឹកចិត្តទៅរែកទឹករៀបចំកន្លែងអោយ យើងដោយមិនគិតរកបាយរកទឹកសោះ ។ ធ្វើការច្រើនហើយបរិភោគមិន ទៀងតិចលោឈឺទៅ ។ អូនជាគ្រូពេទ្យស្រាប់ហើយតើហ៎ មិនដឹងទេ?

ភ្លាមនោះ ចំណានញញឹមឡើង ហើយក៏ឈ្ងោកខ្សិបចំអន់ចរណៃថា :

- បារម្ភចំពោះគ្នាទៅវិញទៅមកដល់ហើយហ្ន៎! មិនដែលឃើញនិយាយគ្នា អីសោះ ស្រាប់តែចេះយល់ចិត្តគ្នាទៅកើត.. ចម្លែកដល់សូរហើយ!

ចរណៃឮប្អូនស្រីស្រដីដូច្នោះ ក៏លូកដៃក្តិចនាងភ្លាម :

- កុំនិយាយតែផ្តាស! ណែ៎ះ ញ៉ាំបាយទៅ អោយរវល់មាត់បន្តិច ដើម្បី កុំអោយនិយាយអ្វីអត់ប្រយោជន៍ច្រើនពេក!!

CHANBOKEO.COM

ចំណានលួចខ្ចប់មាត់សើចខឹក១ កាលបើឃើញបងស្រីនាងខ្មាសឡើង ក្រហមមុខពេលត្រូវនាងចំអន់លេង ។ បន្តិចមក ចរណៃបានលួចដើរចេញ សំដៅទៅផ្ទះគ្រូតែម្នាក់ឯង ទុកអោយចំណាននៅសំណេះសំណាលលេង ជាមួយអ្នកភូមិ ។

លុះមកជិតដល់មាត់របងផ្ទះគ្រូថ្មី ស្រាប់តែចរណៃប្រទះនឹងនារីភូមិ មួយរូបមានវ័យប្រមាណ២០ឆ្នាំ កំពុងជិះកង់យួរចានស្រាក់មកដល់ដែរ ហើយនាងក៏ញញឹមដាក់អ្នកគ្រូរួចជិះហួសចូលទៅក្នុងបរិវេណផ្ទះគ្រូ ព្រម ទាំងកូកហៅថា :

- បងសម្លាកអើយ! ខ្ញុំយកបាយមកផ្ញើនែ៎ក!

ថាហើយនាងចុះពីកង់ ដើរសំដៅគ្រែរនាបឬស្សីមួយនៅក្រោមដើម ស្វាយ ដោះស្រាក់រៀបម្ហូបយ៉ាងផ្ចិតផ្ចង់ ។ ឃើញដូច្នោះ អ្នកគ្រូឈរទ្រឹង នៅក្រៅរបង ឈ្ងោកមុខសម្លឹងបាយកញ្ចប់ស្លឹកឈូកដែលនាងកំពុងយួរ នៅក្នុងដៃ សុខចិត្តនៅស្ងៀមស្ងាត់ មិនហ៊ានដើរចូលទៅទេ ។ ភ្លាមនោះ នារីមួយរូបនោះ កូកថែមទៀត :

- បងសម្លាក! មកពិសារបាយ ឆាប់ឡើង នឹងអាលខ្ញុំយកស្រាក់ទៅវិញ!

ស្រាប់តែអ្នកគ្រូយើងឃើញជាងសម្លាក ឆ្លើយពីលើដំបូលផ្ទះទៅឆវី នោះវិញថា :

- អរគុណខឿនណាស់ដែលខំយកបាយមកអោយ ។ ទុកបាយត្រង់ហ្នឹងសិន ហើយ ចាំខ្ញុំរួចដៃ ខ្ញុំនឹងទទួលទានហើយចាំខ្ញុំលាងចានស្រាក់យកទៅសង វិញណា៎!

- អត់ទេ! (នាងខឿនឆ្លើយវិញ) បងត្រូវតែចុះមកពិសារឥលូវនេះ ។ បើ មិនអញ្ចឹងទេ ខ្ញុំយកទៅវិញហើយព្រោះទុកចោលត្រូវក្តៅវាផ្អូម !

- បាទ! មិនអីទេ! បើខឿនប្រញាប់ ខឿនយកទៅវិញសិនក៏បាន ចាំខ្ញុំដើរ ទៅបរិភោគដោយខ្លួនឯង ។

នាងខឿនងរប៉េវ រអ៊ូថា:

- ខំជិះកង់យកបាយមកអោយហើយមិនព្រមបរិភោគទៀត! យ៉ាប់មែន!

នាងងប៉េវប្រមូលយកអាហារដាក់ស្រាក់វិញ រួចក៏ឡើងជិះកង់ចេញ ទៅវិញយ៉ាងប្រញាប់ ។ លុះឃើញខឿនចេញទៅបាត់ ចរណៃក៏បោះជំហាន ចូលទៅ ។

- បងជាងឡើងដំបូលធ្វើអ្វីហ្នឹង? (អ្នកគ្រូយើងស្តីសួរ)

គ្រាន់តែដាក់ភ្នែកក្រឡេកមកឃើញវត្តមានធិតាមកដល់ភ្លាម ជាង សម្លាកក៏ញញឹមភ្លាមឡើងមួយរំពេច ហើយស្ទុះចុះមកដីរឹងយ៉ាងរហ័ស សំដែងការគោរពចំពោះចរណៃ ព្រមទាំងឆ្លើយតបថា :

- គឺខ្ញុំឡើងចងទ សំរាប់ត្រងទឹកពេលភ្លៀង គ្រាន់នឹងបានទឹកស្អាតសំរាប់ ប្រើប្រាស់ ដោយមិនបាច់ចាំទៅរែកឆ្ងាយផង ។

- ចុះក្រែងនាយខ្លែងថា បងមករែកទឹកនោះអី...?

- បាទ! ខ្ញុំរែកចាក់ពេញពាងអស់ហើយ ។

- អរគុណណាស់បងជាង! ម៉ោះ! ចុះពិសារបាយសិន! នេ៎ះ! ខ្ញុំបានខ្ចប់យក ផ្ញើបងទៀតផង!

CHANBOKEO.COM

ឮចរណៃខ្ចប់បាយផ្ញើ មាណពភ្ញាក់ព្រើត មានកំលាំងប្រឹសតែម្តង។ គេញញឹមតបវិញ រួចហើយក៏ស្ទុះដើរមកទទួលកញ្ចប់បាយយ៉ាងរហ័ស ដោយមិនឮប្រកែកអ្វីមួយម៉ាត់ :

- អរគុណអ្នកគ្រូ!
- ចាំស! មិនអីទេ!

ឃើញមាណពទទួលខ្លួនចូលស្រាយកញ្ចប់បាយមកបរិភោគដោយឥត ប្រកែក ចរណៃញញឹមលាក់គំនួចក្នុងចិត្ត ហើយក៏ដើរទៅយកផ្តិលមួយ ដួសទឹកមកហុចអោយនាយ :

- នេះ ទឹកចាំស! ទទួលទានបាយភ្លេចទឹក ប្រយត្ន័អួលណាំ!

មែនហើយ អាល័យតែខ្មាសមុខអ្នកគ្រូ មាណពយើងភ្លេចរកទឹក ថែមទាំងភ្លេចមើលថាតើម្ហូបអីខ្លះទៅដែលនាយកំពុងបរិភោគ :

- អរគុណ បាទ! (ជាងលូកដៃទទួលយកផ្តិលទឹកពីអ្នកគ្រូ)
- បងជាង! (ចរណៃពោលបន្ថែម) បងមិនបាច់ប្រឹងធ្វើការជួយខ្ញុំអ្វីដល់ ម្លឹងទេ ទុកកិច្ចការខ្លះអោយខ្ញុំធ្វើក៏បានដែរ។ ខ្ញុំមើលទៅបង ឃើញហាក់ ដូចជានឿយហត់ពន់ពេកណាស់ រាល់ថ្ងៃនេះ!
- មិនជានឿយហត់អ្វីទេបាទ! គ្រាន់តែជាទឹកចិត្តបន្តិចបន្តួច កាលបើខ្លួនខ្ញុំ ក្រីក្រ មិនមានទ្រព្យសម្បត្តិអ្វីជួយជ្រោមជ្រែងអ្នកគ្រូបាន.. មានតែកម្លាំង កាយប៉ុនហ្នឹង...
- ហើយចុះ បងជាងមិនចង់អោយខ្ញុំធ្វើអ្វីដោយខ្លួនឯងខ្លះទេ?

មាណពនៅស្ងៀម មិនឆ្លើយទេ គ្រាន់តែគ្រវីក្បាលហើយញញឹមដាក់ អ្នកគ្រូដ៏សោភារបស់យើងតបវិញតែប៉ុណ្ណោះ។ ចរណៃសម្លឹងតាមមើល នាយដោយក្រសែភ្នែកភ្លឺថ្លាផ្លេកៗ ហាក់បីដូចជាកំពុងស្ទង់ទឹកចិត្តរបស់ នរៈចំពោះរូបនាង ធ្វើអោយបុរសយើងនឹករអៀសខ្លួន លើកចានបាយ បែរ មុខចេញទៅម្ខាងបរិភោគបាយបន្តទៅទៀត។ ពេលនោះ ថ្វីបើគេនៅស្ងៀមស្ងាត់រៀងៗខ្លួន តែម្នាក់ៗ ហាក់ដូចជាមានអារម្មណ៏ល្អហើយរំភើប ក្នុងចិត្តចំពោះគ្នាទៅវិញទៅមករកអ្វីប្រៀបមិនបានឡើយ។

មួយស្របក់ក្រោយមក ស្រាប់តែមានឡានហ្ស៊ីបមួយបរមកដល់។ ចរណៃ ក្រលេកឃើញហើយក៏លាន់មាត់ឡើងថា :

- លោកចក្រា!

គ្រាន់តែឃើញវត្តមានលោកចក្រាភ្លាម ជាងសម្លាកថ្លោះទឹកមុខភ្លាម ហើយក៏ងើបគេចខ្លួនចេញទៅ ដោយមិនមានស្រដីអ្វីមួយម៉ាត់ឡើយ ទំនង ដូចជាគេយល់ថា ខ្លួនជាមនុស្សវណ្ណៈតូចទាបមិនសមនៅក្បែរៗនោះ ស្តាប់ការសន្ទនារបស់អ្នកមានវណ្ណៈខ្ពស់ឡើយ។ លោកចក្រាចាប់ហ្វ្រាំងង៉ក់ ហក់ចេញពីរថយន្តយ៉ាងរហ័ស :

- សួស្តី អ្នកគ្រូចរណៃ! សុខសប្បាយជាទេ បាទ?
- ចាំស! ធម្មតាៗទេ។ ចុះលោកវិញ មានដំណើរទៅណាមកណាដែរ?
- គឺមានបំណងមកចូលរួមពិធីបុណ្យនៅវត្តតែពេលខ្ញុំទៅដល់ ឮអ្នកស្រុក ប្រាប់ថា អ្នកគ្រូមកទីនេះ ទើបខ្ញុំមកតាម។

CHANBOKEO.COM

ឮវាចាលោកចក្រាដូច្នេះ ធិតាយើងនឹកគិតក្នុងចិត្តថា :

- បើលោកពិតជាចង់មកចូលរួមពិធីបុណ្យពិតមែន ម៉េចក៏មកដល់វត្តពេល បាយថ្ងៃត្រង់ទៅវិញ? ប្រហែលជាលោកមានបំណងអ្វីផ្សេងហើយ ។

ភ្លាមនោះ លោកចក្រាក៏វាចាបន្តថា :

- ឮថា អ្នកគ្រូធ្វើពិធីឡើងផ្ទះព្រឹកស្អែកមែនទេ?
- ចាស ត្រូវហើយ... គឺគ្មានពិធីអ្វីធំដុំទេ គ្រាន់តែសូត្រមន្តបន្តិចបន្តួច ជា មួយអ្នកភូមិយើងម្តុំៗនេះ ។
- មិនហៅខ្ញុំអោយចូលរួមផងទេហ៎?
- គឺ... បើលោកមិនទើសទាល់ទេ.. សូមអញ្ជើញកុំខាន...
- អូហ៎ន៎ែ ខ្ញុំមានការទៅភ្នំស្រុកម៉ាភ្លែត ដើម្បីទៅដឹកផាមួងទៅឱ្យឈ្មួញ អ្នកគ្រូចង់ទៅលេងទេ? ទៅមើលគេត្បាញសូត្រ.. សប្បាយណាស់...

ថៃដន្យ ចរណៃអាល័យតែងាកលួចរកមើលជាងសម្លាក មិនដឹងថា បាត់នាយទៅណាអំបាញ់មិញ ។ ដោយឮថាទៅមើលគេត្បាញសូត្រ ចរណៃ នឹកហាក់ចង់ទៅលេងដែរ តែមិនហ៊ានទៅតែពីរនាក់ជាមួយលោកចក្រា ដែលជាមនុស្សទើបនឹងស្គាល់គ្នាថ្មី ។ នាងក៏ធ្វើសំណូមពរឡើងថា :

- គឺ... បើខ្ញុំសុំអោយមនុស្សម្នាក់ទៅតាមដែរ លោកចក្រាទើសទាល់ទេ?
- ពុទ្ធោ! ខ្ញុំចង់ទៅតែពីរនាក់អ្នកគ្រូទេ មិនចង់...
- ធ្វើដំណើរតែពីរនាក់មិនសមរម្យភ្នែកអ្នកផងទេលោកចក្រា ( ចរណៃ ស្រដីកាត់) បើសិនមានអ្នកទីបីនោះ យើងអាចចៀសវាងនូវពាក្យចាម អារាមមិនល្អស្តាប់ទាំងឡាយរវាងយើងទាំងពីរនាក់ មែនទេ?

លោកចក្រាមិនហ៊ានតវ៉ាទេកាលបើអ្នកគ្រូវាចាសមរម្យដូច្នោះ ។ គេ ក៏សួរបន្តថា :

- ហើយចុះនរណាទៅដែលជាមនុស្សទីបីដែលត្រូវទៅជាមួយយើង?
- លោកចាំមួយភ្លែត! ខ្ញុំនឹងទៅហៅគេមកសិន ។

ចរណៃស្ទុះរឹងទៅតាមរកជាងសម្លាកមិនបង្អង់ ។ បន្តិចមក នាងក៏រក ជាងសម្លាកឃើញនៅខាងក្រោយផ្ទះកំពុងតែពុសឱសគរទុក :

- អត់ទេ បាទ!... អ្នកគ្រូហៅនាយខ្លែង ឬនាយប្រវឹកទៅវិញទៅ..( ជាង ប្រកែកមិនព្រមទៅជាមួយ) ខ្ញុំគិតថា រូបខ្ញុំមិនសមនឹងធ្វើដំណើររួមជា មួយអ្នកគ្រូនិងលោកចក្រាទេ...
- នរណាថាមិនសម? បងជាងត្រូវតែជូនខ្ញុំទៅណា៎ ដើម្បីជួយរក្សាសុវត្ថិ ភាពឱ្យខ្ញុំផង ឬក៏បងមិនចង់ជួយជ្រោមជ្រែងសន្តិសុខឱ្យខ្ញុំទេ?

មាណពធ្វើកិរិយារេរាអេះអុញ ស្រាប់តែចរណៃស្ទុះទៅទាញជាវអាវ របស់នាយ :

- តោះ! ឆាប់ទៅ! កុំអោយលោកចក្រាចាំ ។ នៅញ៉ឹមញ៉ុមយូរនាំតែយឺត ត្រលប់មកវិញមុនព្រលប់មិនទាន់ទេ ។

CHANBOKEO.COM

ជាងសម្លាកលែងហ៊ានតវ៉ាតែម្តង កាលបើអ្នកគ្រូយើងជំរុញខ្លាំង ទៅហើយ ។ លុះប្រទះឃើញវត្តមានរបស់ជាងសម្លាកភ្លាម លោកចក្រាក៏ បើកភ្នែកសម្លឹងមុខមាណព សំដែងឫកពាហាក់ដូចជាទើសទាល់ក្នុងចិត្ត ដល់សូរហើយ តែដោយខ្លាចចិត្តមាណវីយើង គេក៏នៅស្ងៀមទៅវិញ ។ ចំណែកជាងសម្លាកវិញ ក៏ខ្លាចចិត្តលោកចក្រា តែក៏ខ្លាចចិត្តអ្នកគ្រូដូចគ្នា ។ គេនៅឈរវេរាមួយស្របក់មិនហ៊ានឡើងជិះសោះ ស្រាប់តែអ្នកគ្រូចរណៃ ជំរុញនាយអោយឡើងទៅជាប្រញាប់ ។ ដោយទើសទាល់ ជាងសម្លាកក៏ ពោលថា:

- អ្នកគ្រូឡើងជិះខាងមុខទន្ទឹមនឹងលោកចក្រាទៅ ចាំខ្ញុំជិះខាងក្រោយ ។

ស្រាប់តែមាណវីប្រកែក :

- អត់ទេ! ខ្ញុំចង់ជិះខាងក្រោយវិញ ហើយបងជាងជិះជាមួយប្រុសៗគ្នាឯង ខាងមុខឯនោះវិញទៅ មើលទៅសមរម្យជាង ។

សំដីនេះធ្វើអោយលោកចក្រាកាន់តែទើសទាល់ក្នុងចិត្តថែមឡើងកាន់ តែខ្លាំង ។ គេធ្វើមុខក្រមូវទំនងមិនសប្បាយចិត្ត ។ ដោយទាល់ច្រកមិនដឹង ថានឹងត្រូវធ្វើដូចម្តេច កាលបើពីរនាក់លោកចក្រានិងអ្នកគ្រូសោភាមាន គំនិតមិនដូចគ្នា ជាងសម្លាកស្រដីថា :

- អូហ៍! ខ្ញុំភ្លេចថាខ្ញុំមានធុរៈត្រូវបំពេញនៅឯវត្តខាងលើភ្នំ... ខ្ញុំសូមទោស អ្នកគ្រូ សូមទោសលោកចក្រា..ខ្ញុំមិនអាចរួមដំណើរទៅជាមួយបានទេ...

ថាហើយនាយយើងក៏អោនគំនាប់អ្នកទាំងពីរ រួចដើរចេញទៅយ៉ាង រហ័ស ស្រាប់តែចរណៃថ្លោះទឹកមុខភ្លាមដែរ :

- អញ្ចឹង ខ្ញុំគិតថា ចាំថ្ងៃក្រោយទៅលោកចក្រា ។ ពេលណាយើងមានគ្នា ចាំយើងទៅ ទើបសប្បាយ ។ អរគុណលោកណាស់ដែលបានបបួលខ្ញុំទៅ ដើរលេងថ្ងៃនេះ...!

ធិតាក៏លើកដៃជំរាបលាលោកចក្រា   រួចក៏ដើរចេញតាមក្រោយជាង សម្លាកទៅបាត់ដែរ ទុកអោយបុរសសង្ហានៅអង្គុយខកចិត្ត និយាយមិន ចេញតែម្នាក់ឯង ។ នេះជាលើកទីពីរហើយ ដែលអ្នកគ្រូចរណៃបដិសេធ សំណើរបស់គេ ។ តាមធម្មតា គេជាបុរសរូបសង្ហា ហើយជាកូនដង្ហៅស្រូវ យ៉ាងល្បីមួយរូបនៅស្រុកព្រះនេត្រព្រះមង្គលបុរីសេរីសោភ័ណនេះ ។ ក្រមុំ ទាំងឡាយ ក្នុងភូមិតំបន់នេះ តែងតែចោមរោមប៉ងប្រាថ្នារូបគេជាគូជីវិត តែគេមិនដែលនឹកភ្នកយកភ្នែកមើលម្តងណាសោះ ។ ចម្លែកអីអ្នកគ្រូយើង បែរជាមិនអើពើចំពោះរូបគេទៅវិញ ថែមទាំងមិនសំដែងចិត្តរំភើបអ្វីបន្តិច ដែលនាយបានធ្វើវិភាគទាននូវឈើនិងសង្ក័សីសំរាប់សង់ផ្ទះគ្រូ ។ គេអង្គុយ ខាំមាត់សង្រ្កឹតជើងធ្មេញតែម្នាក់ឯងនៅក្នុងឡាន ហើយស្រដីខ្សិបៗថា :

- ខ្ញុំមិនព្រមចុះចាញ់ទេ! គ្រាន់តែជាគ្រូបង្រៀនបឋមសិក្សាមួយរូប តើ មានអ្វីគួរអោយអស្ចារ្យទៅ បានជាវាយឫកឆ្មើងឆ្មៃចំពោះយើង? តើជាង សម្លាកនោះត្រូវជាយ៉ាងម៉េចនឹងរូបនាងដែរ ចរណៃ បានជានាងហាក់ដូច ជាចាប់អារម្មណ៍នឹងគេនោះម្ល៉េះ? ហើយនៅរាល់ដងដែលយើងប្រទះអ្នក គ្រូចរណៃ

CHANBOKEO . COM

យើងក៏សង្កេតឃើញវត្តមានរបស់ជាងសម្លាកដូចគ្នា... តើគេជា មនុស្សសំខាន់របស់នាងមែនទេ? ហេតុអីបានជានាងមានទំនាក់ទំនងជា មួយមនុស្សដែលមានវណ្ណៈអន់ៗដូចនាយសម្លាកបែបនេះ? តើនាងស្គាល់បុរសក្រីក្រនោះតាំងពីអង្កាល់?

ចក្រាសំកុកម៉ូម៉ៅក្នុងចិត្តតែម្នាក់ឯង ក្រោមពន្លឺថ្ងៃរះដ៏សែនក្ដៅ...

រីឯអ្នកគ្រូយើងវិញក៏ដើរចេញទៅយ៉ាងលឿន ត្រលប់ទៅដើរសំដៅ ទៅផ្ទះជាងសម្លាក តែឃើញផ្ទះបិទទ្វារស្ងាត់ឈឹង មិនឃើញស្រមោល របស់នរៈយើងឡើយ ។ ធិតាក៏ដើរហួសតាមផ្លូវលំក្រវិកក្រវក់មួយរហូត ដល់បានមកដល់មាត់អូរ ស្រាប់តែប្រទះនឹងមាណពយើងកំពុងស្រាវខ្សែ ទូកបំរុងអុំចេញដំណើរទៅ :

- បងជាង! (ចរណៃស្រែកហៅ)

ជាងសម្លាកភ្ញាក់ព្រើតបែរក្រោយយ៉ាងរហ័ស ថែមទាំងឧទានថា :

- អ្នកគ្រូ?...

ចរណៃក៏សួរបន្ត :

- បងជាងទៅណាហ្នឹង? ចុះក្រែងថាមានការនៅឯលើភ្នំ មិនមែនទេ?

- បាទ..គឺ..គឺមានពិតមែន...

- ហើយចុះម៉េចក៏មកអុំទូកក្នុងអូរទៅវិញ?

ឃើញធិតាសួរផ្ទាន់ នាយយើងធ្វើកិរិយាអេះអុញៗ រួចក៏ឆ្លើយថា :

- គឺ.. តាមការពិត ខ្ញុំចង់អុំទៅរកបេះព្រលិត ផ្កាស្មៅ ដកត្រកួនឈ្លក់ទឹក តាមវាលយកទៅធ្វើតាៗនៅលើភ្នំបន្តិច ។ ហើយចុះអ្នកគ្រូមិនទៅជាមួយ លោកចក្រាទេ?

ចរណៃញញឹមឡើង :

- បើទៅជាមួយ ម៉េចនឹងបានឃើញបងជាងលួចមកអុំទូកលេងកើត?

ជាងសម្លាកលួចញញឹមតិចតបវិញ ហាក់ដូចជានឹកខ្មាសធិតាតិចៗ :

- អ្នកគ្រូ! ចង់ជិះទូកលេងទេ? ជិះទៅមើលវាលស្រែស្រុកព្រះនេត្រព្រះ នេះណា៎ នៅរដូវទឹកឡើង ទីនោះមានទេសភាពស្រស់ស្អាតណាស់ ។

ធិតាងក់ក្បាលហើយឆ្លើយថា :

- អោយតែម្ចាស់ទូកមិនទើសទាល់ ខ្ញុំក៏ចង់ជិះដើរលេងដែរ ។

ជាងសម្លាកពួដូច្នោះក៏ប្រញាប់ចុះទប់ទូកអោយធិតាដើរឡើងភ្លាម ។ បន្ទាប់មក គេក៏អុំនាំធិតាចេញសំដៅទៅវាលស្រែដែលមានទឹកលិចវាលល្ហ ល្ហាចឃើញចុងស្រូវវារលូតអើតកប្រណាំងនឹងត្រួយត្រកួនខ្ចីល្ងក់ ។ នៅ កន្លែងខ្លះមានព្រលិតរំចង់ក្រជីបបញ្ចេញផ្កាប្រណាំងគ្នាយ៉ាងចម្រុះពណ៌គួរ អោយគយគន់ចាប់ភ្នែក ។ ជាងយើងអុំទុកបណ្ដើរលួចគយគន់សម្រស់នារី ដែលនៅអង្គុយចំពោះមុខបណ្ដើរ ។ យូរៗម្ដង គេលួចលេបទឹកមាត់ផ្អើម

CHANBOKEO.COM

បំពង់កដ៏ស្ងួតត្បិត ព្រោះគេរកនឹកពាក្យអ្វីនឹងមកនិយាយជាមួយធិតាមិន

បានសោះក្រៅតែភាពរំភើបក្នុងចិត្តយ៉ាងអាថិកំបាំងតែប៉ុណ្ណោះ ។ នៅរាល់ ដងដែលគេមានការសន្ទនាជាមួយអ្នកគ្រូចរណៃ

គឺមានតែមាណវីយើងទេ ដែលជាអ្នកបើកឱកាសមុន ។ បើមិនដូច្នោះទេ គឺច្បាស់ជាជាងយើងគ្មានអ្វី

មួយម៉ាត់ឆ្លើយឆ្លងជាមួយនារីយើងសោះឡើយ ។

កាលបើឃើញជាងសម្លឹងមុខពេក កល្យាណីក៏ញញឹមហើយសួរថា :

- បងជាង ចង់សួរអ្វីខ្ញុំ មែនទេ?

- អត់ទេ.. គ្រាន់តែ...គ្រាន់តែ...

- ចាំស? គ្រាន់តែ...យ៉ាងម៉េច?

ការពិត បុរសយើងកំពុងស្រម័យទៅដល់រង្វង់ភក្ត្រាយុវតីមួយរូប ដែលមានថ្ពាល់ខួច មុខញញឹម សំដីរួសរាយ ។

គេក៏ឆ្លើយឡើងថា :

- គ្រាន់តែនឹកដល់គេម្នាក់...ដែលបានបែកទៅយូរឆ្នាំហើយ...

ធិតាសម្លឹងមើលជាងដោយក្រសៃភ្នែកភ្លឺថ្លាផ្លេក១ :

- ហើយគេនោះជានរណាដែរ?

- គឺ..គឺ...គេជា...

- នរណា? សង្សារបងជាងមែនទេ?

- អត់ទេ... ការពិត គេគឺជាភរិយារបស់ខ្ញុំ...

- ភរិយា? បងជាងរៀបការរួចហើយហ្អែស?

- បាទ..!

ធិតាព្លហើយសម្តែងទឹកមុខប្លែកតែម្តង :

- ចុះម៉េចបានជាតាមេភូមិហៅបងថា ជាងកម្លោះទៅវិញ?

- គឺគាត់និយាយលលេងនឹងខ្ញុំតើហ៎ ព្រោះឃើញខ្ញុំនៅម្នាក់ឯង ។

- ហើយចុះភរិយារបស់បងនោះ គេនៅឯណាដែរសព្វថ្ងៃ បានជាបងជាង នៅតែម្នាក់ឯង?

ជាងសម្លាកទំលាក់ច្រវាចុះ ដាក់មុខជ្រប់ ហើយស្រដីខ្សិប១ថា :

- គេបែកពីខ្ញុំទៅ១០ឆ្នាំហើយ...

- ពុទ្ធោ!...

- ខ្ញុំនឹកគេណាស់...នឹករាល់ថ្ងៃ...មិនអាចបំភ្លេចគេបានទេ ហើយ...ក៏នៅ តែសង្ឃឹមរង់ចាំការវិលវិញរបស់គេជានិច្ច...

CHANBOKEO.COM

រំពេចនោះស្រាប់តែនរៈឈ្ងោកមុខសម្រក់ទឹកភ្នែកច្រោក ។ មាណវី ឃើញដូច្នោះ រន្ធត់ក្នុងចិត្តនឹកអាណិតបុរសយើងយ៉ាងណាមិនដឹង ហាក់ដូច ជាចង់ស្រក់ទឹកភ្នែកតាមបុរសយើងដែរ ។ នាងក៏ហូតក្រមាដែលខ្លួនកំពុង រុំកេសាបាំងកំដៅថ្ងៃហុចឱ្យនរៈភ្លាម :

- ឱ្យចរណៃសុំទោសផងដែលនាំបង និយាយរឿងកំសត់ៗយ៉ាងនេះ ។

មាណពទទួលក្រមាយកមកផ្ចិតទឹកភ្នែកយ៉ាងស្ងាត់ស្ងៀម ។ មួយ ស្របក់ក្រោយមកក៏ ញញឹមកម្លាចិត្តខ្លួនឡើងវិញព្រមទាំងស្រដីថា :

- ខ្ញុំក៏សូមទោសអ្នកគ្រូដែរ ដែលមិនចេះទប់ចិត្តទប់អារម្មណ៍ របស់ខ្លួន បណ្តាលឱ្យខូចបរិយាកាសអស់រលីង ។

ឃើញនាយញញឹមមកវិញ ដួងចិត្តរបស់ចរណៃហាក់ដូចជាមានធូរ ស្រាលរីករាយមកវិញដែរ ។ ភ្លាមនោះធិតាក៏ឈ្ងោកបន្ទាបខ្លួនលូកស្រវា បេះផ្ការំចង់មួយទងក្បែរនោះ ។ នាងយកដៃម្ខាងឈោងបេះ ដៃម្ខាងទៀត ច្រត់ទប់ខ្លួន តែបែរជាឃ្លោងលំនឹងទប់ខ្លួនមិនជាប់ ក៏រលំជំហរ ធ្លាក់ខ្លួនទៅ ក្នុងទឹកប្រឡងតែម្តង ។ ជាងសម្លាកក្រលេកឃើញភ្លាម ក៏ហក់ចុះរឹងរូច ហែលទៅជួយស្រង់មាណវីដាក់ទូកវិញយ៉ាងរហ័ស :

- អ្នកគ្រូមិនអីទេ? (នរៈសួរដោយក្តីបារម្ភក្នុងចិត្តចំពោះកល្យាណី)

ធិតាមិនឆ្លើយទេ ត្បិតនឹកក្នុងខ្លួនខ្មាសណាស់ កាលបើរាងកាយទទឹក ជោគអស់ ត្រូវនឹងអាវនាងស្តើងទៀត ធ្វើអោយនាងរិតតែខ្មាស់និយាយ លែងចេញ ។ម្យ៉ាងទៀត កាលបើមាណពកាន់ប៉ះរាងកាយរបស់នាងពេលជួយលើកនាងដាក់ទូកវិញដូច្នោះទៀត ចរណៃរិតតែញាប់ញ័រក្នុងចិត្តឡើង រហូតដល់រងាររណ្តំចង្កាតែម្តង ។ មាណពឃើញដូច្នោះធិតារងាញ័រមាត់ ក៏ទាញក្រមាមកលាតរុំដណ្តប់អោយនាងវិញយ៉ាងផ្ចិតផ្ចង់ រួចហើយគេងាកអង្គុយបែរទៅម្ខាង ឈ្ងោកមុខចុះមិនហ៊ានស្រដីអ្វីទេ ខ្លាចធ្វើឱ្យធិតា យើងល្អក់កករក្នុងអារម្មណ៍ ។ បន្តិចមក គេដកផ្ការំចង់មួយទងមកកាច់ជា កម្រងយ៉ាងស្អាត រួចក៏មានវាចាទៅកាន់អ្នកគ្រូយើងថា :

- បើខ្ញុំសូមបំពាក់កម្រងផ្ការំចង់មួយនេះជូនអ្នកគ្រូ តើអ្នកគ្រូទទួលយក ទេហ៏បាទ?...

ធិតាសម្លឹងមុខបុរសយើងដោយក្រសែភ្នែកភ្លឺថ្លា តែមិនឮឆ្លើយតបថា ម៉េចសោះ ។ ឃើញនាងនៅស្ងៀម ជាងសម្លាកក៏ពោលបន្តថា :

- បើអ្នកគ្រូមិនទទួល ក៏មិនអីដែរបាទ!

គេក៏ដាក់កម្រងផ្កាចុះទៅលើភ្លៅរបស់គេ ហើយលូកទាញច្រវ៉ារកអុំ ទូកត្រលប់ក្រោយវិញ ស្រាប់តែធិតាពោលឡើងថា :

- គឺ...ថា...បើបងជាងបំពាក់អោយ  ខ្ញុំសូមទទួលយកចុះណា៎ !

ជាងសម្លាកឮហើយនឹកអរភើតក្នុងចិត្តតែម្តង ។ គេក៏ដាក់ច្រវ៉ាចុះ រួច ហើយស្រវាយកកម្រងផ្ការំចង់មកបំពាក់ឱ្យធិតាដែលកំពុងឈ្ងោកកេសា អោយនាយយើងបំពាក់ ។ ទាំងពីរនាក់សម្លឹងមុខគ្នា ហើយញញឹមឡើង ។ ក្រសែភ្នែករបស់គេទាំងពីរហាក់ដូចជាកំពុងសាសងភាសាដួងចិត្តយ៉ាង សម្ងាត់មួយដែលមានជំរៅមិនអាចថ្លាថ្លែងបាន ។ ទាំងជាងសម្លាក ទាំងធិតា យើង

CHANBOKEO.COM

មានចិត្តរំភើបញ្ជាប់ញ័រចំពោះគ្នាទៅវិញទៅមកមិនខុសគ្នាឡើយ ។ មិនដឹងជាហេតុអ្វីទេ ដែលនាំអោយគេមាននិស្ស័យនឹងគ្នាយ៉ាងជិតស្និទ្ធមិន អាចបរិយាយបាន ។ ភ្លាមនោះ មាណវីក៏ពោលឡើងថា :

- បងជាងពិតជាលោកសេដ្ឋីនៅម្តុំភូមិព្រះនេត្រព្រះនេះហើយ!

- ម៉េចក៏អ្នកគ្រូមានប្រសាសន៍ដូច្នោះ បាទ? (ជាងសម្លាកសួរទាំងឆ្ងល់)

- គឺ... បងសម្បូណ៌ខ្សែរកល្អៗប្លែកៗ យកមកបំពាក់អោយខ្ញុំនោះអី ។ ថ្ងៃ មុនមួយកម្រង ថ្ងៃនេះ មួយកម្រងទៀត តើថ្ងៃស្អែកជាកម្រងអ្វីដែរទៅ ហ្ន៎? ខ្ញុំចង់ដឹងដល់ហើយ ។

ធិតាសើចខឹកៗសម្តែងភាពរីករាយក្នុងចិត្ត ។ នរៈក៏តបវិញថា :

- បើអ្នកគ្រូមិនប្រកាន់ ខ្ញុំក៏មិនខ្វះខ្សែរកស្អាតៗជូនអ្នកគ្រូដែរណ៎?

- មែនហ្អែស? អញ្ចឹង ពេលណាបងជាងមានកម្រងផ្កាស្អាតៗ កុំភ្លេចយក ផ្ញើខ្ញុំផងណ៎ ។

- បាទ! ដោយរីករាយជានិច្ច ។

គេក៏ញញឹមដាក់គ្នាឡើងម្តងទៀតជាថ្មី ។ ពេលនោះ ជាងសម្លាកមាន អារម្មណ៍ថា បេះដូងរបស់គេ បានទទួលនូវការប្រស់ព្រំពីទេវតា នូវសេចក្តី សុខមួយក្នុងចិត្តដែលគេរង់ចាំទទួលជាយូរឆ្នាំមកហើយ ។ គេអង្គុយគយ គន់ធិតាមិនដាក់ភ្នែកសោះឡើយ រហូតដល់គេអុំទូកមកដល់មាត់កំពង់ ក្បែរផ្ទះវិញ ។ ចំណែកនារីយើងវិញ ក៏មានសេចក្តីសុខក្សេមក្សាន្តក្នុងចិត្ត មិនតិចដែរកាលបើនាងបានទទួលនូវការយកចិត្តទុកដាក់ពីបុរសយើង ។

លុះមកដល់មាត់កំពង់កាលណា ជាងក៏ហក់ឡើងទៅលើច្រាំង ហើយ ហុចដៃអោយធិតាតោងកាន់ឡើងច្រាំង ។ នាងមើលមុខជាង រួចលូកដៃ ស្រវាកាន់ដៃនរៈវិញយ៉ាងណែន ទើបដើរទប់ខ្លួនឡើងច្រាំងដោយប្រយត្ន័ ខ្លាចក្រែងត្រូវធ្លាក់ទឹកសាជាថ្មី ។ កាលបើដៃទាំងគូប៉ះគ្នាទៅវិញទៅមក ភ្លាម គេក៏បានទទួលអារម្មណ៍របស់គ្នាទៅមកដែរថា ដៃរបស់គេត្រជាក់ ស្រេបដូចគ្នា ហើយក៏ញាប់ញ័រចម្លែកដូចគ្នា ។ ដោយឃើញជាងសម្លាក សម្លឹងមុខនាងមិនឈប់ ធិតានឹកខ្មាសក្នុងចិត្តណាស់ ក៏ទាញក្រមាបាំងមុខ រួចដើរឡើងច្រាំងគេចចេញទៅ ។ ជាងយើងក៏លួចញញឹមទាំងញាប់ញ័រក្នុង ចិត្តតែម្នាក់ឯង ។

- បងជាង! ពេលនេះ ព្រលប់ងងិតហើយ... ខ្ញុំទៅផ្ទះសិនហើយណ៎!

ធិតាលើកដៃបក់បោយលាមាណព ដើរចេញទៅ ។ ស្រាប់តែ :

- អូនណែ! (មាណពស្រែកហៅពីក្រោយ)

ភ្លាមនោះ ស្រាប់តែចរណៃបែរក្រោយយ៉ាងរហ័ស :

- បងជាង... ចង់មានប្រសាសន៍អ្វីមែនទេ?

ជាងសម្លាកមិនឆ្លើយទេ តែបែរជាបោះជំហានទៅជិតនាងយ៉ាងរហ័ស ហើយបន្លឺវាចាសួរនាងខ្សិបៗថា :

CHANDOKEO.COM

- សូមឆ្លើយប្រាប់បងអោយត្រង់មក ថាអូនជាអូនណៃរបស់បង!

ចរណៃបើកភ្នែកធំៗ ធ្វើមុខភាំង កាលបើឮវាចារបស់នាយដូច្នោះ ។
ជាងសម្លាកសម្លឹងកែវភ្នែករបស់នាងដោយក្រសៃភ្នែកយ៉ាងមុត ធ្វើអោយ នារីយើងរន្ធត់ក្នុងឱរាជាថ្មីទៀតហើយ ។
នាងក៏ទំលាក់មុខចុះ សម្តែងការ ចុះចាញ់អនុភាពខ្សែភ្នែករបស់មាណព ។ ស្រាប់តែនាយយើងយកដៃចាប់
ចង្កានាងភ្ញើយឡើងអោយសម្លឹងមុខនាយវិញ :

- ណៃ! មើលមុខបងហើយឆ្លើយមក ថាអូនជានារីដែលបងកំពុងរង់ចាំ! អូនឆ្លើយមក... ឆ្លើយមក...!

ប៉ុន្តែ ចរណៃបែរជាបិទភ្នែកមិនព្រមសម្លឹងនាយវិញទេ ហើយក៏មិន ព្រមតបនាយយើងវិញដែរ
ព្រោះនាងកំពុងតែរន្ធត់ញាប់ញ័រក្នុងចិត្តជាខ្លាំង មិនអាចទប់អារម្មណ៍បានក៏សុខចិត្តនៅស្ងៀមរំងាប់ដួងចិត្តដែលកំពុងរំភើប
រំជើបរំជួលនោះ ។ ទ្រាំមិនបាន ជាងសម្លាកលូកដៃស្រវាអោបចង្កេះនារីរួច ទាញខ្លួនរបស់នាងមកផ្អិបនឹងទ្រូងរបស់គេយ៉ាងណែន
បន្ទាប់មកក៏ឱនយក យកនាសាថើបថ្ពាល់ ថើបបបូរមាត់នាងយ៉ាងរហ័ស ដោយគ្មានគិតអ្វីទាំង អស់
ធ្វើឱ្យចិតាភ្ញាក់ស្រលាំងកាំងតែម្តង ដែលបុរសប្រព្រឹត្តយ៉ាងឆ្គាំឆ្គង មកលើរូបនាងដូច្នោះ ។
ឆវីក៏លូកដៃម្ខាងគក់ទ្រូងបុរសយ៉ាងខ្លាំង ហើយ យកដៃម្ខាងទៀតក្រញ៊ីមុខបុរសយើងភ្លាម ព្រមទាំងគំហកថា :

- ផ្តេសផ្តាស! នែ៎! បងជាង! លែងខ្ញុំមើស៍...!!

តែជាងមិនស្តាប់ទេ ត្បិតអីបេះដូងរបស់គេកំពុងតែត្រូវភ្លើងស្នេហ៍ដុត
រោលពេញដើមទ្រូងទៅហើយ ។ គេចាប់កាយឆវីផ្អិបនឹងខ្លួនរបស់គេរិតតែ ណែនខ្លាំងឡើង
ហើយក៏យកនាសាឈ្មុសឈ្មុលទៅលើរូបកាយរបស់នារី ទាំងកម្រោល ទោះបីចិតាយើងខំរើបំរះយ៉ាងណាក៏មិនរួចឡើយ ។ រំពេច
នោះ ស្រាប់តែកន្និដ្ឋាស្រក់ទឹកភ្នែកច្រោក យំសសឹកខ្សឹកខ្សួល ព្រមទាំង វាចាដោយសម្លេងយ៉ាងត្រជាក់ស្រែបថា :

- ណៃមិននឹកស្មានថា បុរសម្នាក់ដែលណៃធ្លាប់គោរពស្រលាញ់ពេញក្នុង បេះដូង មួយជីវិតកន្លងមក
ការពិតគឺជាមនុស្សដែលមានចិត្តប្រេតនរក បែបនេះសោះ ។ ធ្វើទៅ...ប្រព្រឹត្តទៅ...នោះណៃនឹងបានដឹងកាន់តែច្បាស់
ថាគេជាមនុស្សតិរិច្ឆានប្រាកដមែន!

កាលបើឮសំដីចិតា ដែលពោលទាំងអួលអាក់ដោយការខកចិត្តដូច្នោះ
មាណពយើងស្វាងស្មារតីរលីងធេងពីភ្លើងភ្លើតភ្លើនអំបាញមិញនេះ ។ គេក៏ ងើបមុខឡើង ព្រលែងខ្លួននាងចេញហើយជ្រួញចិញ្ចើម
ឈរធ្វើមុខស្លូត សម្តែងនូវកិរិយាប្រកបដោយវិប្បដិសារី :

- អោយបងសូមទោសផង អូនណៃ! បងភ្លេចខ្លួន វង្វេងស្មារតី ទប់ អារម្មណ៍មិនបាន! បងសូមទោសណា៎...!! បងសូមទោស!!

អ្នកគ្រូក្មេងក៏ងើបឡើងពីគ្រែ សម្លឹងមុខបុរសយើងដោយក្រសៃភ្នែក ឈឺចាប់បំផុត រួចយារដៃទះកំភ្លៀងគេមួយដៃយ៉ាងធ្ងន់
បន្ទាប់មកក៏ទាញ ក្រមារុំខ្លួនរត់ចេញទៅបាត់ ក្នុងស្បៃអន្ធការដ៏ងងិតតែម្នាក់ឯងយ៉ាងរហ័ស
ទុកអោយមាណពឈរធ្វើភាំងមួយស្របក់ ត្បិតមិនដឹងថាត្រូវធ្វើយ៉ាងណា
ដើម្បីសូមទោសចិតាអោយនាងស្រាកស្រាន្តកំហឹងនិងក្តីអាមាស ។ លុះគេ

CHANBOKEO.COM

នឹកទៅដល់សុវត្ថិភាពរបស់នាង បុរសយើងក៏ស្ទុះរឹងរត់តាមក្រោយភ្លាម ។
បន្តិចមក គេក៏រត់តាមនាងទាន់ នៅក្បែរផ្ទះសែបប៉ូលីសដែលនាងស្នាក់ នៅ ។
នរៈយើងស្រវាអោបនាងពីក្រោយហើយស្រដីប្រាប់នាងខ្សិប១ថា :
- ណែ! អោយបងសូមទោស ណា៎អូនណា៎! បងសូមទោសដែលបង ប្រព្រឹត្តមិនគប្បីទៅលើអូន...

តែធិតាយើងបែរជាស្រក់ទឹកភ្នែកខ្សឹកខ្សួលកាន់តែខ្លាំងដោយការឈឺ ចិត្ត ព្រោះនាយយើងបានប្រមាថជាន់ឈ្លីមកលើកត្តិយសនាង ដោយមិន គោរពទឹកចិត្តនាងអ្វីបន្តិច ។ ជាងសម្លាកក៏ទទូចបន្តទៅទៀតថា :
- ណែ! អូនចង់ទះកំភ្លៀងបង ចង់អោយបងលុតជង្គង់សូមទោសអូន ឬក៏ ឱ្យធ្វើអ្វីទៀតក៏បានដែរ អោយតែអូនស្រាកស្រាន្តកំហឹង.. បងនឹងធ្វើជូន អូនទាំងអស់..សូមតែអូនលើកលែងទោសអោយបងទៅ..ណា៎អូនណា៎!

តែមាណវីនៅតក់ស្លុតក្នុងចិត្តនៅឡើយ ។ ថ្វីបើជាងទទូចសូមទោស អស់ជាច្រើនម៉ាត់មកហើយ ក៏មិនទាន់អាចពន្លត់កំហឹងនិងការខកចិត្តរបស់ នាងបានឡើយ ។ ធិតាខ្ទេះដៃបុរសយើងចេញហើយឈ្ងោកមុខរត់យំខ្សឹក ខ្សួលចូលទៅក្នុងផ្ទះបាត់ទៅ....

មាណពខឹងនឹងខ្លួនឯងណាស់ ។ គេឈរក្រញឹសក់តែម្នាក់ឯងស្ទើរតែ របោចអស់ពីក្បាលទៅហើយ ក្នុងចិត្តនឹកស្ដាយចំពោះឥរិយាបថមិនថ្លៃថ្នូរ របស់ខ្លួនទៅលើចរណៃ នឹកស្ដាយដែលខ្លួនទប់អារម្មណ៍ពុះកញ្ជ្រោលនៅ ក្នុងចិត្តមិនបាន... ស្ដាយ... ស្ដាយដែលខ្លួនធ្វើអោយបាត់បង់នូវសេចក្ដីទុក ចិត្តពីសំណាក់នារីបណ្ដូលចិត្តរបស់គេ ។ តើហេតុអ្វីទៅដែលគេក្លាយខ្លួន
ទៅជាមនុស្សកំរោលដូច្នោះ កាលបើគេបានអត់ធ្មត់ សាងខ្លួនជាមនុស្សដ៏ល្អ
តាំងពីយូរមកហើយនោះ?

ពេញមួយរាត្រីហើយ.. មាណពគេងគងថ្ងាស បន្ទោសខ្លួនឯង ម្ដង ហើយម្ដងទៀត មិនឈប់ឈរ នឹកថា មិនដឹងជាត្រូវរកមធ្យោបាយណា ទើបអាចទៅសូមទោសអោយឆវីយើងរលត់កំហឹងបាន ។ ទឹកភ្នែកជាច្រើន តំណក់បានហូរប្រជែងគ្នាមកប្រលែងរង្វង់ភក្ត្ររបស់បុរសយើង ។ គេខំទប់ ចិត្តណាស់ថាជាកូនប្រុសមិនត្រូវស្រក់ទឹកភ្នែកទេ ។ គេត្រូវតែរឹងប៉ឹងជានិច្ច តែក៏គេធ្វើមិនបានសោះ ។ មួយរាត្រី ហាក់បីដូចជាមួយសតវត្ស ចំពោះរូប នាយយើងដែលកំពុងតែបន់អោយភ្លឺឆាប់ៗ នឹងអាលមានឱកាសទៅសូម ទោសចរណៃសាជាថ្មីម្ដងទៀត ។ មួយរាត្រីដ៏យូរលង់ បាននាំមកនូវ ស្រមោលអតីតកាលទាំងឡាយ មកក្រសោបបេះដូងបុរសយើងឱ្យកាន់តែ សោកសៅឡើងៗ អោយនឹកធិតាយើងឡើង នឹងរកពាក្យអ្វីមកថ្លាថ្លែង សមស្មើមិនបានឡើយ...

0000000000000000000

00000

0

CHANBOKEO.COM

# វគ្គទី៤
# ដើម្បីបងស្រី

ឃុំព្រះនេត្រព្រះ ថ្ងៃចូលឆ្នាំខ្មែរ ឆ្នាំ១៩៤៨...

នៅវត្តព្រះនេត្រព្រះក្រោម គេមានប្រារព្ធបុណ្យចូលឆ្នាំអធិកអធម្ម ណាស់ ថែមទាំងមាន ការលេងល្បែងប្រជាប្រិយ និងការសម្តែងល្ខោន យីកេទៀតផង ។ ចៃដន្យ តាមាំងបានក្លាយខ្លួនទៅជាពិការអាមណាម មិន អាចដើរទៅណាមកណាឆ្ងាយផ្ទះបានឡើយ ហើយកិច្ចការរោងជាងក៏ត្រូវ ទុកចោលមួយអន្លើ ។ មីងនួនសំរេចយកបាយទៅវត្តហើយប្រញាប់ត្រលប់ មកផ្ទះវិញ ដើម្បីអោយកូនស្រីរបស់គាត់ទាំងពីរនាក់អាចទៅលេងបុណ្យង វត្តហ្នឹងគេ ។ ម្យ៉ាងទៀត គាត់បានសង្កេតឃើញកងណៃរសើបជើងណាស់ ចង់ទៅវត្តលេងឈូង ត្បិតធិតាចូលចិត្តច្រៀងផ្តោះផ្តងបង្អាប់កម្លោះៗនៅ ក្នុងភូមិណាស់ ។ នរណាក៏ស្គាល់ថ្វីដៃរបស់ធិតាតូចយើងដែរ ។ ព្រឹកនេះ នាងតុបតែងខ្លួនយ៉ាងស្រស់ស្អាតមិនចាញ់បងស្រីក្រមុំរបស់នាងទេ ថ្វីបើ នាងនៅជាក្មេងស្រីជំទង់មិនទាន់ពេញវ័យនៅឡើង ។ មើលទៅរូបរាងនិង កំពស់កំព នាងខ្ពស់ជាងបងស្រីច្រើនណាស់ហើយក៏រូសរាយណាស់ដែរ មិន ដូចបងនាងទេ ដែលសុភាពស្ងាត់ស្ងៀម ញឹមៗ ស្រដីមួយម៉ាត់បានការ ។

នៅកណ្តាលទីធ្លាវត្ត ក្រមុំកម្លោះជាច្រើន កំពុងលេងឈូងស្រែក ច្រៀងផ្តោះផ្តងគ្នាយ៉ាងសប្បាយ ។ កងណៃនិងបងស្រីនាងក៏ស្ថិតនៅក្នុង ចំណោមនោះដែរ ។ រំពេចនោះ កងណាវយកដៃកេះប្អូនហើយសួរថា :

- អូនណៃ! ម៉េចមិនឃើញបងខ្នាមកលេងបុណ្យនឹងគេថ្ងៃនេះ?
- ណៃអត់ដឹងទេបងណាវ! ប្រហែលគាត់ទៅលេងនៅវត្តផ្សេងក្រៅភូមិ យើងទេដឹង?

ពេលនោះ កងណាវរអ៊ូឡើងថា :

- គួរអោយស្តាយណាស់ បើសិនជាគាត់ទៅលេងបុណ្យនៅភូមិក្រៅ មិន ចូលរួមជាមួយអ្នកភូមិរបស់យើនេះ ។
- កុំទៅស្តាយអីបង! អ្នកភូមិដែលមិត្តយើងដទៃទៀតមានអោយគរគោក ចាំបាច់អីទៅចាំមើលផ្លូវគាត់មួយហ្នឹង?

ថាហើយកងណៃស្ទុះត្រលប់ចូលទៅលេងឈូងវិញតែកងណាវបែរជា បាត់សប្បាយរលីង កាលបើមិនឃើញនាយខ្នាមកលេងបុណ្យអ្វីហ្នឹងគេ ។ មួយស្របក់ក្រោយមក នាងក៏អូសប្អូនស្រីមកខ្សិប :

- អូនណៃ! បងពឹងអីបន្តិចបានទេ?
- មានការអីទៅបង?
- គឺ ប្អូនទៅតាមរកបងខ្នាបន្តិចមើល៍ តើគាត់មានរឿងអីបានជាមិនមកធ្វើ បុណ្យចូលឆ្នាំនឹងគេ?

CHANDBOKEO.COM

- បងខ្នាជាមនុស្សស្ងៀមស្ងាត់ ប្រហែលជាគាត់មិនចូលចិត្តភាពអ៊ូអរទេ ដឹង បានជាមិនមក...
ហើយម៉េចក៏បងមិនទៅតាមរកគាត់ខ្លួនឯង?

- យី! ប្អូនស្រី វៀនមានចិត្តកំណាញ់នឹងបងតាំងពីអង្កាល់ហ្នឹង? ណេះ ជួយ ទៅតាមហៅបងខ្នាបន្តិចមកណា៎!

- ពុទ្ធោអើយ! ប្រើណៃបែបនេះ ណៃខានលេងឈ្លូងអស់!

កងណៃរអ៊ូផង ដើបដើរចេញពីវត្តទៅផង ដើម្បីតាមរកនាយខ្នាតាម ដែលបញ្ជាបងស្រី។ បន្តិចក្រោយមក នាងតូចបានមកដល់ផ្ទះនាយខ្នា រួចក៏ប្រទះនាយនៅអង្គុយសំកុកក្នុងអង្រឹង លើរានហាលខាងមុខផ្ទះតែ ម្នាក់ឯង :

- បងខ្នា!

នាយខ្នាឮសម្លេងស្រែកហៅក៏បែរមើល ស្រាប់តែប្រទះនឹងធិតាយើង ស្លៀកអន្លូញជាមួយអាវប៉ាក់ពណិស៊ីជំពូ ធ្វើអោយបុរសយើងសម្លឹង ឡើង ភ្លឹក ស្ទើរតែភ្លេចដកដង្ហើមតែម្តង។

- បងខ្នា!...អង្គុយងក់លក់ក្នុងឬ បានជាធ្វើធ្មឹង មិនឮខ្ញុំហៅ?

បុរសយើងភ្ញាក់ព្រើត យកដៃញីភ្នែក :

- ពុទ្ធោអើយ! អូនណៃ! តែងខ្លួនដូច្នោះទៅស្រស់ស្អាតដូចស្រីក្រមុំតែម្តង ធ្វើអោយបងមើលអូនលែងស្គាល់!!

កងណៃសើចខឹកៗកាលបើឮសំដីនាយយើងដូច្នោះ :

- ណៃមិនស៊ីជោរទេ បងខ្នាអើយ! ទុកពាក្យហ្នឹងទៅសរសើរសង្សារបង វិញទៅ?

- ហ្អាស់? ថាម៉េច? នរណាជាសង្សារបងនោះ?

- សង្សារបងនោះ គឺ...

កងណៃទុចង៉ក់ ហើយក៏ពោលបន្ទប់វិញថា :

- បើចង់ដឹងទៅវត្តទៅ... គាត់កំពុងនៅចាំបងឯណោះ...

- ចេះតែថាហើយអូនណៃ! បងមានសង្សារពីអង្កាល់?

- ម៉េចក៏ថាអត់?

- មែនណា៎! អ្នកក្រ រូបអាក្រក់ដូចបងនេះ តើនរណាគេមកបេតីនោះ?

- ហែស់! អោយតែស្រលាញ់ គេមិនមើលពីទ្រព្យសម្បត្តិឬក៏រូបកាយក្រៅ របស់បងទេ បងខ្នាអើយ...គឺគេមើលចិត្តបងតើហ៎!

- យីអើ! កូនក្មេងស្អី ចេះដឹងរាក់ជ្រៅរឿងមនុស្សចាស់ម្ល៉េះហ្ន៎?

- អត់ដឹងទេ គ្រាន់តែធ្លាប់ឮចាស់ៗ គេនិយាយអញ្ចឹង។

ថាហើយកងណៃសើចកក្អឹកៗកាលបើបានលលេងនាយខ្នា។ បន្តិចមក ធិតាក៏តឿនមួយសាទៀត :

- បងខ្នា! ទៅផ្លាស់ខោអាវមក ទៅវត្ត!

- បងមិនទៅទេ អូនណៃ!

- ហេតុអីមិនទៅ?

CHANBOKEO.COM

- គឺបង...មិនសូវសប្បាយក្នុងចិត្តនោះអី? (ខ្នានិយាយទាំងទឹកមុខស្ងួត)

- អូហ៎? បងខ្នាកំពុងមានរឿងអីហ្នឹង?

- គឺ..បងនឹកពុក.. ចង់ទៅលេងគាត់ណាស់ តែគ្មានសោហ៊ុយ

- ពុទ្ធោ!... ហើយបើណែជួយរកលុយអោយបងបាន បងពិតជាសប្បាយ ចិត្តមែនហ្មែស?

- មែនហើយ!

- ហើយបើសប្បាយចិត្តពិតមែន តើបងអាចទៅលេងឈូងនៅវត្តជាមួយ ណែបានទេថ្ងៃនេះ?

- អញ្ចឹងអូនណែប្រាប់បងសិនមកថាអូនអាចជួយបងបែបណា?

- គឺ..មិនប្រាប់ទេ សូមអោយតែបងដឹងថា អូនណែយកប្រាក់មកឱ្យបង ធ្វើដំណើរទៅក្រឡាញ់គ្រប់ចំនួនសំរាប់ទៅមក។

យុវជនយើងក៏ញញឹមឡើងហើយពោលបន្តថា :

- សូមអោយតែអូនណែជួយបងដោយវិធីសុចរិតណាអូន។

ស្រាប់តែកងណែក្ដិចកំភួនដៃនាយខ្នាលាន់ប៉ាត់ :

- អីក៏ហ៊ាននិយាយមើលងាយណែម្ល៉េះ? ឃើញណែជាមនុស្សអាក្រក់តាំង ពីអង្កាល់? ស្អប់មែន!

- អីយ៉ូយ! ស្រាំងនេះទិចឈឺម្ល៉េះ? គ្រាន់តែនិយាយលេងក៏មិនបានដែរ។

- មិនអោយលេងទេ...កាលបើមាក់ងាយទឹកចិត្តរបស់ណែយ៉ាងនេះ ណែ ឈប់និយាយរកបងហើយ។

ថាហើយនាងងរប៉េវ ដើររឹងចុះជណ្ដើរទៅដីវិញយ៉ាងលឿន។ នាយ យើងឃើញដូច្នោះ ក៏ស្ទុះងើបពីអង្រឹងទៅចាប់ដៃនាងជាប់ :

- បងសូមទោសណាអូនណែ! កុំខឹងអី!

ធិតាតូចបេះដៃនាយចេញ :

- បើចង់អោយណែឈប់ខឹង ទាល់តែបងទៅវត្តជាមួយខ្ញុំឥលូវនេះ!

ខ្នាសម្លឹងមុខនាងហើយនិយាយលួងចិត្តធិតាដោយវាចាយ៉ាងស្រទន់ ទៅកាន់នាងថា :

- បាទ! បងនឹងទៅវត្តជាមួយអូនណែឥលូវនេះ ឈប់ខឹងងរង៉ក់ទៅស្រីតូច របស់បង!

នាយយើងយកដៃបបោសកេសានាងថ្នមៗ លួងចិត្តនាង ហើយក៏ស្ទុះ ទៅផ្លាស់ខោអាវយ៉ាងរហ័ស។ បន្ទាប់មក នាយអូសដៃកងណែ ដើរសំដៅ ទៅវត្តភ្លាមដែរ។ ដើរចេញផុតពីផ្ទះមិនបានប៉ុន្មានផង ស្រាប់តែកងណែ ដាច់ស្បែកជើងម្ខាង :

- យ៉ាប់មែន! ដាច់ថ្ងៃមិនដាច់ បែរជាមកដាច់ថ្ងៃនេះទៅវិញ!

កងណែរអ៊ូ។ ពេលនោះ នាយខ្នាស្រដីថា :

- អូនណែពាក់ស្បែកជើងបងសិនទៅ បងដើរជើងទទេក៏បានដែរ។

- មិនទេ ស្បែកជើងរបស់បងធំប៉ុនទូក ពាក់ទៅ ល្អមើលស្លាប់ហើយ។

- តែបើមិនពាក់ទេ អូនណែច្បាស់ជារលាកពងជើងហើយ ព្រោះដើរជើង ទទេលើដីខ្សាច់ផ្លូវកណ្ដាលថ្ងៃក្ដៅ...

CHANDOKEO.COM

- តែណៃមិនពាក់ស្បែកជើងធំក្រមាងរបស់បងទេ។

- អញ្ចឹងបងមានមធ្យោបាយហើយ អូនចាំបងនៅក្រោមម្លប់ឈើនេះទៅ បន្តិចទៀតបងមកវិញ។ កុំទៅណាំព្វនៅ!!

- ចាំស!

នាយខ្នារត់ទៅផ្ទះមួយស្របក់ក៏ត្រលប់មកវិញ យកស្បែកជើងមួយគូ មកបំពាក់អោយធិតា :

- អូនណៃពាក់វាមើល ល្មមហើយនៅ?

តរុណីយកជើងស៊កស្រាប់តែត្រូវល្មម ក៏សួរថា :

- បងបានស្បែកជើងពីណាហ្នឹង អីក៏ពណ៌ដូចគ្នាហ្នឹងស្បែកជើងបងអំបាញ មិញនោះម្ល៉េះ?

- គឺស្បែកជើងរបស់បងដដែលនោះអី។ គឺបងយកវាទៅច្បេរចេញអោយ តូច ដើម្បីអោយអូនណៃពាក់នោះអី។

- អូហ៍ បងខ្នាប្រសព្វមែនហ្ន៎ ហើយចុះបងបានអីពាក់?

- មិនអីទេ បងដើរជើងទទេក៏បានដែរ។

ឃើញនរៈមានសមានចិត្តចំពោះនាង ធិតានឹករំភើបចិត្តតែម្តង :

- អរគុណបងខ្នា!

បន្តិចមក នាងក៏ដឹកដៃនាយខ្នារហូតដល់វត្ត សំដែងនូវការរីករាយ ដែលបុរសយើងព្រមមកជាមួយ ត្បិតដឹងថា បងស្រីនាងច្បាស់ជាសប្បាយ ចិត្តណាស់កាលបើនាយខ្នាបានមកលេងបុណ្យនៅវត្តនឹងគេ។ មែនហើយ ថ្ងៃនោះ គេទាំងបីនាក់សប្បាយរីករាយក្រៃលែង ដែលបានលេងល្បែង ប្រពៃណីជុំគ្នា ថែមទាំងបាននៅមើលការសំដែងយីកេរឿងខ្យងសង្ខ័រហូត ដល់ចប់ទៀតផង។ ពេលនោះ គ្មាននរណាដឹងទេ ថាក្នុងជំរៅចិត្តម្នាក់ៗ គេគិតយ៉ាងណាខ្លះ គ្រាន់តែឃើញថា គេរីករាយហើយសម្តែងភាពស្និទ្ធ ស្នាលចំពោះគ្នាយ៉ាងរមនាក្រៃលែង។

ព្រហាមស្រាងៗ ថ្ងៃបន្ទាប់...

កងណាវនឹកឆ្ងល់ក្នុងចិត្តណាស់ ដែលឃើញប្អូនស្រីរបស់នាងក្រោកពី ព្រហាម ខុសទម្លាប់របស់នាង។ ធិតាក៏ក្រោកឡើង លួចតាមមើលនាង ថាតើនាងកំពុងធ្វើអ្វីដែរ។ កងណៃមិនបានដឹងខ្លួនទេ។ នាងចេះតែធ្វើអ្វីៗ តាមតែនឹកឃើញប៉ុណ្ណោះ។ លុះមកដល់ទ្រុងមាន់ក្រោយផ្ទះ នាងក៏ស្រវា មាន់ចាប់ចងជើងចំនួនបួនប្រាំ ហើយក៏ស្រវាកង់របស់បងស្រី ធាក់សំដៅ ទៅផ្សារក្នុងភូមិ ទុកអោយកងណាវឈរមើលតាមបង្អួចទៅទាំងចិត្តងឿង ឆ្ងល់។ បន្តិចមក នាងតូចក៏បានមកដល់ផ្ទះនាយខ្នា ឃើញនាយកំពុងតែ រែកទឹកដាក់ពាង :

- បងខ្នា! នេះសោហ៊ុយ សំរាប់ទៅលេងពុកបងនៅក្រឡាញ់!

- អរគុណ! គឺបងខ្ចីសិនទេ ចាំថ្ងៃណាបងរកបាន បងនឹងសងអូនវិញ។

- មិនបាច់សងទេ អូនណៃជូនបងចុះ។

- ហើយអូនទៅបានប្រាក់ពីណាមកហ្នឹង?

CHANBOKEO.COM

- ប្រាក់បរិសុទ្ធទេ មិនមានលួចគេទេណាំបង! សូមបងខ្មាទៅលេងពុកបង អោយបានសប្បាយចុះ ហើយពេលមកវិញ កុំភ្លេចទិញក្រឡានធ្មើរណៃញុំា ផងណាំបង!

ថាហើយនាងក៏ធាក់កង់ចេញត្រលប់ទៅវិញ ។ មាណពឈរកាន់ប្រាក់ ជាប់នឹងដៃ ក្នុងចិត្តនឹកពិភាល់យ៉ាងណាមិនដឹងទេ ។ មិនអស់ចិត្ត នាយក៏ ដើរសំដៅទៅផ្ទះកងណែពីក្រោយភ្លាមដែរ ។

គ្រាន់តែកងណែមកដល់មុខផ្ទះ ស្រាប់តែនាងប្រទះមីងនួននិងបងស្រី របស់នាងនៅឈរចាំមុខផ្ទះជាស្រេច ហាក់ដូចជាចង់ឈ្លេចសួរនាងរឿងអ្វី:

- ម៉ែ! បងណារ៍ !

មីងនួនស្រវាកងណែអោយចុះពីកង់ហើយទាញរំពាត់យកមកគំរាម នាងថា :

- មើលនាងណែ! កូនទើបមកពីណាទាំងព្រហាម?

- គឺ...គឺ...មកពីផ្សារ...ម៉ែ...!

- ហើយទៅផ្សារធ្វើអ្វី?

- គឺ...គឺ...

ធិតាមិនហ៊ាននិយាយទេ ថានាងយកមាន់ទៅលក់ ទើបពោលតបវិញ ទាំងតតាក់តតុបយ៉ាងនេះ ។ មីងនួនក៏សំលុតថែមទៀត :

- ឆ្លើយមក ថាកូនកំពុងលួចមាន់ទៅលក់...

- ចាំស..គឺកូនចាប់មាន់ទៅលក់មែន តែមិនបានលួចទេ..

- បើមិនលួច..ម៉េចក៏កូនមិនសុំម៉ែ? ហើយឯងត្រូវការយកលុយទៅណាំ?

- ព្រោះ...កូនគិតថា មួយសំបុកនោះជាមាន់របស់កូន ព្រោះកូនបានចិញ្ចឹម វាមកតាំងយូរហើយ...ហើយកូនមិនបានយកលុយទៅណាទេ... គឺយកទៅ ធ្វើបុណ្យចំពោះអ្នកខ្វះខាតម្នាក់ដែលជាញាតិជិតខាងរបស់យើង...

- ព្រហើន! ថ្ងៃនេះម៉ែត្រូវវាយកូនហើយ កុំអោយកូនលួចធ្វើអីមិនប្រាប់ ម៉ែដូច្នេះទៀត ។ ឆាប់ដាក់ដៃមក៏!

កងណែលាតដៃទាំងពីរឡើង ។ មីងនួនរលាស់រំពាត់ផ្តៅខ្វាប់ៗទៅលើ សាច់ដៃដ៏ខ្ចីរបស់នាង :

- នេះជាមេរៀនណាំកូន! ថ្ងៃក្រោយកុំធ្វើដូច្នេះទៀត ។

ថាហើយ គាត់ក៏បោះរំពាត់ចោល ហើយដើរចេញទៅ ។ កងណែឱន ឈ្ងោកមើលស្នាមឈាម ដែលហូររឹមលើបាតដៃ ដោយសាររងរំពាត់ផ្តៅពី មីងនួន ។ នាងឈឺខ្លាំងណាស់ តែនាងបែរជាខំមាត់លេបទឹកភ្នែកទៅវិញ ។ ពេលនោះ ឆវីនឹកខកចិត្តក្រៃលែង ចំពោះបងស្រីរបស់នាងដែលបានទៅ ប្រាប់ម្តាយថានាងលួចមាន់លក់ ។ ការពិត អ្វីដែលនាងធ្វើ គឺដើម្បីបងស្រី របស់នាងទាំងអស់ តែហេតុអ្វី បងស្រីរបស់នាងបែរជានាំម្តាយមកដាក់ ទោសនាងទៅវិញ? ធិតាងើបមើលមុខបងស្រី សម្លក់នាងដោយកំហឹង ព្រមទាំងស្រែកគំហកអោយនាងថា :

CHANBOKEO.COM

- ពីថ្ងៃនេះទៅ... បងណាវមិនបាច់ពឹងខ្ញុំរឿងអ្វីទេ..ខ្ញុំឈប់ជួយបងហើយ!

កងណៃរត់ចូលទៅក្នុងបន្ទប់ ក្រាបមុខលើខ្នើយយំខ្សឹកខ្សួលតែម្នាក់ ឯង ។ ចំណែកកងណាវវិញ កាលបើឃើញប្អូនត្រូវរំពាត់ក៏ហាក់ដូចជានឹក ស្តាយក្រោយណាស់ ដែលខ្លួនបានទៅជំរាបម្តាយថាកងណៃលួចយកមាន់ ទៅលក់ ។ បើសិនដឹងមុនថាកងណៃនឹងត្រូវរំពាត់ឈាមដៃ ម្ល៉េះសមនាង បិទមាត់ឱ្យជិតទៅហើយ មិនឱ្យប្អូនត្រូវរំពាត់ដោយសារមាន់បីបួនក្បាល នោះឡើយ ថ្វីបើនាងមិនទាន់មិនដឹងថាកងណៃលក់មាន់ដើម្បីអ្វីក៏ដោយ ។ រំពេចនោះ នាយខ្នាក៏បានដើរមកដល់ :

- ណាវ! បងសុំផ្ញើប្រាក់នេះអោយទៅអូនណៃផង ។

- ប្រាក់ស្អីហ្នឹង បងខ្នា?

- គឺអូនណៃមកបបួលបងឱ្យទៅលេងវត្តកាលពីម្សិល ដោយសន្យាថានឹង
អោយប្រាក់បងខ្ចីធ្វើសោហ៊ុយធ្វើដំណើរទៅលេងពុកបងនៅក្រឡាញ់ រួច មុននេះបន្តិច នាងបានយកប្រាក់មកអោយបងមែន តែបងគិតថា បងមាន
នៅសល់ខ្លះដែរ ទើបយកប្រាក់នេះមកសងអូនណៃវិញ ។

យុវជនយើងស្រដីចប់ ក៏ហុចប្រាក់មួយរមូរអោយទៅកងណាវវិញ
ថែមទាំងផ្តាំជាចុងក្រោយថា :

- ផ្តាំទៅអូនណៃផង ថាបងអរគុណណាស់ នូវទឹកចិត្តដ៏ល្អរបស់ប្អូន ។

បន្ទាប់មកនាយខ្នាក៏បែរក្រោយដើរសំដៅទៅផ្ទះរបស់នាយវិញ ទុក អោយកងណាវឈរទ្រឹង លេបទឹកភ្នែករលីងរលោង ។ ពេលនេះនាងយល់ ហើយថាហេតុអ្វីប្អូនស្រីរបស់នាងចាប់មាន់លក់...ប៉ុន្តែគួរអោយស្តាយ ខ្លួន
បែរជាធ្វើអោយប្អូនត្រូវរំពាត់ឈឺខ្លួនទៅវិញ ។ បន្តិចមក នាងក៏ចូលទៅក្នុង បន្ទប់ ហៅប្អូនស្រី :

- ណៃ! ឱ្យបងសុំទោសណាំដែលបងគិតច្រឡំពីប្អូន...ឯណាដៃ..ហុចមក នេះ៎ ចាំបងលាបថ្នាំអោយ...

តែកងណៃនៅតែយំ មិនព្រមនិយាយរកនាងវិញទេ ថែមទាំងយកដៃ លាក់បាត់ទៅក្រោមខ្នើយមិនអោយបងស្រីប៉ះផង ។ កងណៃឃើញដូច្នោះ ក៏និយាយសាជាថ្មី ទាំងអួលអាក់ក្នុងចិត្ត :

- ណៃ! អូនដឹងទេ ថាពេលអូនត្រូវរំពាត់ឈឺ បងក៏ទទួលការឈឺចាប់ក្នុង បេះដូងរបស់បងដូចគ្នាដែរ ។ ពេលនោះ
បងដឹងហើយថាបងគិតខុស ធ្វើ ខុស... បណ្តាលអោយប្អូនស្រីរបស់បងឈឺខ្លួន ដោយមិនសមហេតុផល ។
សូមអូនអភ័យទោសអោយបងទៅណាំ... បងពិតជាខុសមែន! ម៉ោះ!.. អោយដៃមក់! បងលាបដៃអោយប្អូនណាំ...

កងណៃងើបមុខឡើងបែរមើលបងស្រី ឃើញកងណាវមានស្នាមទឹក
ភ្នែកដក់នៅលើថ្ពាល់ក៏នឹករំជួលចិត្តតែម្តង :

- បងណាវ...!

កងណាវក៏ស្រដីបន្តទៅទៀតថា :

CHANBOKEO.COM

- បងស្រលាញ់អូនណែណាស់ ព្រោះប្អូនរបស់បងជាមនុស្សល្អ...! បងសូម អរគុណដែលអូនមានទឹកចិត្តចំពោះបងនិងចំពោះបងខ្នា គឺបងទេដែលខុស ព្រោះបងគិតមិនដល់..អភ័យទោសអោយបងផងណាំប្អូនស្រីសម្លាញ់បង!

កងណែរំភើបចិត្តណាស់កាលបើឮសំដីបងស្រីដូច្នោះ ។ នាងក៏ស្ទុះងើប ឡើងស្រវាអោបបងស្រីវិញយ៉ាងណែន ។ បន្តិចមក កងណាវក៏យកថ្នាំមក លាបស្នាមរបួសអោយប្អូន :

- បងសន្យាណាំអូនណាវ...មិនអោយប្អូនត្រូវឈឺខ្លួន ឬឈឺចិត្តដោយសារ បងជាលើកទីពីរទៀតទេ ក្នុងមួយជីវិតបងចាប់ពីថ្ងៃនេះតទៅ!!

កាលបើបានទទួលការថ្នាក់ថ្នមពីបងស្រីរបស់ខ្លួន នាងតូចកងណែក៏ បាត់ឈឺអស់រលីង ។ នាងក៏យកដៃជូតទឹកភ្នែក ហើយញញឹមឡើងវិញ ហើយលូកដៃស្រវាអោបបងស្រី ដោយសេចក្ដីស្រលាញ់យ៉ាងជ្រាលជ្រៅ ក្នុងចិត្ត ។ រំពេចនោះ ស្រាប់តែនាងដាក់ភ្នែកទៅមាត់ទ្វារ ឃើញឪពុកនាង ឈរទប់ខ្លួននឹងឈើច្រត់ក្បែរម្ដាយរបស់នាងកំពុងសម្លឹងមកអ្នកទាំងពីរ :

- ពុក! ម៉ែ!

អ្នកទាំងពីរបែរក្រោយងើបទទួលឪពុកម្ដាយភ្លាម ។ កងណាវឃើញ ឪពុកធ្វើមុខមាំ ក៏សួរទាំងញញើតញញើមថា :

- ពុកមានការអ្វីត្រូវប្រើណាវឬចាំស?

- មិនមានទេ! (តាមាំងឆ្លើយ) គឺពុកចង់មកសួរថាតើហេតុអ្វីកូនណែលួច ចាប់មាន់ទៅលក់...?

កងណែបែរមើលទៅបងស្រីហើយឆ្លើយរតាក់រតុបថា :

- គឺខ្ញុំដាច់ស្បែកជើងកាលពីម្សិល... ចង់ទិញស្បែកជើងថ្មី..ហើយមិនហ៊ាន សុំលុយពុកម៉ែ...ទើប..

- កុហក! ហើយចុះអាខ្នាវាមកទីនេះព្រឹកមិញ ហុចលុយអោយនាងណាវ នោះជាលុយអ្វីដែរ?

តាមាំងគំហកកាត់ ។ ឃើញស្ថានការណ៍កាន់តែធ្ងន់ធ្ងរ កងណាវលែង ហ៊ានភូតភរតទៅទៀត ព្រោះខ្លាចប្អូនស្រីត្រូវរំពាត់រិតតែច្រើនក៏សារភាព តាមត្រង់ថា :

- កូនសូមទោសពុកជំនួសអូនណែផង...ការពិតជាកំហុសរបស់កូនទេ..

- ហ្អាស? ហេតុអ្វីក៏ដូច្នោះទៅវិញ កូនណាវ?

កងណាវក៏រៀបរាប់ជំរាបឪពុកតាមដំណើររឿង ។ បន្តិចក្រោយមក តាមាំងក៏ដកដង្ហើមធំ សួរថា :

- ហើយចុះអាខ្នាវាធ្វើការអ្វីដែរសព្វថ្ងៃនេះ?

- គឺ..គាត់ធ្វើស្រែ តែឆ្នាំកន្លងទៅនេះមិនបានធ្វើទេ ព្រោះអាល័យតែមាន ជំងឺគ្រុនចាញ់ ទើបតែត្រូវព្រះគ្រូឧត្តរះនាំគ្រូមកព្យាបាលជាថ្មីៗនេះឯង ។ ឮថាគាត់នឹងចូលបួសក្នុងវស្សាខាងមុខនេះ ។

តាមាំងគ្រវីក្បាល ស្រដីទៅកូនថា :

- កូនណែ! ឯងឃើញពុកនិងម៉ែជាមនុស្សចិត្តអាក្រក់តាំងពីអង្កាល់បានជា កូនមិនហ៊ានជំរាបសុំពុកម៉ែរឿងតូចតាចប៉ុណ្ណឹង? ការពិតបើកូនសុំពុកម៉ែ នោះពុកម៉ែច្បាស់ជាអោយលុយកូនទៅជួយអាខ្នាបាត់ទៅហើយមិនពិបាក

CHANBOKEO . COM

អោយឯងទៅលួចចាប់មាន់លក់ទេ ។

កងណៃឈ្ងោកមុខឆ្លើយវិញខ្សិបៗថា :

- មកពីកូនខ្លាចចិត្តពុក...មិនហ៊ានរំខាន ព្រោះពុកឈឺយូរខានធ្វើការយូរ

ហើយ..ក៏សុខចិត្តដោះស្រាយតាមបែបដែលកូនធ្វើបានទៅ ។

- ខុសលើកនេះ ពុកលើកលែងទោសអោយកូនចុះ តែលើកក្រោយកុំរៀន ធ្វើដូច្នោះទៀតណាំកូន! មានការអ្វី

ត្រូវរៀនពិគ្រោះនឹងចាស់ទុំ កុំចេះតែ ខ្លាចៗ ហើយក៏ចេះតែប្រព្រឹត្តខុសទៅនេះទេ ឮហើយនៅ ?

- ចាំសពុក!

- បើអញ្ចឹង ទៅហៅអាខ្នាអោយពុកបន្តិចមក!

កងណៃបែរមើលមុខបងស្រីសម្តែងការងឿងឆ្ងល់ក្នុងចិត្តតែមិនហ៊ាន ប្រកែកអ្វីដែរ ។ នាងក៏ឡើងធាក់កង់ចេញទៅ ។ មួយសន្ទុះក្រោយមក នរៈ ក៏បានឌុបកងណៃត្រលប់មកដល់ដីភូមិលំនៅរបស់តាមាំងវិញ ។ កាលបើ ឃើញវត្តមានរបស់នាយហើយ តាមាំងក៏សួរថា :

- អាខ្នា! បើពូសុំអោយឯងជួយពូខ្លះតើបានទេហ៎?

- បាទ! អោយតែខ្ញុំអាចធ្វើបាន ខ្ញុំនឹងជួយទាំងអស់!

- គឺយើងមានជំងឺពិការ ចោលរោងដែកយូរហើយ ។ យើងចង់បង្រៀនឯង អោយធ្វើការ

ក្រែងនឹងមានមុខរបរអ្វីនឹងគេទៅអនាគត ។ តើឯងចង់ធ្វើ

ការជាជាងដែកទេ?

- បាទពូ! ជាងដែក ជាងឈើ ឬជាងអ្វីក៏បានដែរ អោយតែមានការធ្វើ ខ្នាធ្វើទាំងអស់បាទ ។

- ប្រសើរណាស់ យើងក៏គ្មានកូនប្រុសនឹងទទួលការហ្វឹកហ្វឺននេះដែរ ដូច នេះ យើងសុំចែកចំណេះនេះអោយឯងចុះ!

នាយខ្នាក៏លុតជង្គង់ លើកដៃសំពះតាមាំង :

- ក្មួយសូមអរគុណចំពោះទឹកចិត្តដ៏ថ្លៃថ្លានេះណាស់!!

កងណៃនិងកងណាវក៏ចាប់ដៃគ្នាញញឹមឡើង ដោយឃើញឪពុករបស់ គេមានមេត្តាធមិចំពោះនាយខ្នាដូច្នោះ ។ ចាប់តាំងពីថ្ងៃនោះមក នាយខ្នាក៏ ត្រូវមកហ្វឹកហ្វឺនកិច្ចការនៅក្នុងរោងដែក ដោយមានតាមាំងជាអ្នកណែនាំយ៉ាងហ្មត់ចត់ក្រៃលែង ។ នាយយើងបានខំប្រឹងប្រែងយ៉ាងអស់សមត្ថភាព ដោយមិនត្អូញត្អែរឡើយ ។ ម្យ៉ាងទៀត ភាពកក់ក្តៅនៅក្នុងក្រុមគ្រួសារ របស់តាមាំងនិងមេត្តាធមិរបស់ចាស់ៗទាំងពីររូប បានធ្វើអោយរូបគេមាន អារម្មណ៍ថាជីវិតរបស់គេមានសេចក្តីសុខជាងមុនឆ្ងាយណាស់ ។

ចំណែកកងណៃនិងកងណាវ ក៏រឹតតែមានឱកាសឃើញមុខនាយខ្នា ញឹកញាប់ណាស់ដែរ ។ ថ្វីបើកងណាវមិនសូវហ៊ាននិយាយស្តីអ្វីជាមួយនឹង នាយខ្នាច្រើន ព្រោះនាងមានចរិតកិរិយាក្នុងក្របខណ្ឌជាស្រីក្រមុំតែនាងក៏ លួចជួយលើកទឹកចិត្តនាយស្ងាត់ៗតាមរយៈប្អូនស្រីរបស់នាង ដែលចូលចិត្ត ញ៉ិកញ៉ុកនឹងនាយខ្នាយ៉ាងស្និទ្ធស្នាល

CHANBOKEO . COM

ធ្វើឱ្យមាណពមានចិត្តរីករាយជានិច្ច ។ ចំពោះនាយខ្នាវិញ ពិតមែនតែកងណាវជានារីសុភាពស្រគត់ស្រគំ ប៉ុន្តែគេបែរជារាប់រកនាងជាញាតិប៉ុណ្ណោះ ។ ចំពោះកងណៃវិញដែលមានសំដីរួស រាយ មានប្រាជ្ញាឈ្លាសវៃ ធ្វើការរហ័សរហួន ហើយកំប្លែងលេងច្រើនបន្តិច នាយបែរជាមានអារម្មណ៍គិតផ្ដេសផ្ដាសក្នុងចិត្តទៅវិញ ។ ទោះបីគេខំហាមចិត្តរបស់គេណាស់ថាមិនលួចពេញចិត្តនឹងក្មេងស្រីម្នាក់នេះក៏ដោយ ក៏គេ មិនអាចហាមឃាត់អារម្មណ៍របស់គេមិនអោយសុបិនឃើញធិតានោះបាន ឡើយ ។ គ្រាន់តែស្នាមខួចញញឹមនៅលើផ្ទៃមុខរបស់ធិតាតូច ក៏ជាឱសថ យ៉ាងសក្តិសិទ្ធបំផុតដែលធ្វើអោយនាយខ្នាធ្វើការបំរើតាមាំងដោយមិន នឿយហត់អស់កម្លាំងឡើយ ។ ឥរិយាបថរបស់យុវជនយើងមិនបានលាក់ជិតពីក្រសែភ្នែករបស់ចាស់ៗទាំងពីរនាក់ឡើយ តែគ្មាននរណាម្នាក់ដឹងថា គាត់ទាំងពីរមានអារម្មណ៍យ៉ាងណាឡើយចំពោះរឿងកូនចៅដែលស្ថិត នៅក្រោមការឃុំគ្រងរបស់គាត់ ។

ថ្ងៃដន្យ មិនយូរប៉ុន្មាន នាយខ្នាត្រូវលាក្រុមគ្រួសាររបស់តាមាំងចូល រក្សាផ្នួសនៅវត្តតាមដែលនាយធ្លាប់សន្យាជាមួយព្រះគ្រូចៅអធិការ ។ នៅថ្ងៃបំបួសនាគ ក្រុមគ្រួសាររបស់តាមាំងបានទៅចូលរួមគ្រប់ៗគ្នា ។ នៅពេលដែលនាយខ្នាកំពុងកោរសក់ កងណៃក៏លួនទៅជិតលួចខ្សិបថា :

- បងខ្នា! ពេលនៅផ្នួស ខំរៀនណាំបង! ដល់បងសឹកមកវិញ នឹងមាននារី ដ៏ស្រស់ស្អាតមួយរូបរង់ចាំរៀបការជាមួយបងហើយ!

នាយខ្នាភ្ញាក់ព្រើតសួរវិញថា :

- នារីណាគេទៅដែលរង់ចាំបុរសមើលមិនបានដូចបងនេះ?

- ណៃមិនប្រាប់ទេ...ដល់ថ្ងៃ គង់តែបងដឹងខ្លួនឯងហើយ ។

ការពិតកងណៃនិយាយលេងនាយខ្នាអោយទៅបងស្រីខ្លួនទេ ។ រីឯ កងណាវដែលនៅក្បែរនោះកាលបើឮប្អូនស្រីនិយាយដូច្នោះ នាងក៏លូកដៃ ក្តិចប្អូនមិនអោយនិយាយតទៅទៀត ។ ប៉ុន្តែនាយខ្នាបែរជាយល់ច្រឡំទៅវិញ ហើយបែរជាសួរបញ្ជាក់ថា :

- ណៃ! ប្រាប់បងបានទេ ថានារីដែលរង់ចាំបងនោះ កំពុងស្ថិតនៅចំពោះ មុខបងពេលនេះ? បើដូច្នោះមែន...បងនឹងខំរៀនអោយអស់សមត្ថភាព!

នាយខ្នានិយាយបញ្ឆិតបញ្ឆៀងអោយធិតា តែនាងមិនយល់ទេ បែរជា ឆ្លើយទៅវិញថា :

- ចូលផ្នួសហើយ...កុំគិតមមើមមាយទៀត! ចាំដល់ថ្ងៃណាថ្ងៃហ្នឹងទៅ.. បើគេមិនព្រម ចាំណៃជួយចាត់ការអោយណាំ!

រំពេចនោះ តាមាំងក៏ដើរមកដល់កាត់ការសន្ទនារវាងអ្នកទាំងពីរ ។ គេ ក៏ផ្អាកជជែកគ្នាទៅ ។ តាមាំងក៏មានប្រសាសន៍ទៅនាយខ្នាថា :

- ខ្នាអើយ! បួសហើយខំរៀនណាំកូន! ហើយឧស្សាហ៍ធ្វើការបំរើវត្តផង កុំ ធ្វើខ្លួនទំនេរឥតប្រយោជន៍ ។ ពេលណាឯងលាផ្នួសមកវិញ យើងនឹងប្រគល់ រោងជាងនោះអោយឯងរកស៊ីដាច់មុខ ដូច្នេះ ឯងនឹងមានរបរចិញ្ចឹមជីវិត រហូតតទៅមិនក្រីក្រខ្វះមុខក្រោយតទៅទៀតទេ ។

នាយខ្នាក៏បន្ទាបខ្លួនលុតជង្គង់សំពះតាមាំង :

CHANBOKEO.COM

- ខ្ញាសូមអរគុណពូណាស់ដែលមានមេត្តាចំពោះខ្ញុំ ។ ក្រៅពីឪពុករបស់ខ្ញុំ និងលោកតាចៅអធិការឧត្តរៈចេញ ខ្ញុំមានតែពូនិងមីងទេជាទីពឹង ។ ដូច្នេះ ជាតិនេះតទៅ ខ្ញាសូមបូជាជីវិតដើម្បីសងគុណពូនិងមីងព្រមទាំង...

ថាហើយនាយក៏បែរមើលទៅកូនស្រីទាំងពីររបស់តាមាំង ហើយក៏ ស្រដីបន្តថា :

- ការពារថែរក្សាកូនរបស់ពូមីងអោយបានសុខសប្បាយរហូតរៀងទៅ ។

គេក៏ក្រាបបង្គំតាមាំងនិងមីងនួនក្បាលដល់ដីចំនួនបីដងសំដែងនូវភាព កត្តញ្ញូនិងក្តីគោរពដែលគេមានចំពោះលោកទាំងពីរ ។ ពេលវេលាហែនាគ ក៏ចូលមកដល់ ។ នាយខ្ញាក៏បានក្លាយទៅជាសាមណេរមួយព្រះអង្គ ដែល ត្រូវបានព្រះគ្រូឧត្តរៈដាក់នាមអោយថ្មីថាករុណា ។ ចាប់តាំងពីពេលនោះមក ភិក្ខុករុណាក៏បាននៅបួសរក្សាសីលយ៉ាងមធ្យត់ ប្រកបដោយវិន័យនិង សម្បទា ពេញលក្ខណៈជាភិក្ខុក្មេងគំរូប្រចាំវត្តតែម្តង ។ រៀងរាល់ថ្ងៃ នាងតូចណៃតែងតែយួរស្រាក់អាហារ ដែលបងស្រីនាងធ្វើមកប្រគេនព្រះ គ្រូនិងភិក្ខុករុណាជាអលជ្ជី ហើយភិក្ខុករុណាក៏តែងតែនិមន្តមកសួរសុខទុក្ខ តាមាំងនិងមីងនួនជារឿយៗដែរ ដោយព្រោះតាមាំងមានពិការភាព មិនអាចដើរទៅណាមកណាបានស្រួលដូចពីដើមឡើយ ។

0000000000000000

00000

0

# វគ្គទី៥

# ផ្កាឈូកដប់ទង

ឃុំព្រះនេត្រព្រះ ចុងខែសីហាឆ្នាំ១៩៥៨...

នៅផ្ទះគ្រូដែលទើបនឹងសង់ហើយថ្មីៗនេះ អ្នកស្រុកអ្នកភូមិបានមក ដល់កុះករបន្តបន្ទាប់ រង់ចាំពិធីសម្ពោធឡើងផ្ទះជូនអ្នកគ្រូបង្រៀននិងអ្នក គ្រូពេទ្យ ដែលនឹងមកស្នាក់នៅដើម្បីបំរើសេចក្តីត្រូវការក្នុងភូមិ ដោយមិនទទួលប្រាក់បៀវត្សរ៍ចំនួនពេញមួយឆ្នាំ ។ លោកចំណាប់ដែលជាភូឈួយ ខេត្តក៏បានមកដល់ពីបាត់ដំបងដែរ ព្រមទាំងនាំភរិយារបស់លោកឈ្មោះ អ្នកស្រីចន្ថាមកជាមួយផង ។ ប៉ុន្តែលោកភូរិនមិនបានអញ្ជើញមកទេ ត្បិតភរិយារបស់លោកទើបឆ្លងទន្លេថ្មីៗ ។

អ្នកគ្រូចំណានបានមកដល់ផ្ទះគ្រូ ជួយធ្វើការអ្នកស្រុក រៀបចំទីកន្លែង មួយព្រឹកហើយ តែមិនឃើញអ្នកគ្រូចរណៃមកដល់សោះ ក៏នឹកពិភាល់ក្នុង ចិត្តតែម្តង ។ បន្ទិចមក មាណវីក៏ដើរទៅជិតភរិយាសែបផុន សួរថា :

- ហើយចុះឯណាបងចរណៃ ម៉េចមិនទាន់ឃើញមកដល់អញ្ចឹង?

ភរិយាសែបផុនក៏ឆ្លើយវិញថា :

- មិនដឹងដែរអ្នកគ្រូអើយ! ព្រឹកមិញមីងឃើញគេមានទឹកមុខមិនល្អសោះ ហើយឮប្រាប់មីងថា ឈឺក្បាល ប៉ុន្តែនាងប្រាប់ថា នឹងមកដល់កន្លែងបុណ្យ នេះអោយទាន់ពេលចាប់ផ្តើមពិធី ។

រំពេចនោះ លោកចក្រាបររថយន្តហ្ស៊ីបថ្មីស្រឡាងមួយដឹកស្ត្រីចំណាស់ មួយរូបដែលមានរូបស្រស់ឆើតឆាយមកដល់ ហើយក៏នាំលោកស្រីនោះ ទៅសំពះសួរលោកចំណាប់និងអ្នកស្រីចន្ថា :

- ជំរាបសួរបាទ! នេះជាអ្នកស្រីស៊ីផាជាម្តាយរបស់ខ្ញុំ!

ចាស់ទុំទាំងបីនាក់ក៏ជួបគ្នាសំណេះសំណាលយ៉ាងរីករាយស្និទ្ធស្នាល ។ ភ្លាមនោះ ចក្រាក្រលេកឃើញអ្នកគ្រូចរណៃពាក់អាវប៉ាក់ទទូរកន្សែងស រុំ មុខស្មើរតែជិតអស់ ដើរមកដល់ ។ គេក៏ស្ទុះទៅរកបំរុងនឹងគួរសមស្រាប់ តែនាងធ្វើមិនឃើញ ហើយដើរគេចវឹងសំដៅទៅហ្វូងយាយៗចាស់ៗដែល កំពុងរៀបអាហារទទួលភ្ញៀវ ។ គេថ្លោះទឹកមុខហាក់ដូចជាខកចិត្តក៏លួច ទៅកេះម្តាយស៊ីញ៉ូបង្ហាញនារីដែលគេពេញចិត្ត ។ អ្នកស្រីស៊ីផាញញឹមរួច ហើយបែរមកសន្ទនាជាមួយលោកចំណាប់និងភរិយាខ្សិបៗ ។ ចាស់ទុំទាំង បីរូបនិយាយគ្នាផង សើចក្អាកក្អាយផង ហាក់ដូចជាត្រូវដងត្រូវផ្លែគ្នាដល់ ហើយ ។ បន្តិចមក អ្នកស្រីស៊ីផាក៏សួរទក់ទឹកចិត្តលោកចំណាប់និងអ្នកស្រី ចន្ថាថា :

CHANBOKEO.COM

- អត់ទោសចុះ! កុំថាអីថាវ៉ាន់ណាំលោកភូឈ្មួយខេត្ត...ឧបមាថាបើសិន គ្រួសារយើងទាំងពីរភ្ជាប់និស្ស័យនឹងគ្នា ជាគ្រួសារតែមួយវិញនោះ តើ លោកនិងលោកស្រីគិតយ៉ាងម៉េចដែរ?

ពេលនោះ លោកភូឈ្មួយខេត្តហាក់ដូចជាយល់ន័យក៏ឆ្លើយវិញថា :

- ខ្ញុំជាមនុស្សជឿនលឿនរបៀបអឺរ៉ុបបន្តិច មិនសូវជាចូលចិត្តបង្ខំចិត្តកូន ចៅក្នុងរឿងគូស្រករទេ ។

ចំណែកអ្នកស្រីចន្ថាមានប្រសាសន៍ថា :

- កូនស្រីរបស់ខ្ញុំមានការអប់រំប្រពៃ ហើយគេក៏មានការសិក្សាខ្ពស់អាច ជួយខ្លួនគេបាន ។ មើលទៅទាល់តែសួរចិត្តគេហើយ ។ ចំណែកយើងជា ម្តាយឪពុកត្រូវតែជួយលើកទឹកចិត្តកូននូវការសំរេចចិត្តរបស់គេ ។

អ្នកស្រីស៊ីផាឮដូច្នោះ ក៏មានប្រសាសន៍ថា :

- ចក្រាកូនប្រុសរបស់ខ្ញុំបានលួចប្រាប់ខ្ញុំថា គេកំពុងនិស្ស័យមានចំណងចិត្ត ជាមួយកូនចៅរបស់លោកភូឈ្មួយខេត្ត ហើយឮថាគេដូចជាពេញចិត្តគ្នា ទៅវិញទៅមកផង ។ មើលទៅ...យើងចាស់ៗជិតបានស៊ីក្បាលជ្រូកឆាប់ៗ ហើយទេដឹង?

លោកភូឈ្មួយខេត្តនិងអ្នកស្រីចន្ថាបែរមើលមុខគ្នា សម្តែងភាពងឿង ឆ្ងល់ ថាតើកូនស្រីមួយណារបស់លោក ដែលមានមានការចាប់អារម្មណ៍ ទៅលើលោកចក្រានោះ កាលបើគ្មានកូនស្រីណាម្នាក់សោះមកញ៉ិកញ៉ុក រអ្វូករអឺននឹងចក្រាផង ឃើញតែនាំគ្នាដើរគេចចេញរៀងៗខ្លួនយ៉ាងនេះ?

អ្នកគ្រូចំណានឃើញបងស្រី ហាក់ដូចជាមិនមានអារម្មណ៍រីករាយ ត្រកាលដូចសព្វដង ក៏ដើរទៅជិតដាក់ខ្លួនអង្គុយក្បែរហើយខ្សិបសួរថា :

- បងណៃ! មានរឿងអ្វីឬបង? ខ្ញុំឃើញបងមានទឹកមុខមិនស្រស់តាំងពី យប់មកម្ល៉េះ? នរណាធ្វើអ្វីអោយបងមិនសប្បាយចិត្តមែនទេ?

ចរណៃងើបមុខឡើងសម្លឹងចំណាន :

- បងមិនអីទេអូន! គ្រាន់តែមិនសូវស្រួលខ្លួន...

ប៉ុន្តែចំណានបានសង្កេតឃើញថា អ្នកគ្រូចរណៃមានភ្នែកក្រហមដក់ ដោយតំណក់ទឹកភ្នែកសើមៗនៅឡើយទេ ថ្វីបើនាងខំញញឹមបន្លប់ប្អូនស្រី យ៉ាងណាក៏ដោយ ។ ចំណានក៏ស្រដីលួងលោមថា :

- បើសិនបងមានការអោយប្អូនជួយអី បងប្រាប់មកចុះ កុំលាក់ទុកនៅក្នុង ចិត្តអោយសោះ ក្រែងយើងអាចជួយគ្នាដោះស្រាយបានណាំបង ។

- អរគុណអូនណាស់ តែបងមិនអីទេ ។ ប្អូនទៅជួយមើលការខុសត្រូវនៅ ខាងក្រៅទៅ ទុកអោយបងនៅជាមួយយាយៗទីនេះហើយ បងមិនមាន អារម្មណ៍ចង់ជួបមុខនរណាទេ ។ សូមជួយទទួលភ្ញៀវជំនួសបងផងណាំ!!

- ចាំស!

ថាហើយ ចំណានក៏ងើបចេញទៅ ។ ការពិត ចរណៃខឹងឈឺចិត្តយំខ្សឹក ខ្សួល ខឹងនឹងខ្លួនឯងអស់ពេញមួយយប់ហើយ ដែលនាងទុកចិត្តបុរសម្នាក់ ហើយបណ្តោយអោយគេមានឱកាសឆ្មក់បំពានលើនាងដោយឥតគិតក្រែង ចិត្តនាងសោះ ។

CHANBOKEO.COM

នាងយំរហូតដល់ហើមភ្នែក នឹកមិនអស់ចិត្តសោះថាហេតុ អ្វីដែលនាងបណ្តោយអោយបុរសម្នាក់នោះមានឱកាសធ្វើដូច្នោះ ។ ថ្វីបើនាងប្រឹងបំភ្លេចហេតុការណ៍នោះចោលតែរូបភាពនៅក្នុងហេតុការណ៍នោះ បានលេចចេញមកលងក្នុងអារម្មណ៍របស់នាងឥតស្រាកស្រាន្ត ពេញមួយ យប់ទើសភ្លឺ ។ នាងមិនយល់ចិត្តខ្លួនឯងសោះ ថាហេតុអ្វីនាងមានអារម្មណ៍ជាប់ជំពាក់នឹងបុរសអ្នកភូមិម្នាក់នោះម្ល៉េះ ទោះបីជាគេគ្រាន់តែជាមនុស្ស ប្រុសក្នុងភូមិធម្មតាៗ ជាជាងផ្ទះដ៏សាមញ្ញម្នាក់មិនសូវមាត់មិនសូវក មិនមានវណ្ណៈ... តើហេតុអ្វីក៏នាងចាប់អារម្មណ៍នឹងគេម្ល៉េះ? ហេតុអី..? ការពិតនាងខឹងនឹងគេមែន...តែនៅក្នុងពេលដែលនាងបែកពីគេមក នាង ក៏នឹកគេនឹករហូតមិនអាចធ្មេចភ្នែករំលត់សេចក្តីនឹករលឹកចំពោះរូបគេនោះ បាន ពិតមែនតែគេបានប្រព្រឹត្តខ្លួនបំពានលើនាងយ៉ាងកំរោលភ្លេចអស់ នូវព្រំដែននៃសេចក្តីថ្លៃថ្នូរយ៉ាងណាក៏ដោយ....

ភ្លាមនោះ ព្រះគ្រូអធិការឧត្តរៈនិងព្រះសង្ឃពីរអង្គទៀត ក៏និមន្តមក ដល់ព្រមជាមួយតាមេឃុំ នាយកុំ និងសមាជិកផ្តើមបុណ្យជាច្រើនទៀត ។ ពិធីបុណ្យក៏ចាប់ផ្តើមឡើង... ចៃដន្យអ្នកគ្រូចរណៃនៅសម្ងំលាក់មុខរហូតមិនឃើញចេញមកចូលរួមក្នុងពិធីនឹងគេទេ សូម្បី អ្នកគ្រូចំណានចេញទៅ តាមមកប៉ុន្មានដងហើយក៏ដោយ ។

មុននឹងបញ្ចប់កម្មវិធីដើម្បីទទួលអាហារថ្ងៃត្រង់ លោកចក្រាក៏ឡើង ទៅលើវេទិកាប្រកាសដំណឹងដ៏ប្លែកមួយថា :

- ជំរាបបងប្អូនទាំងអស់ក្នុងភូមិ ។ ថ្ងៃនេះ ខ្ញុំបាទចក្រាសូមប្រកាសដំណឹង សំខាន់មួយជូនអ្នកទាំងអស់អោយបានជ្រាប...

ពេលនោះ អ្នកភូមិទាំងឡាយដកករហង់រង់ចាំស្តាប់ដំណឹងឡើងស្ងាត់ ជ្រៀប ។ បន្ទាប់មកលោកចក្រាក៏ពោលបន្តថា :

- គឺថា...ចក្រាសូមប្រកាសលាជីវិតកម្លោះនៅពេលឆាប់ៗនះហើយ ។

អ្នកស្រុកនាំគ្នាទះដៃហ៊ោកញ្ជ្រៀវឡើងយ៉ាងអ៊ូអរ ។ អ្នកភូមិម្នាក់ លើកដៃសួរឡើងថា :

- លោកចក្រា! តើនារីណាម្នាក់ទៅដែលមានវាសនាវិសាលបានរៀបការជាមួយបុរសសង្ហាជាជង្គោមានទ្រព្យស្តុមស្តម្ភយ៉ាងនេះ?

រំពេចនោះ អ្នកស្រីស៊ីផា ម្តាយរបស់លោកចក្រាក៏មានប្រសាសន៍ថា:

- គឺក្រុមគ្រួសាររបស់ខ្ញុំនឹងមានភ្ជាប់ចំណងមេត្រីជាមួយនឹងគ្រួសារលោក ភូឈួយខេត្តចំណាប់...

- ប៉ុន្តែលោកចំណាប់មានបុត្រីដល់ទៅពីររូប ម្នាក់ជាអ្នកគ្រូចរណៃ ម្នាក់ ជាអ្នកគ្រូចំណាន តើមួយណាទៅជាគូរបស់លោកចក្រា? (តាមេភូមិសួរ)

លោកជង្គោសង្ហាក៏ញញឹមឡើងហើយស្រដីថា :

- តាមប្រពៃណីខ្មែរ យើងមិនអាចដណ្តឹងប្អូនរំលងបងបានទេ ។ ដូច្នោះខ្ញុំ សម្រេចចិត្តគោរពតាមប្រពៃណីនេះចុះ គឺថានៅពេលអាទិត្យក្រោយនេះ ខ្ញុំនឹងនាំចាស់ទុំលើកស្លាចូលស្តីអ្នកគ្រូចរណៃ ដែលជាបុត្រីច្បងរបស់លោកចំណាប់អ្នកស្រីចន្ទាជាគូជីវិតចាប់ដៃគ្នាសាងគ្រួសាររហូតតទៅ ។

រំពេចនោះ អ្នកស្រុកមានការភ្ញាក់ផ្អើលគ្រប់គ្នា ត្បិតគេមិននឹកស្មាន ថាលោកចក្រាបោះជំហានរហ័សដល់ម្លឹងទេ សូម្បីតែតាញ៉ោនិងយាយព្រីង ក៏ភ្ញាក់ផ្អើលដែរ ។ វិសេចក្តីប្រកាសក្នុងឃោសនសព្ទ៍នោះមានឥទ្ធិពល ល្មម

CHANBOKEO.COM

គ្រប់គ្រាន់នឹងផ្សាយសម្លេង អោយឮដល់ត្រចៀករបស់អ្នកគ្រូចរណៃដែល

កំពុងសម្ងំលាក់ខ្លួនឯរោងបាយជាមួយយាយៗយ៉ាងច្បាស់បំផុត ។ គ្រាន់តែ ឮសេចក្តីប្រកាសនេះកាលណា

ធិតាបើកភ្នែកធំៗដោយការភ្ញាក់ផ្អើល ។ កល្យាណីក៏ឧទានឡើងខ្លាំងៗ កាត់ឡើងថា :

- អត់ទេ...!

កាលបើឮសម្លេងអ្នកគ្រូរបស់យើងខ្លាំងៗដូច្នោះ អ្នកស្រុកក៏បែរមើល

រហង់ ។ ធិតាក៏ស្ទុះសំដៅទៅវេទិកាបុណ្យជាប្រញាប់ ថែមទាំងប្រកែក បន្ថែមទៀតថា :

- នាងខ្ញុំមិនទទួលពាក្យ...

ស្រាប់តែមានសម្លេងស្រែកកាត់សំដីរបស់ឆវីយើងយ៉ាងលាន់រំពងថា:

- ជួយផង! ជួយផង! មានមនុស្សខ្យល់គ....

អ្នកស្រុកក៏រត់ស្រូស្រាចេញទៅ បាត់របៀបរៀបរយអស់ ហើយក៏គ្មាន នរណាចាប់អារម្មណ៍អ្នកស្តាប់អ្នកគ្រូយើង

ឬក៏លោកចក្រាប្រកាសតទៅ ទៀតដែរ ។ ពេលនោះ អ្នកគ្រូចរណៃឮសូរសម្លេងនាយប្រវឹកនិងនាយខ្លែង ស្រែកព្រមៗគ្នាថា :

- តាមេឃុំៗ ពូជាងសម្លាកខ្យល់គ ដួលសន្លប់បាត់មាត់ នៅខាងក្រោរបង កណ្តាលថ្ងៃឯណោះ ។

ឮប្រយោគនោះកាលណា ធិតានឹកស្លុតក្នុងចិត្តតែម្តង ថែមទាំងលាន់ មាត់ខ្សិបតែម្នាក់ឯងថា :

- បងជាង?

ពេលនោះ នាងហាក់ដូចជាចាប់អារម្មណ៍ នឹងសុខទុក្ខរបស់មាណព ភ្លាមតែម្តង ។

នាងក៏ស្ទុះទៅប្រជ្រៀតជាមួយអ្នកភូមិចូលមើលបុរសយើង តែយឺតបន្តិចទៅហើយ

ត្បិតនាយភុំបានលើករាងកាយជាងសម្លាកលីដាក់ រទេះគោបរចេញទៅយ៉ាងលឿន ព្រមជាមួយយាយព្រីង ប្រពន្ធតាញ៉ៅនិង

ស្រីចំណាស់ម្នាក់ទៀត ។ ឆវីឈរភាំង មិនដឹងថានឹងត្រូវធ្វើដូចម្តេចទៀត ។ ពេលនោះ ស្រាប់តែនាយខ្លែងរើសបានផ្កាឈូកមួយបាច់

ដែលធ្លាក់ចោល

នៅកណ្តាលផ្លូវ :

- មើលហ្នែក! មានបាច់ផ្កាឈូកដល់ទៅដប់ទងហើយមានចងសំបុត្រមួយ

ច្បាប់ផងនៅលើបាច់ផ្កានោះផង ។

នាយប្រវឹកក៏ឆក់សំបុត្រវឹងយកមកមើលឈ្មោះ ឃើញសូរសេរថា :

- ជូនអ្នកគ្រូចរណៃ...!

- ជូនអ្នកគ្រូចរណៃ?

នាយខ្លែងលាន់មាត់ រួចក៏ឆក់សំបុត្រនោះមកវិញ ហើយមកផ្គួបជា មួយផ្កាឈូកទាំងដប់ទងនោះជូនទៅអ្នកគ្រូយើងភ្លាម

ថែមទាំងវាចាថា :

CHANBOKEO.COM

- នេះប្រហែលជាផ្កាដែលពូសម្លាកបេះយកមកចងដៃអ្នកគ្រូថ្ងៃឡើងផ្ទះថ្មី នេះហើយ...ចៃដន្យគាត់ខ្យល់គ ទើបមិនបានជូនអ្នកគ្រូផ្ទាល់ដៃ... ដូច្នេះ ខ្ញុំសូមជូនផ្កាឈូកនេះជូនពរអ្នកគ្រូជំនួសគាត់ទៅចុះ ។

ចរណៃលូកដៃទទួលយកទាំងដួងចិត្តញាប់ញ័របំផុត ក្នុងចិត្តនៅតែនឹក បារម្ភពីរូបគេមិនដាច់ ។ រំពេចនោះ អ្នកគ្រូពេទ្យចំណានក៏បានមកដល់ក្បែរ លួចកេះធិតាហើយខ្សិបថា :

- បងភ្លេចហើយហ្អែសថាខ្ញុំជាពេទ្យ? ម៉ោះ យើងទៅមើលបងជាងមើល៍ ថាតើគាត់យ៉ាងម៉េចហើយ...

បន្តិចនោះ អ្នកគ្រូចំណានសុំកូនសោរឡានពីលោកចំណាប់ដែលជា ឪពុក បរនាំបងស្រីរបស់នាងចេញទៅតាមផ្លូវលំក្នុងភូមិយ៉ាងលឿនស្លេវ ប្រហែលជាមាណវីដឹងជំរៅ និងភាពខ្វល់ខ្វាយ នៅក្នុងចិត្តរបស់បងស្រី ហើយមើលទៅ ។ លុះមកដល់មុខផ្ទះរបស់ជាងសម្លាកពេលណា ធិតាចុះ ពីរថយន្តចាប់អូសដៃចរណៃចូលទៅរកមើលជាង តែចរណៃបែរជាក្រាញ មិនហ៊ានដើរចូលទៅសោះ ។ ឃើញកិរិយាចម្លែករបស់ចរណៃដូច្នោះ ធិតា ក៏មិនបង្ខំដែរ ។ នាងក៏ចាប់សំពៀតដាក់ប្រដាប់ពិនិត្យជំងឺដើរឡើងលើផ្ទះ របស់ជាងយើងភ្លាម ស្រាប់តែប្រទះយាយព្រឹងនិងអ្នកភូមិម្នាក់ទៀតកំពុង ដើរចេញមកវិញ ។ យាយព្រឹងស្រដីប្រាប់ទៅអ្នកគ្រូពេទ្យយើងថា :

- អំបាញ់មិញនេះ ខ្ញុំរកដោះអាវកោសខ្យល់អោយគេ តែគេមិនព្រមឱ្យ ដោះអាវសោះ គេថាគេមានតំណម មិនអោយស្រីៗដោះអាវអោយទេ ថែមទាំងដេញអោយខ្ញុំនិងយាយខាងនេះចេញមកក្រៅទៀតផង ។ ពេល នេះ ខ្ញុំអោយនាយភុំនៅកំដរសិន គិតថាទៅតាមគ្រូហ្មប្រចាំភូមិអោយ មកមើលគេវិញ ។

ថាហើយ គាត់ទាំងពីររូបនោះក៏ដើរចេញទៅបាត់ ។ ឆរីយើងដើរចូល ទៅក្នុង ក៏ប្រទះឃើញភុំកំពុងទាញភួយដណ្ដប់អោយបុរសយើងដែលកំពុង ធ្មេចភ្នែកឱបដៃក្រញុននៅលើគ្រែ ក្នុងអាការៈហាក់ដូចជារងាក្រៃលែង ។ ឃើញវត្តមានរបស់អ្នកគ្រូយើងមកដល់ ភុំឧទានថា :

- បងជាង... អ្នកគ្រូពេទ្យចំណានមកដល់ហើយបង! អោយគាត់ពិនិត្យ អាការៈបន្តិចទៅណ៎ា...!

អ្នកគ្រូចំណានស្ទុះទៅជិតអ្នកជំងឺ :

- អោយខ្ញុំសុំពិនិត្យរោគបានទេបងជាង? មូរដៃអាវមកក៏ ខ្ញុំវាស់ឈាមឱ្យ ហើយដោះឡេវអាវខាងមុខពីរបីឡេវមក ខ្ញុំចង់ស្ដាប់ដំណើរឈាមក្នុង បេះដូងរបស់បង ។

ភ្លាមនោះ ជាងសម្លាកបើកភ្នែកហើយបែរខ្លួនមករកអ្នកគ្រូព្រមទាំង វាចាថា :

- ខ្ញុំមិនអីទេ អ្នកគ្រូ! មិនបាច់ពិនិត្យទេ...ខ្ញុំគ្រាន់តែអត់ងងុយ...គេងបន្តិច ទៅ នឹងបានស្រួលបួលវិញហើយ ។

តែអ្នកគ្រូរបស់យើងមិនជឿទេ ។ នាងក៏ទាញដៃបុរសយើងមកមូរដៃ អាវឡើងត្បិតគេពាក់អាវដៃវែងដល់កដៃឯណោះ ។ តែបុរសយើងឆក់ដៃ យកវិញយ៉ាងរហ័ស :

- មិនអីទេ បាទ... អ្នកគ្រូ! (ជាងសម្លាកពោល)

CHANBOKEO.COM

មូរដៃអាវមិនបាន អ្នកគ្រូចំណានក៏យកដៃបេះឡេវអាវមុខបំរុងដាក់ ប្រដាប់ស្តាប់ដំណើរបេះដូង ស្រាប់តែ នាយយើងយកដៃទប់អាវជាប់ រួច ក្រឡះបែរខ្លួនមិនអោយនាងដោះឡេវអាវពិនិត្យជំងឺឡើយ ។ ភ្លាមនោះភុំ ដែលកំពុងជ្រួលច្របល់ក្នុងចិត្តចំពោះសុខទុក្ខរបស់ជាង ក៏ពោលអង្វរនាយ ដោយសំដីយ៉ាងស្រទន់ឡើងថា :

- បងជាង! អោយអ្នកគ្រូពេទ្យពិនិត្យអាការៈរោគបងទៅណាំ..ណាំ!

តែជាងបែរជាបិទភ្នែក ប្រែខ្លួនទៅម្ខាងធ្វើមិនដឹងមិនឮអ្វីតទៅទៀត មិនថានាយភុំទទូចអង្វរយ៉ាងណាក៏ដោយ ។

នៅខាងក្រៅផ្ទះ អ្នកគ្រូចរណៃចុះពីរថយន្ត កាន់ផ្កាឈូកទាំងដប់ទង យ៉ាងណែនក្នុងដៃ ។ រីភ្នែករបស់នាងវិញ ម្តងសម្លឹងទៅផ្ទះជាងសម្លាក ម្តង សម្លឹងកូនលិខិតតូច ដែលចងរុំភ្ជាប់ទៅនឹងបាច់ផ្កាឈូកក្រពុំទាំងដប់ទង... សំដែងទឹកមុខអន្ទះសាកន្ទះរាយ៉ាងណាមិនដឹង ។ បន្តិចមក ធិតាក៏ដកហូត យកកូនលិខិតតូចនោះចេញមកពីបាច់ផ្កាហើយហែកអានយ៉ាងស្ងៀមស្ងាត់ ម្នាក់ឯង ។ នៅក្នុងឱរា បេះដូងរបស់នាងកំពុងយោលរណ្តំទន្ទ្រាំកាយឡើង ញាប់ញ័រស្ទើរតែដួលសន្លប់តាមជាងម្តងៗទៅហើយ ។ ដៃនាងញ័រទទ្រើក ទឹកភ្នែកក៏ស្រក់ហូរចុះមកដោយឯកឯង កាលបើបានអានលិខិតដ៏មានន័យ យ៉ាងធំធេង...

- មកដល់អូនណៃ នារីតែមួយគត់ដែលបេះដូងបងរង់ចាំគ្រប់ពេលវេលា!!

បងមិនដឹងថា អូននឹងផ្តល់ឱកាសអោយបងបានសូមទោសឬក៏យ៉ាងណាទេ តែបងសូមសរសេរលិខិតនេះផ្ញើជូនអូន ក្រែងលោបងគ្មានឱកាសនឹងរៀប រាប់ប្រាប់ពៅអំពីចិត្តរបស់បងប្រាប់អូនផ្ទាល់ ។ ការពិតបងបានរង់ចាំឱកាស នេះចំនួនដប់ឆ្នាំមកហើយ...ចាំជួបអូន ដើម្បីនិយាយប្រាប់ថា បងនឹកអូន ព្រួយពីអូនប៉ុនណា ។ ប៉ុន្តែគួរឱ្យស្តាយ!....នៅពេលបងបានជួបអូនហើយ បងបែរជាបំផ្លាញ ឱកាសនោះឱ្យរលត់រលាយទៅវិញយ៉ាងសោះកក្រោះ ។ ពេញមួយយប់កន្លងមក សម្បជញ្ញៈបានជេរស្តីបងច្រើនណាស់... ធ្វើឱ្យបង នឹកខ្មាសខ្លួនឯង! ខ្មាសក្រៃលែង! ខ្មាសនឹងរកពាក្យអ្វីមកបរិយាយអោយ សមស្មើ មិនបានឡើយ ។ អូនណៃ! បងនឹកអូនណាស់! នឹកគ្រប់វេលា... តាំងពីពេលដែលរូបអូនបានចាកចេញពីជីវិតរបស់បងទៅ...ហើយបងតែង តែបែបន់សុំអោយអូនវិលត្រលប់មកវិញ ក្រែងលោបងបានទទួលក្តីមេត្តា ពីអូន ។ ថៃដន្យ បងជាមនុស្សអន់...ជាមនុស្សគ្មានសតិ.... គ្មានសេចក្តី ថ្លៃថ្នូរ.. ជាមនុស្សវង្វេងដោយភាពស្រើបស្រាល... ពេលនេះបងដឹងថា ខ្លួនមានកំហុសធ្ងន់ណាស់ ពិបាកនឹងឱ្យអូនណៃអភ័យទោសអោយបាន ។ ការពិត គឺមកពីបងមិនស្គាល់ខ្លួនឯង... ហ៊ានប្រមាថមាក់ងាយស្ត្រីដ៏ល្អ មួយរូបដែលមានលក្ខណៈខ្ពង់ខ្ពស់ជាងបងហៅមិនឮ ទាំងវិជ្ជា ទាំងឋានៈ ទាំងកិត្តិយស ទាំងរូបសម្បត្តិ ។ ចំណែកបងវិញ គ្រាន់តែជាជនកំទេចកំទី មួយរូប... មិនគួរឡើយនឹងច្រឡំវាយឫកប្រមាថ អ្នកដែលបងគួរគោរព កោតក្រែងរអែងចិត្តនោះឡើយ ។ បងនឹកអាមាសនឹងមារយាទរបស់បង ណាស់... ហើយក៏មានវិប្បដិសារីយ៉ាងធំធេង ព្រមទាំងសោកស្តាយក្នុងចិត្ត ជាទីបំផុត ។ បងមិនដឹងថាត្រូវធ្វើយ៉ាងណា ដើម្បីអោយអូនរសាយកំហឹង ទៅវិញបានទេ ។ បងពិតជាបុរសល្ងង់ណាស់.. ពេលនេះ បងដឹងតែម្យ៉ាង គត់ គឺបងស្រលាញ់អូន ស្រលាញ់ស្មើរលេប ស្រលាញ់តាំងពីយូរមកហើយ ហើយក៏ស្រលាញ់អូនរហូតតទៅ គ្មានថ្ងៃដែលបងដូរចិត្តវិញឡើយ គឺបង បានកាត់បេះដូងរបស់បងផ្ញើឱ្យទៅអូនណៃ

CHANBOKEO.COM

តាំងពីថ្ងៃដែលអូនបានយក កាំបិតមកគូសខ្វែងជើងក្អែកកណ្ដាលទ្រូងរបស់បងថ្ងៃនោះម្ល៉េះ... បងគ្មានសល់បេះដូងសំរាប់នារីដទៃណាទៀតទេ... បើសិនពេលនេះ បងត្រូវព្រាត់ ពីអូនជារៀងរហូតទៅ នោះបងក៏ដឹងជារស់នៅសំរាប់នរណាតទៅទៀត ដែរ ។ បងកណ្ដោចកណ្ដែងណាស់..បងរងាណាស់...សែនរងា...! មួយជីវិត នេះបងមិនដែលទទួលការកក់ក្ដៅក្នុងចិត្តម្ដងឡើយ ក្រៅតែពីពេលដែល បងមានរូបអូននៅក្បែរៗបងប៉ុណ្ណោះ ។ ស្ដាយណាស់ដែលបងធ្វើខុសលើ រូបអូនហើយគ្មានឱកាសនឹងកែខ្លួនសាជាថ្មី...ពេលនេះបង គ្មានអ្វីផ្ញើអូនទេសំរាប់ជាភស្ដុតាងបញ្ជាក់នូវវិប្បដិសារី និងការលន់តួសូមទោសរបស់បង ក្រៅពីផ្កាឈូកទាំងដប់ទងតំណាងឱ្យម្រាមដៃរបស់បងទាំងដប់ ប្រណម្យ ដើម្បីសូមការអភ័យទោសពីអូន និងប្រណម្យបន់គុណព្រះរតនត្រ័យ សូមឱ្យអូនបានសុខសប្បាយរៀងរហូតទៅ ព្រោះបងគ្មានឱកាសនឹងនៅបំរើ អូន ថ្នមថែរក្សាអូនដូចដែលបងធ្លាប់សន្យាជាមួយអ្នកមានគុណរបស់អូន នោះឡើយ ។ អភ័យទោសអោយបងផងណាំព្រលឹងមាសបង! បើសិនជាបងត្រូវបែកពីអូនរហូតតទៅលុះអវសាន... សូមអោយបងបានបិទ ភ្នែកជិតផង!! ស្រលាញ់អូនណែជានិច្ច... ស្រលាញ់អូនពេញបេះដូង... ស្រលាញ់រហូតដល់រូបកាយបងលាផ្ញើព្រះធរណីវិញ....បងខ្លា!!

ចរណៃអានសំបុត្រទាំងទឹកភ្នែកខ្សឹកខ្សួលអណ្ដឹតអណ្ដក់ ។ ចិត្តដែល ខឹង ដែលស្អប់ដែលមួម៉ៅចំពោះមាណពរបស់យើងកន្លងមកទាំងប៉ុន្មាន បានរលាយខ្សុះអស់ពីបេះដូងរបស់នាងអស់រលីង ។ ហេតុអ្វីទៅ? ហេតុអ្វីបានជាលិខិតមួយច្បាប់នោះ មានអនុភាពដណ្ដប់ចិត្តនាងដល់ម្លឹង...? នាង ពិតជាមិនអាចទ្រាំបានទេ.. បើសិនជាគេបែកឃ្លាតពីនាងទៅរហូតពិត មែន...! ថ្វីបើគេបានប្រព្រឹត្តឆ្គាំឆ្គងមកលើនាងក៏ដោយ ក៏នាងមិនចង់ឱ្យគេព្រាត់ពីនាងទៅណាឡើយ...

មួយស្របក់ក្រោយមក ឆវីយកដៃជូតទឹកភ្នែកពីថ្ពាល់ យ៉ាងរហ័សហើយក៏កាន់សំបុត្រនិងបាច់ផ្កាដើរឡើងទៅលើផ្ទះជាងសម្លាករឹង ។ នៅទី នោះ អ្នកគ្រូចំណាននិងភុំអង្គុយមើលមុខគ្នាត្រវីក្បាលត្បិតមិនដឹងថា ត្រូវជួយជាងសម្លាកបែបណា ។ លុះឃើញវត្តមានរបស់អ្នកគ្រូចរណៃទៅ ដល់ភ្លាម អ្នកគ្រូចំណានក៏មិចភ្នែកស៊ីញ៉ូហៅភុំអោយគេចចេញមកក្រៅ ស្ងាត់ៗ ។ ភុំហាក់ដូចជាយល់ហេតុការណ៍ ក៏ស្ទុះដើរចុងជើងលបៗចេញទៅតាមក្រោយអ្នកគ្រូចំណានបាត់ទៅ ទុកអោយអ្នកគ្រូចរណៃនៅ តែពីរនាក់ជាមួយនឹងមាណពរបស់យើងតតួ ។ នៅលើគ្រែជាងសម្លាកគេង ដណ្ដប់ក្រមាបិទភ្នែកបែរខ្នងមកមាត់ទ្វារមិនព្រមរវល់នឹងនរណាទាំងអស់ ទោះបីជាពេលនោះនាយបានឮសិរបជើងមនុស្សដើរចូលមកក្នុងផ្ទះរបស់ ខ្លួនក៏ដោយ ។ គេនៅតែធ្មេចភ្នែកធ្វើមិនដឹងមិនឮ...

ចរណៃកាន់បាច់ផ្កាឈូកទៅដាក់លើដៃរបស់គេយ៉ាងថ្នមៗ... ហើយក៏ដាក់ខ្លួនអង្គុយចុះនៅលើគ្រែរនាបឫស្សីក្រាលកន្ទេលក្រហម ក្បែរជាង សម្លាក រួចនៅសម្ងំស្ងៀមស្ងាត់មិនស្រដីអ្វីឡើយ ។ នាងអង្គុយសម្លឹងបុរស បុរសយើងដែលប្រឹងបិទភ្នែកមិនចង់ឃើញពិភពលោកជុំវិញខ្លួន ។ នៅលើ ផ្ទៃមុខរបស់គេមានស្នាមក្រចកខ្វាចក្រញៅជាច្រើនឆ្នូត ។ ឆវីលើកដៃ នាងឡើង សម្លឹងម្រាមដៃខ្លួន ធ្វើកិរិយារេរាៗ ហាក់នឹកស្ដាយដែលនាងបានខ្វាចបុរសយើងដាច់ពេញមុខ ។ នាងទំលាក់ដៃចុះវិញ រួចអង្គុយស្ងៀម បណ្ដោយឱ្យពេលវេលាកន្លងទៅដោយឯងៗ...

CHANBOKEO.COM

ជាងសម្លាកគេងសំងំយ៉ាងយូរ ទំរាំដាច់ចិត្តបើកភ្នែកឡើង សម្លឹងវត្ថុ ចំលែកក្នុងបាតដៃ ស្រាប់តែគេប្រទះនឹងបាច់ផ្កាឈូកដប់ទង ដែលគេបាន ចងរុំកាលពីព្រឹកមិញនេះ ។ មាណពស្រវាយកមើលយ៉ាងរហ័ស ឃើញថា បាច់ផ្កានោះមិនបានស្ថិតនៅដូចសភាពដូចដើមទេ ត្បិតលិខិតដែលគេបាន សរសេរចងភ្ជាប់នឹងទងផ្កានោះបានបាត់រូបទៅហើយ ។ ជាងក៏ស្ទុះក្រោក បែរក្រោយភ្លែតយ៉ាងលឿន ស្រាប់តែគេប្រទះនឹងវត្តមានរបស់អ្នកគ្រូ ចរណៃនៅចំពោះមុខគេតែម្តង ។ នរៈបើកភ្នែកធំៗដោយការភ្ញាក់ផ្អើល ត្បិតមិននឹកស្មានថាធរីយើងនឹងមកដល់ទីនេះទេ... ។ ភ្លាមនោះ គេឧទាន ឡើងទាំងញាប់ញ័រថា :

- អូនណៃ...?

កាលបើឃើញជាងសម្លាកក្រោកឡើង បែរមើលនាង សំដែងកិរិយា ភ្ញាក់ភន្តំភាំងដូច្នោះ ធិតាក៏សួរឡើងថា :

- បាច់ផ្កាឈូកក្រពុំនេះ...ជារបស់បងជាងមែនទេ?...

ជាងសម្លាកលេបទឹកមាត់ផ្សើមបំពង់កបន្តិច ទើបឆ្លើយតបវិញថា :

- បាទ! មែនហើយ...

- ហើយបងចងបាច់ផ្កា ទុកយកផ្ញើនរណាគេដែរទៅ...?

- គឺ...ផ្ញើ...គេម្នាក់..ដែលកំពុងតែខឹងអាក់អន់ចិត្ត...ព្រោះ..ខ្ញុំបានប្រព្រឹត្ត មិនប្រពៃទៅលើគេ..ដើម្បីជាការសូមទោស...

មាណពស្រដីទាំងឈ្ងោកមុខចុះ សំដែងភាពសោកស្តាយក្នុងចិត្ត ។

- ហើយម៉េចក៏បងមិនយកទៅអោយគេអញ្ចឹង? (ធិតាសួរបន្ត)

- គឺ... មិនហ៊ាន... ខ្លាចគេមិនទទួលយក...បានជាស៊ូទ្រាំឈរនៅ ហាលថ្ងៃ ក្រៅរបងផ្ទះគ្រូ...មិនហ៊ានចូលទៅរំខាន ។

- បងមិនទាន់បានយកទៅអោយគេផង... ម៉េចក៏ដឹងកើត ថាគេមិនទទួល យកពីបងនោះ?

- គឺ...មកពីខ្ញុំ...ជាមនុស្សគ្មានសេចក្តីក្លាហានទេដឹង?...

- ហើយ... ចុះបើសិនជាបងចង់យកបាច់ផ្កាឈូកក្រពុំទាំងដប់ទងនេះ ទៅ ឱ្យគេ តើបងបំរុងនិយាយជាមួយគេថាម៉េចដែរ?

ពេលនោះ ស្រាប់តែមាណពងើបមុខឡើងសម្លឹងធិតាវិញដោយក្រសែ ភ្នែកភ្លឺថ្លា ថែមទាំងតបវិញថា :

- គឺ...ខ្ញុំមានរឿងច្រើនណាស់...ដែលខ្ញុំចង់ប្រាប់គេអោយដឹង...

- ពិតមែនហ្អែស? រួចម្តេចក៏មិនយកផ្កានេះ ទៅសុំទោសគេឥលូវនេះទៅ តិចលោគេអង្គុយរង់ចាំទទួលផ្កាពីបង ស្កកស្រូវអស់ទៅ! ហើយនៅពេល បងជួបគេ សូមបងកុំភ្លេចប្រាប់គេផងនូវអ្វីដែលបងចង់និយាយឱ្យគេដឹង.. ព្រោះគេកំពុងតែនៅរង់ចាំស្តាប់ពាក្យពន្យល់ពីបងហើយ!!

គ្រាន់តែឮប្រយោគនេះកាលណា ជាងសម្លាកប្រែទឹកមុខញញឹមឡើង ដោយក្តីរំភើបក្នុងចិត្តរហូតទឹកភ្នែករលីងរលោងដោយក្តីត្រេកអរ :

CHANBOKEO.COM

- អូនណៃ...អូនគឺពិតជាអូនណៃរបស់បងប្រាកដណាស់...!

ភ្លាមនោះ បុរសយើងក្តាប់បាច់ផ្កា ងើបចុះពីលើគ្រែ ឈរសម្លឹងភក្ត្រ អ្នកគ្រូចរណៃរបស់យើងមួយស្របក់ រួចក៏លុតជង្គង់ចុះទៅលើក្តារក្រាល បីបាច់ផ្កាទាំងដប់ទងដោយដៃពីរ លើកហុចឱ្យទៅស្រីស្រស់ទងវង់បណ្តូលចិត្តរបស់គេដោយដួងចិត្តរំភើបញាប់ញ័រ ថែមទាំងស្រដីថា :

- អូនណៃ..គឺថា.. អ្នកគ្រូចរណៃ... ខ្ញុំបាទឈ្មោះករុណា...សូមចូលខ្លួនយក ផ្កាឈូកដប់ទងមកសុំទោសអ្នកគ្រូដែលខ្ញុំមានឥរិយាបថមិនប្រពៃចំពោះ អ្នកគ្រូកាលពីម្សិលមិញ...សូមអ្នកគ្រូអភ័យទោសអោយខ្ញុំផង!!

គេស្រដីទៅមាណវីដោយសម្លេងស្រទន់លាយនឹងភាពរន្ធត់ញាប់ញ័រ ។ ទើបតែបានប៉ុន្មានម៉ាត់...គេក៏ស្លាក់ពាក្យនិយាយលែងចេញតទៅទៀត ។ ចរណៃសម្លឹងតាមកិរិយារបស់នាយឥតព្រិចទេ ។ កាលបើឃើញនាយហុចបាច់ផ្កាមកនាង ធិតាក៏លូកដៃទទួលយកភ្លាម ថែមទាំងស្រដីតបថា :

- ណៃ..លែងខឹងនឹងបងហើយ... សូមឱ្យបងឈប់មានកិរិយាមិនល្អដូច្នេះ ដាក់ណៃសាជាថ្មីទៀតទៅណា៎!

ឮប្រយោគនោះកាលណា ជាងសម្លាកងើបមុខឡើង សម្លឹងកែវភ្នែក ស្រីស្រស់វិញដោយដួងចិត្តរំជើបរំជួលៈ

- បងសន្យាថាមិនប្រព្រឹត្តឆ្គាំឆ្គងដូច្នេះទៅលើណៃជាលើកទីពីរឡើយ ។

ចរណៃ ក៏ទាញបាច់ផ្កាឈូកមកកាន់នៅដៃឆ្វេង ហើយបោះដៃស្តាំហុច ទៅអោយជាងរបស់យើង :

- ម៉ោះ យើងចាប់ដៃគ្នាសាជាថ្មីវិញ!

នរៈភ្ញាក់ព្រើតដែលធិតាធ្វើដូច្នោះ ។ គេសម្លឹងមុខនាងជាថ្មី រួចហើយ លើកដៃស្តាំរបស់ខ្លួនស្រវាចាប់ដៃធិតាយឺតៗ ទំនងខ្លាចចិត្ត ។ លុះគេចាប់ បានដៃឆវីក្តាប់ណែនពេលណា បេះដូងរបស់គេក៏រណ្តំយ៉ាងចម្លែកទៀត ហើយទោះបីគេទប់អារម្មណ៍ថាមិនរំភើបមិនបានសោះ ។ បាតដៃរបស់គេ ក្លាយជាត្រជាក់ស្រេប ។ ភ្នែកគេក្លាយជាស្រវាំងជោគជាំដោយតំណក់ទឹក ភ្នែក ។ ខ្លួនគេវិញក៏ត្រជាក់រងា...រងារកអ្វីប្រៀបមិនបាន... ។ ហេតុអ្វីទៅ? ហេតុអ្វី.. កាលបើនារីដែលគេតែងគេងនឹក គេងស្រម័យជាយូរឆ្នាំមក ហើយ បានមកដល់ចំពោះមុខ តែចិត្តរបស់គេនៅតែរងាដូច្នេះ? ហេតុអ្វី..?

កាលបើឃើញតំណក់ទឹកភ្នែកមាណព ស្រក់ធ្លាក់មកលើខ្នងដៃរបស់ នាង ធិតាយើងនឹករំជួលចិត្តអនេក ។ ទប់ចិត្តមិនបាន ចរណៃក៏ឧទានថា :

- បងជាង...!

ស្រាប់តែត្រូវស្លាក់ទៅវិញ.. ត្បិតនាងអួលដើមករកស្រក់ទឹកភ្នែកដូចគ្នាដែរ ។ ភ្លាមនោះ បុរសយើងក៏ឱនឈ្ងោកយកនាសាទៅផ្តិតលើខ្នងដៃ នារី ហើយស្រដីខ្សឹបៗថា :

- អរគុណណាស់ អូនណៃ ដែលអូនអភ័យទោសអោយបង..

CHANBOKEO.COM

គេចង់ស្រដីច្រើនទៀតប្រាប់នារីយើង... ប៉ុន្តែ បំពង់កគេបែរជាស្ងួត អស់រលីង រកពាក្យអ្វីមកនិយាយទៀតមិនបានទេ។ គេអង្គុយសម្លឹងមុខគ្នា យ៉ាងយូរ.. ហាក់បីដូចជាកំពុងផ្ញើសារបេះដូង ឆ្លើយឆ្លងតាមក្រសែភ្នែក ដែលកំពុងប្រទាក់គ្នានោះហើយ ។ មួយស្របក់ក្រោយមក ចរណៃប្រមូល អារម្មណ៍បានវិញ ហើយបន្លឺវាចាទៅមាណពយើងថា :

- ចុះឯណាដែលថាបងមានរឿងច្រើនណាស់ចង់ប្រាប់ណៃ?...ណៃចាំស្ដាប់ យូរហើយ...ម៉េចមិនឃើញបងនិយាយប្រាប់អ្វីអញ្ចឹង?

ភ្លាមនោះ បុរសយើងក៏ងើបឡើងទៅអង្គុយចំពីមុខនាង ហើយលើក យកដៃស្ដាំរបស់មាណវីមកដាក់លើទ្រូងខាងឆ្វេងរបស់ខ្លួនរួចឆ្លើយថា :

- ណៃស្ទាបទ្រូងបងទៅ នោះអូននឹងដឹងសព្វយ៉ាងទាំងអស់... ថាពេលនេះ បេះដូងរបស់បងកំពុងសារភាពប្រាប់អូនថាម៉េចខ្លះ!!...

កាលបើឃើញកិរិយារបស់មាណពដូច្នោះ ធិតាក៏ឧទានខ្សិបៗឡើង :

- បងខ្នា...!

ជាងសម្លាកភ្ញាក់ព្រើតកាលបើឮនាងហៅខ្លួនរបៀបនោះ ត្បិតឈ្មោះ របស់គេនោះបានបាត់ខ្លួនទៅជាមួយម្ចាស់ចិត្តរបស់គេយូរឆ្នាំមកហើយ.:

- បើអូនណៃនៅចាំបងខ្នា... ហើយចុះអូនមានចាំទេ ថាបងខ្នាធ្លាប់បាន សច្ចាថាម៉េចខ្លះចំពោះអូនណៃមួយ?

ពេលនោះ ស្រាប់តែធិតាស្រក់ទឹកភ្នែកច្រោកៗ រួចលើដៃស្រវាអោប បុរសយើងយ៉ាងរហ័ស ធ្វើអោយនាយភ្ញាក់ស្រលាំងកាំងតែម្ដង :

- បងខ្នា!! អូនណៃ...នឹកបងណាស់!!

គេក៏លូកដៃត្រកងចង្កេះរបស់នាង រួចស្រវាអោបយ៉ាងណែនតបវិញ ទាំងដួងចិត្តញាប់ញ័រឥតឧបមា :

- ណៃបណ្ដូលចិត្តបង...បងក៏នឹកអូនដូចគ្នាដែរ នឹកខ្លាំងណាស់ទៀតផង!

ទើបតែពេលនេះទេដែលបេះដូងមាណពរបស់យើងបានទទួលនូវភាព កក់ក្ដៅរមនាជាលើកដំបូង ដែលគេមិនដែលបានជួបប្រទះមួយជីវិតរបស់ គេ។ រីធិតាវិញក៏យំសសឹក ដោយក្ដីរំភើបចិត្តនិងក្ដីនឹករលឹកដ៏ធំធេង។ នរៈយកដៃអង្អែលខ្នងនារីបន្ដើរៗ សំដែងនូវសេចក្ដីអាណិតស្រលាញ់ដែល ខ្លួនធ្លាប់រក្សាទុកជូនឆវីជាយូរកន្លងឆ្នាំមក។ មែនហើយ! ពេលនេះនារី ដែលគេធ្លាប់ស្រម័យ ធ្លាប់នឹករលឹកនោះ បានមកដល់ចំពោះមុខទៅហើយ រឿងអីដែលថាគេមិនរីករាយរំភើបរំជើបរំជួលចិត្ត? នរៈយើងត្រកងឱប កល្យាណីផ្ទាប់នឹងដើមទ្រូងរបស់គេយ៉ាងណែន ឱ្យនាងផ្ដេកកេសាកើយ ឱរា ស្ដាប់សូរសៀងបេះដូងរបស់គេរណ្ដំប្រាប់ធិតា នូវចម្រៀងស្នេហាភក្ដី ដែលគេបានចងក្រងទុកសំរាប់រូបនាងជាយូរឆ្នាំមកហើយ....

មួយស្របក់មុននេះ... គេខ្វល់ចិត្តស្ទះដង្ហើមស្ទើរតែស្លាប់បាត់ពីលោក នេះទៅហើយ ពេលគេបានឮសេចក្ដីប្រកាសរបស់លោកចក្រាដង្ហៅក្មេង នៅឯកន្លែងបុណ្យ។ ប៉ុន្តែ ពេលនេះ ស្រាប់តែគេមានកម្លាំងប្រឹសដោយ

CHANBOKEO.COM

ឯកឯងតែម្តង ថ្វីបើគេមិនបាននិទ្រាឬក៏បរិភោគអីមួយម៉ាត់សោះមួយយប់មួយថ្ងៃមកហើយក៏ដោយ ។

កំពុងតែទទួលភាពក្រេមក្សាន្តក្នុងចិត្ត ស្រាប់តែអ្នកទាំងពីរឮសូរិប ជើងមនុស្សដើរឡើងជណ្តើរមកលើផ្ទះ ។ គេក៏បំបែកគ្នាអង្គុយរៀបតរិយា បថរៀង១ខ្លួន ។ ភ្លាមនោះ តាមេឃុំនាំបុរសចំណាស់មួយរូបមកដល់ :

- ជាងអើយ! តានាំគ្រូហ្មមកមើលឯងណា៎... ម៉េចទៅហើយជាង? ឮថា ឯងមានតំណមមិនអោយស្រី១គេប៉ះខ្លួនកោសខ្យល់អោយទេ... ទើបតា ទៅហៅគ្រូហ្ម មកជំនួសវិញនេះអី!

ជាងសម្លាកឈ្ងោកមុខ ដៀងកន្ទុយភ្នែកទៅអ្នកគ្រូ ហើយឆ្លើយវិញ ទាំងអឹមអៀនថា :

- គឺ.. ខ្ញុំបានស្រួលខ្លួនបន្តិចហើយ បានជាមិនចង់រំខានចាស់១...

- អញ្ចឹងបានន័យថាឯងមិនត្រូវការគ្រូមើលជំងឺឯងទេ?

- បាទ... មិនត្រូវការទេ!

តាមេឃុំក្រលេកទៅឃើញអ្នកគ្រូចរណៃអង្គុយឈ្ងោកមុខនៅស្ងៀម នៅម្ខាងបន្ទប់ ក៏បែរមកមើលនាយយើងវិញ ធ្វើមុខញញឹមហាក់ដូចជា យល់ស្ថានការណ៍ :

- អឺ! បើឯងស្រួលវិញហើយ តានាំគ្រូហ្មទៅវិញហើយណា៎... បើថ្ងៃនេះ ស្រួលខ្លួនវិញ កុំភ្លេចទៅចូលរួមបរិភោគអាហារនៅផ្ទះតាកុំខាន ។ តែបើ មិនទាន់ស្រួលទេ ក៏ហីទៅ.. ហើយកុំភ្លេចថែខ្លួនផង កុំអោយអត់បាយអត់ ងងុយច្រើនពេកណា៎ !

- បាទ!

តាមេឃុំក៏នាំគ្រូហ្មភូមិចេញទៅ ។ អ្នកគ្រូចរណៃក៏បែរសួរនរះថា :

- មិននឹកស្មានសោះថា...បងខ្មាកំណាញ់ដល់ម្លឹង?

- បងកំណាញ់រឿងអីទៅ អូនណៃ?

- គឺកំណាញ់មិនអោយស្រី១ ដោះអាវ កោសខ្យល់អោយបងនោះអី..!

- អូនណៃចង់អោយបងរំលឹករឿងចាស់១របស់យើងនោះមែនទេ?

ចរណៃញញឹមលាក់គំនួច :

- ហើយចុះបងខ្មានៅចាំរឿងចាស់របស់យើងប៉ុនណាដែរ...?

រំពេចនោះ មាណពស្ទុះមកចាប់ដៃនាងអោយមកប្រឡេះឡេវអាវ របស់ខ្លួន ។ ឆវីភ្ញាក់ព្រើតដកដៃចេញរហ័ស :

- បងកំពុងគិតធ្វើអ្វីផ្តេសផ្តាសទៀតហើយហ្នឹង?

- អត់ទេ..គឺបងចង់អោយអូនឃើញអ្វីមួយ?

- អ្វីទៅ?

- ដោះអាវបងមើលទៅ អូននឹងឃើញច្បាស់មិនខាន...

CHANBOKEO.COM

ធិតាជ្រួញចិញ្ចើម តែលុះឃើញទឹកមុខបុរសយើងហាក់ដូចជាមុតមាំ ទំនងមិនមានលាក់គំនួចអាក្រក់ ធិតាក៏យកដៃដោះអាវនាយចេញពីខ្លួន ។ ភ្លាមនោះ នាងក៏បានប្រទះនឹងស្នាមសាច់ផ្លែ ជាសំណាកខ្វែងជើងក្អែកនៅត្រង់ទ្រូងរបស់នាយខាងឆ្វេង ថែមទាំងមានស្នាមរលាកភ្លើងជាច្រើន កន្លែងទៀតនៅលើដងខ្លួនរបស់មាណពយើងផង ។ មាណវីក៏ឧទានឡើង ទាំងភ្ញាក់ផ្អើលបំផុត :

- ពុទ្ធោ! បងខ្នា!

បុរសយើងសម្លឹងមុខកន្និដ្ឋា ដោយក្រសែភ្នែកប្រកបដោយសេចក្តីស្នេហាយ៉ាងធំធេងជ្រាលជ្រៅនឹងរកអ្វីវាស់អោយស្មើមិនបានឡើយ ។ បន្ទាប់មក គេក៏ញញឹមឡើង ហើយក៏ស្រដីសួរទៅធិតាយើងថា :

- ពេលនេះ អូនណែដឹងហើយឬនៅ... ថាហេតុអ្វី បងមិនអោយស្ត្រីប៉ះខ្លួន របស់បង មិនថាស្ត្រីនោះមានវ័យចំណាស់ណាទេ?

មែនហើយ! ពេលនេះ នារីយើងញាប់ញ័រក្នុងចិត្តសាជាថ្មីទៀតហើយ ត្បិតអារម្មណ៍របស់នាងកំពុងវិលទៅរកអនុស្សាវរីយ៍មួយ នាអតីតកាល គឺអនុស្សាវរីយ៍ ដែលមិនព្រមរលប់បាត់ពីដួងចិត្តរបស់នាង មួយនាទីណាតាំងពីយូរយារមកហើយ...

CHANBOKEO . COM

0000000000000000000

0000000

0

# វគ្គទី៧
# រាត្រីឧក្រិដ្ឋ

ឃុំព្រះនេត្រព្រះ ខែតុលាឆ្នាំ១៩៤៨...

នៅរំលងអាធ្រាតជិតភ្លឺ ស្រាប់តែមានឆ្កែព្រុសលាន់ នឹងស្នូរសន្ធឹក ជើងសេះមកដល់មុខផ្ទះ ។ តាមាំងវាចាខ្សិប១ ដាស់មីងនួនឡើង :

- នួនអើយ! នៅខាងក្រៅមានរឿងអ្វីហ្នឹង? ឬក៏ពួកចោរភ្នំជញ្ជាំងវាមក អុកឡុកភូមិយើងទៀតហើយ?

មិនទាន់ងើបពីគ្រែស្រួលបួលផង ស្រាប់តែមានបុរសបិទមុខម្នាក់ធាក់ ទ្វារចូលមក ថែមទាំងគំរាមថា :

- បើចង់រស់នៅអោយស្ងៀម ហើយឆាប់ប្រមូលលុយមាសប្រាក់មកឱ្យជា ប្រញាប់ ។

រំពេចនោះ ស្រាប់តែតាមាំងឮសម្លេងកូនស្រីរបស់គាត់ទាំងពីរនាក់ ស្រែករំពងឡើងនៅបន្ទប់ម្ខាង ។ គាត់ក៏ស្ទុះហក់ចេញពីគ្រែ តែក៏ដួល ថ្ងោលទៅលើក្តារផ្ទះ :

- នែ៎! កុំធ្វើអី កូនស្រីយើង... ឯងចង់បានអីក៏យកទៅ..សូមតែកុំប៉ះពាល់ កូនយើងបានហើយ (តាមាំងស្រែកខ្លាំង១)

មីងនួនរត់រឹងទៅរកជួយកូនរបស់គាត់ តែត្រូវមេចោរគៀសជើងដួល គ្រាំងទៅនឹងក្តារផ្ទះ :

- យើងប្រាប់ហើយថានៅអោយស្ងៀម បើចង់មានជីវិត...(ចោរគំរាម)

ស្រាប់តែមីងនួនឮសម្លេងកូនស្រីទាំងពីរស្រែកហៅ :

- ជួយផង! ជួយផង! ម៉ែ ពុក!... បងណាវ...

មីងនួនស្ទុះរឹងទៅរកជួយកូន ស្រាប់តែមេចោរនោះ លើកកាំបិតគប់វ៉ៃ ត្រូវចំស្លាបប្រជ្រៀវឆ្វេងរបស់មីងនួនពីក្រោយ ធ្វើអោយមីងដួលប្រួសទៅ ក្នុងថ្លុកឈាម ។ ពួកចោរទាំងបីនាក់នោះ ក៏ប្រមែប្រមូលតវ៉ាន់តាមអំពើ ចិត្តរួច ហើយក៏ប្រទាញប្រទង់កូនស្រីក្រមុំទាំងពីររបស់តាមាំងដាក់លើខ្នង សេះបំផាយចេញទៅ...

នៅឯកុដិមួយក្នុងវិហារវត្តព្រះនេត្រព្រះ ភិក្ខុករុណាតើនឡើងដើម្បី សំណាក់ធមិ ស្រាប់តែដាក់ភ្នែកទៅក្រៅតាមប្រឡោះបង្អួច ឃើញអណ្តាត ភ្លើងសន្ធោកប់មេឃនៅម្តុំដីភូមិតាមាំង ។ ព្រះអង្គនឹកពិភាល់ក្នុងចិត្ត ក៏ ស្ទុះរឹងរត់ចេញទៅយ៉ាងលឿន ។ នៅទីនោះ ភិក្ខុករុណាបានប្រទះឃើញតា មាំងបបោយដៃប្រឹងលូនចេញពីផ្ទះដែលកំពុងត្រូវអណ្តាតភ្លើងលេប...

- ពូមាំង...? (ភិក្ខុករុណាលាន់មាត់ឡើង)

CHANBOKEO.COM

ព្រះអង្គក៏ស្ទុះរត់កាត់អណ្ដាតភ្លើង ទៅលើកតាមាំងត្រកងឡើងរត់ ចេញមកក្រៅ។ ខ្លួនតាមាំងវិញបានត្រូវភ្លើងដុលរោលស្ទើរពាសពេញ។ ចំណែកភិក្ខុយើងក៏ត្រូវភ្លើងឆេះរលាកខ្លួនមិនស្ទើរដែរទេ។ ភ្លាមនោះ តាមាំងលើកដៃចង្អុលទៅទិសខាងលិច ខ្សិបប្រាប់ថា ៖

- កូនទៅជួយកូនណាវនិងកូនណៃផង។ ពួកចោរភ្នំជញ្ជាំង..វាចាប់ទៅ...

មានប្រសាសន៍បានតែប៉ុននេះ តាមាំងក៏បាត់ស្មារតីទៅ។ ភិក្ខុយើង ស្លុតចិត្តពេក គិតអ្វីមិនទាន់ ក៏ស្ទុះរត់រឹងកាត់វាលស្រែតាមទិសដែលតា មាំងចង្អុលប្រាប់។ ភ្លាមនោះ មានអ្នកស្រុកពីរបីនាក់មកដល់ ឆ្លេឆ្លារកជួយពន្លត់ភ្លើងក្រែងត្រូវឆេះរាលដាលទៅក្រោលគោនិងជង្រុកស្រូវទៀត។

ភិក្ខុករុណារត់មកដល់ទួលព្រៃគុម្ពោតមួយ ឆ្ងាយពីភូមិប្រហែលជាង ពីរគីឡូម៉ែត្រ ស្រាប់តែប្រទះនឹងសេះបីក្បាល ព្រមទាំងឮសម្រែកមនុស្ស ស្រីស្រែកលាន់ឮគ្រលួច ៖

- ជួយផង..! ជួយ... អាចង្រៃ... លែងយើង...អ៊ុយ...

ពេលនោះ ភិក្ខុករុណាលែងគិតអ្វីឃើញហើយ ក្រៅតែពីស្រវាមែក ឈើងាប់ធំមួយ ស្ទុះទៅវាយចោរទាំងកំរោល។ នៅក្រោមរាត្រីដែលមាន ចំណិតខែដ៏តូច រះចាំងពន្លឺព្រាលៗ ភិក្ខុគ្រវីដំបងមែកឈើនោះយ៉ាងអស់ ទំហឹងដៃ។ ចៃដន្យពួកវាមិនបានប្រុងខ្លួន ត្បិតអាល័យតែផ្ចង់ស្មារតីលើ ការយាយីប៉ុនប៉ងរំលោភក្មេងស្រី ក៏ត្រូវព្រះអង្គវាយដួលត្នោលៗ។ ប៉ុន្តែពួកវាមានគ្នាច្រើននាក់ ទំរាំវាយផ្ដួលពួកវាបាន ព្រះអង្គសោះខ្យល់ស្ទើរតែ មរណាជីវិតដែរ។ ពេលនោះ ចោរទាំងបីដួលបាត់ស្មារតីអស់ មិនដឹងថាពួក វាសន្លប់ឬក៏ស្លាប់ទេ..តែភិក្ខុយើងគ្មានឱកាសនឹងគិតពិចារណាបាបបុណ្យអ្វីតទៅទៀតឡើយ ក្រៅពីគិតម្យ៉ាងប៉ុណ្ណោះ គឺសង្គ្រោះនារីរងគ្រោះពីររូប។ រំពេចនោះ ព្រះអង្គបានប្រទះឃើញកងណាវត្រូវចោរចងមាត់ចងដៃជើង មានខោអាវដាច់ដោចច្រើនកន្លែង តែនាងនៅមានស្មារតីនៅឡើយទេ។ នៅម្ខាងទៀត ភិក្ខុករុណាបានឃើញកងណៃដែលត្រូវពួកចោរសម្រាតខោអាវអស់ពីខ្លួនបំរុងនឹងចាប់រំលោភនោះ កំពុងតែដួលដេកបាត់ស្មារតីឈឹង ក្នុងថ្លុកឈាម។ ភិក្ខុវន្ធត់ស្មារតីណាស់ ក៏ធ្មេចព្រះនេត្រដោះស្បង់ពីកាយ ទៅដណ្ដប់រុំឱ្យធិតារបស់យើង ហើយក៏ដកខ្លួនគេចមកឈរយ៉ាងឆ្ងាយ មិនហ៊ានបែរមើលត្រលប់ទៅវិញទេ។ ចៃដន្យពេលនោះ ភិក្ខុក៏មិនឃើញអ្នក ស្រុកអ្នកភូមិណាម្នាក់រត់មកជួយពីក្រោយសោះ នឹងឈរចាំទីនោះយូរ ក្រែងពួកចោរវាដឹងខ្លួនវិញ... តែបើយកខ្លួនទៅជួយនារីរងគ្រោះទាំងពីរ នោះវារិតតែខុសក្រិត្យវិន័យជាសង្ឃ ត្បិតព្រះអង្គត្រូវប៉ះពាល់ខ្លួននារី... តើព្រះអង្គត្រូវធ្វើយ៉ាងណា? តែលុះពិចារណាយូរទៅឃើញថា ការជួយ សង្គ្រោះជីវិតមនុស្ស និងរក្សាសុវត្ថិភាពជូននារីរងគ្រោះទាំងពីរមានសារៈ សំខាន់ណាស់ ណាមួយព្រះអង្គក៏បានធ្វើខុសវិន័យសង្ឃរួចហើយ ដែលបានរត់ចេញពីវត្ត ទាំងយប់អធ្រាត វាយសំពងចោរសន្លប់ដល់ទៅបីក្បាល ភិក្ខុ យើងក៏លែងគិតអីច្រើនតទៅទៀតដែរ។ ភ្លាមនោះ ព្រះអង្គក៏ស្ទុះ ត្រលប់ក្រោយស្រាយចំណងឱ្យកងណាវភ្លាម ៖

- ណាវដើររួចទេ?

- ចាស... រួច...មិនអីទេ...

ធិតាក៏ត្រដរងើបឡើងដើរទាំងយ៉ាប់យ៉ឺន ។ ភិក្ខុករុណាក៏ស្រវាលូកដៃត្រកងកាយកងណៃបីឡើងរត់សំដៅភូមិវិញយ៉ាងលឿន ។ លុះដើរមក ជាយដីភូមិទើបមានអ្នកស្រុកគេឃើញហើយស្ទុះរត់មកជួយអ៊ូអែ ។ កាល បើដឹងថាពួកចោរវាបាក់លោងនៅត្រង់ម្តុំណាអ្នកស្រុកមួយចំនួនក៏លីផ្គាក់ លីពូថៅសំដៅទីនោះភ្លាម ។ រីឯផ្ទះរបស់តាមាំងវិញក៏បានឆេះរាបដល់ដី ។ ចំណែកតាមាំងបានត្រូវអ្នកជិតខាង ជួយសង្គ្រោះយកទៅរក្សានៅផ្ទះ របស់គេ ។ ដោយហេតុថាផ្ទះរបស់ភិក្ខុករុណាបានបិទទ្វារទុកចោលយូរ ហើយគ្មាននរណានៅ អ្នកស្រុកក៏ស្រុះស្រួលជួយគ្នានាំកងណៃនិងតាមាំងទៅសំរាកព្យាបាលរបួសនៅទីនោះ បណ្តោះអាសន្នសិនទៅ ។

នៅវត្តព្រះនេត្រព្រះ ព្រឹកព្រហាមឡើងថ្ងៃដដែល...

ព្រះគ្រូឧត្តរៈ សូត្រធម៌ឧប្បជ្ឈាយ៍ការលាចាកផ្នួសរបស់ភិក្ខុករុណាដោយមានព្រះសង្ឃនិងចាស់ៗជាច្រើននាក់មកចូលរួមផង ។ បន្ទាប់មក ព្រះគ្រូក៏មានដីការថា :

- ចៅករុណាអើយ! កុំស្តាយក្រោយអី! ហោចណាស់ ចៅក៏បានប្រព្រឹត្ត អំពើល្អក្នុងការជួយសង្គ្រោះអ្នករងគ្រោះដែលជាអ្នកមានគុណរបស់ចៅ ។ ការលាផ្នួសរបស់ចៅពេលនេះ មិនអាប់អោនដូចនេនទុំដែលបោះបង់ស្បង់ចោលព្រោះក្តីរវើរវាយនឹងស្នេហានោះទេ ។ យើងក៏មិនបន្ទោសចៅឡើយ ធ្វើម៉េចចៅមានវាសនានឹងម្លប់ព្រះធម៌បានត្រឹមប៉ុណ្ណោះប៉ុន្តែចិត្តរបស់ចៅ នៅមានសីលធម៌ច្រើនណាស់ក្នុងខ្លួន ទោះបីមិនបាននៅរក្សាផ្នួសក្នុងម្លប់ វត្តអារាមក៏ចៅនឹងមានជីវិតភ្លឺស្វាងថ្ងៃណាមួយមិនខាន ដោយសារតែទឹក ចិត្តដ៏ល្អប្រពៃរបស់ចៅឯង ។

ភិក្ខុករុណាក៏បានក្លាយខ្លួនជានាយខ្នាដូចដើម ។ នៅលើខ្លួនរបស់គេ មានស្នាមរបួសដោយការរលាកភ្លើងជាច្រើនកន្លែងតែចាស់ៗនៅវត្តបាន យកថ្នាំមកលាបបិទឱ្យយ៉ាងផ្ចិតផ្ចង់ ។ បន្តិចមក នាយខ្នាក៏ក្រាបបង្គំលាព្រះគ្រូអធិការនិងព្រះសង្ឃគ្រប់ព្រះអង្គ ត្រលប់មកជួយមើលការខុសត្រូវ ក្នុងគ្រួសារតាមាំងវិញ ។

តាមពិត តាមាំងមានរបួសធ្ងន់ណាស់ដោយការរលាកភ្លើង ប្រហែល មិនអាចនឹងរក្សាជីវិតបានយូរទេ ។ កាលបើឃើញវត្តមានរបស់នាយខ្នាមក ដល់ផ្ទះពេលណា តាមាំងលូកដៃបក់ហៅអោយនាយមកអង្គុយជិត :

- ខ្នាអើយ! ពូអរគុណណាស់ដែលឯងបានពលីខ្លួន ដើម្បីសង្គ្រោះយើងនិង កូនស្រីទាំងពីរ...!

- បាទ៎!មិនអីទេពូ...គ្រាន់តែជាសន្តានចិត្តកតញ្ញូរបស់ក្មួយដ៏តិចតួចចំពោះ ពូ ដែលធ្លាប់មានមេត្តាចំពោះក្មួយតែប៉ុណ្ណោះ ។

- ហើយពេលនេះ កងណៃគេដឹងខ្លួនហើយឬនៅ?

- ខ្ញុំមិនទាន់បានទៅមើលនាងនៅឡើយទេ ពូ...

- អឺ...បើអញ្ចឹង កូនឯងទៅមើលប្អូនផងទៅ...

ថាហើយ តាមាំងក៏ធ្មេចភ្នែកសម្ងំបំបាត់ការឈឺចាប់ទាំងឡាយ ក្នុង ចិត្តនឹកទៅដល់មីងនួនជាប្រពន្ធដែលលាចាកលោកទៅដោយមិនបានលា គ្នាមួយម៉ាត់ ។ ទឹកភ្នែកច្រើនដំណក់បានហូរចាកកែវភ្នែកតាមាំងដែលរអ៊ូ ខ្សិបៗថា :

CHANBOKEO.COM

- នួនអើយ...!! បងនឹងទៅតាមអូនឆាប់នេះហើយ...ទុកឱ្យបងធ្វើកិច្ចការ មួយជាចុងក្រោយសិន មុននឹងបងលាកូនរបស់យើងទៅ...

នៅបន្ទប់ម្ខាងទៀត កងណៃគេងសន្លឹងសន្លៃនៅលើគ្រែតែម្នាក់ឯង ។ នាយខ្នាដើរចូលមកដល់ ឃើញនាងបិទភ្នែកសម្ងំគេង នាយក៏ដាក់ខ្លួន អង្គុយចុះក្បែរនាង ហើយយកដៃស្ទាបថ្ងាសនាងថ្នមៗ ស្រាប់តែធិតាបើក ភ្នែកឡើង :

- អូនណៃ...បានធូរស្រាលខ្លះទេ? (មាណពសួរ)

នៅលើផ្ទៃមុខរបស់ធិតាមានស្នាមជាំជាច្រើនកន្លែង ទំនងជាត្រូវពួក ចោរទះតប់ធ្ងន់ធ្ងរណាស់ ។ គ្រាន់តែក្រលេកឃើញវត្តមានរបស់នាយខ្នា ពេលណា នាងស្រក់ទឹកភ្នែកច្រោក ងើបឡើងស្រវាអោបនាយយ៉ាងណែន ធ្វើអោយយុវជនយើងភ្ញាក់ស្រលាំងកាំង :

- បងខ្នា!....

ធិតាយំខ្សឹកខ្សួលអួលអាក់ក្នុងចិត្តក្រៃលែង ។ នាងទ្រោបមុខលើដើម ទ្រូងរបស់នាយខ្នា យំសស្រាក់ ។ នរៈយើងយកដៃអង្អែលខ្នងនាងថ្នមៗ ជួយលួងលោមអោយនាងបានធូរស្បើយក្នុងចិត្ត :

- ពេលនេះ អូនណៃផុតពីគ្រោះថ្នាក់ហើយ ឈប់ភ័យទៅ! បងខ្នាក៏វិល ត្រលប់មកផ្ទះវិញដែរ មករក្សាការពារអូននិងក្រុមគ្រួសារ...ឈប់ភិតភ័យ ទៀតទៅ ។ រីឯពួកចោរអស់នោះក៏ត្រូវអ្នកស្រុកចាប់អស់ហើយ មិនអាច ត្រលប់មកធ្វើបាបអ្នកស្រុកបានទៀតហើយណ៎ាអូន ។

តែធិតាយើងនៅតក់ស្លុតមិនទាន់បាត់ទេ ណាត្រូវចោរធ្វើបាប ណា បាត់បង់ម្តាយរបស់ខ្លួនទៅដោយបង្ហំ ណាឪពុកមានរបួសធ្ងន់ ឯផ្ទះវិញត្រូវ ភ្លើងឆេះអស់ទៀត... នាងតូចតក់ស្លុតណាស់ មិនអាចទប់ស្មារតីបានទេ :

- បងខ្នា...ពេលនេះ ក្រុមគ្រួសាររបស់ខ្ញុំអស់មានអ្វីទៀតហើយ...

- នរណាថា? យើងអស់ទ្រព្យមែន តែយើងនៅមានជីវិត នៅមានសេចក្តី ស្រលាញ់ចំពោះគ្នា យើងនឹងកាន់ដៃគ្នាកសាងជីវភាពសាជាថ្មី... ណៃ! អូននៅមានបងណ៎ា...បងនឹងជួយអូនជានិច្ច ដរាបណាជីវិតបងមាន... បង មិនអោយអូនត្រូវវេទនាទេ...

នាយខ្នាអោបស្រីតូចក្នុងរង្វង់ដៃ ដោយដួងចិត្តអាណិតអាសូរបំផុត ។ គេនៅថ្នាក់ថ្នមនាង បបោសលួងលោម... ជាបងប្រុសផង.. ជាបុរសដែល លួចពេញចិត្តលើរូបនាងផង... ជាក្មេងកត្តញ្ញូដែលត្រូវគោរពសងគុណតា មាំងអ្នកមានគុណរបស់គេផង... ។ នៅខាងក្រោយខ្នង ឯខាងក្រៅបន្ទប់ កងណាវដើរចេញពីផ្ទះបាយមក ដោយមានកាន់ស្លកបបរសមកជាមួយ ផង ។ កាលបើដើរមកប្រទះឃើញប្អូនស្រីកំពុងស្ថិតនៅក្នុងរង្វង់ដៃរបស់ នាយខ្នា នាងបើកភ្នែកធំៗភ្ញាក់ស្រលាំងកាំង ជ្រួញចិញ្ចើមនឹកខកចិត្ត ណាស់ ប៉ុន្តែនាងរក្សាកិរិយាស្ងៀមស្ងាត់មិនស្តីអ្វីទេ ក៏ដកខ្លួនថយចេញទៅ វិញ មិនអោយអ្នកទាំងពីរឃើញឡើយ ។

ច្រើនថ្ងៃក្រោយមក...

CHANBOKEO.COM

សភាពផ្លូវកាយរបស់ស្រីតូចកងណៃបានប្រសើរបន្តិចហើយ ប៉ុន្តែនាង នៅមានស្មារតីមិនទាន់ល្អនៅឡើយទេ ត្បិតនៅរន្ធត់តក់ស្លុតនឹងហេតុ ការណ៍ថ្មីៗនោះនៅឡើយ ។ ចំណែកកងណាវិញ ពិតមែនតែធិតាជា មនុស្សស្ងៀមស្ងាត់ រួចមិនបានទទួលរងរបួសរូបកាយអ្វីច្រើនដូចជាប្អូនស្រី របស់នាង តែឆវីយើងក៏របួសផ្លូវចិត្តមិនតិចឡើយ ។ ក្រៅពីការបាត់បង់ម្តាយ បាត់បង់ផ្ទះសំបែង នាងក៏បាត់បង់កត្តិយស ដែលខ្លួននឹងប្អូនត្រូវពួក ចោរប្រមាថរូបកាយយ៉ាងធ្ងន់ធ្ងរ ។ ចំណែកឪពុករបស់នាងក៏មានរបួសធ្ងន់ ពិបាកនឹងព្យាបាល ។ ពេលនេះ នាងនៅមានភាពមាំទាំខាងផ្លូវកាយជាងគេ ប៉ុន្តែ សភាពស្និទ្ធស្នាលនិងការថ្នាក់ថ្នមរបស់នាយខ្នាចំពោះកងណៃប្អូនស្រី របស់នាង បានធ្វើអោយមាណវីយើងរិតតែអស់កម្លាំងចិត្តឡើងរាល់ថ្ងៃ មួយថ្ងៃបន្តិច មួយថ្ងៃបន្តិច ទៅដែរ ។

នៅក្រោមម្លប់ឈើចំហៀងផ្ទះ...

កងណៃអង្គុយយោលទោងខ្សែផ្តៅយឺតៗ...តែម្នាក់ឯង ។ ថ្ងៃនេះនាង តូច មានអារម្មណ៍ថា ខ្លួននាងបានធូរស្រាលខ្លះៗហើយទើបងើបមកអង្គុយ លេងនៅក្រៅ ។ ចំណែកកងណាវិញ បានត្រលប់ទៅដីភូមិចាស់របស់នាង ដើម្បីមើលជ្រូកមាន់ទា និងរកបេះដំណាំផ្សេងៗយកមកដណ្តាំស្ល ។ ភ្លាម នោះ នាយខ្នាបានជិះកង់មកដល់ :

- បងខ្នា មកពីណាហ្នឹង?

- បងទៅជួបគេនៅជប់ ។

- អូហ៍ ធ្វើអីទៅបង?

- បងសុំគេធ្វើកូនជាងសង់ផ្ទះ យកប្រាក់ឈ្នួលខ្លះៗមកជួយក្រុមគ្រួសារ របស់យើង...

- ហ៊ឺ! មិនគួរណា ក្រុមគ្រួសារខ្ញុំ ក្លាយជាបន្ទុកធ្ងន់ដល់បងសោះ..

- កុំនិយាយអញ្ចឹងមើល៍អូនណៃ...បងមិនដែលគិតដូច្នោះទេ ។

- ហើយបងចូលធ្វើការអង្កាល់ដែរ?

- ស្អែកនេះហើយ ។ ពេលបងរវល់ អូនណៃមើលថែខ្លួនផងណា៎

- ចា៎ស! អូនណៃជិតជាស្រួលបួលហើយ...បងកុំបារម្ភអី!

ពេលនោះ យុវជនយើងសម្លឹងមើលកងណៃឡើងភ្លឹក កាលបើឃើញ នាងញញឹមមករកខ្លួន ។

- បងមើលអីហ្នឹង? (កងណៃសួរ)

- គឺ..ថា..បងមានអ្វីអោយអូនណា៎!

- អោយអ្វីទៀតហើយ? ណៃគិតថា ច្បាស់ជាខ្សែកទៀតហើយ..!

- យី! ប៉ិនទាយម្ល៉េះ?

- ព្រោះអីពេលណាបងមានអារម្មណ៍ល្អ បងតែងតែធ្វើខ្សែកអោយណៃ ពាក់លេងជានិច្ច ។

- តែខ្សែកថ្ងៃនេះខុសពីថ្ងៃមុនទេណា៎ !

- អញ្ចឹងហ្អែស? នៅឯណា? អូនណៃចង់ពាក់...

CHANBOKEO.COM

នាយខ្នាញញឹមឡើង ហើយដើរគេចទៅម្ខាង មួយស្របក់ក៏ត្រលប់ មកដល់វិញ :

- នេះនែ ! ស្អាតទេ?

- អូហ៎ ស្អាតណាស់...ជាកម្រងផ្កាស្បៃរឿង ស្រស់ដល់ហើយ ។

- ម៉ោះបងពាក់អោយ!

ធិតាតូចអោនក្បាលទទួលកម្រងផ្កាស្បៃរឿងនោះជាប្រញាប់ :

- ណៃស្រស់ទេ បងខ្នា?

- ស្រស់! ស្រស់ណាស់ ដូចទេពធិតាតូចពីស្ថានសួគ៌អញ្ចឹង..

- ប៉ុន្តែឈ្មោះណៃមិនសមជាកូនទេពធិតាសោះ...

- អញ្ចឹងបងដូរឈ្មោះថ្មីអោយ ដាក់ថា...

- ដាក់ថាយ៉ាងម៉េចទៅបងខ្នា?

- ថា ទេពធិតា ចរណៃ យ៉ាងម៉េចដែរ?

- អ៊ុយពិរោះដល់ហើយ...មិនយកទេ..យកឈ្មោះត្រឹមអូនណៃពិរោះជាង!

ទាំងពីរនាក់ក៏សើចកខឹកឡើងប្រកបដោយសេចក្តីសុខក្នុងចិត្ត ។ បន្តិច មកកងណៃស្រដីថា :

- ណៃចូលចិត្តកម្រងផ្កាណាស់ ។ បើសិនបងខ្នាក្រងអោយពាក់រាល់ថ្ងៃ ច្បាស់ជាណៃក្លាយជាទេពធិតារាល់ថ្ងៃហើយ...

- ទោះមិនពាក់កម្រងផ្កា ក៏អូនណៃជាទេពធិតាដ៏ស្រស់ស្អាតក្នុងបេះដូង របស់បងស្រាប់ទៅហើយ អូនមិនដឹងទេហ៎?

- ស្លាប់ហើយ...ណៃមិនចង់បានទេ!

- ហេតុអីទៅ...?

- គឺ... ខ្លាចសង្សារបងខាំ...

- ពុទ្ធោ! បងមានសង្សារពីណា? ចេះតែថាហើយ អូនណៃ!

- ចុះនរណាទៅដឹង?

ស្រាប់តែនាយខ្នាលើកដៃឡើង :

- អោយបងស្បថចុះ...បងគ្មានទេ...បងមានតែអូនណៃម្នាក់គត់...

- ស្លាប់ទៀតហើយបងខ្នា! អូនណៃជាប្អូនស្រី...មិនមែនសង្សារបងទេ... យ៉ាប់មែន បងឯងនេះ!

ថាហើយនាងក៏យកដៃមួលសាច់ចង្កេះរបស់នាយខ្នាភ្លាម :

- អ៊ុយ!... (នាយខ្នាលាន់មាត់ធ្វើមុខជូរហួញ)

- បងខ្នាយ៉ាងម៉េចហ្នឹង?

កងណៃក៏ស្រវាចាប់លាត់អាវនាយខ្នាឡើង ឃើញនាយមានស្នាម រលាកភ្លើងដែលនៅជំថៅមិនទាន់សះនៅឡើយ ។ នាងក៏លើកដៃសំពះនរៈ យើងភ្លាម :

- ពុទ្ធោ! អោយណែសំពះសុំទោសបងផងណា៎...ណែអត់ដឹងថាបងខ្នាមាន របួសទេ...សូមទោស! សូមទោសបងខ្នា!

នាយខ្នាចាប់ដៃនាងជាប់ :

- មិនបាច់សំពះបងទេ...គ្រាន់តែនិយាយថាសូមទោសបានហើយ...ចំពោះ ណែ បងអភ័យទោសអោយអូនបានគ្រប់យ៉ាងទាំងអស់...

ធិតាក៏ញញឹមឡើងតបទៅនាយខ្នាយ៉ាងបំព្រង ។ នៅក្នុងចិត្ត ឆវីមាន អារម្មណ៍ថា ជីវិតនាងមានសេចក្ដីសុខណាស់ ពេលនាងបាននៅជិតគេ  មិន ដឹងថា នោះជាអារម្មណ៍អ្វីដែរទេ គ្រាន់តែដឹងជាសុភមង្គលដ៏ប្លែកមួយ...

នៅខាងក្រៅរបង កងណាវ៉ឈរលិបលៗមិនហ៊ានដើរចូលមកទេ ។ ការពិតនាងបានមកដល់យូរហើយ ហើយថែមទាំងបានឃើញគ្រប់កាយ វិការទាំងអស់ ដែលនាយខ្នានិងប្អូនស្រីប្រស្រ័យនឹងគ្នា យ៉ាងជិតជិតស្និទ្ធ ស្នាល ។ នាងឈរឈ្ងោកមុខ លួចសម្រក់ទឹកភ្នែកតក់ៗ តែម្នាក់ឯង មិនស្រដី...

នៅរសៀលថ្ងៃមួយ...

តាមាំងមានអាការៈកាន់តែធ្ងន់ខ្លាំងឡើងៗហើយ ។ គាត់ហាក់ដូចជា ដឹងខ្លួនមុន ក៏ហៅនាយខ្នាអោយជិះកង់ទៅតាមតាញ៉ៅមេឃុំ យាយព្រីង និងទៅនិមន្តព្រះគ្រូអធិការឧត្តរៈអោយមកជាប្រញាប់ ។ នៅខាងចុងជើង របស់តាមាំង កូនស្រីទាំងពីររបស់គាត់អង្គុយអមឪពុកម្ខាងមួយយាម កំដរថែរក្សាឪពុកនៅគ្រាដង្ហើមចុងក្រោយ ដោយទឹកមុខក្រៀមក្រំសោ កសៅបំផុត ។ រីឯភ្លើងទៀនដែលអុជនៅលើក្បាលដំណេករបស់តាមាំង ក៏កាន់តែអ៊ីវ ទៅៗ បន្តិចម្ដងហើយ...

បន្តិចក្រោយមក នាយខ្នាបាននាំ តាមេឃុំ យាយព្រីង និងព្រះគ្រូ អធិការឧត្តរៈមកដល់ ។ ព្រះគ្រូក៏អោនដាក់ព្រះកាណិស្ដាប់តាមាំងផ្ដាំផ្ញើជា ចុងក្រោយ ដោយមានតាញ៉ៅនិងប្រពន្ធគាត់ជាសាក្សី ចំពោះបណ្ដាំទាំងឡាយនោះ ។

000000000000000

00000

0

CHANBOKEO.COM

# វគ្គទី៨

# ភ្លើងទោសៈ

នៅផ្ទះរបស់ជាងសម្លាក...

ចរណៃដួសបបរក្ដៅៗ ដាក់ស្លាកយកមកដល់ :

- បងជាង! ក្រោកឡើងពិសារបបរ ទាន់នៅក្ដៅ...បងមិនបានទទួល ទានអាហារមួយ យប់មួយថ្ងៃហើយ តិចលោឃីរិតតែធ្ងន់ទៅ...

ជាងសម្លាកកំពុងគេងសម្ងំនៅលើគ្រែ ។ កាលបើឃើញធិតាបំរើ គេ លួចញញឹមក្នុងចិត្ត ហើយស្រដីតបវិញ :

- ណៃហៅបងខុសឈ្មោះ បងមិនងើបទេ...

ភ្លាមនោះចរណៃក៏សើចខឹកៗ ហើយពោលបន្តថា :

- អ៊ុំយ! បងខ្មា! បងក្លាយជាកុមារតាំងពីអង្កាល់ហ្នឹង?

- គឺ...តាំងពីបានអូនណៃមកបំរើបងនោះអី...ថ្ងៃនេះ ដៃបងក៏ឈឺដែរ មិន អាចដួសទទួលទានបានទេ..អូនណៃបញ្ចុកបងណា៎!!

ជាងយើងតបវិញទាំងញញឹមរីករាយ ។ ធិតាក៏សើចខឹកៗឡើងតែនាង មិនបានប្រកែកប្រណាំងនឹងនាយទេ ។ ពេលនេះ អ្នកទាំងពីរហាក់ដូចជា មានអារម្មណ៍វេញធ្លុងមួយទៅហើយ នរណានិយាយអ្វីក៏សុទ្ធតែល្អ សុទ្ធតែ សុភមង្គលទាំងអស់ ។ គេបញ្ចុកអាហារគ្នាទៅវិញទៅមក សាសងគ្នារអឹក លាយឡំនឹងសំណើចកខឹកសាជាថ្មី មើលទៅមិនខុសគូស្វាមីភរិយាមួយគូ ដែលទើបនឹងរៀបការថ្មីៗនោះឡើយ ។ គេមានសេចក្ដីសុខណាស់ ជា សេចក្ដីសុខដែលបេះដូងរបស់គេបានដង្ហោយហៅជាយូរមកហើយ ។

ចៃដន្យ នៅពេលអ្នកទាំងពីរកំពុងតែទទួលសុភមង្គលដ៏សុខុមរមនា ស្រាប់តែលោកចក្រាបរឡានហ្សិបមកដល់ឈប់នៅមុខផ្ទះ រួចស្ទុះហក់ ឡើងចូលមកដល់ក្នុងបន្ទប់របស់ជាងសម្លាកយ៉ាងរហ័ស ។ កាលបើឃើញ ចរណៃកំពុងបញ្ចុកបបរទៅជាងយើង គេក៏ស្ទុះយកដៃទៅទះស្លាបព្រា ដែលនៅក្នុងដៃមាណវី អោយហោះខ្ចាយបបរព្រោងព្រាត ។ រីចានបបរ វិញក៏ហោះពីដៃធិតា ក្រឡាប់ទៅលើក្ដារផ្ទះ កំពប់បបរអស់ ។ ភ្លាមនោះ បុរសយើងក៏ស្រដីថា :

- ចរណៃ...យើងជិតភ្ជាប់ពាក្យនឹងគ្នាហើយ ហេតុអ្វីក៏អ្នកនាងបំបាក់មុខខ្ញុំ យ៉ាងនេះ? នេះឬកិរិយាអ្នកគ្រួដ៏ថ្លៃថ្នូរកូនស្រីលោកភូឈួយខេត្តចំណាប់? អ្នកនាងមិនត្រឹមតែបំបាក់មុខខ្ញុំទេ ថែមទាំងបំបាក់មុខម្ដាយរបស់ខ្ញុំនិង បំបាក់មុខឪពុកម្ដាយរបស់អ្នកនាងទៀត ។ មើលចុះ... តើបុរសម្នាក់នេះ សំខាន់អ្វីដែរ

CHANBOKEO.COM

បានជាអ្នកនាងត្រូវមកមើលថែរក្សាផ្គាប់ផ្គុនវាអីដល់ម្លឹង? នាងមិនគិតពីចិត្តពីបេះដូងរបស់ខ្ញុំខ្លះទេ? ពេលនេះ តើអោយខ្ញុំយកមុខទៅទុកឯណា ព្រះអើយ?

បុរសសង្ហាគំហកកោក១ ញាប់ពេករហូតដល់អ្នកគ្រូរកឆ្លើយមិនទាន់ សោះ។ កំពុងតែភាំងស្មារតី ស្រាប់តែលោកចក្រាលូកស្រវាចាប់ដៃអ្នកគ្រូ អូសនាងចេញទៅក្រៅទីងណាត់ទីងណែង។ ជាងសម្លាកឃើញដូច្នោះ ទ្រាំមិនបានក៏ស្ទុះហក់រឹងទៅច្បាមលោកចក្រា ប្រឡេះដៃនាយចេញពីចរណៃ ហើយ ប្រច្រាននាយចេញច្រលោតតោតយ៉ាងឆ្ងាយចេញពីមាណវី :

- លោកចក្រា! នេះជាផ្ទះរបស់ខ្ញុំ លោកគ្មានសិទ្ធិមកអុកឡុកបង្កហេតុទី នេះឡើយ ជាពិសេសគឺមាក់ងាយស្ត្រីមួយរូបនេះ។

លោកចក្រាដង្ហោកម្លោះដ៏សង្ហាដែលធ្លាប់តែក្អេងក្អាង មិនដែលចុះ ញ៉មនរណា កាលបើត្រូវនាយយើងច្រានច្រលោតទៅមុខទៅក្រោយយ៉ាង ដូច្នោះ ខឹងណាស់ ក៏ស្ទុះងើបឡើងចង្អុលមុខជាងសម្លាកភ្លាម :

- នែ៎ អាខ្នា អាខ្មៅ អាកំសាកសម្លាកមុខ! យើងធ្លាប់ទាត់ឯងឃើខ្លួនច្រើន ដងហើយ នៅមិនចាំទេ? ឯងហ៊ានមកហៃហៃស៊ីដែរ? ឯងដឹងទេ ថាឯង កំពុងបោះសន្ទូចរំលងភ្នំ? ដឹងទេថាអ្នកគ្រូចរណៃជារបស់យើង ដោយមាន ចាស់ទុំដឹងឮទាំងភូមិ?

ទ្រាំអត់ធ្មត់មិនបាន នាយខ្នាក៏ទាញយកចរណៃទៅលាក់ពីក្រោយខ្នង របស់ខ្លួន ហើយគំហករឹងតបវិញ ថា :

- មែនហើយ! កាលនោះ យើងជាក្មេងក្រីក្រ មានជំងឺ មានរាងកាយទ្រុឌ ទ្រោម មិនអាចតទល់អ្វីនឹងឯងបាន តែពេលនេះ យើងមិនមែនជាមនុស្ស ទន់ខ្សោយដូចឯងគិតតទៅទៀតទេ... បើឯងហ៊ានប៉ះពាល់ធ្វើបាបស្ត្រីមួយ រូបនេះពេលណា ឯងនឹងបានទទួលកណ្តាប់ដៃយើងវិញមិនខាន។ ពេលនេះ យើងឈប់អត់ធ្មត់បណ្តោយអោយឯងឈ្នះតទៅទៀតហើយ។ រួចចំពោះស្ត្រីមួយរូបនេះ ឯងក៏ត្រូវតែដឹងដែរថា នាងជាភរិយារបស់យើងយ៉ាងត្រឹម ត្រូវតាមប្រពៃណី។ គឺឯងវិញទេ ដែលកំពុងជាន់ឈ្លីកត្តិយសឪពុកម្តាយ ជាន់ឈ្លីកត្តិយសខ្លួនឯង ដោយឡើងមកលើផ្ទះរបស់គេ ចាប់ជំរិតភរិយារបស់គេទាំងកណ្តាលថ្ងៃ ថែមទាំងគម្រាមធ្វើបាបស្វាមីរបស់គេទៀតផង!

ភ្លាមនោះ លោកដង្ហោកម្លោះបើកភ្នែកធំ១ធ្វើស្រលាំងកាំង :

- ឯងនិយាយអីហ្នឹង អាខ្នា? នរណាជាភរិយារបស់ឯង?

- អឺ..! ស្តាប់អោយច្បាស់ទៅ! គឺអ្នកគ្រូចរណៃជាភរិយារបស់យើង!

- ឆ្កួត! និយាយស៊ីឆ្កួត១អញ្ចឹង? អ្នកគ្រូចរណៃជាកូនស្រីក្រមុំរបស់លោក ភូឈ្មួយខេត្តចំណាប់ ហេតុម្តេចបានក្លាយជាប្រពន្ធរបស់ឯងងាយ១ម្ល៉េះ? ឯងច្បាស់ជាឡប់សតិហើយ!!

- ចាំបាច់អីដែលយើងត្រូវមកពន្យល់ប្រាប់ឯងផង កាលបើឯងធ្វើឫកពា ព្រហើនច្រងេងច្រងាងដាក់យើង? នេះឬភាពថ្លៃថ្នូររបស់កូនអ្នកមាន? ពុទ្ធោអើយ! មានតែលុយតែខ្វះគុណធម៌ គួរអោយអាមាសអ្វីម្ល៉េះលោក!

ចរណៃធ្លាប់តែឃើញជាងសម្លាកជាមនុស្សស្ងៀមស្ងាត់ មិនសូវចេះ ស្រដី។ ពេលនេះ នាងចម្លែកចិត្តណាស់ដែលនាយចេះនិយាយច្រើនហើយ ហ៊ានតតាំងជាមួយកម្លោះអ្នកមានដោយឥតញញើតសោះ។ ភ្លាមនោះ លោកចក្រាក៏បែរមើលទៅចរណៃ ហើយបន្ទាបសម្លេង ស្រដីថា :

CHANBOKEO.COM

- ហេតុដូចម្ដេចក៏អ្នកនាងបណ្ដោយអោយបុរសកំទេចកំទីដូចអាខ្នា វាយក ផេះមកលាបមុខ លាបកត្តិយសរបស់អ្នកគ្រូ អោយប្រលាក់ប្រលូសយ៉ាង នេះកើត? យើងជាកូនអ្នកមានមុខមាត់ បុណ្យសក្តិណាំ... កុំយកកត្តិយស យើងទៅប្រលែងលេងនឹងមនុស្សមិនបានការដូចវានេះអី? អាខ្នាគ្រាន់តែ ជាជាងឈើអង្កាច់អង្កោច ជាមនុស្សក្រហាម រកបាយចុកមាត់មិនបាន ម្ដេចអ្នកគ្រូអោយកត្តិយសវាម្ល៉េះ? នេះ ខ្ញុំមកតាមអ្នកនាងអោយទៅផ្ទះ វិញណាំ។ ជាស្រីក្រមុំ មិនគួរមកនៅសម្ងំផ្ទះមនុស្សប្រុសតែពីរនាក់ស្ងាត់ៗ ដូច្នេះទេ... ម៉ោះ! អ្នកគ្រូចរណៃ យើងត្រលប់ទៅផ្ទះវិញ?

លោកចក្រាក៏ស្ទុះទៅជិតចរណៃ លូកដៃបំរុងចាប់នាងអូសឡើងឡាន របស់ខ្លួនទៅវិញ។

- លែងនាងភ្លាម (នាយខ្នាគំហក) ឯងគ្មានសិទ្ធិប៉ះពាល់ខ្លួនប្រាណនាងទេ សូម្បីតែចុងក្រចក...

ជាងសម្លាកយកដៃច្រានទ្រូងលោកចក្រាចេញ។

- នែ៎ អាខ្នា! យកដៃកខ្វក់របស់ឯងទុកចាប់បាយស៊ីទៅ កុំមកប៉ះយើង...

លោកចក្រាថាផងប្រច្រាននាយវិញផង។ ពេលនេះ ល្បែងដណ្ដើម ស្នេហាក្លាយជាទីលានកីឡាកម្លាំងបាយប្រយុទ្ធយកចាញ់ឈ្នះ។ ស្រាប់តែ នាងខឿនកូនស្រីអ្នកភូមិ បានមកប្រទះឃើញអ្នកទាំងពីរកំពុងប្រវាយ ប្រតប់គ្នា នាងក៏ស្រែកវ៉ាងឡើងកូកហៅរកជំនួយអន្តរាគមន៍។ អ្នកស្រុក ក៏រត់មកដល់ឈូឆរតែម្ដង តែគ្មាននរណាឃាត់ម្នាក់ទេ ត្បិតគេរាល់គ្នាមិន ជាចូលចិត្តលោកចក្រាដ៏ក្អេងក្អាងនោះតាំងពីយូរមកហើយ។ មើលចុះ! គេទាំងពីរមានវ័យស្របាលគ្នា ប៉ុន្តែកាលដើមឡើយ នាយខ្នាជាក្មេងស្គាំង ស្គម ហើយចក្រាជាកូនអ្នកមានមានសាច់មានឈាម តែពេលនេះ អ្វីៗ បែរជាផ្លាស់ប្ដូរមិនទៀង.. នាយខ្នាបានក្លាយខ្លួនជាបុរសដែលមានមាឌមាំ ដំបង មានសាច់ដុំពេញខ្លួន មិនដូចលោកចក្រាដែលមានរូបសស្ដើងស្រឡូន ដូចដើមស្រឡៅនោះទេ។ ការពិត គេជាបុត្រទោលនៃត្រកូលអភិជន។ គេមិនដែលធ្វើការនឹងកម្លាំងម្ដងណាសោះ រឿងអីដែលទៅមានសាច់ដុំនឹង តតាំងជាមួយមេជាង ដែលមានមាឌធំសាច់ដុំមាំនោះកើតទៅ? ពេលនោះ លោកចក្រាក៏ត្រូវជាងសម្លាកទាត់វិលដូចកន្ទេះឡង់ ហើយចាប់បោះផ្លោង ដូចកង្កែប ហោះចេញក្រៅរបងដីភូមិ ទៅដួលដេកនៅកណ្ដាលថ្នល់ ធ្វើ មាត់មួបៗដូចត្រីក្រាយឡើងគោកទៅហើយ។ ចរណៃឃើញដូច្នោះ ក៏ស្ទុះ ទៅឃាត់យ៉ាងរហ័ស ខ្លាចក្រែងមេជាងជ្រុលដៃ :

- បងខ្នា! ឈប់ទៅបង..! ប៉ុណ្ណឹងបានហើយ... កុំអោយដល់ថ្នាក់របួស កាយធ្ងន់ធ្ងរអី មើលទៅគេទ្រាំនឹងកម្លាំងដៃរបស់បងលែងបានហើយ។

ដោយខ្នាសនឹងការចោមរោមអ៊ូអររបស់អ្នកភូមិពេក ហើយក៏ពុំមាន នរណាម្នាក់ចូលធ្វើអន្តរាគមន៍ផងនោះ លោកចក្រាក៏ស្ទុះងើបឡើង ទាញ កូនសោបញ្ឆេះឡានបរចេញទៅយ៉ាងលឿនស្លេវតែម្ដង។ អ្នកស្រុកក៏ទះ ដៃហ៊ោរលាន់ក្រេវ។ ភ្លាមនោះ នាយប្រើកនិងនាយខ្លែងមិនដឹងជាលួច ចេញពីក្រហែងណាមិនដឹងស្រាប់តែស្រែកហ៊ោរឡើងនឹងគេដែរថា :

CHANBOKEO.COM

- ថ្វីដៃអស្ចារ្យមែនពូជាង! ពួកខ្ញុំមិនដឹងសោះថាពូជាងចេះក្បាច់គុនស៊ើង អស្ចារ្យយ៉ាងនេះ...!
តែប៉ុណ្ណោះភូមិយើងមានមេទ័ពហើយ ជយោ!

អ្នកភូមិឃើញខ្លះឃើញជាងមានកម្លាំងមកវិញក៏លាន់មាត់ថា :

- យីអើ! ព្រឹកមិញឃើញខ្សល់គ ដួលបាត់មាត់ យើងខំតែភ័យ ស្រាប់តែ ពេលនេះ
ជាងដាល់គេផ្អើលម៉ាស្រុក...តើជាងលេបថ្នាំអីក៏ជាមានកំលាំង លឿនម្ល៉េះហ្នឹង?

មេជាងឮប្រយោគនេះ នឹករអៀសខ្លួនតែម្តង។ មែនហើយ..ការពិត នោះ គេមិនបានឈឺពុតទេ។ ព្រឹកមិញ គេពិតជាមិនស្រួលខ្លួនពិតមែន តែ ព្រឹកមិញនិងពេលនេះវាខុសគ្នា ត្បិតពេលនេះគេមានថ្នាំលើកកម្លាំងចិត្ត នៅឈរពីក្រោយ មិនដូចព្រឹកមិញដែលកម្លាំងចិត្តរបស់គេ រត់អស់ពីខ្លួន នោះឡើយ។ គេលួចចោលកន្ទុយភ្នែកទៅអ្នកគ្រូចរណៃ ឃើញនាងញញឹម ធ្វើកិរិយារៀងអៀនប្រៀនមិនខុសគ្នាដែរ។ បែរទៅអ្នកភូមិវិញហាក់ដូច ជាចាប់ផ្តើមចាប់ភ្លឹក
អំពីចំណងដួងចិត្តយ៉ាងអាថ៌កំបាំងរវាងគេទាំងពីរ តិចៗហើយ។

មួយស្របក់ក្រោយមក អ្នកភូមិក៏បំបែកហ្វូងចេញទៅវិញ។

- អូនណៃ... ព្រលប់ហើយ..ម៉ោះ! បងជូនទៅផ្ទះ...

នាយខ្នាបបួលធិតាត្រលប់ទៅកាន់ទីកន្លែងរបស់នាងវិញ។ បន្តិចមក អ្នកទាំងពីរក៏កាន់ដៃគ្នាដើរញញឹម រហូតដល់ផ្ទះគ្រូថ្មី ដែលអ្នកគ្រូចរណៃ និងអ្នកគ្រូចំណានត្រូវស្នាក់នៅ។ ជាងសម្លាកជូននាងរហូតដល់មាត់ជណ្តើរ ផ្ទះ រួចស្រដីថា :

- អូនណៃ..គេងលក់សុបិនល្អណា៎...!

- ចា៎សបង!

បុរសយើងក៏លើកដៃរាហើយក៏ដើរបកក្រោយទៅវិញ ទាំងអារម្មណ៍រីករាយ។
ចរណៃឈរសម្លឹងបុរសរហូតដល់គេធ្វើដំណើរបាត់ស្រមោលទៅ ក្នុងស្បៃអន្ធការ ទើបឡើងជណ្តើរទៅលើផ្ទះ
ស្រាប់តែប្រទះនឹងចំណាន ដែលកំពុងឈរញញឹមដាក់នាង :

- បងណៃ! បងជាងស្រួលបួលគ្រាន់បើហើយហ្អែស បានជាមានកំលាំងជូន
ដំណើរបងមកដល់ទីនេះ?

ចរណៃគ្រាន់តែញញឹម មិនហ៊ានឆ្លើយថាម៉េចនឹងប្អូនស្រីទេ។ ចំណាន មិនអស់ចិត្តក៏ចំអន់ទៀតថា :

- មើលចុះ! អ្នកដែលជាពេទ្យ បែរជាខ្វះមធ្យោបាយព្យាបាលអ្នកជំងឺ តែ អ្នកដែលមិនមែនជាពេទ្យ
បែរជាមានដៃទិព្វព្យាបាលអ្នកជំងឺឱ្យជាលឿន នោះលឿនតែម្តងហើយ។ មើលទៅចំណានប្រហែលជាត្រូវបិទគ្លីនិកវិញ
ហើយ...ហែស៎ៗ។

ឆវីសើចខឹកៗ កាលបើឃើញបងស្រីបែរសម្លក់នាងទាំងមុខក្រហម ដោយការខ្មាសអៀន :

- កុំនិយាយច្រើនពេក ប្រយ័ត្នព្យេរឆ្លង ម្តងម្នាក់ទេ។

- តែប្អូនប្រហែលជាមិនមានសំណាងដូចបងទេ ដែលមានគេផ្គាប់ចិត្តព្រឹក ល្ងាចយ៉ាងផ្អែមត្រជាក់ដូច្នោះឡើយ។

CHANBOKEO.COM

- កុំប្រញាប់មើលងាយវាសនាខ្លួនអីអូនណាន។ ជីវិតអនាគតមើលមិន ឃើញទេ

ជួនកាលអូនមានវាសនាជួបមនុស្សដែលស្រលាញ់អូនហើយថៃ ទំារូបអូនផ្អែមល្ហែមជាងនេះទៅទៀតក៏មិនដឹង។

- ប្អូនសូមបន់អោយពិតដូចពាក្យបងជូនពរនេះទៅចុះណា!

- ហើយចុះប៉ាម៉ាក់ត្រលប់ទៅវិញហើយឬអូន?

- ចាំស! លោកប៉ាត្រូវមានការទៅកន្លែងផ្សេងទៀត ម្យ៉ាងគាត់ឃើញ បងអាល័យមានការ ទើបមិនរំខាន។

ចរណៃញញឹមដាក់ប្អូនហើយក៏បែកគ្នាចូលបន្ទប់ដំណេករៀង១ខ្លួន។

នៅវេលាជិតពាក់អាធ្រាតថ្ងៃដដែល...

ចរណៃឮសូរសម្លេងរថយន្តបរមកដល់មុខផ្ទះ ក៏ក្រោកលួចមើលតាម ស្លាបព្រិលបង្អួចឃើញលោកចក្រាបរឡានមកដល់ :

- តើលោកចក្រាមានការអ្វីទាំងយប់ដូច្នេះ?

នាងឈរគិតតែម្នាក់ឯង ស្រាប់តែឮសម្លេងលោកចក្រាគោះទ្វារ :

- អ្នកគ្រូ..បើកទ្វារ...ខ្ញុំមានការបន្តិច..ប្រញាប់ឡើង!

អ្នកគ្រូយើងក៏ស្ទុះទៅបើកទ្វារផ្ទះឡើង :

- លោកចក្រា! មានការអ្វីទាំងយប់?

ពេលនោះ ធិតាដឹងថាលោកចក្រាកំពុងស្រវឹងស្រារួចមានឫកពាមិន ប្រក្រតី។ នាងហាក់ដូចជាចាប់ភ្លឹកថា លោកចក្រាហាក់ដូចជាកំពុងមាន បំណងមិនល្អមកលើនាង។ ធិតាក៏ទាញទ្វារបិទវិញយ៉ាងរហ័ស ស្រាប់តែ លោកចក្រាលូកដៃចាប់ទ្វារជាប់ ហើយបើកទ្វារចូលមកក្នុងផ្ទះនាងយ៉ាង រហ័សតែម្តង។

- លោកចក្រា..! ចង់ធ្វើអីហ្នឹង? នេះជាផ្ទះគ្រូណា...កុំធ្វើអ្វីមិនសមរម្យឱ្យ សោះ!!

- នរណាថាផ្ទះនេះជាផ្ទះគ្រូ... បើអាចក្រាវាមិនអោយឈើអោយសង្កសី ស្មានថាគ្រូបានផ្ទះនេះជ្រកនៅហ្អែស?

- នែ់..នេះជាអំណោយមនុស្សធម៌ មិនមែនលុយជះទិញកត្តិយសគ្រូទេ!

- ទោះជាយ៉ាងណាក៏នៅតែជាសម្បត្តិរបស់យើងដដែលហ្នឹង។

- ឆាប់ចេញទៅវិញទៅលោកចក្រា..លោកស្រវឹងហើយ...ខ្ញុំនឹងទៅតាម មេភូមិឥលូវនេះ។

ថាហើយនាងស្ទុះរឹងរកចេញទៅក្រៅ ស្រាប់តែចក្រាចាប់ដៃជាប់ :

- នែ៎ ប្រញាប់ទៅណាព្រលឹងមាសបង..ម៉េចមិនចង់ទទួលភ្ញៀវទេឬអី?

- អត់ទេ..លែង! នេះ យប់អាធ្រាតហើយ.. លោកឆាប់ទៅរកកន្លែង ទទួលដំណេកទៅ!

- អោយចក្រាទៅណាទៀត...កន្លែងនេះក៏ជាផ្ទះចក្រាដែរ...

តែចរណៃលែងមានអារម្មណ៍ល្អហើយកាលបើចក្រាមានកិរិយាកាន់ តែលូកលើស្មើក្រោម។ នាងក៏ស្ទុះរត់គេចរឹងរកចេញទៅក្រៅសាថ្មី ស្រាប់ តែត្រូវនាយចក្រាចាប់បានដដែល :

CHANBOKEO.COM

- ទៅណាស្រីល្អ?  នៅទទួលបងសិនណាំព្រលឹង!

- នែ៎លែង...

អ្នកទាំងពីរក៏ប្រវាយគ្នាទៅមក ប៉ុន្តែលោកចក្រាបានស្រវឹងជោគជាំ លែងមានស្មារតីដឹងខុសត្រូវទៅហើយ ។ គេក៏ប្រើកម្លាំងបាយលើនាង យ៉ាងឃោរឃៅ ប៉ុន្តែនាងបានយកជើងធាក់ចំថ្វាសរបស់នាយហើយរត់ចេញទៅរកហៅអ្នកភូមិមកជួយ ។ ចៃដន្យ ធិតាមិនដឹងរត់ទៅណា ក៏បែរ ទៅរកផ្ទះ របស់ជាងសម្លាក :

- បងខ្លា...

ឮសម្រែករបស់នាងស្រែកហៅយ៉ាងគ្រលួច ជាងសម្លាកក៏ស្ទុះស្ទាមក ដល់មួយរំពេច ។ ធិតាក៏ហាក់ចូលរង្វង់ដៃរបស់នាយ :

- ជួយអូនផង..បងខ្លា!

- ណៃ...អូនមានរឿងអ្វីហ្នឹង?

ចរណៃសម្លឹងមុខបុរសដោយក្រសែភ្នែកតក់ស្លុតរន្ធត់ក្រៃលែង ។

នៅឯផ្ទះគ្រូវិញ...

ចក្រាច្រឡោតគោតត្លុង ដែលធ្វើអោយចរណៃរត់រួចទៅបាត់ ។ គេក៏ ស្រវាឥវាន់តុបតែងក្នុងផ្ទះទាំងអំបាលម៉ានគប់គ្រវែងបែកបាក់អស់ពេញ ផ្ទះ ។ លុះក្រឡេកមកឃើញរូបថតមួយដាក់តាំងលើតុ គេក៏ចាប់បំរុងនឹង គប់ទៅលើក្តារអោយបែកស្រាប់តែ :

- នោះជារូបថតប៉ាម៉ាក់ខ្ញុំទេ..កុំបំផ្លាញវាអី!

ចក្រាងើបមុខឡើងឃើញនារីម្នាក់នៅឈរចំពោះមុខ :

- មកវិញហើយឬអូនចរណៃ?

- នេះគឺចំណានទេ... មិនមែនបងចរណៃឯណា!

តែលោកចក្រាស្រវឹងជោគទៅហើយ ចំណាននិយាយអ្វីតទៅទៀត ក៏គេស្តាប់មិនបានដែរ ។ ពេលនេះ ក៏ដឹងតែម្យ៉ាងថានឹងយកឈ្នះលើរូប កាយរបស់ចរណៃដើម្បីបញ្ឈឺចិត្តនាយខ្លាប៉ុណ្ណោះ ។ អំណាចស្រាបានដុត រោលសរសៃឈាមក្នុងខ្លួនអោយបុរសយើងលែងស្គាល់ខុសត្រូវហើយ ។  កាលបើឃើញលោកចក្រាមិនសូវស្រួល ចំណានក៏ស្ទុះរត់ចុះដីទៅតាមរកអ្នកភូមិអោយជួយ តែត្រូវចក្រាតាមនាងទាន់នៅមាត់របងហើយក៏ចាប់ ខ្ទប់មាត់នាងអូសត្រលប់យកមកខាងលើផ្ទះវិញទាល់តែបាន ។ កំពុងតែខំ ប្រវាយប្រវោចជាមួយធិតាស្រាប់តែមានដៃមួយមកដាល់ចំមុខចក្រាឱ្យ វិលខ្វាល់ដួលបត់កទៅក្រោយ ។ ចំណានងើបមុខឡើង ក៏ឃើញនាយភុំមក ដល់ ។ នាងត្រេកអរផងហើយក៏ខ្មាសអៀនផង ដែលខោអាវរបស់នាងត្រូវ ដាចដោចដោយការកញ្ឆក់បោចរបស់នាយចក្រាស្ទើរតែអាក្រាតខ្លួនអស់ ទៅហើយ ។ ភុំក៏ដោះក្រមាពីកយកទៅរុំខ្លួនអោយធិតា រួចហើយក៏បែរមក ចង្អុលមុខចក្រា :

- ព្រហើនណាស់! ឯងមិនសមជាកូនប្រុសទេ នាយចក្រា! ឆាប់ចេញពីទី នេះភ្លាម មុននឹងយើងអូសកឯងអោយប៉ូលិស!!

CHANBOKEO.COM

ចក្រាយកដៃជូតឈាមពីមាត់ដែលត្រូវមួយកណ្ដាប់ដៃពីនាយភុំយ៉ាង ធ្ងន់ ។ ដោយដឹងខ្លួនថា នាយស្ថិតនៅក្នុងសភាពអ្នកចាញ់ គេក៏ឈ្ងោកមុខ រត់ចេញទៅ ។

ចំណានញ័រខ្លួនចំប្រប់ដូចកូនសត្វ ដោយការភិតភ័យតក់ស្លុតក្រៃលែង ចំពោះហេតុការណ៍អំបាញមិញនេះ ។ ភុំក៏លើកនាងឡើងអោយអង្គុយនៅ លើក្តារជឿ ក្នុងបន្ទប់ទទួលភ្ញៀវ :

- អ្នកគ្រូ...មិនអីទេ?

ធិតាសម្លឹងមុខនាយភុំ :

- អរគុណភុំណាស់ ដែលបានមកជួយខ្ញុំទាន់ពេល...កុំអី...

ពេលនោះ នាងដាក់មុខជ្រប់ ចង់យំ ។

- ពេលនេះ នាយចក្រាលែងហ៊ានត្រលប់មកវិញហើយ អ្នកគ្រូឈប់ភ័យទៅណ៎ា ( នាយភុំនិយាយលួងលោម)

ភ្លាមនោះ អ្នកគ្រូចំណានសម្លឹងមុខបុរសយើងហើយសួរដោយងឿងឆ្ងល់ចម្លែកថា :

- ហើយ...ចុះហេតុអ្វីបានជាភុំមកទីនេះទាន់ពេលដូច្នេះ?

- គឺ អ្នកភូមិយើងដាក់វេនគ្នាយាមភូមិពេលយប់ការពារចោរព្រៃ ថៃដន្យ ខ្ញុំដើរមកដល់ម្តុំៗនេះក៏ឮសម្លេងស្រែកអោយជួយទើបរត់មក...

ការពិត នាយភុំភូតអ្នកគ្រូទេ ។ គេបានលួចចាប់អារម្មណ៍លើអ្នកគ្រូ ពេទ្យក្មេងនេះតាំងពីយូរហើយ គ្រាន់តែគេមិនហ៊ានមាត់ ហើយគេតែងតែ លួចមកលបតាមដានអ្នកគ្រូជាញឹកញយ ។ រីឯរាត្រីនេះទៀតសោត ក៏ជារាត្រីដំបូងបង្អស់ដែលអ្នកគ្រូទាំងពីរឡើងមកនៅផ្ទះគ្រូដែរ ។ ភុំចេះតែនឹក បារម្ភពីសុវត្ថិភាពរបស់អ្នកទាំងពីរ ក៏លួចដើរមកមើលទាំងកណ្តាលយប់ ស្រាប់តែត្រូវប្រទះហេតុការណ៍ដូច្នេះដោយថៃដន្យទៅ ។

រំពេចនោះ ចរណៃនិងជាងសម្លាកក៏បានមកដល់ដែរ :

- អូនចំណាន! ( ចរណៃលាន់មាត់) ពុទ្ធោអើយ! នេះ នាយចក្រាព្រហើន ដាក់ប្អូនដល់ម្លឹង?

ចំណានស្រវាំអោបបងស្រីធ្វើទឹកភ្នែករលីងរលោង :

- បើកុំតែបានភុំ...ម្ល៉េះសមខ្ញុំធ្លាក់នរកបាត់ទៅហើយ ។

ចរណៃអង្អែលខ្នងប្អូនស្រីជាការលួងលោមដល់នាង :

- ពេលនេះ យើងបានបងជាងនិងភុំមកជួយរក្សាសន្តិសុខអោយយើង ហើយបុរសអប្រិយនោះមិនអាចមកធ្វើអ្វីយើងបានទៀតទេ ។

អ្នកទាំងពីរក៏ញញឹមដាក់គ្នាឡើង ។ ចរណៃក៏លើកគ្រាហ៏ប្អូនស្រីចូល បន្ទប់គេងវិញ ទុកអោយនរៈទាំងពីររូបទទួលខុសត្រូវនៅខាងក្រៅ ។ មុន នឹងងើបចូលទៅ អ្នកគ្រូចំណានលួចចោលកន្ទុយលួចមើលភុំ

CHANBOKEO.COM

ឃើញនាយក៏ លួចមើលមកនាងវិញដោយក្រសែភ្នែកព្រួយបារម្ភ ថ្វីបើនាយមិននិយាយ ស្ដីអ្វីមួយម៉ាត់ក្ដី។ នាងញញឹមដាក់គេភ្លាម ហាក់ដូចជាចង់សម្ដែងនូវពាក្យ ថាអរគុណ មុននឹងនាងចូលដំណេកវិញ។ ភុំឃើញហើយនឹករំភើបក្នុងចិត្ត គ្រលួចតែម្នាក់ឯង។

មិនបានមួយម៉ោងផង ស្រាប់តែអ្នកទាំងបួនភ្ញាក់ព្រើតសាជាថ្មីដោយ ឃើញអ្នកស្រុកស្រែកអ៊ូអរទាំងកណ្ដាលអាធ្រាតទៀតហើយ។ ទាំងបួន នាក់រត់ចេញមកក្រៅ ឃើញអណ្ដាតភ្លើងសន្ធោកប៉មេឃទៅមុំផ្ទះជាងខ្នា តែម្ដង។ គេនាំគ្នាឆោឡោរត់ទៅយ៉ាងរហ័ស តែក៏ជួយអ្វីមិនបានឡើយ។ ផ្ទះទាំងមូលរបស់ជាងខ្នា ក៏បានក្លាយជាចំណីភ្លើងអគ្គីភ័យដ៏ឃោរឃៅ នោះទៅហើយ។ បុរសយើងក្ដាប់ដៃស្រក់ទឹកភ្នែកច្រោក... ចរណៃឃើញ ដូច្នោះ ក៏លូកចាប់ដៃនាយកាន់យ៉ាងណែន :

- បងខ្នា..!

- បងដឹងហើយថា នរណាមានចិត្តឃាឃីលើបង អោយបងរលំរលាយ ខ្ទេចខ្ទីរបែបនេះ!! ( ជាងសម្លាកស្រដីផង យកដៃផ្ដិតទឹកភ្នែកផង)

- អត់ទេ...បងមិនរលំរលាយទៅណាទេ បងភ្លេចហើយហ្អែស? គឺបងនៅ មានជីវិត ហើយបងក៏នៅមានអូនណៃនៅក្បែរបង...យើងនៅមានសង្ឃឹម ក្នុងជីវិតជានិច្ចណាបង...

នរៈធ្មេចភ្នែកលេបទុក្ខសោកទៅក្នុងពោះវិញ ហើយស្រវាចង្កេះធិតា អោយមកក្បែកនឹងខ្លួនប្រាណរបស់នាយ :

- ពេលនេះ បើសិនបងគ្មានអូនទេ...បងមិនដឹងជា...

ស្រាប់តែធិតាយកដៃទប់បបូរមាត់ មិនអោយបុរសយើងស្រដីឡើយ ហើយថែមទាំងឈ្ងោកខ្សិបប្រាប់នាយវិញថា :

- យើងមានតែសេចក្ដីស្រលាញ់ចំពោះគ្នាទេ...ចាប់ពីពេលនេះតទៅ...!!

ជាងសម្លាកឮហើយក៏ញញឹមឡើងទាំងទឹកភ្នែករលីងរលោង...

- បងអរគុណណាស់អូនណៃ!!

រំពេចនោះស្រាប់តែអ្នកស្រុកឆោឡោទៀតហើយ។ ម្ដងនេះ អគ្គីភ័យ បានទន្ទ្រានលេបយកផ្ទះគ្រូម្ដង :

- ពុទ្ធោអើយ! ( អ្នកគ្រូចំណានលាន់មាត់) ខ្ទេចខ្ទីរហើយជាន់នេះ!

តែលើកនេះ អ្នកស្រុកក្រោកមកទាំងភូមិ ស្រែកអ៊ូអរ រកទឹកពន្លត់ ភ្លើងផង រត់ចាប់មនុស្សពាលដែលលួចដុតផ្ទះនោះផង។ យប់នោះ គ្មាន នរណាមួយបានដេកលក់សោះឡើយ ត្បិតអាល័យតែឆោឡោចុះ ឆោឡោ ឡើង នឹងរឿងអគ្គីភ័យ។ ទំរាំភ្លឺមានថ្ងៃរះច្បាស់ ផ្ទះរបស់ជាងខ្នា ក៏បាន ក្លាយជាផេះរាបនឹងដី រីឯផ្ទះគ្រូវិញក៏ត្រូវភ្លើងឆេះអស់ជាងពាក់កណ្ដាល នៅសល់ពាក់កណ្ដាលទៀត រលំច្រងាង ទេរទៅម្ខាង។ នៅទីធ្លាមុខផ្ទះគ្រូ បុរសពីរនាក់បានត្រូវគេចាប់ចងស្លាបសេកឡើងរួញក្រញ៉ុន១។ ភ្លាមនេះ ព្រះគ្រូចៅអធិការឧត្ដរៈ តាញ៉ៅ សែបផុន និងមនុស្សម្នាជាច្រើនក៏បាន មកដល់ឈូឆរ។

CHANBOKEO.COM

- នាយលុតនិងនាយក្រាប នរណាប្រើអោយឯងមកលួចដុតផ្ទះគ្រូនិងផ្ទះ ជាងសម្លាក? (តាញ៉ៅសួរជនឧក្រិដ្ឋទាំងពីរ)
- គឺ..លោកចក្រាប្រើមកទាន!! (នាយក្រាបឆ្លើយទាំងភ័យញ័រ)
- អញ្ជើង ទៅអញ្ជើញលោកចក្រាមក(តាញ៉ៅស្រែកហៅសែបផុន)
- មិនបាច់ទៅហៅទេ...ខ្ញុំមកដល់ហើយ ។

ចក្រាវែកហ្វូងដើរចូលមកដោយមានអ្នកស្រីស៊ីផាមកជាមួយផង ។
- ហេតុអ្វីក៏លោកដុតបំផ្លាញផ្ទះគ្រូនិងផ្ទះនាយខ្មា? (តាញ៉ៅសួរ)
- ខ្ញុំមិនបានដុតទេ ។ គឺអាលុតនិងអាក្រាបវាដុតតើហ៎ បើតាមេឃុំចង់ ដាក់ទោស ដាក់ទោសវាទាំងពីរនោះទៅ ។
- តែលោកចក្រាជាអ្នកប្រើវា ដូច្នេះលោកត្រូវតែទទួលខុសត្រូវ
- រឿងអីដែលខ្ញុំត្រូវទទួលខុសត្រូវផង កាលបើខ្ញុំមិនបានដុត?
- តើលោកជាចៅហ្វាយនាយយ៉ាងម៉េច បានជាបណ្តោយឱ្យកូនចៅឱ្យមក ដុតបំផ្លាញផ្ទះគេឯងយ៉ាងនេះ?
- ខ្ញុំជាអ្នកអោយឈើអោយសង្កសី រឿងអីខ្ញុំយកវិញមិនបាន? ខ្វះអីម៉ា អាលុយ ចង់បានប៉ុន្មាន ខ្ញុំសង់អោយថ្មី! មិនបាច់មកគំហកកំហែងខ្ញុំទេ តាមេភូមិ!!
- ពុទ្ធោអើយ! នេះលោកជាក្មេងបៀមដៃទេហ៎ លោកចក្រា? លោកខឹង ចង់បំផ្លាញទ្រព្យដែលលោកផ្តល់ជាអំណោយនោះ លោកអាចធ្វើបានមែន លោកកុំភ្លេចថា លោកកំពុងជាន់ឈ្លីកម្លាំងមនុស្សមួយភូមិឯណោះ ។
- តែអាមួយនេះជាសត្រូវរបស់ខ្ញុំ! (ចក្រាចង្អុលមុខជាងសម្លាក) អ្វីដែល ជាសេចក្តីសុខរបស់ខ្ញុំ វាតាមបំផ្លាញជានិច្ច ដូច្នេះ ខ្ញុំត្រូវតែបំផ្លាញវាវិញ នូវអ្វីដែលផ្តល់សេចក្តីសុខដល់វា ។
- ជាងសម្លាកជាមនុស្សស្លូតបូតបំផុត ។ ក្នុងស្រុកភូមិយើងនេះ នរណា ក៏ដឹងដែរ ថាជាងគេជាមនុស្សស្ងាត់ស្ងៀម មិនដែលឃើញគេទៅរករឿង ពីណាគេទេ ។ ហេតុអ្វីលោកចក្រាមកចោទគេដូច្នោះ?
- គឺវាបានមកដណ្តើមអ្នកគ្រូចរណៃសង្សារខ្ញុំនោះអី!!
- តែផ្តាស! (អ្នកគ្រូចរណៃឧទានឡើង) ខ្ញុំមិនមែនជាសង្សារលោកទេ កុំច្រឡំ លោកចក្រា!!
- តែចាស់ទុំបានដឹងឮហើយថាយើងនឹងភ្ជាប់ចំណងមេត្រីនឹងគ្នា...
- លោកក៏មកយឺតពេលបន្តិចទៅហើយ លោកចក្រា! ខ្ញុំមិនមែនជានារី ដែលនៅទំនេរដូចលោកស្មាននោះទេ ការពិតខ្ញុំបានរៀបការ មានស្វាមីរួច ហើយ..រីឯកូនកម្លោះនោះគឺជាជាងសម្លាកនេះឯង...
- មិនបាច់កុហកថែមថយសាច់រឿងការពារវាទេ ចរណៃ! អ្នកនាងជាកូន ស្រីរបស់លោកភូឈួយខេត្ត ហេតុអ្វីក៏បែរក្លាយជាប្រពន្ធអាមនុស្សកំទេច កំទីធុនអាខ្មានេះទៅវិញ?
- ឈប់និយាយមើលទាបមើលថោកគេទៅលោកចក្រា ។ លោកកាន់តែ មានពាក្យសម្តីមាក់ងាយគេកាន់តែខ្លាំង វានឹងបង្ហាញនូវភាពយង់ឃ្នង ឧត្បាតក្នុងចិត្តរបស់លោកកាន់តែច្រើនដែរ ។ វាមិនបានធ្វើអោយលោក មានកត្តិយសទៅណាឡើយ ។

CHANBOKEO.COM

- ចរណៃ! ហេតុអ្វីក៏នាងមើលឃើញមនុស្សដូចអាខ្នាជាមនុស្សល្អហើយ ប្រមាថខ្ញុំដូចប្រេតនរកយ៉ាងនេះ?

- ប្រេតនរកប្រហែលជាគ្រាន់បើជាងលោកផងទេដឹង លោកចក្រា ព្រោះ

គេរស់នៅតែស្ថានក្រោម ពួកគេធ្វើទុក្ខបុកម្នេញតែអ្នកមានបាបធ្លាក់ទៅ រស់នៅឋាននរកប៉ុណ្ណោះ។

ពួកប្រេតទាំងនោះមិនមករំខានធ្វើទុក្ខបុក ម្នេញមនុស្សលោកនៅលើដីឡើយ។ តែចំពោះលោកវិញ បែរជាមកធ្វើ

បាបមនុស្សស្លូតត្រង់លើដី...តើលោកគួរមានវណ្ណៈល្អជាងប្រេតម្តេចកើត?

- ចុះអាខ្នាវាល្អត្រង់ណា កាលបើវាបានបំផ្លាញដួងចិត្តរបស់ខ្ញុំដែរនោះ?

- ហើយចុះអូនចំណានវិញ? គេបំផ្លាញអ្វីរបស់លោកដែរ បានជាលោកមក

ប្រើកំលាំងបាយប៉ះពារលើរូបកាយរបស់នាងទាំងកំរោលផង? នេះ បើសិន ជាភុំចូលទៅជួយមិនទាន់ ម្ល៉េះសម...

ស្រាប់តែអ្នកស្រុកផ្អើលឆោឡោអ៊ូអរឡើង កាលបើឮសំដីអ្នកគ្រូ យើងបែបនេះ។ តាញ៉ៅបើកភ្នែកធំៗ :

- លោកចក្រាបានប្រព្រឹត្តដល់ម្លឹងផង?..

- គឺ... មកពីនាយខ្នាធ្វើអោយខ្ញុំខឹង ទើបខ្ញុំផឹកស្រាស្រវឹង...បើចង់បន្ទោស បន្ទោសនាយខ្នាទៅ!! (ចក្រាស្រែកតប)

រំពេចនោះ ស្រាប់តែព្រះគ្រូឧត្តរៈធ្វើអន្តរាគមន៍ឡើង :

- លោកចក្រា...ពេលនេះ បេះដូងរបស់លោកលាបដោយទោសៈមោហៈ ពេញអស់ទៅហើយ នឹងជជែកគ្នារកខុសត្រូវ

គឺពិបាកណាស់ ព្រោះលោក មិនឃើញកំហុសខ្លួនឯង ប៉ុន្តែនៅមានការពិតមួយ ដែលលោកត្រូវស្តាប់។ លុះស្តាប់ចប់ហើយ

នោះលោកនឹងត្រជាក់ចិត្តវិញមិនខាន ហើយច្បាស់ជា ស្តាយក្រោយ ចំពោះឥរិយាបថរបស់លោកនៅពេលនេះមិនខាន។

- តើជាការពិតអ្វីទៅព្រះគ្រូ?...

- ការពិតដែលថា អ្នកគ្រូចរណៃជាភរិយារបស់ជាងសម្លាក យ៉ាងត្រឹមត្រូវ តាមប្រពៃណីនោះអី!!

លោកចក្រាឮដូច្នោះក៏បើកភ្នែកធំៗឡើង :

- ពុទ្ធោ! តើគេរៀបការពីអង្កាល់ កាលបើគេទើបតែជួបគ្នាមិនបានប៉ុន្មាន ផង? ឬក៏គេរកស៊ីផ្លូវកាត់ដោយលួចទៅជួបគ្នាស្ងាត់ៗ?

- រិតតែផ្តាសទៀតហើយលោកចក្រា..! លោកនិយាយយ៉ាងនេះគឺលោក កំពុងតែប្រមាថកត្តិយសខ្ញុំហើយ !

(អ្នកគ្រូចរណៃស្រែកកាត់) ការពិត លោកមិនមានសេចក្តីស្រលាញ់សម្រាប់នរណាទេ ក្រៅពីខ្លួនឯង។ បើសិន

ជាលោកស្រលាញ់នារីម្នាក់ដោយចិត្តបរិសុទ្ធពិតមែន លោកត្រូវតែផ្តល់ កត្តិយសអោយគេ

មិនមែនជាន់ឈ្លីគេដោយការប្រមាថបែបនេះទេ។

ចក្រាបិទមាត់ដូចគេចុក កាលបើឮចរណៃពោលដូច្នោះ។ បន្តិចមក ព្រះគ្រូក៏មានដីការបន្តថា :

- ណ្ហើយចុះ ដើម្បីកុំអោយមានគំនុំគុំគួននឹងគ្នា និងដើម្បីជំរះមន្ទិលក្នុងចិត្ត បុគ្គលខ្លះៗ អាត្មាភាពសូមទុកពេលនេះ

ជូនទៅជាងសម្លាកនឹងអ្នកគ្រូ ចរណៃរៀបរាប់រឿងរបស់គេប្រាប់អ្នករាល់គ្នាទៅចុះ!!

000000000000000000

CHANBOKEO.COM

# វគ្គទី៩

# គូគាប់គូកម្ម

ឃុំព្រះនេត្រព្រះឆ្នាំ ចុងខែតុលា១៩៤៨...

នៅផ្ទះនាយខ្នា...

តាមាំងសំរាន្តសន្ទឹងសន្ធៃនៅលើគ្រែ រង់ចាំព្រះគ្រូចៅអធិការឧត្តរៈ តាញ៉ៅមេភូមិ និងយាយព្រឹងអោយមកជួបគាត់ជាប្រញាប់ ។ នៅចុង ជើងរបស់គាត់ កូនស្រីទាំងពីរនាក់កំពុងអង្គុយកាន់ដៃគ្នាសម្លឹងមុខឪពុក ដែលមានអាការៈកាន់តែទ្រុឌទ្រោមទៅហើយ មិនខុសពីភ្លើងចង្កៀង ដែលរៀបនឹងអស់ខ្លាញ់ទៅនោះដែរ ។ មិនយូរប៉ុន្មាន នាយខ្នាក៏បាននាំតា មេឃុំ ប្រពន្ធគាត់ និងព្រះគ្រូមកដល់ ។ តាមាំងលើកដៃទាំងទ្វេប្រណម្យ ឡើងចំពោះព្រះគ្រូឧត្តរៈរួច ហើយក៏មានប្រសាសន៍ខ្សាវៗទៅព្រះអង្គ ដែលកំពុងដាក់ព្រះកាណ៌ទាបដល់ត្រចៀករបស់គាត់ :

- ក្រាបបង្គំព្រះគ្រូ...ពេលខ្ញុំព្រះករុណាលាចាកលោកទៅ សូមព្រះអង្គ ជួយណែនាំកូនណៃនិងកូនណារី យកសពរបស់ខ្ញុំព្រះករុណាទៅកប់នៅ ល្បាក់ភ្នំព្រះនេត្រព្រះជាមួយភរិយារបស់ខ្ញុំព្រះករុណាផង ហើយ...

តាមាំងក្អកឃ្ហូសៗ ដង្ហក់ៗ ហាក់ដូចជាកាន់តែខ្សោយទៅៗ ។ បន្តិច មក គាត់ក៏មានប្រសាសន៍បន្តថា :

- ខ្ញុំព្រះករុណាសូមអោយព្រះអង្គនិងលោកតាមេភូមិជាសាក្សី ដើម្បីរៀប ចំមង្គលការកូនស្រីម្នាក់របស់ខ្ញុំព្រះករុណាថ្ងៃនេះ ទាន់ខ្ញុំព្រះករុណានៅ មានដង្ហើម អាចឃើញកូនមានគូស្រករកក់ក្តៅក្នុងជីវិត ។

ព្រះគ្រូបានទទួលពាក្យតាមាំងជាច្រើន ។ បន្ទាប់មកព្រះអង្គក៏ហៅ នាយខ្នានិងកូនស្រីទាំងពីរ អោយមកអង្គុយជុំឪពុក រួចក៏មានដីការឡើង ប្រាប់អ្នកទាំងអស់ថា :

- កងណារី! កងណៃ! ថ្ងៃនេះ ឪពុករបស់នាងបានសំរេចចិត្តរៀបចំពិធី មង្គលការកូនស្រីរបស់គាត់ម្នាក់ នៅមុនពេលដែលគាត់ត្រូវលាចាកអ្នក ទាំងពីររៀងរហូតទៅ..

- រៀបការ? (កងណៃលាន់មាត់ ហើយបែរមើលបងស្រី) ពុកគាត់ចង់ រៀបការបងណារី មែនទេ? ជាមួយនរណាគេ? (នាងងាកមើលនាយខ្នា) ឬក៏ជាមួយបងខ្នា?

កងណារីឮដូច្នោះក៏បើកភ្នែកធំៗទំនងភ្ញាក់ផ្អើលដូចគ្នាដែរ ថែមទាំង លួចចោលកន្ទុយភ្នែកមើលទៅនាយខ្នាទៀតផង ប៉ុន្តែឃើញនាយអង្គុយ ឈ្ងោកមុខស្ងៀមឈឹងមិនឮភ្ញាក់ផ្អើលអ្វីសោះ ហាក់ដូចជានាយបានដឹង រឿងអ្វីមុនដូច្នោះឯង ។

CHANBOKEO.COM

រំពេចនោះ តាមាំងស្រវាយកខ្សែកពីរខ្សែរវេញដោយអំបោះក្រហម មានបន្តោងចែកាច់ឆ្លាក់ជាផ្កាចំប៉ាញីមួយឃ្មោលមួយ ហើយក៏លើកដៃដ៏

ញ័រទទ្រើករបស់គាត់កាន់ខ្សែកមួយហុចអោយទៅកូនស្រីរបស់គាត់ :

- ណៃអើយ! មកជិតពុកបន្តិចមក៏កូន!...

កងណៃភ្ញាក់ព្រើត ធ្វើរេរា តែមិនហ៊ានអោយល្អក់ចិត្តឪពុក ក៏លូន ចូលជិតគាត់ភ្លាម ។

តាមាំងក៏លើកខ្សែកមួយបំពាក់អោយធិតា រួចហើយ មានប្រសាសន៏បន្តថា :

- កូនណៃ! ថ្ងៃនេះពុកសូមរៀបការកូនហើយ...

- ចាំស? (ធិតាបើកភ្នែកធំៗដោយការភ្ញាក់ផ្អើល)

- កុំភ្ញាក់ផ្អើលអីកូន! ពុកបានគិតពិចារណាតាំងពីយូរមកហើយ... ពុកគិត ថាបុរសដែលត្រូវមកជាគូស្រករក្សារូបកូននោះ ជាមនុស្សល្អ មានទឹកចិត្ត ហើយក៏ជាមនុស្សដែលពុកទុកចិត្តជាងគេដែរ ។ ពុកយល់ថា គេអាចរក្សា រូបកូនអោយមានសេចក្តីសុខយ៉ាងល្អប្រសើរបំផុតក្នុងជីវិត ។

ប៉ុន្តែកងណៃនៅតែភ្ញាក់ផ្អើលដដែល ដែលឪពុកនាងជ្រើសរើសយក រូបនាងជាកូនក្រមុំនៅរាត្រីនេះ ហើយទឹកឆ្ងល់មិនអស់មិនហើយថាហេតុអ្វី ក៏តាមាំងមិនផ្សំផ្គុំកងណាវជាបងស្រីរបស់នាងវិញ កាលបើគេជាមនុស្ស ពេញវ័យស្រាប់ទៅហើយ ។ ចំណែកនាងវិញ ឆវីគ្រាន់តែជាក្មេងជំទង់ ឡិកឡក់មិនគ្រប់ដប់ តែហេតុម្តេចក៏គាត់បែរជាបង្ខំអោយនាងធ្វើមនុស្ស ធំខុសវ័យរបស់ខ្លួនដូច្នេះ?

បន្ទាប់មក តាមាំងក៏ហៅនាយខ្នា :

- ខ្នា! មកជិតពុកបន្តិចមកកូន!

នាយខ្នាក៏លូនទៅជិតតាមាំង ដែលកំពុងលើកខ្សែករង់ចាំ ។ នរៈបន្ទន់ ខ្លួនឱនកេសាទទួលយកខ្សែកមួយទៀតនោះភ្លាម :

- ពុកសុំផ្ញើកូនណៃនឹងឯងផងណា៎ ខ្នា! សូមកូនរក្សានាងដោយសេចក្តី ស្រលាញ់ហើយអាណិតណា៎កូន! ទោះបីជាកូនក្រទ្រព្យ តែសុំកុំខ្វះទឹកចិត្ត ណា៎កូនសម្លាញ់ពុក!

- បាទ៎ ពុក!

រួចហើយតាមាំងក៏ចាប់ដៃកូនទាំងពីរអោយកាន់ដៃគ្នាឡើង :

- ថ្ងៃនេះ ពុកសូមរៀបការកូនទាំងពីរជាគូស្វាមីភរិយាតាមប្រពៃណីដោយ មានមេបាចាស់ទុំនិងព្រះគ្រូអធិការជាសាក្សី...

កងណៃទទួលយកដៃរបស់នាយខ្នាមកកាន់ទាំងរំជួលចិត្ត ត្បិតនឹកមិន អស់ចិត្តមិនអស់មិនហើយនូវការសំរេចរបស់ឪពុកនាង ។ តែដោយធិតាគិត ថា នោះជាបំណងចុងក្រោយរបស់ឪពុកនាង ទើបនាងតូចកងណាវមិន ហ៊ានស្រដីមាត់កអ្វី អោយខូចអារម្មណ៏របស់តាមាំង មុនពេលគាត់អស់ បុណ្យឡើយ ។ រីឯនាយខ្នាយើងវិញ បានចាប់ដៃធិតាយ៉ាងណែន ហាក់ដូច ជាចង់ប្រាប់ឆវីថា នាយបានទទួលយកនាងតូចដោយការសម្រេចចិត្តយ៉ាង មុតមាំជាទីបំផុត ។

CHANBOKEO.COM

តាមាំងញញឹមដាក់កូនទាំងពីរ ហើយស្រដីបន្ថែមថា :

- កូនណៃ! មិនបាច់ឆ្ងល់ទេថាហេតុអ្វីបានជាពុកជ្រើសរើសកូន ជាកូនក្រមុំ សំរាប់រៀបការថ្ងៃនេះ។ កូនខ្លាគេអាចពន្យល់កូនបាន...ណាំកូន!!

ពេលនេះ តាមាំងមានអាការៈស្រស់បំព្រងហាក់ដូចជាចង្កៀងដែលខំ ជះរស្មីជាចុងក្រោយនៅមុនពេលរលត់សូន្យទៅដូច្នោះឯង។ បន្តិចមក តា មាំង ក៏បែរហៅកូនស្រីច្បងអោយទៅជិតគាត់ :

- ណាវ! កុំតូចចិត្តអីដែលពុករៀបការកូនណៃមុនឯង។ គេនៅក្មេងណាស់ គេពិតជាត្រូវការអាណាព្យាបាលល្អ ដើម្បីជួយគ្រប់គ្រងជីវិតរបស់គេ មុន ពេលដែលគេអត់ពីពុកទៅ ហើយពុកជឿថាខ្លាអាចរក្សាកូនណៃបានយ៉ាង ប្រសើរ។ ចំណែកកូនណាវវិញ កូនមានចរិតចាស់ទុំ ចេះធ្វើការរឹងមាំ អាចជួយខ្លួនឯងបាន បើសិនពុកលែងបាននៅឃើញកូនទៀត គឺពុកមាន ជំនឿចិត្តយ៉ាងមាំថា កូនមានភាពរឹងប៉ឹងអាចរក្សាខ្លួន រក្សាជីវិតក្នុងផ្លូវល្អ ប្រពៃជានិច្ច។

រួចហើយគាត់ក៏បែរមកតាញ៉ៅនិងយាយព្រីង :

- អោយខ្ញុំសុំផ្ញើកូនផងណាំ តាមេឃុំ... យាយព្រីង...

តាញ៉ៅនិងយាយព្រីងងក់ក្បាល :

- មិនអីទេ...យើងនឹងជួយមើលការខុសត្រូវអោយបានល្អបំផុត!!!

តាមាំងសម្លឹងមើលកូនរបស់គាត់ទាំងពីរ និងនាយខ្លាជាកូនប្រសារ ជាចុងក្រោយ ហើយលើកដៃប្រណម្យឡើងភាវនាខ្សិបៗ រួចក៏បិទនេត្រា សន្សឹមៗទៅ ក្រោមតំណក់ទឹកភ្នែកនិងការខ្សឹកខ្សួលរបស់កូនស្រីនិងកូន ប្រសារ... ព្រះគ្រូឧត្តរៈក៏ចាប់ផ្តើមសូត្រធម៌ឡើងរងំ បញ្ជូនដួងវិញ្ញាណ របស់តាមាំងអោយបានទៅដល់ស្ថានសុគតិភព។

នៅលើខ្នងភ្នំព្រះនេត្រព្រះ...

ទាំងបីនាក់ កងណាវ កងណៃ និង នាយខ្លា អុជធូបក្រាបបង្គំចំពោះ មុខផ្នូរមួយគូនៅល្បាក់ភ្នំ។ គេសម្តែងកិរិយាក្រៀមក្រំដែលគេបានបាត់បង់ បុគ្គលជាទីស្រលាញ់ទាំងពីរទៅ។

បន្ទាប់មកកងណាវគេចចេញយ៉ាងរហ័សត្រលប់មកភូមិវិញដោយមិន មានស្រដីអ្វីមួយម៉ាត់ជាមួយប្អូនស្រី ឬក៏ជាមួយនាយខ្លាសោះឡើយ។ កង ណៃឃើញកិរិយាបងស្រីដូច្នោះ ក៏ស្ទុះរឹងរត់ទៅតាម តែត្រូវនាយខ្លាចាប់ កដៃជាប់មិនអោយទៅចោលនាយមុនឡើយ :

- លែងដៃខ្ញុំមើស៍ បងខ្លា!

- អូនណៃ! រៀបចំចិត្តគំនិតជាមនុស្សធំបន្តិចបានទេអូន!

- អត់ទេ! ណៃមិនចង់ធំទេ ចង់ធ្វើជាក្មេងអញ្ចឹងរហូតទៅ..!

- អូនមិនខ្លាចគេសើចទេអី ដែលរៀបការជាប្រពន្ធបងហើយនៅតែ...

- តែផ្តាស! នរណាជាប្រពន្ធបងឯង? (កងណៃងង៉ក់)

- គឺពុកបានផ្សំផ្គុំយើងត្រឹមត្រូវតាមប្រពៃណីហើយ...ម៉េចប្រកែកទៀត?

CHANBOKEO.COM

- នោះគ្រាន់តែជាពិធីឧបកិច្ចដើម្បីអោយអារម្មណ៍ពុកគាត់ស្ងប់តើ..

- តែក៏ជាការជ្រើសរើសដ៏ជាក់លាក់មួយរបស់គាត់ បើមិនដូច្នោះទេ ហេតុ អីគាត់ត្រូវនិមន្តព្រះគ្រូឧត្តរៈ និងតាមេភូមិព្រមទាំងប្រពន្ធគាត់អោយមក ធ្វើជាអធិបតីពេលនោះធ្វើអី?

- តែខ្ញុំជាក្មេងជំទង់ អោយធ្វើប្រពន្ធបងម៉េចនឹងកើត?

- តែបងក៏នឹងរង់ចាំ រហូតដល់អូនពេញវ័យ!

- ផ្កាសទៀតហើយ...បងខ្លានិយាយអីពិបាកស្ដាប់ម្ល៉េះ?

ធិតាខឹងនឹងណាស់ក៏រត់រឹងចុះទៅពីភ្នំតែត្រូវនរៈស្ទុះទៅកាក់ជាប់ ។

- បងខ្លា! ចៀសផ្លូវ!

- អត់ទេ! និយាយស្ដាប់គ្នាបានសិន ទើបបងអោយទៅ ។

- បើនៅតែបង្ខំអោយខ្ញុំទទួលខ្លួនជាប្រពន្ធរបស់បងទៀត ណៃខឹងនឹងបង រហូតមួយជីវិតហើយ!

កងណៃធ្វើមុខកលនឹងយំ ។ នាយខ្លាឃើញដូច្នោះ នឹកអាណិតធិតាក្នុង ចិត្ត ក៏ចៀសផ្លូវអោយនាងដើរទៅតាមសម្រួល ។ នាងតូចក៏រត់ចុះទៅ យ៉ាងលឿន ថែមទាំងស្រែកត្រលប់មកវិញថា :

- ណៃស្អប់បងខ្លាណាស់...កុំអោយណៃឃើញមុខ បងទៀត...

នរៈសម្លឹងតាមឆវីពីក្រោយទាំងដួងចិត្តជ្រួលច្របល់...

នៅរាត្រីថ្ងៃដដែល...

នាយខ្លាប្រមូលអីវ៉ាន់ដាក់សម្ពាយហើយដើរចេញពីផ្ទះទៅ ក៏ប្រទះ នឹងកងណាវនៅមាត់របងផ្ទះ :

- បងខ្លាទៅណាហ្នឹង?

- គឺ...បងគិតថាទៅស្នាក់នៅវត្តវិញ ។

- ម៉េចអញ្ចឹង? ទីនេះជាផ្ទះរបស់បង...ហេតុអី...បានជា...

- មានអ្នកទើសទាល់មិនចង់ឃើញមុខបងទីនេះ...ទើបបងគិតថា បើបង ចេញទៅនៅវត្ត ក្រែងគេមានអារម្មណ៍ល្អជាងមុន...

- ចុះបើមានការយប់ព្រលប់ តើអោយខ្ញុំនឹងអូនណៃទៅពឹងនរណា?

ខ្លាឈ្ងោកមុខចុះ ។ មែនហើយ! បើមានការយប់ព្រលប់ តើអ្នកទាំងពីរទៅពឹងនរណា? រំពេចនោះ ស្រាប់តែកងណៃស្រែកពីលើផ្ទះមកថា :

- បើគាត់ចង់ទៅចោលពួកយើងទៅហើយ បងណាវកុំឃាត់គាត់អី...! ឱ្យ គាត់ទៅចុះ ណៃស្អប់គាត់ណាស់ មិនចង់ឃើញមុខគាត់ទេ!!

នាយខ្លាឮដូច្នោះ ក៏ឈ្ងោកមុខបោះជំហានចេញទៅ ដោយមិនមានស្ដី អ្វីមួយម៉ាត់ឡើយ ទោះបីកងណាវខំឃាត់យ៉ាងណាក៏ដោយ ។ កាលបើ ឃើញខ្លាដើរចេញទៅបាត់ កងណាវស្ទុះមកដល់លើផ្ទះ :

CHANBOKEO . COM

- ម៉េចបានអូនណៃធ្វើយ៉ាងនេះ? ដឹងទេថាយើងកំពុងស្នាក់នៅផ្ទះរបស់គេ ហេតុអ្វីក៏ហ៊ានហាវដេញម្ចាស់ផ្ទះដូច្នេះ?

- ព្រោះខ្ញុំមិនចង់ធ្វើប្រពន្ធគាត់នោះអី!

- គេបង្ខំអូនហ្អែស?

- អត់ទេ! គាត់ថានឹងរង់ចាំ..

- ប៉ុនហ្នឹងសោះ ម៉េចក៏ចាំខឹងដែរ?

- ព្រោះខ្ញុំមិនចង់ធ្វើប្រពន្ធគាត់!

- តែអូនបានរៀបការនឹងគេហើយ ។

- គ្រាន់តែជាពិធិឧបកិច្ចតើហ៏ បង?

- តែជាបំណងចុងក្រោយរបស់ពុកដៃរណាំអូន ។

កងណៃយកដៃឈ្លីសៀតផ្កា ធ្វើអាការៈហាក់ដូចជាឈឺក្បាលណាស់ ហើយក៏ទាញភួយទទូរលែងនិយាយរកបងស្រីតទៅទៀត ។

ច្រើនថ្ងៃកន្លងទៅ...

ព្រឹកមួយ កងណៃអោយបាយជ្រូករួចហើយ ក៏លាងដៃលាងជើង ដើរ ឡើងទៅលើផ្ទះ ស្រាប់តែនាងដាក់ភ្នែកចំកម្រងផ្កាស្បៃរឿងព្យួរនៅលើ ជញ្ជាំងឡើងស្វិតក្រៀម ។ ឆរីក៏លូកឈោងចាប់វាមកកាន់ ស្រាប់តែនឹក ភ្នកទៅដល់នាយខ្នា... ពេលនេះ នាងទើបនឹកឃើញថាខ្លួនខានបានទទួល កម្រងផ្កាយូរថ្ងៃហើយ... ខានបានឮពាក្យសំដីផ្អែមល្ហែមនិងភាពទន់ភ្លន់ ដែលនរៈយើងតែងតែមានចំពោះនាង... ខានបានទទួលការថ្នាក់ថ្នមដ៏កក់ ក្តៅពីរូបគេ ។ ការពិតនាងនឹកគេខ្លាំងណាស់ ប៉ុន្តែ ហេតុអ្វីនាងបែរជាខ្លាច.. ខ្លាចមិនហ៊ានជួបមុខគេទៅវិញ? ជាពិសេស តាំងពីរាត្រីផ្សំផ្គុំនោះមក នាងតូចយើងក៏ប្រែចរិត លែងចេះទន់ភ្លន់តបទៅគេវិញអស់រលីងតែម្តង ។ គិតទៅគិតមក ធិតានៅតែមិនយល់ចិត្តរបស់ខ្លួនឯងសោះ ។ នាងគ្រាន់តែ ជាក្មេងស្រីជំទង់ម្នាក់ មិនទាន់ពេញវ័យស្រួលបួលផង ។ តើអោយនាងគិត ចំពោះនាយខ្នាយ៉ាងណាទៅ កាលបើគេក្លាយជាស្វាមីដោយមានចាស់ទុំ ដឹងឮទៅហើយ? ចុះបងស្រីនាងវិញ តើនាងត្រូវយកបងស្រីទៅដាក់នៅ ត្រង់ណា កាលបើបងស្រី ក៏ធ្លាប់មានការលួចពេញចិត្តចំពោះនាយខ្នាដែរ នោះ? គិតទៅគិតមក ធិតាក្រញីសក់ខ្លួនឯងស្ទើរតែជ្រុះអស់ ។ ភ្លាមនោះ ឆរីក៏ស្ទុះរត់រឹងចេញពីផ្ទះសំដៅទៅវត្តក្រោម ។ ចូលដល់បរិវេណ វត្តពេល ណា ធិតាបានប្រទះឃើញនាយខ្នាកំពុងរែកទឹក :

- បងខ្នា!

មាណពងាករឹងរកម្ចាស់សម្លេង ។ កាលបើប្រទះវត្តមានរបស់កងណៃ ភ្លាម គេក៏ញញឹមឡើងដោយត្រេកអរ :

- អូនណៃ..សុខជាទេ? បាត់ខឹងនឹងបងហើយនៅ?

- មិនបាត់ទេ ព្រោះមិនដឹងថាហេតុអ្វីក៏បងខ្នាមិនទៅផ្ទះ?

- បងមិនទៅ ព្រោះបងមិនចង់អោយអូនខឹងនឹងបងនោះអី...

CHANBOKEO.COM

- តែបើបងមិនទៅផ្ទះ អូនណៃខឹងនឹងបងអស់មួយជីវិត...!

ថាហើយ ធិតាដើរវឹងត្រលប់ក្រោយវិញយ៉ាងរហ័ស ធ្វើអោយនរៈ ឈរធ្វើភាំង មើលនាងពីក្រោយ ។

កងណៃត្រលប់មកដល់ផ្ទះវិញទាំងមុខក្រញូវ ។ ធិតាក៏ចុះទៅអង្គុយ លើស្ពាននៅមាត់អូរ សំយុងជើងទទះទឹកលេង ក្នុងចិត្តនឹកខឹងនាយខ្នា ណាស់ដែលភ្លេចក្រងកម្រងផ្កាមកផ្ញើនាងច្រើនថ្ងៃហើយ ។

កំពុងតែគិតភ្លេចខ្លួន ស្រាប់តែមានគេយកកម្រងផ្កាស្បៃរឿងមកស៊ក ពីលើរង្វង់កេសារបស់នាងតែម្តង ។ ធិតាងាកក្រោយភ្លែតយ៉ាងរហ័សក៏ ប្រទះឃើញភក្ត្រាមួយដែលនាងគេងនឹកច្រើនថ្ងៃមកហើយ :

- បងដឹងថាទេពធិតាមិនសប្បាយព្រះទ័យ ទើបក្រងផ្កាមកផ្ញើលួងចិត្ត

- តែអូនណៃ ឈប់ចង់និយាយចូលបងខ្នាឯងហើយ!

- ម៉េចអញ្ចឹង?

- ព្រោះបងទៅចោលផ្ទះ អោយគេគេងនឹកនោះអី!

- អ៊ូហ៎...តើនរណាគេទៅ គេងនឹកបងនោះ?

- គឺ...បងណាវ... បងណាវ គាត់នឹកបងនោះអី!

- មានន័យថា ក្រៅពីណាវចេញ គ្មាននរណាគេនឹកបងទេ មែនទេ?

កងណៃឈ្ងោកមុខនៅស្ងៀម ។

- បើអញ្ចឹង បងទៅវិញហើយ...ព្រោះនៅទីនេះ គ្មានគេនឹកបងទេ...

ថាហើយនាយក៏បែរខ្លួនត្រលប់ទៅវិញ ស្រាប់តែធិតាតូចវាចាឡើង:

- អូនណៃក៏នឹកបងដែរ...!!

ស្រាប់តែនាងស្រក់ទឹកភ្នែកច្រោក ។ ចំណែកនាយខ្នាវិញក៏ទុចចង់កំរួច ងាកបែរក្រោយ ។ កងណៃក៏ស្ទុះងើប រត់មកអោបចង្កេះនាយយ៉ាងណែន ហើយក៏យំសសឹកឡើង :

- ហេតុអីក៏បងចង់ទៅចោលអោយណៃនឹកបងអញ្ចឹង?

នាយខ្នាភ្ញាក់ព្រើតដែលធិតាមានកិរិយាដូច្នោះ ។ គេក៏បែរខ្លួនយកដៃ បបោសខ្នងនាងបន្ថើរៗដោយក្តីអាណិតស្រលាញ់ពេញបេះដូង :

- បងមិនទៅណាទេ អូនណៃ... ទីនេះជាផ្ទះបង ជាកន្លែងដែលផ្តល់សេចក្តី សុខបំផុតសំរាប់ជីវិតបង ។ អំបាញមិញបងនិយាយលេងទេ...ឈប់យំទៅ!

ថាហើយ គេក៏យកដៃជូតទឹកភ្នែកអោយស្រីតូច ដែលស្រដីថា :

- អោយណៃសូមទោសបងផង ដែលនិយាយស្តីមិនពិរោះដាក់បង...

- មិនអីទេ! បងមិនដែលគិតក្នុងចិត្តឡើយ! ឈប់យំទៅទើបបងស្រលាញ់

ធិតាក៏ជូតទឹកភ្នែកហើយញញឹមឡើង :

CHANBOKEO.COM

- អញ្ជឹង ថ្ងៃនេះ បងមកពិសារបាយផ្ទះជុំគ្នាទីនេះណា៎!

នរៈញញឹមហើយងក់ក្បាលទទួលយល់ព្រម ។ អស់ពីយំ ធិតាយើងក៏ ញញឹមភ្លាម ហើយស្ទុះរត់យ៉ាងលឿន ដើម្បីទៅប្រាប់ដំណឹងដល់បងស្រី ថៃដន្យ ស្រាប់តែជំពប់វាក់អើជាមួយនាង ពេលកងណែរត់ឡើងច្រាំង មិនដឹងថាកងណាវឈរទីនោះតាំងពីអង្កាល់ ។ រំពេចនោះ ស្រាប់តែ កងណាវ ដើរគេចចេញទៅដោយមិនស្រដីអ្វីមួយម៉ាត់ឡើយ ។

ថ្វីបើនាយខ្លាបានវិលមកបរិភោគបាយជុំគ្នា ជាមួយអ្នកទាំងពីរនៅផ្ទះ វិញដូចធម្មតាវិញ តែបរិយាកាសគ្រួសារហាក់ដូចជាផ្លាស់ប្តូរអស់រលីងតែ ម្តង ។ ម្នាក់ៗនៅស្ងៀមស្ងាត់ប្រយត្ន័មាត់ករៀងៗខ្លួន ។ នាងតូចណែមិនហ៊ានជជែកអ្វីស្និទ្ធស្នាលជាមួយនឹងនាយខ្នាទេ ត្បិតខ្លាចបងស្រីទើសទាល់ ក្នុងចិត្ត ។ ចំណែកនាយខ្នាវិញបែរជាគេចមុខមិនសូវហ៊ានមាត់កជាមួយកង ណាវដែរ ត្បិតគេគិតថាកងណាវស្ថិតក្នុងឋានៈជាបងថ្លៃរបស់ខ្លួន ត្រូវរក្សា ក្របខណ្ឌ័អោយល្អត្រឹមត្រូវជានិច្ច ។

ពេលវេលាចេះតែកន្លងទៅ...

កងណាវចេះតែស្គមទៅស្គមទៅៗ រាល់ថ្ងៃ ។ ថ្វីបើនាងមិនមាត់មិនក ឬនិយាយស្តីអ្វីច្រើន តែនាងតូចកងណែយល់ចិត្តបងស្រីណាស់ ថាហេតុអ្វី បានជានាងចេះតែស្គមទៅដូច្នោះ ។ ថ្ងៃមួយ នាងដាច់ចិត្តនិយាយជាមួយនឹងនាយខ្នាដោយត្រង់ៗ :

- បងខ្នា! បើណែសុំបងរឿងមួយ បងអោយអូនបានទេ?
- បាទ! បាន! តើមានរឿងអ្វីដែលត្រូវពឹងបងអោយធ្វើមែនទេ?

ភ្លាមនោះ ធិតាក៏ស្រវាលូកដោះខ្សែកអំបោះក្រហមបន្តោងផ្កាចំប៉ា ដែលតាមាំងបំពាក់អោយនោះយកមកហុចអោយទៅនាយខ្នា :

- គឺ..សូមបងទទួលយករបស់នេះ ទៅបំពាក់ឱ្យនារីដែលសក្តិសមនឹងធ្វើជា ភរិយារបស់បងទៅ...
- ហេតុអ្វីទៅអូនណែ?
- ខ្ញុំបានគិតរួចហើយថាបងណាវសក្តិសមជាមួយបងណាស់! ចំណែកខ្ញុំវិញ នៅក្មេងសេចក្តីណាស់ មិនទាន់ចង់មានគូស្រករទេ ។
- តែបងមានដែលស្រលាញ់អូនណាវឯណា?
- បើបងមិនស្រលាញ់បងណាវ តើបងស្រលាញ់នារីណាវិញ?
- អូនមិនដឹងពិតមែនហ្អេស ដែលថាបងស្រលាញ់អ្នកណា?
- មិនដឹងទេ.. តែបើបងហ៊ានស្រលាញ់ស្រីផ្សេងក្រៅពីបងណាវ ណែនឹង ចាក់បងអោយស្លាប់!

កល្យាណីយកកាំបិតចិតផ្លែឈើជន្លលើទ្រូងនាយ ស្រាប់តែយុវជន យើងពើងទ្រូងឡើង ថែមទាំងនិយាយថា :

CHANBOKEO.COM

- បើអញ្ចឹង អូនចាក់បងអោយស្លាប់ពេលនេះទៅ ព្រោះបងបានស្រលាញ់ គេផ្សេងរួចទៅហើយ មិនអាចទទួលអូនណាវតាមពាក្យអូនសុំបានឡើយ!

- បងខ្នា! កុំនិយាយលេងមើល៍! ខ្ញុំនឹងចាក់បងមែនណា៎។

- បងមិននិយាយលេងទេ គឺបងស្រលាញ់អ្នកផ្សេងក្រៅពីណាវមែន។

- អញ្ចឹង អូនចាក់សម្លាប់បងហើយ!

ធិតាពោលផង... ស្រក់ទឹកភ្នែកផង...ហើយក៏យារកាំបិតរកចាក់នរៈ យើងមែន ប៉ុន្តែលុះនាងដាក់កាំបិតចំសាច់ទ្រូងរបស់គេពេលណា ធិតាបែរ ជាមិនហ៊ានធ្វើទៅវិញ។ តែដោយក្តីឃ្នាន់ខ្នាញ់ ចង់ចាញ់ចង់ឈ្នះនាយខ្នា នាងតូចណែក៏យកកាំបិតឆូតខ្វែងជើងក្អែកលើទ្រូងនាយហើយស្រដីថា :

- នេះជាស្នាមគូសចំណាំថា ណែស្អប់បងណាស់ ខឹងបងណាស់!!

រំពេចនោះ ឈាមក៏ហូរស្រក់ចេញមកតាមស្នាម ដែលធិតាយកកាំបិត ឆូត មួយតំណក់ហើយមួយតំណក់ទៀត។ ឆវីរន្ធត់ចិត្តណាស់ក៏វាចាទាំង ទឹកភ្នែករលីងរលោងថា :

- បងខ្នា! ហេតុដូចម្តេចបានជាបងមិនគេច?

- បងប្រាប់អូនហើយតើ ថាបងដូរចិត្តទេ!

- អញ្ចឹងប្រាប់មក ថាបងស្រលាញ់អ្នកណា?

នរៈសម្លឹងមុខធិតា ហើយក៏ហុចបាតដៃស្តាំទៅអោយនាង :

- ចុះឯណាខ្សែកនោះ? ឱ្យបងសុំសិនមក !

កងណៃយកដៃជូតទឹកភ្នែក ហើយលើកខ្សែកដាក់ក្នុងដៃបុរសភ្លាម។ លុះទទួលបានហើយ នាយខ្នាក៏លើកខ្សែកឡើងកាន់ហើយស្រដីថា :

- ពេលនេះ ណៃប្រគល់សិទ្ធិអោយបងហើយមែនទេ?

ស្រីតូចងក់ក្បាល។ នរៈក៏ញញឹមឡើង :

- អញ្ចឹងពេលបងបំពាក់នរណា...សូមកុំជំទាស់ណា៎!!

ធិតាងក់ក្បាលសាជាថ្មី។ ស្រាប់តែនាយខ្នាលើកខ្សែកឡើងបំពាក់ឱ្យ ស្រីតូចវិញហើយចងសំលាប់មុខយ៉ាងរហ័ស។ នាងបើកភ្នែកមូលក្រឡង់ :

- បងខ្នា?

- អូនណៃ! បងសូមផ្ញើបេះដូងរបស់បងជាមួយអូនផងណា៎!

- អត់ទេ..! បងខ្នា...កុំនិយាយលេងឱ្យណៃភ័យមើល៍!

- នេះជាការពិតណា៎អូនណៃ...ព្រមទទួលស្គាល់ទៅ...!!

- អត់ទេ...បងខ្នាឆ្កួតហើយ ស្រលាញ់កូនក្មេង!!

CHANBOKEO.COM

ថាហើយនាងក៏បោះកាំបិតចោលហើយខ្ទប់មុខយំរត់ចេញទៅ ។ មែន ហើយ! ពេលនេះ ធិតាយើងមានចិត្តជ្រួលច្របល់ណាស់... តើឱ្យនាងគិត យ៉ាងណាទៅវិញ កាលបើនាយខ្លាបានទាញរូបនាង ឱ្យក្លាយជាតួឯកម្នាក់ក្នុងភ្លើងស្នេហាបីមុំនោះ?

សូមបើកវង់ក្រចកបន្តិច...

ក្នុងរវាងច្រើនឆ្នាំកន្លងមកហើយ ក្រុមចោរជាច្រើនតែងតែចុះមកពីភ្នំ ជញ្ជាំង ចូលភូមិប្លន់អ្នកស្រុក ដុតផ្ទះ និងចាប់កូនក្រមុំអ្នកភូមិញឹកញាប់ ។ ថ្មីៗនេះ រាជការបានចាត់កងការពារសន្តិសុខ ឱ្យចេញមកប្រតិបត្តិការជំរះសំបុកចោរដែលបង្កការភិតភ័យដល់អ្នកស្រុកអ្នកភូមិ នៅម្តុំខាងលិចព្រះ នេត្រព្រះរួមទាំងភូមិជប់រហូតដល់មង្គលបុរី សេរីសោភ័ណទៀត ។ កិច្ច ប្រតិបត្តិការកាន់តែមានជោគជ័យឡើងជាលំដាប់ ដោយសារមានកំលាំង សាមគ្គីពីអ្នកស្រុក ។ កាលពីប៉ុន្មានថ្ងៃមុននេះ កងរក្សាសន្តិសុខមួយក្រុម ក៏បានមកដាក់ទីតាំងនៅឃុំព្រះនេត្រព្រះនេះមួយកន្លែងដែរ ដែលសព្វថ្ងៃអ្នកស្រុកចំណាំហៅថា ភូមិប៉ុស្តិ៍ចាស់ ។

..................................................

លុះកង់ណៃរត់ចេញទៅបានបន្តិច ក៏នឹកឃើញដល់នាយខ្លាដែលមាន របួសហូរឈាមដោយសារនាង ក៏ស្ទុះរត់ទៅផ្ទះចិននៅម្តុំផ្សារព្រះនេត្រព្រះ រកទិញកៅអ៊ែកយកមកអោយនាយបិទ ស្រាប់តែវាក់អីនឹងឡានហ្ស៊ីប របស់កងប៉ូលីសសន្តិសុខ ដែលកំពុងបរត្រលប់មកទីតាំង ក៏ក្បៀរអូសឆវី អស់ប៉ុន្មានម៉ែត្រ ។ បុរសចំណាស់ម្នាក់ក៏ចុះពីរថយន្ត សួរទៅនាងថា :

- យ៉ាងម៉េចទៅហើយកូនស្រី? ត្រូវរបួសត្រង់ណាទេ?

បុរសនោះមានមុខមាត់ស្លូតបូត សំដីទន់ភ្លន់ណាស់ ។ នាងតូចងើប ឡើងតបវិញថា :

- ខ្ញុំគ្រាន់តែរលាត់កែងដៃបន្តិចបន្តួច មិនអីទេ លោកពូ!

- អញ្ជឹងឡើងឡានមក ចាំពូនាំទៅរកកៅអ៊ែកបិទ ។

នាងក៏ឡើងជិះឡានទៅជាមួយប៉ូលីសមួយក្រុមនេះ ។ មកដល់ទីតាំង កាលណា នាយកងមួយរូបនេះក៏យកកៅអ៊ែកមកបិទអោយ ថែមទាំងឱ្យ នាងថែមមួយបាច់ទៀតសំរាប់បិទថ្ងៃក្រោយ ។ នាងក៏លើកដៃសំពះថ្លែង អំណរគុណ ស្រាប់តែនាយកងនោះសួរថា :

- ហើយចុះផ្ទះនាងតូចនៅឯណាដែរ ចាំពូបើកឡានជូនទៅ ។

- ផ្ទះខ្ញុំត្រូវពួកចោរដុតឆេះអស់ហើយ សព្វថ្ងៃស្នាក់ផ្ទះអ្នកជិតខាង ។

- អូហ៍ពុទ្ធោ...ហើយចុះក្រុមគ្រួសាររបស់នាង?

- ពុកម៉ែខ្ញុំត្រូវស្លាប់ដោយសារស្នាដៃពួកចោរ នៅសល់តែខ្ញុំនិងបងស្រី

- ហ៊ឺ! នៅក្មេងសោះ កំព្រាឳពុកម្តាយ គួរអាសូរមែន!!

នាយកងមួយរូបនោះហាក់ដូចជាមាននិស្ស័យហ្នឹងធិតាយើងណាស់ ។ បន្តិចមក គាត់មានប្រសាសន៍បន្តថា :

CHANBOKEO.COM

- ដឹងទេ? ខ្ញុំមានកូនស្រីម្នាក់ដែរ អាយុប្រហែលប្អូនជាងនាងបន្តិចបន្តួច ។ គ្រាន់តែឃើញនាងភ្លាម ខ្ញុំនឹកទៅដល់កូនស្រីតែម្តង ព្រោះនាងមានភិន ភាគប្រហាក់ប្រហែលនឹងកូនស្រីរបស់ខ្ញុំណាស់ ។

ឮដូច្នោះ ធិតាក៏និយាយលេងថា :

- បើអញ្ចឹង លោកពូសុំខ្ញុំធ្វើកូនម្នាក់ទៀតទៅ បានពីរនាក់ មួយនៅផ្ទះ មួយនៅកន្លែងធ្វើការ ។

ស្រាប់តែនាយកងនោះសើចខឹក១ :

- មានអី! បើកូនស្មគ្រ័ធ្វើកូនស្រីរបស់ប៉ា ព្រឹកឡើងត្រូវតែមកបំរើប៉ាទីនេះ រាល់ព្រឹកកុំខានណា៎!

ធិតាយើងរីករាយណាស់ កាលបើលោកមិនរើសអើងរូបនាង ដែលជា កូនអ្នកក្រសាមញ្ញ ។ ធិតាលើកដៃសំពះលាហើយក៏រត់ចេញទៅ រួចស្រាប់ តែរត់បកមកវិញ :

- នាងមានការអីដែរកូន? (នាយកងសួរ)

- គឺថា...តើលោកប៉ាមានឈ្មោះអីដែរ ចាស?

- ឈ្មោះអធិការចំណាប់!

- ចាំស អរគុណ! ជំរាបលាលោកប៉ាចំណាប់!

ធិតាក៏ត្រលប់ចេញទៅ ។ លោកមេកងសម្លឹងតាមក្មេងទាំងទឹកមុខ ញញឹម ។ រំពេចនោះ ភ្នាក់ងារម្នាក់ស្រដីថា :

- លោកមេកង! មើលទៅនាងជាក្មេងឆ្លៀវឆ្លាតណាស់!

- ខ្ញុំក៏គិតថាអញ្ចឹងដែរ! នាងរហ័សរហួនហើយសំដីរួសរាយល្អណាស់ ។

- មិនដឹងជានាងបានរៀនសូត្រអីនឹងគេដែរទេហ្ន៎?

- ចាំយើងធ្វើពិសោធន៍អោយនាងអានសៀវភៅលេងទៅនឹងដឹងហើយ ។

កងណៃមកដល់ផ្ទះវិញ ឃើញបងស្រីកំពុងឈរចាំនាងនៅមាត់របង :

- អូនណៃធ្វើអីបងខ្លា បានជាគាត់ឈាមពេញខ្លួន?

- បងកុំសួរមើល៍! ណៃមិនមែនជនឧក្រិដ្ឋទេ!

- តែអូនកុំសូវកាចដាក់គាត់ពេកណា៎អូន! ប្រយ័ត្នតែគេខឹង គេស្អប់ ហើយ គេដេញយើងចេញពីផ្ទះ តើយើងទៅរស់នៅឯណា?

នាងតូចបាត់មាត់ មិនហ៊ានតមាត់នឹងបងស្រីទេ ។ បន្ទាប់មក នាងក៏ ហុចកៅអ៊ាកទៅអោយបងស្រី :

- នេះ! បងយកទៅបិទរបួសអោយគាត់ផង ។

- អត់ទេ! នរណាធ្វើអោយគេរបួស អ្នកហ្នឹងទទួលខុសត្រូវ ។

ថាហើយ កងណាវដើរគេចទៅបាត់ ទុកអោយកងណៃរអ៊ូរង៉ូវថា :

- គ្រាន់តែជួយប្អូនបន្តិចមិនបាន ។

CHANBOKEO.COM

តុក! តុក! តុក!

កងណៃបើកទ្វារចូលទៅឃើញនាយខ្នាគេងលើគ្រែធ្វើមុខស្អុយប៉ែ ។ រី
ឯទ្រូងរបស់នាយវិញក៏នៅតែប្រលាក់ឈាមពាសពេញដដែល :

- ចង់ស្លាប់ហីអី បានជាគេងអោយឈាមហូរយ៉ាងនេះ បងខ្នា?

នាយនៅតែធ្វើភ្នែកភ្លិះៗ មិនមាត់ដដែល ។ នាងក៏ដាក់កៅអ៊ាកចុះ ក្បែរខ្លួននាយហើយក៏ប្រាប់ថា :

- នេះកៅអ៊ាក ឆាប់បិទទៅប្រយត្ន័របួសវាក្លាយជាដំបៅទៅ ។

ថាហើយនាងក៏ចេញទៅវិញ ។ ថ្ងៃនោះ នាយខ្នាមិនចេញពីបន្ទប់មក បរិភោគបាយឡើយ ។
កាលបើមិនឃើញនាយបរិភោគបាយ កងណៃស្ទុះ រឹងទៅបើកទ្វារបន្ទប់នាយបំរុងជំទាលស្តីឱ្យ ស្រាប់តែឃើញនាយនៅគេង
ស្ងកកន្លែងដដែល ។ ឯកៅអ៊ាកដែលនាងដាក់ពីថ្ងៃត្រង់ណោ ក៏នៅត្រង់នោះ ដដែលទៀត ។ ទាស់ចិត្តពេក
នាងក៏ស្ទុះទៅលើកទឹកក្តៅមួយក្លាំមកជូត របួសលាបថ្នាំអោយភ្លាម :

- បងឯងឆ្កួតហើយឬបានជាមានរបួសមិនលាបថ្នាំ?

ធិតាយើងលាងរបួសអោយនាយផងស្តីអោយផង មិនឈប់មាត់សោះ
តែនាយខ្នាមិនតបមួយម៉ាត់ឡើយ ។ នេះជាកិរិយាយ៉ាងចម្លែកលើកដំបូង
ហើយដែលនាយធ្វើដាក់កងណៃ ។ ភ្លាមនោះ នាងតូចមានអារម្មណ៏ថា ប្រហែលជានាយខ្នាកំពុងខឹងនឹងរូបនាងហើយ :

- បង! កុំធ្វើអញ្ចឹងមើល៍..! ណៃសូមទោសណាំបង!

តែនាយបែរជាបិទភ្នែកនៅស្ងៀមដដែល ។ កងណៃឃើញដូច្នោះ នឹក ស្តាយក្រោយគ្រលួច រួចក៏លុតជង្គង់ចុះ
លើកដៃសំពះនាយខ្នា :

- បងខ្នា! ឱ្យណៃសូមទោសផង! ណៃមានកិរិយាមិនល្អដាក់បង! ពេល នេះណៃដឹងខ្លួនខុសហើយ ។ និយាយរកណៃវិញមកណាំ!
កុំនៅស្ងៀមឈឹង
បែបនេះ ណៃតឹងទ្រូងណាស់...

និយាយបានតែប៉ុននេះ នាងក៏អួលដើមក ស្រក់ទឹកភ្នែកច្រោក :

- ណ្ហើយចុះ! បើបងខ្នាមិនដាក់ទោសអូនទេ! ទុកអោយអូនដាក់ទោសខ្លួន ឯងក៏បានដែរ ព្រោះអូនណៃជាក្មេងមិនល្អ...!

ថាហើយនាងក៏ស្ទុះងើបរឹងឡើងបំរុងរត់ចេញទៅក្រៅ ស្រាប់តែនាយ ខ្នាចាប់ដៃនាងយ៉ាងរហ័សមិនអោយនាងទៅឡើយ ។
ស្រីតូចភ្ញាក់ព្រើត បែរមកវិញ ស្រាប់តែនាយយកដៃឆ្វេង ទៅដាក់នៅលើកន្លែងរបួសលើទ្រូង រួចក៏វាចាខ្សិបៗឡើងថា :

- ចាំទុកចុះអូនណៃ! អ្នកដែលមានសិទ្ធិធ្វើអោយទ្រូងបងរបួស មានតែ ម្នាក់ទេ ហើយចាប់ពីពេលនេះតទៅ
បងក៏មិនអនុញ្ញាត្តិអោយនារីណាបាន ប៉ះពាល់រូបកាយបងឡើយ ក្រៅពីអ្នកដែលចាក់បងឱ្យរបួសនោះ!

ធិតាឮដូច្នោះកាន់តែស្រក់ទឹកភ្នែកខ្លាំងឡើងៗ ។ ការពិតធិរីមិនស្គាល់
ថាស្នេហាជាអ្វី មានន័យបែបណា ជំរៅយ៉ាងណាទេ.. ប៉ុន្តែ អ្វីដែលនាងដឹង

CHANBOKEO.COM

ច្បាស់នោះ គឺនាយខ្នាបានទំយើរូបនាង ធ្វើតាមចិត្តនាងសព្វយ៉ាង រហូត ដល់នាងខូចទំលាប់អស់ ហើយក៏បែរក្លាយជាមានចរិតផ្ដេសផ្ដាស ប្រព្រឹត្ត ផ្ដេសផ្ដាស សំដីព្រហើន ។ មើលចុះ! ពេលនេះ នាងក៏បានធ្វើអោយគេក្លាយទៅជាមនុស្សដ៏ចម្លែកម្នាក់ ដែលមិនសប្បាយរីករាយ មិនទន់ភ្លន់ ដូចរូបខ្នាដែលនាងធ្លាប់ស្គាល់កន្លងមកនោះទេ ។ គិតទៅគិតមក៏ ធិតានឹក អាណិតនាយខ្នាកាន់តែខ្លាំងឡើង ដែលនាយបានក្លាយជាមនុស្សដែលរងគ្រោះដោយសារកិរិយាដ៏មិនប្រពៃរបស់នាង ។

កាលបើឃើញធិតាយំខ្សឹកខ្សួល នាយខ្នាក៏ក្រោកអង្គុយឡើងយកដៃជូតទឹកភ្នែកអោយនាង រួចហើយក៏ស្រដីថា :

- បងមានឈឺអីឯណា គ្រាន់តែអស់កម្លាំងបន្តិចទេតើហ៎! ម៉េចចាំបាច់យំ ព្រួយគិតអីពីបងដល់ម្លឹង? ម៉ោះ! ឈប់យំទៅណា៎! ពេលនេះ បងខ្នា ជាវិញហើយ!!

ធិតាសម្លឹងមុខនរៈទាំងទឹកចិត្តរំជើបរំជួលក្នុងចិត្តក្រៃលែង :

- បងខ្នា!

ថាហើយ នាងក៏លូកដៃស្រវាឱបចង្កេះនរៈរួចដាក់កេសាលើស្មានរៈ :

- ឱ្យណែសូមទោសផង! ណែជាក្មេងព្រហើន គួរណាស់តែបានទទួលការ ដាក់ទោស តែហេតុអ្វីក៏បងនៅតែល្អនឹងអូនដដែល?

- គឺមកពីបងស្រលាញ់អូននោះអី អូនណែ... បងប្រាប់អូនហើយតើហ៎ ថា ចំពោះណែ បងអាចអភ័យទោសអោយគ្រប់រឿងជានិច្ច ។

មែនហើយ... ទោះបីជាគេលួចអន់ចិត្តខ្លះៗនឹងចរិតរបស់ណែ ក៏បុរសយើងនៅតែអភ័យទោសឱ្យនាងរាល់ដង នោះព្រោះតែសេចក្ដីស្រលាញ់ ដែលនាយមានចំពោះធិតាយ៉ាងជ្រាលជ្រៅ ។ បរិយាកាសក៏ប្រែធូរស្រាល មកវិញ កាលបើនាយខ្នាព្រមទទួលយកអាហារមួយស្លកពីកងណែជាការ ទទួលកំហុសរបស់នាង ។ រាត្រីនោះ ធិតាមានអារម្មណ៍យ៉ាងចំលែកនៅក្នុង ជំរៅចិត្តចំពោះបុរសយើង... មិនដឹងថាហេតុអ្វីទេ ពេលណានាងកាន់តែ ខឹង កាន់តែស្អប់គេខ្លាំងប៉ុណ្ណា នាងក៏កាន់តែត្រូវការរូបគេត្រលប់មកវិញ ខ្លាំងប៉ុននោះដែរ ។ ពេញមួយយប់នោះ នាងគេងរំជួលចិត្តស្ដាយក្រោយ ផងដែលបានធ្វើមិនល្អទៅលើនាយខ្នា តែក៏នឹកស្រលាញ់គេផង ដែលគេតែងតែមានចិត្តសណ្ដោសនាងជានិច្ច...មិនថាពេលណា...

ថ្ងៃខែចេះតែកន្លងទៅ...

រាល់ថ្ងៃ នាយខ្នាចេញទៅធ្វើការអោយគេ ជាកូនជាងឈើសំណង់ ។ កងណាវបន្តរបរចិញ្ចឹម ជ្រូកមាន់ទា ពីម្ដាយរបស់នាង ដោយមានកងណែ ជាដៃជើង ។ បន្ទាប់ពីអោយចំណីមាន់បាយជ្រូកហើយ កងណែក៏រត់ទៅទីស្នាក់ការកងសន្តិសុខដើម្បីជួបឪពុកធម៌របស់នាងគឺលោកមេកងចំណាប់ ។ លោកជាមនុស្សមានប្រាជ្ញាហើយមានមេត្តាធម៌ណាស់ ។ ពេលឃើញស្រី តូចមកបំរើទឹកក្ដៅត្រជាក់ជូនលោក លោកបានអោយសៀវភៅនាងច្រើន ក្បាលសម្រាប់អាន

CHANBOKEO.COM

ដើម្បីពិសោធន៏ចំណេះវិជ្ជារបស់នាង ។ តែធិតាអាន ចប់គ្រប់សៀវភៅ ហើយយល់អត្ថន័យរាក់ជ្រៅក្នុងអត្ថបទបានយ៉ាងច្បាស់លាស់ ។  លោកចំណាប់ឃើញនាងមានសម្បទា និងមាននិស្ស័យចំពោះការ
សិក្សា ក៏បបួលនាងឡើង :

- បើប៉ាបបួលកូនទៅនៅបាត់ដំបង ចូលរៀនសូត្រយកតម្រេះ ដើម្បីចាប់ ការងារខ្ពង់ខ្ពស់ តើកូនគិតយ៉ាងណាដែរ?

ធិតាត្រេកអរណាស់ កាលបើបានទទួលការទំនុកបំរុងពីលោកឪពុក ធម៌ ។ តែលុះនាងពិគ្រោះជាមួយកងណារ៍និងនាយខ្នាទាំងពីរនាក់បញ្ចេញ ការរារែកក្នុងចិត្ត ត្បិតគេមិនស្គាល់ក្រុមគ្រួសារលោកចំណាប់ ។ កាលបើ អ្នកទាំងពីរមិនជ្រោមជ្រែងកងណៃអស់កម្លាំងចិត្តរលីងតែម្តង ។

រាត្រីមួយ...

មានក្រុមចោរចូលប្លន់ក្នុងភូមិទៀតហើយ ។ ក្រុមចោរនិងកងពិសេស ក៏បានប៉ះទង្គិចគ្នា ។
ក្រុមចោរមួយហ្វូងបានរត់មកដល់ម្តុំដីភូមិនាយខ្នា ចាប់ អ្នកទាំងបីជាចំណាប់ខ្មាំង ។ ដោយការឆ្លៀវឆ្លាតរហ័សរហួន នាយខ្នាក៏រត់រួច ហើយរំដោះបានកងណារ៍ចេញមក តែនៅជាប់កងណៃក្នុងដៃចោរនៅ ដដែល ។ គេទាំងពីរក៏ចូលរួមជាមួយអ្នកស្រុកនិងកងរាជការការពារ សន្តិសុខ វាយសម្រុកហ្វូងចោរ ។ កាលបើប្រទះឃើញកងណៃស្ថិតក្នុងដៃ ចោរម្នាក់ កងណារ៍ក៏លើកស្នាដៃករបស់ឪពុកនាងបាញ់ចោរនោះធ្លាយ បំពង់ក ។ ស្រាប់តែចោរម្នាក់ទៀត លើកកាំភ្លើងបាញ់វិញ ចំកណ្តាលខ្លួន របស់កងណារ៍ធ្វើអោយនាងដួលប្រួសទៅដីដាច់ខ្យល់មួយរំពេច ។ នាងតូច ណៃឃើញហើយក៏ស្ទុះរត់មកជួយបងស្រី តែត្រូវពួកចោរបាញ់ចំចង្កេះស្តាំ ដួលខ្ចោកបាត់ស្មារតីទៅ ។

ព្រហាមឡើង...

ពួកចោរត្រូវស្លាប់អស់ជាច្រើន តែក៏ត្រូវចាប់ខ្លួនបានច្រើនដែរ ។ អ្នក
ភូមិក៏បានបាត់បង់ជីវិតអស់ជាច្រើននាក់រួមទាំងកងណារ៍ផង ។ នៅលើគ្រែ រនាបឫស្សី
កងណៃគេងសន្លប់បាត់ស្មារតីមិនទាន់ដឹងខ្លួននៅឡើយទេ ។  នាយខ្នាដើរចុះដើរឡើងយ៉ាងអន្ទះសា
ស្រាប់តែលោកចំណាប់បានមកដល់ ហើយមានប្រសាសន៏ទៅនាយយើងថា :

- ពូត្រូវយកនាងទៅមន្ទីរពេទ្យធំហើយ គ្រែងលោអាចរក្សាជីវិតរបស់ នាងបាន ព្រោះនាងមានរបួសធ្ងន់ណាស់ ។ ថ្ងៃនេះពូនិងសហការីត្រូវផ្លាស់ វេនទៅបាត់ដំបងវិញ ហើយក្រុមថ្មីគេនឹងចូលជំនួស ។ សំរេចចិត្តទៅ ថា
ក្មួយចង់អោយនាងនៅ ឬក៏អោយនាងទៅ?

នរៈសម្លឹងមើលទៅធិតាដែលគេងសន្ធឹងសន្ធៃនៅលើគ្រែ ។ ក្នុងទ្រូង របស់គេខ្វល់ខ្វាយចំពោះនារីយើងណាស់ ខ្វល់ខ្វាយរហូតមិនដឹងថានឹងត្រូវ ធ្វើយ៉ាងណាទៅហើយ ។ បើនឹងទុកនាងនៅ ក៏មានសង្ឃឹមតិចណាស់ថា កងណៃនឹងផុតគ្រោះថ្នាក់ ។ បើសិនអោយនាងទៅវិញ ប្រហែលជានាង អាចមានឱកាសសាជាថ្មីម្តងទៀត ។ ប៉ុន្តែ... តើគេអាចទុកចិត្តបានទេថា លោកមេកងចំណាប់ និងក្រុមគ្រួសាររបស់លោក មានធម៌មេត្តាចំពោះនារី យើង... ហើយក៏រិតណាដែរ? អ្វីៗសុទ្ធតែជាការប្រថុយប្រថាន ។ ទីបំផុត គេក៏សំរេចចិត្តអោយនាងចាកចេញទៅ

CHANBOKEO.COM

ជាមួយលោកមេកងធំណាប់... ដោយមិនបានលាគ្នាមួយម៉ាត់ ។ រថយន្តចេញដំណើរទៅហើយ.. បរដឹករូប
កាយស្លុកស្តឹងរបស់នារីចេញឆ្ងាយទៅៗ កប់បាត់ទៅក្នុងផ្សែងធូលីដីខ្ពល ខ្ទាញ់ដោយនាំទាំងបេះដូងរបស់នាយខ្នាបាត់ទៅផងដែរ ។ ខ្នាឈរសំរក់ទឹក ភ្នែកតែម្នាក់ឯងលើផ្លូវថ្នល់ បែបទន់អស់ទេវតាឥន្ទព្រហ្មទាំងឡាយឱ្យលោក
ជួយតាមថែរក្សាកល្យាណីម្ចាស់បេះដូងរបស់គេអោយបានសុខសប្បាយ...

ចាប់តាំងពីថ្ងៃនោះមក.. នាយខ្នាក៏លែងបានទទួលដំណឹងអ្វីទាំងអស់ ពីកងវែណៃ មិនដឹងថានាងលាចាកលោកនេះទៅហើយ ឬក៏នាងមានជីវិត នៅឡើយទេ ។ រីឯផ្លូវចរាចរពីសេរីសោភ័ណទៅសៀមរាប បានស្ថិតនៅ ក្នុងភាពគ្រោះថ្នាក់អស់ជាយូរឆ្នាំ បន្តបន្ទាប់មក ដោយសារតែអសន្តិសុខ បង្កដោយក្រុមចោរភ្នំជញ្ជាំងដ៏កាចសាហាវ ។ ទំរាំរាជការរៀបចំបោស
សំអាតសំបុកចោរបានអស់ពីភូមិស្រុក គឺចំណាយអស់រយៈពេលជិត១០ឆ្នាំ
ឯណោះ ។

ក្រោយមក នាយខ្នាបានបែរមកចាប់អាជីពជាជាងសំណង់ រហូតដល់ បានក្លាយជាមេជាងយ៉ាងចំណានល្បីល្បាញមួយរូប នៅម្តុំស្រុកព្រះនេត្រ ព្រះ ភ្នំស្រុកនិងក្រឡាញ់នេះ ។ ព្រមពេលជាមួយគ្នានោះដែរ គេក៏បានប្រែ
ក្លាយទៅជាមនុស្សដែលមានជីវិតកណ្តោចកណ្តែង រស់នៅស្ងាត់ស្ងៀម មិន សូវរវីរវល់នឹងនរណាទេ ក្រៅតែពីតាញ៉ៅ យាយព្រីង និងព្រះគ្រូចៅ អធិការឧត្តរៈ តែប៉ុណ្ណោះ... គឺគេបានបិទទំព័រដួងចិត្តរបស់គេ ចោលនៅ មួយអន្លើ
ដោយមិនរវល់នឹងនឹកអើពើសេរីអនុស្សាវរីយ៍របស់គេមកវិញ ឡើយ...

0000000000000000000

00000000

0

CHANBOKEO . COM

# វគ្គទី១០
# ចរណៃដួងច័យា

ភូមិព្រះនេត្រព្រះ ឆ្នាំ១៩៥៨...

- ការពិត អ្នកគ្រូចរណៃជាកុមារីកងណៃកូនពៅតាមាំងនោះទេ?

- មែនហើយលោកចក្រា! (អ្នកគ្រូចរណៃតបវិញ)

ចក្រាដកដង្ហើមយូៗបន្ទួទ្រូង ហើយក៏វាចាទៅកាន់ព្រះគ្រូឧត្តរះថា:

- នេះជាការពិតមែនឬព្រះគ្រូ?

- ជាការពិត ឥតក្លែងក្លាយឡើយ លោកចក្រា! (ព្រះគ្រូមានដីការបន្ទរ) សូមទទួលយកការពិតទៅ នោះស្មារតីរបស់លោកនឹងបានភ្លឺស្វាងមកវិញ!

- តែខ្ញុំនៅតែមិនជឿដដែល...លុះណាតែមានការបញ្ជាក់ពីលោកភូឈួយ ខេត្តនិងភរិយាថែមទៀត...

លោកចក្រានិយាយដោយមិនអស់ចិត្ត។

- ខ្ញុំនិងភរិយាមកដល់ហើយលោកចក្រា! លោកត្រូវការសួរបញ្ជាក់រឿង អ្វីពីយើងទាំងពីរមែនទេ?

ចក្រាបែរក្រោយរឹងឃើញ អ្នកគ្រូចំណានទឹងនាយភុំនាំលោកភូឈួយ ខេត្តចំណាប់និងភរិយាចូលមកដល់។ គេបើកភ្នែកធំៗ ដោយការភ្ញាក់ផ្អើល ហើយក៏កំពុងរអៀសខ្លួនដែរ ដែលខ្លួនបានប្រព្រឹត្តមិនគប្បីកាលពីយប់មិញ ចំពោះកូនស្រីរបស់លោកទាំងពីរនាក់។ បំពង់ករបស់គេស្ងួតអស់រលីង ថ្វី បើគេប្រឹងលេបទឹកមាត់ប៉ុន្មានដងហើយក៏ដោយ។ បន្ទាប់ពីប្រមូលសេចក្តី ក្លាហានបានវិញ គេក៏សួរទាំងស្អិតបំពង់កថា :

- លោកភូឈួយខេត្ត តើពិតដែរទេ ដែលថាអ្នកគ្រូចរណៃ គេ...?

- អ្វីដែលកូនស្រីរបស់ខ្ញុំបានរៀបរាប់ទាំងអំបាលម៉ាននោះ ជាការពិតទាំង អស់ លោកចក្រា! (លោកភូឈួយខេត្តតបវិញ) តើមានប្រយោជន៍ដែល នាងត្រូវភូតភរអោយអាប់កត្តិយសខ្លួនធ្វើអ្វី?

ពេលនោះ លោកចក្រាមានទឹកមុខស្វាយល្អកហាក់ដូចចង់ខ្យល់ចាប់ ដួលទាំងជំហរតែម្តង។ អ្នកស្រុកក៏ស្រែកអ៊ូអរឡើង ទារបំណុលថ្លៃកម្លាំង ដែលគេបានខាតពេលវេលាមកជួយកសាងផ្ទះគ្រូ។ ខ្លះជួយទារបំណុលឱ្យ ជាងសម្លាកដែលបានបាត់បង់ផ្ទះទៅ។ ខ្លះទាមទាររកយុត្តិធម៌អោយអ្នក គ្រូទាំងពីរនាក់។ ខ្លះទៀតអោយចក្រាលុតជង្គង់សូមទោសជាងសម្លាក។ ខ្លះអោយចក្រាសូមទោសលោកភូឈួយខេត្ត។ល។ កាលពីយប់មិញលោក ចក្រាស្រវាំងភ្នែកស្រវាំងស្មារតីព្រោះស្រា ពេលនេះគេស្រវាំងនេត្រាត្បិត ព្រោះសម្រែកអ្នកស្រុកទាមទាររកយុត្តិធម៌។

CHANBOKEO.COM

ស្នូរសម្លេងអ្នកស្រុកអ្នកភូមិ ស្រែកសម្លុតបានធ្វើអោយគេរន្ធត់ស្មារតីមិនតិចឡើយ ។ ភ្លាមនោះ នាងខឿនចេញមុខមកដល់កណ្តាលចំណោម យកដៃចង្អុលមុខដង្ហៅចក្រា :

- ពួកយើងត្រូវតែចាប់វាដាក់ខ្នោះបញ្ចូលទ្រុងទើបបាន ព្រោះវាជាប្រេត តិរច្ឆាននៅក្នុងស្រោមទេវតា!!

ស្រាប់តែអ្នកស្រីស៊ីផាធ្វើទឹកមុខភ្ញាក់ផ្អើល ហើយក៏យកខ្លួនទៅរាំង បាំងកូនប្រុសរបស់អ្នកស្រី :

- នែ៎ និយាយស្អីអោយវាស្គាល់អំបូរ ស្គាល់វណ្ណៈផង នាងល្អ!

- អូហ៎! សូមទោសអ្នកស្រី! សូមពន្យល់ពួកយើងផងបានទេថាអ្នកស្រីនិងកូនអ្នកស្រីអំបូរអ្វី វណ្ណៈអ្វីដែរ ដែលមានកូនប្រុសដើរទំលាក់កូនចោលដូច ជ្រូកបា? អំបូរជ្រូកបា វណ្ណៈដេកក្នុងជុចមែនទេ? (នាងខឿនតបវិញ)

អ្នកស្រុកហ៊ោរគិលឡើង កាលបើឮប្រយោគនេះ :

- មានន័យថាយ៉ាងម៉េចហ្នាំសនាងខឿន? (អ្នកស្រីស៊ីផាសួរ )

- មានន័យថា តើអាឪរបស់អាក្មេងនៅក្នុងពោះខ្ញុំមួយនេះ និងឪរបស់អា ក្មេងតូចមួយនេះ (នាងខឿនយកដៃចង្អុលកូនតូចមួយអាយុប្រហែលពីរ ឆ្នាំដែលនាងកំពុងឈរកាន់ដៃ) តើវាជាជ្រូកបា វណ្ណៈអ្វី អំបូរអ្វីដែរ? ខ្ញុំចង់ដឹងណាស់ព្រោះវាហ្នឹងកំពុងឈរនៅក្រោយខ្នងរបស់អ្នកស្រីហើយ ។

នាងស្រដីផង យកដៃចង្អុលមុខលោកចក្រាផង ។ ទាំងអស់គ្នាផ្អើល គិលឡើង ។ ទីបំផុតលោកចក្រាក៏មុខស្វាយអស់ក្រឡាលោតតែម្តង :

- កុំនិយាយតែផ្តាស នាងខឿន! (លោកចក្រាគំហក)

- មិនផ្តាសទេ ព្រោះយើងមានសាក្សីច្រើនទៀត...ចង់អោយយើងហែក កេរ្តិ៍របស់លោកទៀតទេ?

ស្រាប់តែអ្នកស្រីស៊ីផាយកដៃរាឡើង ត្បិតដឹងថាខ្លួនគាត់នឹងកូនកំពុង លេងអុកងាប់ក្រឡាឈឹង លោតលេងរួច :

- អឺ! ណ្ហើយចុះ! តើនាងចង់បានជំងឺចិត្តប៉ុន្មានដែរ?

- ខ្ញុំមិនចង់បានលុយទេ អ្នកស្រី! អ្វីដែលខ្ញុំចង់បាន គឺវានេះដេកគុក!!

- ស្លាប់ហើយ! អីក៏ធ្ងន់ធ្ងរម្ល៉េះ?

សែបផុនដែលស្ងៀមស្ងាត់យូរហើយ ក៏មានប្រសាសន៍ឡើងថា :

- ភូមិយើងធ្លាប់បានត្រូវចោរឃ្មួញភ្នំជញ្ជាំងធ្វើទុក្ខបុកម្នេញអស់ជាយូរឆ្នាំទំរាំយើងបានទទួលសន្តិសុខវិញ ។ ឥលូវស្រុកទេសមានច្បាប់ទម្លាប់ហើយ ហេតុដូចម្តេចក៏យើងបង្រៀនខ្លួនឱ្យកាន់មារយាទដូចជាពួកចោរព្រៃទាំង នេះទៅវិញ? មនុស្សយើងនេះ មិនថាអ្នកកើតមកក្នុងត្រកូលអ្វី វណ្ណៈអ្វីទេ កាលបើយើងកាន់មារយាទជាចោរព្រៃហើយ យើងហ្នឹងក៏ជាចោរព្រៃដែរ មិនមែនអ្នកល្អ អ្នកថ្លៃថ្នូរអ្វីទៀតទេ! ថ្វីបើយើងមានទ្រព្យច្រើនយ៉ាងណា ក៏ដោយ ក៏ទ្រព្យមិនអាចយកស្រោបមារយាទកខ្វក់របស់យើងបានដែរ ។ យើងមិនខុសពីចោរព្រៃទេកាលបើមារយាទយើងមិនប្រពៃ ។ បើសិនជា យើងតាំងខ្លួនជាអ្នកមានកត្តិយសពិតមែន

CHANBOKEO.COM

សូមរក្សាមារយាទខ្លួនអោយ ថ្លៃថ្នូរផង ។ សព្វថ្ងៃ យើងសុទ្ធតែជាអ្នកភូមិជាមួយគ្នា ហេតុអ្វីក៏តាំងខ្លួនជាសត្រូវនឹងគ្នាទៅវិញដូច្នេះ? ហើយបើកាន់មារយាទរបៀបនេះ តើ ថ្ងៃណាទៅភូមិយើងនឹងមានសេចក្ដីស្ងប់ស្ងៀម កាលបើភាពស្អប់ខ្ពើម ភាព និន្ទា និងកំហឹងឈ្នានីស នៅដុតរោលជីវិតយើងរៀងរាល់ថ្ងៃ ។ យើងបានបង្ក្រាបចោរព្រៃភ្នំជញ្ជាំងរួចហើយ ។ ពេលនេះ ដល់ពេលហើយដែលយើង ត្រូវកំចាត់ចោរក្នុងស្រុកដែលចាំតែបំផ្លាញអ្នកភូមិ និងចោរឧត្បាតនៅក្នុង ចិត្តដែលចាំតែប្រទុសនឹងមនុស្សដូចគ្នា..!

សំដីនេះបានធ្វើអោយលោកចក្រារួញមុខតូចប៉ុនអាចម៍សុច ។ បន្ទាប់មក សែបផុនក៏ពោលទៅលោកចក្រាថា :

- ពេលនេះ យើងមានសាក្សីច្រើនណាស់ ដែលបានដឹងឮ អំពីអំពើឧក្រិដ្ឋរបស់លោក តាំងពីរឿងដុតបំផ្លាញទ្រព្យអ្នកដទៃ បំពានលើរូបកាយអ្នក ដទៃនៅក្នុងដីកម្មសិទ្ធរបស់គេ យាយីរូបកាយស្ត្រី និងរឿងដុតបំផ្លាញ ទ្រព្យរួមដូចជាផ្ទះគ្រូនេះជាដើម ។ ដូច្នេះ លោកត្រូវទទួលទោសច្រើនជាន់ ច្រើនថ្នាក់ណាស់ ។ ប៉ុន្តែ យើងសូមអោយលោករើសយកផ្លូវដែលងាយជាង គេ ។ ទីមួយគឺចុះអេតាស៊ីវិលទទួលនាងខឿនជាភរិយាពេញច្បាប់ និងចុះសំបុត្រកំណើតអោយកូនទាំងពីរអោយបានត្រឹមត្រូវ ។ ទីពីរត្រូវសង់ផ្ទះគ្រូ សងវិញអោយដូចដើម តែមិនត្រូវជិះជាន់កម្លាំងអ្នកស្រុកតទៅទៀតទេ ។ ទីបី សង់ផ្ទះអោយនាយខ្នាវិញ ។ ទីបួនសូមទោសនាយខ្នា អ្នកគ្រូចរណៃ និងអ្នកគ្រូចំណាន ។ ទីប្រាំ សូមទោសអ្នកស្រុកទាំងអស់ដែលអត់ងងុយ ខានដេកពួន ខានទៅធ្វើការងារ ព្រោះតែរវល់មកជួយពន្លត់អគ្គីភ័យកុំឱ្យ ឆេះរាលដាល ។ ទីប្រាំមួយ សូមទោសគ្រប់គ្នាដែលត្រូវរំខានដោយសារ រឿងរបស់នាយ ដូចជាព្រះគ្រូ តាមេភូមិ លោកចំណាប់ជាដើម ។ ហើយបើ សិនមិនសុខចិត្តធ្វើតាមនូវសំណូមពរនេះទេ ខ្ញុំសូមវាយខ្នោះដៃជូនលោកឥលូវនេះ រួចនៅពេលព្រឹកស្អែក រូបលោកនឹងមានផ្សាយនៅទំព័រទីមួយ ក្នុងកាសែតពតិមានប្រចាំខេត្ត ។

លោកចក្រាសម្លឹងមុខម្ដាយ ហាក់ដូចជាចង់សួរយោបល់ ចំប៉ះលើអ្នក ស្រីស៊ីផាដែលជាមនុស្សគំរិះម៉ៅស្ងិត ។ ពេលនេះ អ្នកស្រីស្ដាយលុយដែល ត្រូវសងគេនោះណាស់ តែអ្នកស្រីក៏មិនអាចបណ្ដោយអោយរូបកូនប្រុសរបស់អ្នកស្រីចុះនៅទំព័រទីមួយលើកាសែតបានដែរ ។ កំពុងតែរេរា មេជាង សម្លាកក៏លើកដៃឡើង :

- ជំរាបកាត់ប្រសាសន៍បន្ដិចបាទ! យើងទាំងបីនាក់ អ្នកគ្រូចំណាន អ្នកគ្រូ ចរណៃ និង ខ្ញុំបាទ មិនត្រូវការសំណងអ្វីទេ ក្រៅពីការសូមទោសនិងសូម អោយលោកចក្រាកែខ្លួន ។ ឯចំណែកថ្លៃខូចខាតដែលត្រូវសងខ្ញុំវិញនោះ ខ្ញុំសូមកាច់ជាដីស្រែដើម្បីទុកជូនបងប្អូនទីនេះធ្វើស្រែចិញ្ចឹមជីវិតទៅចុះ ។

អ្នកភូមិទះដៃហ៊ោរក្រេវឡើង បញ្ចេញនូវឯកភាពរបស់គេចំពោះ គំនិតនេះ ។ ក្រោយពីព្រះគ្រូចៅអធិការឧត្តរៈ តាមេភូមិ សែបផុន លោក ចំណាប់ និងចាស់ទុំជាច្រើនទៀតសម្រុះសម្រួលគ្នាទៅ លោកចក្រាក៏ត្រូវបង់ផាកពិន័យដោយផ្ទេរដីស្រែចំនួនដល់ទៅ ២០ហិកតារ អោយទៅអ្នក ស្រុកព្រះនេត្រព្រះវិញ រួចត្រូវទទួលយកនាងខឿនជាភរិយាពេញច្បាប់ ដោយមានលោកចក្រានិងអ្នកស្រីស៊ីផាស៊ីញ៉ែទទួលខុសត្រូវទាំងពីរនាក់ ។ ថ្វីបើទើសទាល់យ៉ាងណា ចក្រានិងអ្នកស្រីស៊ីផាក៏អស់ក្រឡានឹងដើរគេច ដែរ ។ គេត្រូវតែបង្ខំចិត្តទទួលយកសំណើនោះ

CHANBOKEO.COM

ដើម្បីសម្រាលទោសរបស់ លោកចក្រាដែលលង់ទោសៈមោហៈភ្លេចខ្លួនរហូតដល់បង្កការខូចខាតវត្ថុ ទ្រព្យរបស់អ្នកភូមិនិងជាន់ឈ្លីរូបកាយអ្នកដទៃ...

ក្រោយមកអ្នកស្រុកក៏បំបែកជួរទៅ។ អ្នកគ្រូចរណៃនិងប្អូនស្រីក៏បាន ត្រលប់មកស្នាក់នៅផ្ទះសែបផុនដូចដើមវិញដដែល។ ចំណែកនាយខ្លាវិញ ក៏ទៅស្នាក់នៅជាមួយតាញ៉ៅ ហើយបានវិលត្រលប់ទៅធ្វើការងារជាមួយ អ្នកភូមិធម្មតាវិញ។

យូរថ្ងៃកន្លងទៅ...

ព្រឹកនេះជាថ្ងៃបវេសនកាល អ្នកគ្រូចរណៃតុបតែងខ្លួនដោយសំពត់ ខៀវអាវសយ៉ាងសុភាពតែស្រស់ស្អាតថ្លៃថ្នូរណាស់ ដោយមានអ្នកគ្រូ ចំណានជួយអោយយោបល់ផង :

- ថ្វីបើបងស្រីខ្ញុំស្ថិតនៅក្នុងសម្លៀកសុភាពយ៉ាងនេះក៏ដោយ ក៏សម្ផស្ស របស់បងបានលេចធ្លោយ៉ាងត្រកាល! ខ្ញុំថាបើសិនបងខ្លាបានឃើញបងនៅ ពេលនេះ បេះដូងគាត់ច្បាស់ជាលោតធ្លាយដើមទ្រូងមិនខានឡើយ។

ចរណៃយកដៃក្តិចប្អូន :

- កុំនិយាយលេងហួរហែពេក អ្នកកវីអើយ! គិតតែពីប្អូនទៅ! ឥលូវនេះ បងឧស្សាហ៍ឃើញកន្លង់សង្ហាមួយ ចេះតែហោះឆ្វៀលម្តុំនេះញឹកញាប់ដល់ សួរហើយ...

ចំណានយកដៃខ្ទប់មុខ :

- អត់ទេ បងណៃ! កុំនិយាយអញ្ចឹងមើល៍...! ស្អប់បងដល់ហើយ!

ចរណៃសើចខឹកៗ កាលបើឃើញប្អូនស្រីអៀនឡើងក្រហមមុខ។ រំពេចនោះ លោកចំណាប់និងភរិយាក៏បានមកដល់ :

- ជំរាបសួរ លោកប៉ា! ម៉ាក់!

ចរណៃនិងចំណានស្ទុះទៅទទួលលោកទាំងពីរ ហើយសួរបន្ថែមថា :

- មានការអ្វីសំខាន់នៅម្តុំនេះឬ បានជាលោកប៉ាបើកឡានមកពីបាត់ដំបង តាំងពីព្រហាម.?... ព្រោះពេលនេះ ម៉ោងមិនទាន់៨នៅឡើយទេ...

លោកចំណាប់ក៏មានប្រសាសន៍តបថា :

- មែនហើយកូន! ប៉ាម៉ាក់មានការសំខាន់ចាំបាច់ណាស់ ខានមិនបានទេ!

ភ្លាមនោះ ស្រាប់តែមានអ្នកស្រុកជាច្រើនបានមកដល់មុខផ្ទះរបស់ សែបផុន។ ចរណៃក៏នាំគ្រួសារសែបផុន ព្រមទាំងឪពុកម្តាយរបស់នាង ចុះទៅទទួលដោយមានអ្នកគ្រូចំណានរត់ចុះតាមពីក្រោយផង :

- បងប្អូនមានការអ្វីហ្នឹង បានជានាំគ្នាមកដល់ទីនេះយ៉ាងកុះករ?

ភ្លាមនោះ នាយខ្លែងដែលស្ថិតក្នុងសម្លៀកយ៉ាងស្អាត ចេញមុខមក ឆ្លើយប្រាប់អ្នកគ្រូថា :

- គឺយើងបានទទួលបញ្ជាពីតាមេឃុំអោយដង្ហែអ្នកគ្រូនិងក្រុមគ្រួសារទៅ កន្លែងបុណ្យ!

- កន្លែងបុណ្យ? បុណ្យអ្វីទៅ ម្តេចក៏ខ្ញុំមិនដឹងដូច្នេះ?

CHANBOKEO.COM

- ពួកយើងក៏មិនទាន់ដឹងដូចគ្នាដែរអ្នកគ្រូ ។ សូមអញ្ជើញឡើងមក!

អ្នកគ្រូចរណៃក្រលេកទៅក្រោយខ្នងអ្នកភូមិឃើញរទេះគោមួយគូ ដែលមានការតុបតែងយ៉ាងស្អាតខុសធម្មតា ។ រទេះមួយទំនេរ មានក្រាល កន្ទេលក្រហមយ៉ាងស្រស់ ។ រទេះមួយទៀត ចងកម្រងផ្កានិងមានចងឆត្រ័ ប្រកបដោយរំយោលទឹកមាសផ្លេក១គួរអោយចាប់ភ្នែកក្រៃលែង ។

- សូមអ្នកគ្រូឡើងលើរទេះដែលមានឆត្រ័នេះមកក្រាបទូល ។

ចរណៃនិងអ្នកគ្រូចំណានក៏ឡើងជិះរទេះដែលមានឆត្រ័ ។ ចំណែក ចាស់១ជិះរទេះកន្ទេលក្រហម ។ បន្ទាប់មកអ្នកស្រុកក៏ហែនាំមុខរទេះចេញ ទៅ ។ ចរណៃនិងចំណានមើលមុខគ្នា :

- អូនដឹងទេ ថាអ្នកស្រុកគេកំពុងធ្វើបុណ្យអី?

- ចំណានក៏មិនដឹងដែរ តែពេលនេះដូចជាមានប្រផ្នូលថា មានពីធីពិសេស ដ៏រំភើបរីករាយជាមិនខាន ។

រំពេចនោះ ចរណៃចាប់ភ្លឹកថា អ្នកស្រុកបានបររទេះនាំក្បួនយាត្រា សំដៅដីភូមិរបស់ជាងសម្លាក ។ នាងភ្ញាក់ស្មារតីព្រើត ទឹកភើតក្នុងពោះ គ្រលួច ។ ឯបេះដូងក៏លោតឱបខ្ទាក់១ខុសចង្វាក់តែម្តង ។ មកដល់ក្លោងទ្វារ របងដីភូមិជាងខ្ចា គេរាល់គ្នាក៏ប្រទះនឹងគេហដ្ឋានដ៏ថ្មីមួយខ្នងសង់អំពីឈើ ខ្ពស់ពីដី ប្រក់ក្បឿងក្រហមយ៉ាងស្រស់ ថែមទាំងមានសង់រោងការយ៉ាងធំ នៅពីមុខផ្ទះទៀតផង ។ ពេលនេះ ចរណៃរិតតែភិតភ័យញាប់ញ័រក្នុងចិត្ត ត្រជាក់អស់ជើងដៃ ត្បិតនាងកាត់ស្មានយល់ហើយ ថាអ្នកស្រុកអ្នកភូមិគេ កំពុងតែធ្វើអ្វីនៅពេលនេះ ។

នៅចំពោះមុខព្រះគ្រូចៅអធិការឧត្តរៈ ដោយមានតាញ៉ៅ យាយព្រីង លោកចំណាប់ អ្នកស្រីចន្ថា សែបផុននិងភរិយាដែលជាអធិបតី ព្រមទាំង មានអ្នកស្រុកអ្នកភូមិជាច្រើនអ៊ូអរទៀតឈរមើលជាសាក្សី ជាងសម្លាក បត់ជើងសម្ពឹងមុខអ្នកគ្រូចរណៃ ដែលស្ថិតនៅក្នុងសម្លៀកកូនកម្លោះក្រមុំ ក្នុងពិធីមង្គល បន្ទាប់មកក៏ញញឹមហើយវាចាយ៉ាងស្រទន់ថា :

- អូនណៃ! ពុកបានចងដៃខ្សែកអំបោះក្រហមមួយខ្សែអោយអូននៅថ្ងៃ ដែលគាត់ទុកដាក់យើងជាស្វាមីភរិយា ។ ថ្ងៃនេះ បងសូមចងដៃភរិយាបង នូវខ្សែកមួយខ្សែទៀតជំនួសកម្រងផ្កាទាំងឡាយដែលបងខានក្រងបំពាក់ អោយអូនក្នុងរយៈដប់ឆ្នាំកន្លងមក...

មាណពក៏លើកខ្សែកមាសទឹកដប់ដ៏ក្រហមច្រាលមួយខ្សែ ដែលមាន បន្តោងបេះដូងយ៉ាងស្អាត លើកបំពាក់ទៅអោយកល្យាណីព្រមទាំងស្រដី ថែមទៀតថា :

- ខ្សែកនេះជាវត្ថុដែលបងរកបាន ដោយកម្លាំងញើសឈាមរបស់បង រួម ទាំងផ្ទះថ្មីមួយខ្នងនេះផង ។ បងសូមចងដៃអូនណៃជូនជាបណ្ណាការក្នុងពិធី មង្គលការរបស់យើងលើកទីពីរនៅថ្ងៃនេះ សូមណៃរក្សាទុកផងណា៎អូន!

ចរណៃញញឹមតបវិញទាំងរលីងរលោងទឹកភ្នែក ដោយក្តីរំភើបចិត្តនឹង រកពាក្យថ្លែងអោយសមស្មើមិនបានឡើយ ។ បន្ទាប់មក អ្នកទាំងពីរបាន ក្រោកក្រាបបង្គំ ព្រះគ្រូ តាញ៉ៅ យាយព្រីង លោកចំណាប់និងភរិយា ព្រមទាំងសែបផុននិងភរិយាផង ដើម្បីសម្តែងនូវក្តីគោរពនិងភាពកតញ្ញូ ដែលគេមានចំពោះអ្នកមានគុណទាំងឡាយគ្រប់គ្នា ។ រំពេចនោះ សូរសព្ទ

CHANBOKEO.COM

ភ្លេងបាយខុនចងដៃក៏បន្លឺឡើងយ៉ាងខ្ទរខ្ទារ លាយនឹងសព្ទ័សៀងសាធុការ ដល់គូស្វាមីភរិយាថ្មីយ៉ាងទ្រហឹងអឹងអាប់ពីអ្នកភូមិ ។ ស្នូរសំណើចក្អាក ក្អាយរបស់គ្រប់ៗគ្នា ដែលបានមកចូលរួមបានធ្វើអោយពិធីមង្គលបាន ប្រព្រឹត្តទៅដោយមហោឡារឹក ។

ថ្ងៃដន្យ ស្រាប់តែមានរថយន្តហ៊្សីបមួយបានបរមកឈប់នៅមុខផ្ទះ ដោយនាំបុរសសង្ហាម្នាក់មកជាមួយផង ។ គេរាល់គ្នាប្រហោងពោះធ្លុង ត្បិតនឹកថា ប្រហែលជាលោកចក្រាមករករឿងចលាចលក្នុងពិធីអ្វីទេដឹង ។ តែការពិត បុរសនោះមិនមែនជាលោកចក្រាងណា តែជាបុរសចម្លែកមួយ រូបដែលគ្មាននរណាស្គាល់ម្នាក់ឡើយក្រៅពីអ្នកគ្រូចំណានដែលឧទានថា :

- បងភក្តិ? ពុទ្ធោអើយ! ហេតុអ្វីក៏បងមកដល់ទីនេះដែរ?

ភក្តិមានរូបរាងសង្ហាណាស់ មិនចាញ់តារាភាពយន្តឡើយ ។ ថ្ងៃដន្យ គេមានទឹកមុខប្រកបដោយសេចក្តីទុកព្រួយជាខ្លាំង ថ្វីបើគេខំញញឹមបន្លប់ យ៉ាងណាក៏ដោយ ។ បន្ទាប់ពីគោរពចាស់ទុំទាំងឡាយហើយ គេក៏បែរមក រកចរណៃនិងកូនកម្លោះដ៏សង្ហារបស់នាង :

- ជំរាបសួរចា៎ទ! គឺ...សំណាងល្អណាស់...ដែលខ្ញុំមកទាន់ពេលបានចងដៃ អ្នកទាំងពីរ... ខ្ញុំសូមជួយអបអរសាទរនឹងអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរ ផង! សូមចាប់ដៃគ្នាសាងគ្រួសារប្រកបដោយសេចក្តីសុខរៀងរហូតទៅ ។

មាណពស្រដីទាំងរលីងរលោងទឹកភ្នែក ហើយក៏សំពះលាចេញទៅ ទុកអោយគ្រប់គ្នាដៅចម្ងល់នៅក្នុងបេះដូងយ៉ាងស្ងៀមស្ងាត់ ។

នៅក្នុងបន្ទប់ផ្ទំដំណេក...

- ណៃ...!

- ចា៎ស..!

- អូនមិយាយប្រាប់បងបានទេ ថាបុរសសង្ហាឈ្មោះភក្តិនោះជានរណាគេ? ហេតុអ្វីបានជាគេសម្រក់ទឹកភ្នែកពេលមកចងដៃយើង?

- គឺ...ជាមិត្តម្នាក់...ដែលធ្លាប់រៀនជាមួយណៃនោះអី ណា៎បង!

- ហើយចុះ... ចុះ... (ជាងខ្នានិយាយស្លាក់ៗ...មិនហ៊ានសួរតទៅទៀត)

- បងចង់ដឹងមែនទេ ថាអូនណៃមានចំណងពាក់ពន្ធ័នឹងគេយ៉ាងម៉េច?

ជាងខ្នាងក់ក្បាលហើយនិយាយថា :

- អូនណៃកុំខឹងអីណា៎ កាលបើបងចង់ដឹង...

ចរណៃសម្លឹងមុខស្វាមីមួយស្របក់ក៏ញញឹមឡើង :

- ណៃមិនខឹងទេ... ហើយណៃក៏គ្មានត្រូវជាអ្វីនឹងគេដែរ...បងឈប់មាន អារម្មណ៍ល្អក់កករទៅ ។

- អញ្ចឹងអូននិយាយប្រាប់បងបានខ្លះៗបានទេ ពីជីវិត១០ឆ្នាំរបស់អូននៅ បាត់ដំបង ថាហេតុអ្វីបានជាអូនដូរឈ្មោះទៅជាចរណៃ ហើយមានអ្វីខ្លះ កើតឡើងក្នុងជីវិតរបស់អូន...

CHANBOKEO.COM

- ចាំស! ចាំអូននិយាយប្រាប់ ប៉ុន្តែអោយអូនសួរបងរឿងមួយសិន។

- រឿងអ្វីទៅ?

- គឺថា..តើបងមានបានទៅទទូចសុំរៀបការអូនណៃពីពុកមាំងទេ នៅមុន ពេលគាត់ចែកឋានទៅ?

- ម៉េចក៏អូនដឹងកើតថាបងទៅទទូចសុំពុករៀបការអូនណៃ?

- គឺកាលបើខ្ញុំលួចស្តាប់ឮបងនិយាយគ្នាជាមួយពុក មុនពេលបងទៅនិមន្ត ព្រះគ្រូមក។ ពេលនេះបងសារភាពហើយមែនទេ ថាបង...?

- មែនហើយ...អូនទាយត្រូវណាស់! គឺបងទទូចសុំដូច្នោះមែន។

- បងឯងផ្តាសណាស់!

- មិនផ្តាសទេ..គឺបងធ្វើតាមបេះដូងរបស់បងបង្គាប់ទេ អូនណៃ។ ការពិត បងបានប្រាប់អូនណៃរៀងរហូតមកថាបង ស្រលាញ់អូនណៃ ប៉ុន្តែ...

- ប៉ុន្តែ យ៉ាងម៉េចទៅបង?

- គឺ..បងមិនដែលបានដឹងចិត្តអូនទេ...ថាអូនគិតយ៉ាងណាដែរចំពោះបង។ ព្រឹកមិញនេះ ពេលដែលបងឃើញភក្រ្តរបស់បុរសសង្ហាម្នាក់នោះ ទើបបង នឹកគិតឃើញថាបងបានបង្ខំរូបអូនឱ្យធ្វើតាមចិត្តបងពេកហើយ មិនបាន ទុកពេលវេលាឱ្យអូន សំរេចចិត្តជ្រើសរើសសេចក្តីសុខនិងសុភមង្គលសំរាប់ ខ្លួនអូនផ្ទាល់។ អូនណៃ! ឆ្លើយប្រាប់បងបានទេ ថាអូនគិតយ៉ាងណា មាន អារម្មណ៍យ៉ាងណាចំពោះសម្ពន្ធ័មេត្រីរវាងយើងទាំងពីរ។ ពិតមែនហើយ ដែលបងស្រលាញ់អូន ស្រលាញ់អូនណាស់មិនដែលភ្លេចមួយនាទីទេ គឺ ស្រលាញ់រហូតដល់បងមិនអាចលើកដៃបំផ្លាញទឹកចិត្តអូនបាន...

នរៈស្រដីដោយដួងចិត្តញាប់ញ័រនិងទឹកភ្នែករលីងរលោង ៖

- បងចង់ទុកឱកាសអោយអូនជ្រើសរើសម្តងទៀត។ បើសិនអូនមាន អារម្មណ៍ទើសទាល់ក្នុងចិត្ត ថាបងទទូចមនុស្សចាស់អោយមកបង្ខំចិត្តអូន សូមនិយាយប្រាប់បងមក! បងអាចទទួលយកចម្លើយពីអូនបានគ្រប់យ៉ាង មិនថាជាចម្លើយវិជ្ជមានឬអវិជ្ជមានទេ។ ចំពោះណៃ...អ្វីក៏បងអាចអោយ អូនបានដែរ សូម្បីតែជីវិតរបស់បង អោយតែអូនប្រាប់បងដោយត្រង់មក.. ណាំអូន...ណាំអូនណៃតែមួយរបស់បង...

ឮប្រយោគដូច្នោះ ធិតាស្រក់ទឹកភ្នែករលីងរលោង និយាយលែងរួច តែម្តង។ នាងសម្លឹងមុខមាណពយ៉ាងយូរដោយមិនស្រដីអ្វីឡើយ។ បន្តិច មក ជាងសម្លាកក៏ចាប់ដៃនាងកាន់ឡើង ៖

- អូនណៃ... បងគ្រាន់តែជាអ្នកភូមិធម្មតាៗ មិនមានមុខមាត់កត្តិយសអ្វី ទេ...រូបសម្បត្តិទៀតសោតក៏ប្រៀបមិនបាននឹងបុរសទីក្រុងទេ ហើយមាន ការងារជាជាងឈើប្រើកម្លាំងសុទ្ធសាធ គ្មានចំណេះគ្មានប្រាជ្ញា...បងពិត ជាគ្មានអ្វីជាមុខមាត់ធំដុំជូនអូនឡើយ ក្រៅពីបេះដូងដ៏បរិសុទ្ធតែមួយ របស់បង។ ចំណែកអូនជាគ្រូបង្រៀនជានារីដែលមានវណ្ណៈខ្ពង់ខ្ពស់ជាង បង...ហើយគេនោះ...ជាអ្នកទីក្រុង មានទ្រព្យមានកត្តិយស... ប្រហែល ជាគេសក្តិសមនឹងអូនជាង...ហើយ...

CHANDOKEO.COM

មកដល់ត្រង់នេះ គេហាក់ដូចជាមានអារម្មណ៍អួលណែនក្នុងចិត្តរិតតែ ខ្លាំងឡើងរហូតនិយាយលែងចេញ ។ មួយស្របក់ក្រោយមក គេក៏យកដៃ ទៅអង្អែលកេសានាងបន្ទើរៗហើយស្រដីយ៉ាងស្រទន់បន្តថា :

- បើសិនជាអូននៅមានអារម្មណ៍ជាប់ជំពាក់នឹងគេនៅឡើយ... ប្រាប់បង មក.. កុំលាក់នឹងបងអី.. កុំអោយបងក្លាយជាបុរសដែលបង្ខំចិត្តអូនឱ្យអូន ព្រាត់ម្ចាស់បេះដូងពិតប្រាកដ...!!

ចរណៃនៅតែឈ្ងោកស្រក់ទឹកភ្នែកស្ងៀមស្ងាត់ដដែល មិនព្រមឆ្លើយ សោះ ។ ឃើញដូច្នោះ មាណពក៏ងើបឈរឡើងនិយាយថា :

- យប់នេះ បងទៅគេងនៅខាងក្រៅ ។ ចាំស្អែក ពេលអូនមានអារម្មណ៍ ល្អឡើងវិញ បងនឹងមកស្តាប់ចម្លើយពីអូន...

ថាហើយ នាយក៏ងើបដើរទៅបើកទ្វារបន្ទប់ បំរុងចេញទៅ ស្រាប់តែ ធិតាស្រក់ទឹកភ្នែកតក់... ថែមទាំងស្រដីគំហកអោយនាយថា :

- បើបងខ្មាំបែរខ្នង ដើរចេញពីអូនណៃពេលនេះ សូមបងចេញរហូតទៅ កុំ ត្រលប់មកវិញអោយសោះ...! ហើយណៃនឹងស្អប់បងមួយជីវិត...!

ថាហើយនាងក៏ក្រាបមុខលើខ្នើយមង្គលទ្រោបមុខយំហ៊ូតែម្តង ។ នរៈ ឮសំដីដូច្នោះ ក៏នឹករំភើបក្នុងចិត្ត ហើយបែរក្រោយវិញយ៉ាងរហ័ស :

- អូនណៃ...!

មាណពដាក់ខ្លួនក្បែរនាងហើយយកដៃអង្អែលស្មានាងបន្ទើរៗ :

- អញ្ចឹងបងមិនទៅទេ... បងនឹងនៅកំដរអូនទីនេះ! បងស្រលាញ់អូន ណាស់អូនណៃ! បងនឹងធ្វើតាមអូនជានិច្ច ។

ស្រាប់តែនាងងើបមុខឡើង ស្រដីទាំងទឹកភ្នែកថា :

- ហេតុអ្វី? ហេតុអ្វីបានជាបងត្រូវធ្វើតាមចិត្តណៃគ្រប់វេលាអញ្ចឹង? បង មិនចេះប្រកែក មិនចេះខឹង មិនចេះម៉ូម៉ៅ ប្រចណ្ឌ័អីខ្លះទេហ៎?

គេក៏ញញឹមហើយឆ្លើយវិញថា :

- អូនភ្លេចហើយឬ ថាបងឈ្មោះករុណា... ករុណាមានន័យថា ជាសេចក្តី សន្តោស... ហើយចំពោះនាងតូចម្នាក់ដែលធ្លាប់តែមានមាត់តូចមាត់ធំដាក់ បងមួយជីវិតមកហើយនោះ... បងតែងតែមានចិត្តសណ្តោសរូបនាងជានិច្ច ព្រោះគេជានារីខ្មិកខ្មក់គួរអោយស្រលាញ់ណាស់...តើអូនដឹងហើយនៅ?

ឮដូច្នោះ នាងក៏ជូតទឹកភ្នែកហើយស្រដីថា :

- ហើយចុះបងវិញ មានដឹងទេថា បើកូនកម្លោះដើរចោលបន្ទប់ នៅរាត្រី ផ្សំដំណេកនោះជាការនាំបណ្តាសាដល់ជីវិតគូស្រករ...?

- អូហ៎ ពុទ្ធោ! បងសូមទោសអូនណៃ..! បងអត់ដឹងទេ ។

- បងឯងនេះល្ងង់ណាស់!!

- ល្ងង់ក៏ព្រោះតែបងស្រលាញ់ណៃ មិនចង់អោយណៃឈឺចិត្តដោយសារ ការបង្ខំចិត្តនោះឡើយ ។

CHANBOKEO.COM

- ម៉េចក៏បងដឹងកើតថាអូនណែឈឺចិត្តនោះ...?

- គឺ...តាំងពីយូរមកហើយ បងមិនដែលឃើញអូនពាក់ខ្សែកដែលពុកបាន

ចងដៃអូនទេ...ប្រហែលជាអូនមិនពេញចិត្តនឹងទទួលវាហើយ ។

- ហើយចុះ ម៉េចក៏បងមិនសួរណែទៅថាចិត្តណែគិតយ៉ាងណាដែរ?

នរៈសម្លឹងមុខកន្និដ្ឋាហាក់ដូចជាស្ទង់ទឹកចិត្តរបស់នាង ស្រាប់តែនាង

ចាប់ដៃស្តាំរបស់មាណពយកទៅដាក់នៅលើទ្រូងរបស់នាងរួចស្រដីថា :

- មកពីអូនមិនដែលពាក់អាវវាលក ទើបបងមិនដែលឃើញ! បើចង់ដឹង ការពិតច្បាស់ បងសួរបេះដូងអូនមួយនេះទៅ...

ថាដែលឃើញខ្សែកនោះ ទេ? ហើយសួរគេផងថាហេតុអីបានអូនដូរឈ្មោះថាជា ចរណែទៅវិញ?

ស្រាប់តែនរៈយើងត្រជាក់ដៃស្រឹត ។ ឯបេះដូងរបស់គេវិញក៏រណ្តំ លាន់ក្តុកក្តាក់ៗស្ទើរតែធ្លាយទ្រូងមកក្រៅតែម្តង

កាលបើដៃរបស់គេបាន ទៅស្ទាបប៉ះទ្រូងក្រពុំរបស់កល្យាណី ដែលគេកំពុងមានចិត្តបេតីស្ទើរលេប ទាំងរស់ ។

គេងើបមុខឡើងសម្លឹងនេត្រាដ៏រលោងភ្លឺថ្លារបស់នាងសាជាថ្មី ។

កល្យាណីញញឹមបញ្ចេញថ្ពាល់ខួចដ៏មានសោភណ៍មួយមកសណ្តំដួងចិត្ត នរៈអោយកាន់តែរំភើប

កាន់តែរន្ធត់ញាប់ញ័រក្នុងចិត្តខ្លាំងឡើងៗ ។ បុរស សម្លឹងមុខនាងយ៉ាងយូរស្ទើរតែភ្លេចដកដង្ហើម... រួចហើយក៏ឱនឈ្ងោក

យកនាសាផ្តិតលើថ្ពាល់ក្រពុំក្រហមរលោងរបស់ធិតា ដោយថ្នមៗ ប្រកប ដោយក្លិនមន្តស្នេហ៍ទន់ត្រជាក់

ព្រមជាមួយវាចាផ្អែមល្ហែមប្រាប់ទៅដល់ ម្ចាស់ដួងហឫទ័យរបស់គេថា :

- ណែ! ឱ្យបងសុំអនុញ្ញាតយកបេះដូងរបស់បង ទៅសាកសួររកចម្លើយ ពីបេះដូងរបស់អូនពេលនេះបានទេ

ម្ចាស់ស្នេហ៍កំពូលជីវិតរបស់បង?

ធិតាបិទនេត្រា ញញឹមទទួលការថ្នាក់ថ្នមរបស់មាណព ហើយងក់ កេសាជាសញ្ញាជំនួសពាក្យឆ្លើយតបទៅវិញ ។

នរៈរំភើបចិត្តណាស់ ក៏លាត វង្វង់ដៃស្រវាអោបកាយធិតា មកផ្ទឹបជាប់នឹងដើមទ្រូងរបស់គេ យ៉ាង ណែន

ដោយដួងចិត្តរន្ធត់ញាប់ញ័រក្រៃលែង រកថាមិនត្រូវសោះឡើយ ។ រំពេចនេះ

បេះដូងរបស់គេបានបញ្ចេញសូរសៀងចំរៀងស្នេហាភក្តីមួយបទ យ៉ាងពិរោះ ឆ្លើយឆ្លងតបទៅនឹងចង្វាក់តន្ត្រីដែលបេះដូងរបស់ធិតា

កំពុង តែប្រគំរណ្តំរងំក្នុងទ័យា យ៉ាងមនោរម្យ :

- អូនដឹងទេថា នៅក្នុងចិត្តរបស់បង រូបអូនគឺជាទេពធិតាចរណៃ ដែលបង បានប្រតិស្ឋានមឱ្យតាំងពីគ្រាមួយនោះមកម្ល៉េះ!!

- ចាំស! អូនដឹង.. ហើយដឹងរហូតមក... ព្រោះបងក៏ជាទេវបុត្រក្នុង

ដួងចិត្តរបស់អូនតែម្នាក់គត់ជារៀងរហូតមកតាំងពីពេលនោះមកដែរ!!

- ចរណៃម្ចាស់ដួងទ័យារបស់បង!... សូមអូនទទួលយកសេចក្តីស្នេហាដ៏

សែនស្មោះស្ម័គ្រភក្តីរបស់បងទៅរក្សាទុកលុះអវសានផងណាំអូនណាំ...

- ចាំស! ដោយក្តីសោមនស្សពេញដួងហឫទ័យបំផុត គ្មានងាករេឡើយ!

CHANBOKEO.COM

តន្ត្រីដួងចិត្តមួយបទយ៉ាងពិរោះនោះ បានរណ្ដំឡើងសាជាថ្មី បបោស លួងលោមសណ្ដំអារម្មណ៏របស់គេទាំងពីរឱ្យបានយល់នូវភាពកក់ក្ដៅ និង សេចក្ដីសុខសាន្ដរមនា ក្នុងរាត្រីទឹកឃ្មុំព្រះចន្ទ័ ប្រកបដោយសុភមង្គលជ្រាលជ្រៅធំធេងឥតព្រំដែន...

**ចប់**

CHANBOKEO.COM

# វាចាចុងក្រោយ

- មានតែសេចក្ដីស្រលាញ់ និងការអភ័យទោសចំពោះគ្នាទេ ដែលអាចនាំ ចិត្តយើងអោយយល់សេចក្ដីសុខក្នុងបេះដូងបាន។

- ឳពុកម្ដាយជាអ្នកត្រួសត្រាយផ្លូវតម្រងផ្លូវអោយកូនដើរ តែកូនវិញ គឺជាអ្នកសំរេច
ថាតើដើរផ្លូវណាមួយទៅទើបចៀសកន្លុកជីវិតអវិចីផុត។

- សុភមង្គលពិតប្រាកដកើតឡើងដោយការយល់ចិត្ត និងការបើកចំហដួង
ចិត្តប្រាប់គូស្នេហ៍អំពីអារម្មណ៏ពិតប្រាកដរបស់គេចំពោះគ្នាទៅវិញទៅមក

- សេចក្ដីស្រលាញ់គឺជាការពលី...លះបង់ដើម្បីសេចក្ដីសុខជូនមនុស្សដែល យើងស្រលាញ់...
ហើយយើងរមែងតែបានទទួលនូវសេចក្ដីស្រលាញ់តប វិញមិនលែងឡើយ។

- ទ្រព្យសម្បត្តិធនធានទាំងឡាយមិនអាចលើកតម្លៃមនុស្សអោយថ្លៃថ្នូរ បានឡើយ កាលបើមារយាទនិងការប្រព្រឹត្តរបស់បុគ្គល
ប្រាសចាកនូវ សីលធម៌និងគុណធម៌ចំពោះមនុស្សដូចគ្នា។

- ការវង្វេងនឹងទោសៈ អាចនាំអន្តរាយដល់អ្នកដទៃ ដល់ស្រុកភូមិ ជា ពិសេសដល់ខ្លួនឯងផ្ទាល់និងក្រុមគ្រួសារតែម្ដង។

- មានតែសាមគ្គីធម៌ទេ ដែលរក្សាសេចក្ដីសុខនិងសន្តិសុខក្នុងសង្គមបាន។

អ្នកស្រី កែវ ចន្ទ័បូរណ៏

CHANBOKEO . COM